វិទ្យាស្ថានបណ្ដុះបណ្ដាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

# សង្ខេប
# របាយការណ៍អភិវឌ្ឍន៍
# ប្រចាំឆ្នាំ២០១១-១២





ការបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន វបសអ

វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវ
ដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)

# សង្ខេប
# របាយការណ៍អភិវឌ្ឍន៍
# ប្រចាំឆ្នាំ២០១១-១២

*Annual Development Review*
*2011 - 2012*

ភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០១២

ក្នុងលក្ខណៈជា វិទ្យាស្ថានឯករាជ្យមួយរបស់កម្ពុជា ខាងការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ CDRI មានបេសកកម្មចូលរួមចំណែកដល់ការអភិវឌ្ឍន៍ ប្រទេសកម្ពុជាប្រកបដោយចីរភាព និងការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយចំណេះដឹង និងការកសាងសមត្ថភាព។

CDRI ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការងារជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា ។

**© រក្សាសិទ្ធិឆ្នាំ២០១២ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

រក្សាសិទ្ធិគ្រប់យ៉ាង - គ្មានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានចម្លងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជាអេឡិចត្រូនិកយន្តកម្មថតចម្លង...។ល។ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជាឡើយ ។

ISBN 978–99950–52–61-4

**សង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០១១-២០១២**
*Annual Development Review 2011-12*
ភ្នំពេញ ខែកុម្ភៈ ឆ្នាំ២០១២

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវលេខ ៣១៥

✉ ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☏ ទូរស័ព្ទ៖ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣

🖷 ទូរសារ៖ (៨៥៥-២៣) ៨៨០-៧៣៤

អ៊ីមែល៖ cdri@cdri.org.kh

គេហទំព័រ៖ http://www.cdri.org.kh

កែសម្រួល និងរចនាដោយ៖ អ៊ឹង-សុជាតិ ម៉េន-ច័ន្ទធីតា អ៊ំ-ចាន់ថា និង យូ សិទ្ធីរិទ្ធ
បកប្រែដោយ៖ ខេង-សេង
បោះពុម្ពនៅប្រទេសកម្ពុជា ដោយរោងពុម្ព T & S ភ្នំពេញ

# មាតិកា

បញ្ជីរូបភាព និងតារាង ...... vii
បញ្ជីអក្សរកាត់ ...... ix

**សេចក្តីផ្តើមៈ ចក្ខុវិស័យកម្ពុជា - ការពិនិត្យទូទៅ** ...... 1
១. សេចក្តីផ្តើម ...... 1
២. សេដ្ឋកិច្ច និងការអភិវឌ្ឍនៅកម្ពុជានាពេលបច្ចុប្បន្ន ...... 1
៣. គោលដៅអភិវឌ្ឍន៍ យុទ្ធសាស្រ្ត និងការប្រមើលឃើញ ...... 4
៤. ការអភិវឌ្ឍប្រទេសកម្ពុជា និងបរិបទក្នុងតំបន់ ...... 7
៥. បញ្ហាប្រឈមធំៗមួយចំនួន ចំពោះដំណើរឆ្ពោះទៅមុខ ...... 9
៦. សេចក្តីសន្និដ្ឋានៈ អាទិភាពគោលនយោបាយមួយចំនួន ...... 12
ឯកសារយោង ...... 13

**ផ្នែកទី ១. សេដ្ឋកិច្ច** ...... 15

**១. ការវិភាគរបាំងកំណើនសេដ្ឋកិច្ចដោយប្រើវិធីសាស្រ្តវិភាគកំណើនៈ ករណីប្រទេសកម្ពុជា** ...... 17
១. សេចក្តីផ្តើម ...... 17
២. ក្របខ័ណ្ឌនៃការវិភាគ ...... 18
៣. ភស្តុតាងអំពីឧបសគ្គរាំងកំណើនសេដ្ឋកិច្ចនៅកម្ពុជា ...... 19
៣.១. ចំណាយ និង លទ្ធភាពប្រើប្រាស់ហិរញ្ញវត្ថុ ...... 19
៣.២. លទ្ធភាពទាបក្នុងការប្រមូលផលចំណេញ ...... 21
៣.៣. ផលចំណេញពីសង្គម ...... 25
៤. សេចក្តីសន្និដ្ឋាន ...... 28
គន្ថនិទ្ទេស ...... 29

**២. សមាសភាពតាមវិស័យនៃកំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងវិសមភាព នៅប្រទេសចិនៈ បទពិសោធន៍ខាងគោលនយោបាយ និងអភិវឌ្ឍន៍ សម្រាប់ប្រទេសកម្ពុជា** ...... 31
សម្រង់អត្ថបទ ...... 31
១. សេចក្តីផ្តើម ...... 31
២. ការសិក្សាពីប្រទេសចិនលើការកាត់បន្ថយភាពក្រីក្រ និងកំណើនសម្រាប់គ្រប់គ្នា ...... 32
២.១. កត្តាកំណត់មួយចំនួននៃការកាត់បន្ថយភាពក្រីក្រផ្អែកលើកំណើន ...... 32
២.២. បទពិសោធន៍រៀនសូត្របានៈ យុទ្ធសាស្រ្តកាត់បន្ថយភាពក្រីក្រ ...... 40
៣. សេចក្តីសន្និដ្ឋាន និងគោលនយោបាយពាក់ព័ន្ធ ...... 41
គន្ថនិទ្ទេស ...... 42

**ផ្នែកទី ២. ធនធានធម្មជាតិ និងបរិស្ថាន** ........ 45

**៣. និន្នាការដំណាំកសិកម្មក្នុងតំបន់អេកូឡូស៊ីផ្សេងៗ និងបម្រែបម្រួលអាកាសធាតុនៅកម្ពុជា** ........ 47
១. សេចក្តីផ្តើម ........ 47
២. គោលបំណងស្រាវជ្រាវ និងវិធីសាស្ត្រ ........ 48
៣. ការអភិវឌ្ឍកសិកម្មនាបច្ចុប្បន្ន ........ 49
៣.១. ដំណាំស្រូវ ........ 50
៣.២. ដំណាំផ្សេងៗ ........ 51
៣.៣. ដំណាំកៅស៊ូ ........ 52
៣.៤. សត្វពាហនៈ ........ 52
៣.៥. ការប្រើប្រាស់ដី ........ 53
៣.៦. ធនធានជលផល ........ 54
៣.៧. ធនធានព្រៃឈើ ........ 55
៣.៨. ឥណទាន ........ 57
៣.៩. ហេដ្ឋារចនាសម្ព័ន្ធ ........ 57
៤. ឧបសគ្គបម្រែបម្រួលអាកាសធាតុ ចំពោះវិស័យកសិកម្ម ........ 58
៥. ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ស្តីពីបម្រែបម្រួលអាកាសធាតុ និងកសិកម្ម... 60
៦. ការពិភាក្សា និងសេចក្តីសន្និដ្ឋាន ........ 60
៧. អនុសាសន៍ ........ 62
គន្ថនិទ្ទេស ........ 63

**៤. បទពិសោធន៍រៀនបានពីកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក** ........ 67
សេចក្តីសង្ខេប ........ 67
១. សេចក្តីផ្តើម ........ 67
២. គោលដៅ និងកម្មវត្ថុ ........ 68
៣. វិធីសាស្ត្រ សកម្មភាព និងទីតាំងសិក្សា ........ 68
៤. លទ្ធផលសំខាន់ៗ ........ 69
៥. សមិទ្ធផលយូរអង្វែងសំខាន់ៗ ........ 70
៦. អត្ថប្រយោជន៍មាននិរន្តរភាពទៅអនាគត ........ 71
៧. អនុសាសន៍ ........ 73
គន្ថនិទ្ទេស ........ 74

**ផ្នែកទី ៣. សុខាភិបាល** ........ 75

**៥. ហិរញ្ញប្បទានសុខភាព និងធនធានមនុស្សសម្រាប់វិស័យសុខាភិបាល៖ ការវិភាគស្ថានភាពក្នុងប្រទេស** ........ 77
១. សេចក្តីផ្តើម ........ 77
២. គោលបំណង ........ 77
៣. វិធីសាស្ត្រ ........ 78
៤. លទ្ធផល ........ 78
៤.១. អ្នកពាក់ព័ន្ធ ........ 78
៤.២. គោលនយោបាយ ផែនការ និងកម្មវិធី ........ 81
៤.៣. ការស្រាវជ្រាវប្រព័ន្ធសុខាភិបាល ........ 82
៤.៤. បណ្តាញជួយទ្រទ្រង់ការពង្រឹងប្រព័ន្ធសុខាភិបាល ........ 83
៤.៥. ឱកាសស្រាវជ្រាវ ........ 83
៥. សេចក្តីសន្និដ្ឋាន ........ 84
គន្ថនិទ្ទេស ........ 85

**៦. គោលនយោបាយ និងការអភិវឌ្ឍបុគ្គលិកសុខាភិបាលនៅកម្ពុជា៖ ការពិនិត្យជាទូទៅ** ........ 87
១. សេចក្តីផ្តើម ........ 87
២. ការអភិវឌ្ឍវិស័យសុខាភិបាល ........ 87
៣. ការពិនិត្យទូទៅលើប្រព័ន្ធសេវាសុខាភិបាលបច្ចុប្បន្ន ........ 88
៤. ការអភិវឌ្ឍធនធានមនុស្សសម្រាប់វិស័យសុខាភិបាល ........ 90
៥. បញ្ហាប្រឈមចំពោះ ការជ្រើសរើសបុគ្គលិក ការរក្សា ការបែងចែក និងការអនុវត្តរបស់បុគ្គលិកសុខាភិបាល ........ 91
៦. បរិយាកាសលើកទឹកចិត្តសម្រាប់បុគ្គលិកសុខាភិបាល ........ 92
៧. តួអង្គខាងរដ្ឋាភិបាល ........ 93
៨. ចន្លោះខ្វះខាតសំខាន់ៗក្នុងការយល់ដឹងពីគ្រឿងលើកទឹកចិត្តបុគ្គលិកសុខាភិបាល .. 94
៩. សេចក្តីសន្និដ្ឋាន ........ 95
គន្ថនិទ្ទេស ........ 96

**ផ្នែកទី ៤. យេនឌ័រ** ........ 99

**៧. ការវិភាគយេនឌ័រក្នុងកំណែទម្រង់វិមជ្ឈការនៅកម្ពុជា** ........ 101
១. គោលបំណង និងវិធីសាស្ត្រនៃការស្រាវជ្រាវ ........ 101
២. យេនឌ័រក្នុងបរិបទប្រទេសកម្ពុជា ........ 102
៣. ការយល់ឃើញជារួមរបស់មេឃុំ និងក្រុមប្រឹក្សា អំពីកំណែទម្រង់វិមជ្ឈការ និងយេនឌ័រ ........ 102
៤. ការពិភាក្សា និងសេចក្តីសន្និដ្ឋាន ........ 103
គន្ថនិទ្ទេស ........ 104

**៨. យេនឌ័រក្នុងការបន្សាំនឹងបម្រែបម្រួលអាកាសធាតុ៖ ករណីសិក្សាតាមដងទន្លេមេគង្គ និងក្នុងអាងទន្លេសាប** ..........109
១. សេចក្តីផ្តើម..........109
២. វិធីសាស្ត្រស្រាវជ្រាវ..........110
៣. លទ្ធផលស្រាវជ្រាវ..........111
៣.១. បម្រែបម្រួលអាកាសធាតុ..........111
៣.២. យេនឌ័រក្នុងការបន្សាំនឹងបម្រែបម្រួលអាកាសធាតុ..........117
៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍..........120
គន្ថនិទ្ទេស..........121

**៩. ការផ្តល់សិទ្ធិអំណាចឲ្យនារី ចូលរួមកាន់តែច្រើនក្នុងទីផ្សារពលកម្ម** ..........123
១. សេចក្តីផ្តើម..........123
១.១. សាវតារ..........123
១.២. គោលបំណង..........124
១.៣. វិធីសាស្ត្រស្រាវជ្រាវ..........124
២. កំណើនមានការរាប់បញ្ចូល (សូចនាករសមភាពយេនឌ័រ)..........124
៣. ការវិភាគយេនឌ័រនៃទីផ្សារពលកម្ម និង ការងារសមស្រប..........125
៣.១. ការរួមចំណែកក្នុងទីផ្សារពលកម្ម..........125
៣.២. ការចូលរួមក្នុងកម្លាំងពលកម្ម..........127
៣.៣. ចំណាកស្រុក..........128
៣.៤. ការងារក្នុងវិស័យក្រៅផ្លូវការ..........128
៤. ការវិភាគយេនឌ័រនៃក្របខ័ណ្ឌគោលនយោបាយការងារ..........128
៥. សេចក្តីសន្និដ្ឋាន និងអនុសាសន៍..........132
គន្ថនិទ្ទេស..........133

**បញ្ជីឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន CDRI** ..........135

# បញ្ជីរូបភាព និងតារាង

**សេចក្តីផ្តើម**
រូបភាព ១៖ ការគន់គូរពី ផសស ក្នុងមនុស្សម្នាក់ របស់កម្ពុជា (ឆ្នាំ២០១០-២០៣០) ............. ៥

**១**
រូបភាព ១៖ កំណើន ផសស ប្រចាំឆ្នាំ គិតតាមថ្លៃថេរឆ្នាំ២០០០ ..........................................18
រូបភាព ២៖ គំនូសដើមឈើបញ្ហាសម្រាប់វិភាគកំណើន......................................................19
រូបភាព ៣៖ អត្រាការប្រាក់ពិតលើកម្ចី និង អត្រាវិនិយោគ ឆ្នាំ២០០៨-២០០៩ ...................... 20

រូបភាព ៤៖ អត្រាអតិផរណា និង អត្រាប្តូរប្រាក់ ឆ្នាំ២០០៤-២០១១ ................................... 22

តារាង ១៖ កត្តាចោទបញ្ហាធំៗជាងគេ ចំពោះការធ្វើអាជីវកម្មនៅកម្ពុជា ឆ្នាំ២០០៨-២០១០......21
តារាង ២៖ សូចនាករនៃគុណភាពស្ថាប័ន និងបទបញ្ញត្តិ ឆ្នាំ២០០៩-២០១០......................... 23
តារាង ៣៖ ការចាត់ថ្នាក់នៃទំហំ និងឥទ្ធិពលនៃការយកព័ន្ធ និងអត្រាពន្ធ នៅអាស៊ី ................. 24
តារាង ៤៖ សូចនាករនៃការរកឃើញផលិតផលនៅកម្ពុជា .................................................. 24
តារាង ៥៖ អត្រាចុះឈ្មោះចូលរៀនសរុបតាមបណ្តាប្រទេសសមាជិកអាស៊ាន......................... 26
តារាង ៦៖ សូចនាករសំខាន់ៗនៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងបណ្តាប្រទេសអាស៊ាន ............. 26
តារាង ៧៖ ពន្ធលើអគ្គិសនីនៅបណ្តាប្រទេសសមាជិកអាស៊ាន ឆ្នាំ២០១០............................ 27

**២**
រូបភាព ១៖ កំណើនផលិតកម្មនៅកម្ពុជា ការប្រែប្រួលប្រចាំឆ្នាំជា % គិតពីឆ្នាំ១៩៩០-២០០៨ 34
រូបភាព ២៖ កំណើនផលិតកម្មនៅចិន ការប្រែប្រួលប្រចាំឆ្នាំជា % គិតពីឆ្នាំ១៩៩០-២០០៩.... 34
រូបភាព ៣៖ ចំណែកកម្លាំងពលកម្មតាមវិស័យនៅចិន ឆ្នាំ១៩៩៣-២០០៨............................ 36
រូបភាព ៤៖ ចំណែកកម្លាំងពលកម្មតាមវិស័យនៅកម្ពុជា ឆ្នាំ១៩៩៣-២០០៨ ........................ 36
រូបភាព ៥៖ ចំណាយរបស់រដ្ឋាភិបាលកម្ពុជាតាមមុខងារ..................................................... 39
រូបភាព ៦៖ សូចនាករអភិបាលកិច្ចនៅប្រទេសចិន និងកម្ពុជា លំដាប់ថ្នាក់ជា % (០-១០០)... 40

តារាង ១៖ ទិន្នផលដំណាំ ការប្រើប្រាស់បច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា
និងក្នុងតំបន់ ............................................................................................ 37

**៣**
រូបភាព ១៖ ដំណាំស្រូវ ពីឆ្នាំ១៩៨០-២០១០.................................................................. 50
រូបភាព ២៖ ដំណាំស្រូវប្រាំង ពីឆ្នាំ១៩៨០-២០១០ .......................................................... 50
រូបភាព ៣៖ ផលិតកម្មដំណាំផ្សេងៗប្រចាំឆ្នាំ ពីឆ្នាំ១៩៨០-២០១០.......................................51
រូបភាព ៤៖ សត្វពាហនៈ ឆ្នាំ១៩៨០-២០១០ (ពាន់ក្បាល)................................................ 53
រូបភាព ៥៖ ការនាំចូលជី ឆ្នាំ១៩៩៨-២០០៨ (តោន) ......................................................... 53

រូបភាព ៦៖ ផលនេសាទប្រចាំឆ្នាំ (តោន) ពីឆ្នាំ១៩៨០-២០១០ ..... 54
រូបភាព ៧៖ បណ្តាញផ្លូវថ្នល់ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៨ ..... 58
រូបភាព ៨៖ ដំណាំស្រូវបំផ្លាញដោយទឹកជំនន់ ..... 59
រូបភាព ៩៖ ដំណាំស្រូវបំផ្លាញដោយគ្រោះរាំងស្ងួត ..... 59

តារាង ១៖ ទីតាំងសិក្សាបែងចែកតាមតំបន់អេកូឡូស៊ីនៃដំណាំកសិកម្ម ..... 49
តារាង ២៖ បម្រែបម្រួលគម្របព្រៃ ពីឆ្នាំ១៩៦៥-២០១០ ..... 56

**៥**

រូបភាព ១៖ រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងសុខាភិបាល ..... 79

**៦**

រូបភាព ១៖ ប្រព័ន្ធសេវាសុខាភិបាលរបស់រដ្ឋាភិបាល ..... 89

តារាង ១៖ ចំនួនវេជ្ជបណ្ឌិត គិលានុបដ្ឋាក និងពេទ្យឆ្មប នៅទីក្រុងភ្នំពេញ ធៀបនឹងខេត្តនានា (ឆ្នាំ២០០៣ និង ២០០៨) ..... 91

**៨**

រូបភាព ១៖ ផែនទីភូមិអង្កេតនានា ..... 111
រូបភាព ២៖ ការយល់ឃើញពីការខូចខាតបង្កដោយគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ក្នុងរយៈពេល ៥ឆ្នាំមុន ធៀបនឹងរយៈពេល ១០-១៥ឆ្នាំមុន ..... 112
តារាង ១៖ ការខាតបង់ទ្រព្យសម្បត្តិបង្កដោយគ្រោះទឹកជំនន់ និងការរាំងស្ងួត ក្នុងរយៈពេល ៥ឆ្នាំកន្លងទៅ ធៀបនឹងកាលពី ១០-១៥ឆ្នាំមុន ..... 113
តារាង ២៖ ការបាត់បង់ទ្រព្យសម្បត្តិក្នុងគ្រួសារបង្កដោយគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ..... 114
តារាង ៣៖ ទស្សនៈរបស់អ្នកឆ្លើយសម្ភាសន៍អំពីស្ថានភាពបម្រែបម្រួលអាកាសធាតុនានា ..... 115
តារាង ៤៖ ទស្សនៈរបស់អ្នកឆ្លើយសម្ភាសន៍អំពីប្រព័ន្ធប្រកាសអាសន្ន និងការផ្សព្វផ្សាយព័ត៌មាន ..... 115
តារាង ៥៖ យុទ្ធសាស្ត្រដោះស្រាយ តាមប្រភេទមហន្តរាយ ..... 117
តារាង ៦៖ វិធានការសម្របខ្លួនរបស់អ្នកឆ្លើយសម្ភាសន៍ ..... 119

**៩**

រូបភាព ១៖ ភាគរយនៃប្រជាជនកម្ពុជាអាយុ25ឆ្នាំ ឬលើសពីនេះ បែងចែកតាមកម្រិតសិក្សា និងភេទ ក្នុងឆ្នាំ2009 ..... 126

តារាង ១៖ សូចនាករសមភាពយេនឌ័រសំខាន់ៗ ..... 125
តារាង ២៖ កម្លាំងពលកម្ម អាយុ ១៥-៦៤ឆ្នាំ គិតតាមភេទ ..... 127

# បញ្ជីអក្សរកាត់

| | |
|---|---|
| គ.ម | គីឡូម៉ែត្រ (Kilometer) |
| ផសស/GDP | ផលិតផលក្នុងស្រុកសរុប (Gross Domestic Product) |
| | |
| ADB | ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank) |
| AEC | សហគមន៍សេដ្ឋកិច្ចអាស៊ាន (ASEAN Economic Community) |
| AFTA | តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (Asian Free Trade Area) |
| ARF | វេទិកាតំបន់របស់អាស៊ាន (ASEAN Regional Forum) |
| ASEAN | សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (Association of South East Asian Nations) |
| AusAID | ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ (Australian Agency for International Development) |
| CAR | ក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល (Council for Administrative Reform) |
| CARD | ក្រុមប្រឹក្សាស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ (Council for Agricultural and Rural Development) |
| CDC | ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (Council for the Development of Cambodia) |
| CDHS | អង្កេតប្រជាសាស្ត្រ និងសុខភាពកម្ពុជា (Cambodia Demographic and Health Survey) |
| CDRI/វបសអ | វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (Cambodia Development Resource Institute) |
| CMDGs | គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (Cambodian Millennium Development Goals) |
| CPA | សំណុំសកម្មភាពបង្គ្រប់ (Complementary Package of Activity) |
| CSES | អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជា (Cambodia Socio-economic Survey) |
| DRF | វេទិកាស្រាវជ្រាវការអភិវឌ្ឍ (Development Research Forum) |
| DTIS | យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម (Diagnostic Trade Integration Strategy) |
| FA | រដ្ឋបាលព្រៃឈើ (Forestry Administration) |
| FAO | អង្គការស្បៀងអាហារ និងកសិកម្ម (Food and Agriculture Organization) |
| FDI | វិនិយោគផ្ទាល់ពីបរទេស (Foreign Direct Investment) |
| FGDs | ការពិភាក្សាតាមក្រុមស្នូល (Focus Group Discussion) |
| FiA | រដ្ឋបាលជលផល (Fisheries Administration) |

| | |
|---|---|
| FWUCs | សហគមន៍កសិករប្រើប្រាស់ទឹក ( Farmer Water User Communities ) |
| GMS | មហាអនុតំបន់មេគង្គ ( Greater Mekong Sub-region ) |
| IFC | អង្គការសាជីវកម្មហិរញ្ញវត្ថុអន្តរជាតិ ( International Finance Corporation ) |
| ILO | អង្គការពលកម្មអន្តរជាតិ ( International Labour Organization ) |
| IMF | មូលនិធិរូបិយវត្ថុអន្តរជាតិ ( International Monetary Fund ) |
| IPCC | គណៈអន្តររដ្ឋាភិបាលស្តីពីបម្រែបម្រួលអាកាសធាតុ ( Intergovernmental Panel on Climate Change ) |
| JICA | ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន ( Japan International Cooperation Agency ) |
| LDCs | ប្រទេសលូតលាស់តិចជាងគេ ( Least Developed Countries ) |
| MAFF | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ( Ministry of Agriculture Forestry and Fisheries ) |
| MBPI | គម្រោងប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ ( Merit Based Performance Incentives ) |
| MEF/MoEF | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ( Ministry of Economy and Finance ) |
| MoE | ក្រសួងបរិស្ថាន ( Ministry of Environment ) |
| MoH | ក្រសួងសុខាភិបាល ( Ministry of Health ) |
| MoLVT | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ( Ministry of Labour and Vocational Training ) |
| MOP | ក្រសួងផែនការ ( Ministry of Planning ) |
| MoWA | ក្រសួងកិច្ចការនារី ( Ministry of Women's Affairs ) |
| MPA | សំណុំសកម្មភាពអប្បបរមា ( Minimum Package of Activity ) |
| MPWT | ក្រសួងសាធារណការ និងដឹកជញ្ជូន ( Ministry of Public Works and Transportation ) |
| MRC | គណៈកម្មាធិការទន្លេមេគង្គ ( Mekong River Committee ) |
| NBC | ធនាគារជាតិនៃកម្ពុជា ( National Bank of Cambodia ) |
| NBS | ការិយាល័យជាតិស្ថិតិ នៃប្រទេសចិន ( China's National Bureau of Statistics ) |
| NGOs | អង្គការមិនមែនរដ្ឋាភិបាល ( Non Governmental Organizations ) |
| NIS | វិទ្យាស្ថានជាតិស្ថិតិ ( National Institute of Statistics ) |
| NSSF | មូលនិធិជាតិសុវត្ថិភាពសង្គម ( National Social Safety Fund ) |
| ODA | ជំនួយអភិវឌ្ឍន៍ផ្លូវការ ( Official Development Assistance ) |
| PMAS | ប្រព័ន្ធគ្រប់គ្រងការអនុវត្ត និងគណនេយ្យភាព ( Performance Management and Accountability System ) |
| PMG | កម្មវិធីកន្សោមអាទិភាព ( Priorities Mission Group ) |

| | |
|---|---|
| POC | គម្រោងចំណាយប្រតិបត្តិការអាទិភាព ( Priority Operating Cost ) |
| RGC | រាជរដ្ឋាភិបាលកម្ពុជា ( Royal Government of Cambodia ) |
| RTC | មជ្ឈមណ្ឌលបណ្តុះបណ្តាលតាមតំបន់ ( Regional Training Centre ) |
| RUPP | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ ( Royal University of Phnom Penh ) |
| SAW | យុទ្ធសាស្ត្រសម្រាប់កសិកម្ម និងទឹក ( Strategy for agriculture and Water ) |
| SEZ | តំបន់សេដ្ឋកិច្ចពិសេស ( Special Economic Zone ) |
| SITC | ចំណាត់ថ្នាក់ស្តង់ដារពាណិជ្ជកម្មអន្តរជាតិ ( Standard International Trade Classification ) |
| SME | សហគ្រាសធុនតូច និង មធ្យម ( Small and Medium Enterprise ) |
| SOA | ទីភ្នាក់ងារប្រតិបត្តិការពិសេស ( Special Operating Agency ) |
| UNDP | កម្មវិធីអភិវឌ្ឍន៍អង្គការសហប្រជាជាតិ ( United Nation Development Programme ) |
| UNESCO | អង្គការ ការអប់រំ វិទ្យាសាស្ត្រ និងវប្បធម៌ សហប្រជាជាតិ ( United Nations Education, Scientific and Cultural Organisation ) |
| UNFPA | អង្គការមូលនិធិសហប្រជាជាតិបម្រើប្រជាជន ( United Nations Population Fund ) |
| UNIFEM | មូលនិធិអភិវឌ្ឍន៍សហប្រជាជាតិសម្រាប់នារី ( United Nations Development Fund for Women ) |
| WB | ធនាគារពិភពលោក ( World Bank ) |
| WDC | មជ្ឈមណ្ឌលអភិវឌ្ឍន៍នារី ( Women's Development Centre ) |
| WDI | សូចនាករអភិវឌ្ឍន៍ពិភពលោក ( World Development Indicator ) |
| WEF | វេទិកាសេដ្ឋកិច្ចសាកល ( World Economic Forum ) |
| WHO | អង្គការសុខភាពពិភពលោក ( World Health Organization ) |
| WRMRCDP | កម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវនិងគ្រប់គ្រងធនធានទឹក ( Water Resource Management Research Capacity Development Programme ) |
| WTO | អង្គការពាណិជ្ជកម្មពិភពលោក ( World Trade Organisation ) |

# សេចក្តីផ្តើម
## ចក្ខុវិស័យកម្ពុជា - ការពិនិត្យទូទៅ

*ដោយលោក ហ៊ីង វុត្ថា លោក យៀង សុធី លោក លន់ ពិដេ លោក សាំង ច័ន្ទហង្ស និងលោក ឡារី ស្រេត្ត[១]*

### ១. សេចក្តីផ្តើម

របាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០១១-១២ របស់វិទ្យាស្ថាន CDRI នេះ ត្រូវបានចេញផ្សាយនៅពេលប្រជុំ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១២ ដែលធ្វើឡើងក្រោមកិច្ចសហការជាដៃគូរវាងវិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal។ សន្និសីទចក្ខុវិស័យឆ្នាំ២០១២ ក្រោមប្រធានបទ *"អាទិភាពប្រទេសកម្ពុជា ដើម្បីលើកកម្ពស់កំណើនសម្រាប់គ្រប់គ្នា សមាហរណកម្មក្នុងតំបន់ និង ការដឹកនាំអាស៊ាន"* ផ្តោតលើបញ្ហាសំខាន់ៗបី និងការប្រមើលឃើញផ្នែកសេដ្ឋកិច្ច-សង្គមកិច្ចសម្រាប់កម្ពុជា គឺមាន (១) វិធីសាស្ត្រដើម្បីសម្រេចបានកំណើនសម្រាប់គ្រប់គ្នាក្នុងកម្រិតខ្ពស់ និងការអភិវឌ្ឍប្រកបដោយចីរភាព ក៏ដូចជាការកាត់បន្ថយភាពក្រីក្រផងដែរ (២) តួនាទីដ៏សំខាន់នៃសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងមហាអនុតំបន់មេគង្គ អាស៊ាន និងតំបន់អាស៊ីបូព៌ា ដើម្បីសម្រេចបានការអភិវឌ្ឍនិងកំណើនសម្រាប់គ្រប់គ្នា និង (៣) ឱកាសល្អនៃវេណប្រទេសកម្ពុជាធ្វើជាប្រធានអាស៊ាននៅឆ្នាំ២០១២ ដើម្បីជំរុញល្បឿន និងគុណភាពសមាហរណកម្ម។ អត្ថបទនេះធ្វើការពិនិត្យជាទូទៅអំពីស្ថានភាពសេដ្ឋកិច្ច និងការអភិវឌ្ឍនាពេលបច្ចុប្បន្ន ការប្រមើលឃើញនិងកត្តាចាំបាច់សម្រាប់កំណើននិងការអភិវឌ្ឍនាពេលអនាគត បរិបទក្នុងតំបន់ និង បញ្ហាប្រឈមមួយចំនួន ក៏ដូចជា វិធានការខាងគោលនយោបាយដែលគួរពិចារណានៅពេលកម្ពុជាកំពុងឈានទៅមុខនេះ។

### ២. សេដ្ឋកិច្ច និងការអភិវឌ្ឍនៅកម្ពុជានាពេលបច្ចុប្បន្ន

សេដ្ឋកិច្ចកម្ពុជានាពេលបច្ចុប្បន្ន ជាលទ្ធផលនៃការផ្លាស់ប្តូរគោលនយោបាយជិតពីរទសវត្សរ៍ ចេញពី "សេដ្ឋកិច្ចផែនការ" មកជា "សេដ្ឋកិច្ចបែបទីផ្សារ" ដែលលើកទឹកចិត្តដល់វិនិយោគ ពាណិជ្ជកម្ម និងការអភិវឌ្ឍវិស័យឯកជន នៅក្នុងបរិបទ អនុតំបន់ (GMS) តំបន់ (អាស៊ាន និងអាស៊ីបូព៌ា) និង សាកល។ កំណែទម្រង់គោលនយោបាយ ការបញ្ចប់សង្គ្រាមស៊ីវិល និងស្ថិរភាពនយោបាយ បានជំរុញឲ្យមានកំណើនយ៉ាងលឿន (ជាមធ្យម ៧,៨% នៅចន្លោះឆ្នាំ១៩៩៤ និង ២០០០) ដោយបង្កើនចំណូលក្នុងមនុស្សម្នាក់ ពី ២៤៨ដុល្លារ ដល់ ៧៣៥ដុល្លារ និងបានផ្លាស់ប្តូរហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចពីសេដ្ឋកិច្ចកសិកម្ម មកជា សេដ្ឋកិច្ចចម្រុះមានតុល្យភាពល្អរវាងវិស័យកសិកម្ម ឧស្សាហកម្ម និងសេវាកម្ម[២]។

---

១ លោក ហ៊ីង វុត្ថា លោក យៀង សុធី លោក លន់ ពិដេ និងលោក សាំង ច័ន្ទហង្ស ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI ហើយលោក ឡារី ស្រេត្ត ជានាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI។

២ ចំណែកវិស័យកសិកម្មក្នុង ផសស បានធ្លាក់ចុះខ្លាំងពី ៤៦% នៅឆ្នាំ១៩៩៤ មកត្រឹម ២៧,៤% នៅឆ្នាំ២០០០ ហើយចំណែកវិស័យឧស្សាហកម្ម បានកើនពី ១៣,៥% ដល់ ២៦,៤% រីឯចំណែកវិស័យសេវាកម្ម បានកើនឡើងយ៉ាងទៀងទាត់ពី ៣៥,៣% ដល់ ៤០,៦% នៃ ផសស។

កំណើនក្នុងរយៈពេលមួយទសវត្សរ៍កន្លងមកនេះ ទទួលបានពីបួនវិស័យសំខាន់ៗ៖ សំលៀកបំពាក់និងស្បែកជើង សណ្ឋាគារនិងភោជនីយដ្ឋាន សំណង់ និង កសិកម្ម។ អនុវិស័យសំលៀកបំពាក់និងវាយនភ័ណ្ឌ ដែលនាំមុខគេនៅកម្ពុជាក្នុងការនាំចេញ បានរួមចំណែក ១២% នៃ ផសស ក្នុងឆ្នាំ២០១០ និងមានកំណើនជាមធ្យម ៣០% ក្នុងមួយឆ្នាំ។ អនុវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន រួមចំណែក ៤,៤% នៃ ផសស ឆ្នាំ២០១០ និង កើនជាមធ្យម ១៣% ក្នុងមួយឆ្នាំ រីឯអនុវិស័យសំណង់ កើនជាមធ្យម ១១% ក្នុងមួយឆ្នាំ។ វិស័យកសិកម្ម ដែលរួមមានសកម្មភាពដាំដំណាំ ចិញ្ចឹមសត្វនិងបសុបក្សី នេសាទ និងប្រមូលផលព្រៃឈើ ជាដើម ជាវិស័យមានកំណើនថេរល្អ ប៉ុន្តែយឺតជាងគេ (ជាមធ្យម ៥% ក្នុងមួយឆ្នាំ) និងងាយរងការប៉ះពាល់ពីគ្រោះធម្មជាតិ ដូចជា ទឹកជំនន់ និងការរាំងស្ងួត។ កំណើនកសិកម្មក៏មានមូលដ្ឋានតូចចង្អៀត ដូច្នេះងាយរងគ្រោះខ្លាំងដោយសារការប៉ះទង្គិចពីខាងក្រៅ និងមិនទំនងជាមាននិរន្តរភាពក្នុងរយៈពេលវែងទេ។ គួរកត់សម្គាល់ដែរថា ក្រៅពីកសិកម្មដែលមានកំណើនថេរមួយចេញ វិស័យជំរុញកំណើនផ្សេងៗទៀត បានរងការប៉ះទង្គិចធ្ងន់ធ្ងរអំពីវិបត្តិហិរញ្ញវត្ថុសាកល។

កំណើនប្រកបដោយនិរន្តរភាព បានបង្កការប្រែប្រួលក្នុងរចនាសម្ព័ន្ធការងារ។ នៅឆ្នាំ ១៩៩៥ វិស័យកសិកម្មបានផ្តល់ការងារប្រមាណ ៨១,៤% នៃកម្លាំងពលកម្មសរុប ហើយនៅឆ្នាំ២០០៧ អត្រានេះបានធ្លាក់ចុះមកត្រឹម ៥៥,៩% (IMF 2009)។ ក្នុងពេលដំណាលគ្នា កម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្ម កើនឡើងយ៉ាងខ្លាំងពី ២,៩% ដល់ ១៥,៤% នៃកម្លាំងពលកម្មសរុប ហើយក្នុងវិស័យសេវាកម្ម វាកើនស្ទើរមួយជាពីរ ពី ១៥,៧% ដល់ ២៨,៧%។ កំណើនសេដ្ឋកិច្ចយ៉ាងលឿន ធ្វើឲ្យអត្រាភាពក្រីក្រធ្លាក់ចុះយ៉ាងខ្លាំង ប៉ុន្តែគំលាតវិសមភាពរីកធំឡើង។ អត្រាភាពក្រីក្រជាតិ ធ្លាក់ចុះពី ៣៩% នៅឆ្នាំ១៩៩៤ មកត្រឹម ៣០,១% នៅឆ្នាំ២០០៧។ អត្រាភាពក្រីក្រនៅតំបន់ទីក្រុង និងជនបទ ក៏ធ្លាក់ចុះដែរ ទោះបីជាភាពក្រីក្រនៅតែមានកម្រិតខ្ពស់នៅតំបន់ជនបទក្តី។ ក្នុងពេលជាមួយគ្នា គំលាតប្រាក់ចំណូលបានកើនឡើងរវាងអ្នកមាន និងអ្នកក្រ ហើយមេគុណ Gini ដែលគណនាចេញពីទិន្នន័យជាតិស្តីពីចំណាយប្រើប្រាស់ បានកើនឡើងពី ០,៣៥ នៅឆ្នាំ១៩៩៤ ដល់ ០,៤៣ នៅឆ្នាំ២០០៧។ ទិន្នន័យថ្មីបំផុតស្តីពីភាពក្រីក្រ ដែលទទួលបានពីមូលដ្ឋានទិន្នន័យឃុំ/សង្កាត់របស់វិទ្យាស្ថានជាតិស្ថិតិ បានបង្ហាញការថយចុះភាពក្រីក្រថែមទៀត មកត្រឹម ២៧,៤% នៅឆ្នាំ២០០៩ និង ២៥,៨% នៅឆ្នាំ២០១០ (NIS 2010)។

យុទ្ធសាស្ត្រអភិវឌ្ឍន៍របស់កម្ពុជា បានចាត់ទុក សេរីភាវូបនីយកម្មវិនិយោគ និងពាណិជ្ជកម្ម ជាគន្លឹះ ដើម្បីធានាឲ្យកំណើនសេដ្ឋកិច្ចមាននិរន្តរភាពល្អ និងសម្រាប់គ្រប់គ្នា ហើយអាចរួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្រ និងការអភិវឌ្ឍសង្គម។ អាទិភាពគោលនយោបាយនានា មានគោលដៅ៖ (១) បង្កើតបរិយាកាសអំណោយផលផ្នែកហិរញ្ញវត្ថុ និងម៉ាក្រូសេដ្ឋកិច្ច (២) លើកកម្ពស់សមាហរណកម្មសេដ្ឋកិច្ច និងសហប្រតិបត្តិការក្នុង អនុតំបន់ តំបន់ និង សាកលលោក (៣) ជំរុញភាពប្រកួតប្រជែង និង ពិពិធកម្មពាណិជ្ជកម្មនិងសេដ្ឋកិច្ច (៤) ពង្រឹងការចូលរួមរបស់វិស័យឯកជន និង (៥) ទាក់ទាញវិនិយោគតាមរយៈបរិយាកាសអំណោយផលដល់វិនិយោគ និងពាណិជ្ជកម្ម។ កម្ពុជាជាប្រទេសចូលរួមសកម្មមួយក្នុងកម្មវិធីសេដ្ឋកិច្ច-សង្គមកិច្ចនានាក្នុងអនុតំបន់និងក្នុងតំបន់ដូចជាមហាអនុតំបន់មេគង្គ (GMS) អង្គការពាណិជ្ជកម្មពិភពលោក (WTO) យុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ច ACMECS (Ayeyawady-Chao Phraya Mekong Economic Cooperation Strategy) អាស៊ាន និង គម្រោងផ្តួចផ្តើមដោយអាស៊ានមួយចំនួន

រួមមាន តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (AFTA) តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ចិន តំបន់ពាណិជ្ជកម្មសេរីអាស៊ាន-កូរ៉េ និងតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-ជប៉ុន។ កម្ពុជាបានចាប់អនុវត្តកំណែទម្រង់ជាច្រើនដើម្បីធានាឲ្យគោលនយោបាយ និងរបៀបរបបពាណិជ្ជកម្មនានាមានភាពយុត្តិធម៌ គ្មានការរើសអើង មានតម្លាភាព និងអាចទស្សន៍ទាយបាន។

កម្មវិធី និងកំណែទម្រង់សំខាន់ៗជាច្រើន បានចាប់ផ្តើមអនុវត្តដើម្បីកែលម្អបរិយាកាសវិនិយោគថែមទៀត។ នៅឆ្នាំ២០០៥ មានធ្វើវិសោធនកម្មច្បាប់វិនិយោគ ដើម្បីញាំងឲ្យក្របខ័ណ្ឌបទបញ្ញត្តិកាន់តែងាយស្រួល និងអំណោយផលសម្រាប់ទាំងវិនិយោគក្នុងស្រុក និងពីក្រៅប្រទេស។ វេទិកា រដ្ឋាភិបាល-ផ្នែកឯកជន បានរៀបចំឡើងចំនួនពីរដងជារៀងរាល់ឆ្នាំ ដោយមានការចូលរួមពីសម្តេចនាយករដ្ឋមន្ត្រី ខុទ្ទកាល័យនៃរាជរដ្ឋាភិបាលកម្ពុជា និងអ្នកតំណាងមកពីវិស័យឯកជន។ នៅឆ្នាំ២០០៥ រដ្ឋាភិបាលក៏បានបង្កើតតំបន់សេដ្ឋកិច្ចពិសេស (SEZ) តាមរយៈព្រះរាជក្រឹត្យពិសេសមួយ ដើម្បីទាក់ទាញគម្រោងវិនិយោគឧស្សាហកម្ម និងបម្រើឲ្យការនាំចេញ។

របបគ្រប់គ្រងសេដ្ឋកិច្ចបែបសេរីនិយម និងបើកចំហទៅខាងក្រៅបែបនេះ បានជំរុញកំណើនពាណិជ្ជកម្ម និងវិនិយោគយ៉ាងលឿន។ ពីឆ្នាំ១៩៩៥ ដល់ ២០០៩ ពាណិជ្ជកម្មសរុបកើនឡើងតាមអត្រាប្រចាំឆ្នាំជាមធ្យម ១៧,០២% រហូតដល់ ១០,០២ពាន់លានដុល្លារ ហើយកើនលើស ផសស ដោយមានផលធៀបពាណិជ្ជកម្មសរុប ជាមួយនឹង ផសស (ផលធៀបនេះ ជាទូទៅគេហៅថា សន្ទស្សន៍ភាពពឹងផ្អែកលើពាណិជ្ជកម្ម) ដល់ទៅ ១០៥,៧%។ ការនាំចេញផ្តោតខ្លាំងលើផលិតផលមួយចំនួនតូច ដូចមានឆ្លុះបញ្ចាំងក្នុងសន្ទស្សន៍ប្រមូលផ្តុំផលិតផលនាំចេញកម្រិតខ្ពស់ ដល់ ៣៦,៤%។ ការនាំចេញផលិតផលវាយនភ័ណ្ឌ និងសំលៀកបំពាក់ រួមចំណែក ៣,៤៥ពាន់លានដុល្លារ ឬ ៧៦% នៃការនាំចេញសរុប រីឯស្បែកជើង រួមចំណែក ៣៥៦លានដុល្លារ ឬ ៧,៦% នៃការនាំចេញសរុប។ ផលិតផលនាំចេញផ្សេងៗទៀត រួមមាន ផលិតផលឈើ កៅស៊ូ អង្ករ ជំឡូងឈើ និងសត្វចិញ្ចឹម។ ផលិតផលនាំចេញរបស់កម្ពុជា ក៏មានការប្រមូលផ្តុំគ្នាខ្លាំងដែរ នៅក្នុងទីផ្សារមួយចំនួនតូច ដោយក្នុងនោះ ទីផ្សារនៅសហរដ្ឋអាមេរិក និងសហភាពអឺរ៉ុបស្រូបយកប្រហែលពីរភាគបី នៃផលិតផលនាំចេញរបស់កម្ពុជា ដែលមានជាចម្បង សំលៀកបំពាក់ និងស្បែកជើង។ ទីផ្សារនាំចេញសំខាន់ៗផ្សេងទៀត រួមមាន ហុងកុង (១៩,៣%) កាណាដា (៦,៧%) និងវៀតណាម (៣,៩%)។

វិនិយោគផ្ទាល់ពីបរទេស (FDI) បានកើនស្ទើរចាប់ពីសូន្យនៅចុងទសវត្សរ៍១៩៨០ រហូតដល់ ១៦៣លានដុល្លារជាមធ្យមក្នុងមួយឆ្នាំ នៅចន្លោះឆ្នាំ១៩៩៣ និង ២០០៤ ហើយកើនដល់ ៦០៤លានដុល្លារ នៅពាក់កណ្តាលទី២ នៃទសវត្សរ៍២០០០។ ស្តុក FDI នៅចន្លោះឆ្នាំ១៩៩៣ និង ២០១០ បានកើនដល់ ៥,៥៨ពាន់លានដុល្លារ ឬ ៣៤% នៃវិនិយោគឯកជនសរុប ឬ តំណាងឲ្យជាមធ្យមប្រចាំឆ្នាំ ៥,៤% នៃ ផសស ។ ទោះយ៉ាងនេះក្តី FDI នៅកម្ពុជា នៅមានកម្រិតទាបបើធៀបនឹងបណ្តាប្រទេសសមាជិកអាស៊ាននៅជិតខាងខ្លួន។ សកម្មភាពវិនិយោគនៅជួបឧបសគ្គមួយចំនួន ដែលធ្វើឲ្យបរិយាកាសវិនិយោគមិនសូវអំណោយផលនិងមិនសូវទាក់ទាញសម្រាប់ការធ្វើជំនួញ។ អង្កេតលើការធ្វើអាជីវកម្ម អនុវត្តដោយធនាគារពិភពលោក បានកំណត់អភិបាលកិច្ច និងអំពើពុករលួយ ថាជាឧបសគ្គចម្បងបំផុតចំពោះកំណើនអាជីវកម្មឯកជន (World Bank 2010)។ ឧបសគ្គចម្បងៗផ្សេងទៀតរួមមានបទល្មើសផ្សេងៗ ចោរកម្ម កង្វះសណ្តាប់ធ្នាប់ ឧបសគ្គក្នុងការចូលទីផ្សារនិងការប្រកួតប្រជែង ភាពមិនប្រាកដប្រជានៃបទបញ្ញត្តិគោលនយោបាយ និងភាពទន់ខ្សោយនៃប្រព័ន្ធតុលាការ បទបញ្ញត្តិពាណិជ្ជកម្ម គយ និងរដ្ឋបាលពន្ធដារ។

កង្វះហេដ្ឋារចនាសម្ព័ន្ធ ក៏ជាបញ្ហាចម្បងមួយដែរ ក្នុងការបង្កើនសមត្ថភាពប្រកួតប្រជែង និងកំណើនរបស់កម្ពុជា (WEF 2011)។ ការដឹកជញ្ជូនតាមផ្លូវថ្នល់ នៅក្មេងខ្ចីណាស់ មិនទាន់មានប្រសិទ្ធភាពទេ។ ទោះបីមានកម្មវិធីជួសជុលកែលម្អក្តី ក៏ប្រព័ន្ធផ្លូវដែកនៅតែមានលក្ខណៈទន់ខ្សោយ មិនសូវមានតម្រូវការប្រើប្រាស់ទេ។ ចំពោះកំពង់ផែវិញ ប្រសិទ្ធភាពបានកើនឡើង ហើយ ប៉ុន្តែបន្ទុកចំណាយដឹកជញ្ជូនតាមផ្លូវទឹកនៅតែមានកម្រិតខ្ពស់។ ការផ្គត់ផ្គង់អគ្គិសនីនៅតែមានតម្លៃខ្ពស់ មិនគ្រប់គ្រាន់ និងមិនអាចទុកចិត្តបានប៉ុន្មានទេ។ ដែនគ្របដណ្តប់នៃប្រព័ន្ធទូរគមនាគមន៍ ក៏នៅមានកម្រិតដែរ។ ទាំងកម្មវិធីហេដ្ឋារចនាសម្ព័ន្ធជាតិ និង កម្មវិធីហេដ្ឋារចនាសម្ព័ន្ធ GMS ដើម្បី "ការភ្ជាប់ទំនាក់ទំនង" មានសារៈសំខាន់បំផុតសម្រាប់កំណើន និងការអភិវឌ្ឍនាពេលអនាគត ក្នុងនេះ ត្រូវមានការពង្រីក ផ្លូវថ្នល់ ផ្លូវដែក ផ្លូវទឹក ស្ពាន កំពង់ផែ ការផលិតអគ្គិសនី និងហេដ្ឋារចនាសម្ព័ន្ធស្ថាប័ន ដើម្បីជួយដល់ការដឹកជញ្ជូន និងការផ្គត់ផ្គង់។

## ៣. គោលដៅអភិវឌ្ឍន៍ យុទ្ធសាស្ត្រ និងការប្រមើលឃើញ

បំណងប្រាថ្នា និងយុទ្ធសាស្ត្រអភិវឌ្ឍន៍របស់កម្ពុជា មានឆ្លុះបញ្ចាំងនៅក្នុងផែនការអភិវឌ្ឍន៍ប្រទេស ដូចជា យុទ្ធសាស្ត្រចតុកោណជំហានទី១ និងទី២ របស់រដ្ឋាភិបាល និង ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១៣ ជាដើម។ ដូចមានគូសបញ្ជាក់នៅក្នុងឯកសារគោលនយោបាយនានាខាងលើ សម្រាប់ទសវត្សរ៍ក្រោយនេះ កម្ពុជាមានបំណង៖ (១) ចាកផុតពីស្ថានភាពជាប្រទេសលូតលាស់តិចជាងគេ (LDCs) (២) សម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ចប្រកបដោយនិរន្តរភាព (៣) កាត់បន្ថយភាពក្រីក្រ (៤) ក្លាយជាប្រទេសពឹងផ្អែកលើជំនួយតិច (៥) កសាងបាននូវប្រព័ន្ធសេដ្ឋកិច្ចសម្បូរបែប និងមានលក្ខណៈដុល្លារូបនីយកម្មតិច (៦) សម្រេចបានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និង (៧) សម្រេចបានការបែងចែកទ្រព្យធនមានសមធម៌ជាងមុន។

**កម្ពុជាចាកផុតពីស្ថានភាពជាប្រទេសលូតលាស់តិចជាងគេ និងរក្សាបានស្ថិរភាពបរិយាកាសម៉ាក្រូសេដ្ឋកិច្ច៖** ដោយសន្មតថា ប្រទេសមានប្រាក់ចំណូលមធ្យម មាន ផសស ក្នុងមនុស្សម្នាក់យ៉ាងហោចណាស់ ១០៧៥ដុល្លារ និង អត្រាកំណើន ២% ក្នុងមួយឆ្នាំ ហើយដោយប្រើអត្រាកំណើន ផសស ពិតក្នុងមនុស្សម្នាក់ បីកម្រិតដើម្បីគណនា ពោលគឺ ៩% (កំណើនខ្ពស់) ៧% (កំណើនមធ្យម) និង ៥% (កំណើនទាប) វិទ្យាស្ថាន CDRI បានប៉ាន់ស្មានថា កម្ពុជាអាចក្លាយជាប្រទេសមានប្រាក់ចំណូលមធ្យមនៅឆ្នាំ២០១៦ ក្រោមសេណារីយ៉ូកំណើនខ្ពស់ នៅឆ្នាំ២០១៨ ក្រោមសេណារីយ៉ូកំណើនមធ្យម និង នៅឆ្នាំ២០២៤ ក្រោមសេណារីយ៉ូកំណើនទាប ប្រសិនបើកត្តាផ្សេងទៀតនៅថេរ (រូបភាព ១)។

កិច្ចខំប្រឹងប្រែងធ្វើឧស្សាហូបនីយកម្មសេដ្ឋកិច្ចរបស់រដ្ឋាភិបាល អាចសម្រេចបានកំណើនយ៉ាងហោចណាស់ ដល់ ៦,២% ប្រសិនបើប្រភពនៃកំណើនបានធ្វើពិពិធកម្ម ហើយសេដ្ឋកិច្ចក៏កាន់តែធន់ទ្រាំបាននឹងការប៉ះទង្គិចពីខាងក្រៅ។ កម្ពុជាអាចសម្រេចបានអត្រាកំណើន ៥-៧% ប៉ុន្តែការសម្រេចអត្រាកំណើនដល់ ៩% ត្រូវជួបបញ្ហាប្រឈមច្រើនជាង និងដាក់សម្ពាធខ្លាំងជាងទៅលើការបែងចែកធនធានមនុស្ស និងធនធានធម្មជាតិដើម្បីគាំទ្រដល់វិស័យជំរុញកំណើននានា និងវិស័យផុសឡើងថ្មី ហើយក៏ទាមទារវិនិយោគច្រើនថែមទៀតក្នុងវិស័យថាមពល ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និង ការអភិវឌ្ឍធនធានមនុស្សប្រកបដោយគុណភាព។

រូបភាព ១៖ ការគន់គូរពី ផសស ក្នុងមនុស្សម្នាក់ របស់កម្ពុជា (ឆ្នាំ២០១០-២០៣០)




*ប្រភព៖ ការគន់គូររបស់ CDRI ដោយប្រើសេណារីយ៉ូមានកំណើន ៥% ៧% និង ៩%*

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (ឆ្នាំ២០១០) បានគន់គូរថា អតិផរណានឹងនៅតែទាបជាង ៥% នៅចន្លោះឆ្នាំ២០១០ និង ២០១៥ ទោះបីជារឿងនេះ ងាយរងឥទ្ធិពលពីការឡើងចុះថ្លៃប្រេង អាហារ និងផលិតផលប្រើប្រាស់ក្តី។ អតិផរណាក៏អាចកើនឡើងដែរ ប្រសិនបើរដ្ឋាភិបាលវិនិយោគប្រាក់ចំណូលពីធនធានប្រេង និងឧស្ម័ន យ៉ាងច្រើនៗនិងឆាប់រហ័សពេក ទៅក្នុងផ្នែកហេដ្ឋារចនាសម្ព័ន្ធសង្គម។ ហានិភ័យទី១ អាចដោះស្រាយបាន តាមរយៈគោលនយោបាយនាំចេញស្រូវរបស់រដ្ឋាភិបាល រីឯហានិភ័យទី២ អាចជៀសវាងបាន តាមរយៈការចំណាយហិរញ្ញវត្ថុដោយប្រយ័ត្នប្រយែង និងមានវិន័យល្អ។ តាមការអនុវត្តបែបនេះ កម្រិតថ្លៃទំនិញអាចបន្តមានស្ថិរភាពនៅទសវត្សរ៍ក្រោយទៀត។

**កម្ពុជាពឹងផ្អែកតិចលើជំនួយ៖** គេនៅតែសម្គាល់ថា កម្ពុជាជាប្រទេស "ពឹងផ្អែកលើជំនួយ"។ ប្រាក់ជំនួយសរុប មានទាំងប្រាក់បើកផ្តល់ឲ្យអង្គការមិនមែនរដ្ឋាភិបាលផង មានប្រមាណ ១០,៨៧៣ពាន់លានដុល្លារក្នុងចន្លោះឆ្នាំ១៩៩២ និង ២០១០។ នៅឆ្នាំ១៩៩២ ប្រាក់ជំនួយបើកផ្តល់ឲ្យ មានត្រឹម ២៥០,២លានដុល្លារប៉ុណ្ណោះ ហើយភាគច្រើនជាជំនួយសង្គ្រោះសម្រាប់គ្រោះធម្មជាតិ និងសង្គ្រាមស៊ីវិល។ នៅឆ្នាំ២០១០ ប្រាក់បើកផ្តល់ បានកើនដល់ ១,០៨៥ពាន់លានដុល្លារ ហើយគ្របដណ្តប់លើវិស័យដូចជា អភិបាលកិច្ច កសិកម្ម បរិស្ថាន ការអប់រំ ការថែទាំសុខភាព ថាមពល និងការដឹកជញ្ជូន[៣]។

ការពឹងផ្អែកលើជំនួយ នឹងថយចុះជាបណ្តើរៗ ដោយសារ ចំណូលពន្ធនឹងកើនឡើងទន្ទឹមគ្នានឹងកំណើនសេដ្ឋកិច្ច។ អនុបាតនៃចំណូលក្នុងស្រុក ជាមួយនឹង ផសស កើនពី ១០,១% នៅឆ្នាំ២០០០ ដល់ ១២,៦% នៅឆ្នាំ២០១០ ហើយរំពឹងថានឹងកើនដល់ ១៥,២% នៅឆ្នាំ២០១៥ (MEF 2010)។ អនុបាតនៃការបើកផ្តល់ជំនួយ ជាមួយនឹងចំណាយថវិកាសរុប បានធ្លាក់ចុះយ៉ាងខ្លាំងពី ៨៧,៥% នៅឆ្នាំ១៩៩៩ មកត្រឹម ៤៧,៩% នៅឆ្នាំ២០១០ (CDC 2010)។ ម្យ៉ាងទៀត

៣ សម្រាប់ព័ត៌មានលម្អិត សូមមើលរបាយការណ៍ប្រសិទ្ធភាពជំនួយនៅកម្ពុជា (CDC 2007, 2008 & 2010)។

មានប្លុកប្រេង និងឧស្ម័នជាច្រើនកន្លែងក្នុងសមុទ្រកម្ពុជា ហើយប្រេង និងឧស្ម័នទាំងនោះ រំពឹងថានឹងបង្កើតប្រាក់ចំណូលយ៉ាងច្រើនក្នុងពីរ-បីឆ្នាំខាងមុខ។ ចំណុចនេះបង្ហាញពីការផ្លាស់ប្តូរជាបណ្តើរៗចេញពីស្ថានភាពពឹងផ្អែកលើជំនួយ។

**កម្ពុជាមានរបបសេដ្ឋកិច្ចកាន់តែសម្បូរបែប៖** នៅឆ្នាំ២០០៦ រដ្ឋាភិបាលបានសហការជាមួយ UNDP បង្កើត "យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្ម" (DTIS) ដែលបានកំណត់ផលិតផល និងសេវាកម្ម ចំនួន ១៩មុខ មានសក្តានុពលនាំចេញកម្រិតខ្ពស់ខុសៗគ្នា (UNDP 2007a)[៤]។ DTIS ត្រូវបានបង្កើតឡើងក្នុងបំណងធ្វើពិពិធកម្មមូលដ្ឋាននាំចេញ និងទីផ្សារនាំចេញរបស់កម្ពុជា។ បន្ទាប់មក មានការដាក់អនុវត្ត អភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម ដើម្បីជួយសម្របសម្រួល និងគ្រប់គ្រងជំនួយសម្រាប់ពាណិជ្ជកម្មកម្ពុជា។ ការបង្កើតគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករ នៅពាក់កណ្តាលឆ្នាំ២០១០ រំពឹងថានឹងជួយពង្រីកវិស័យស្រូវអង្ករបន្ថែមទៀត។ ក្រសួងពាណិជ្ជកម្ម ក៏បានចាប់ផ្តើមស្វែងរកទីផ្សារថ្មីៗសម្រាប់ការនាំចេញសំលៀកបំពាក់ ដូចជា ទីផ្សារជប៉ុន រុស្ស៊ី និងបណ្តាប្រទេសនៅតំបន់មជ្ឈិមបូព៌ា ជាដើម។

ការបង្គរទុកមូលធន មានសារៈសំខាន់ណាស់សម្រាប់ពិពិធកម្មមូលដ្ឋានតូចចង្អៀតនៃសេដ្ឋកិច្ចកម្ពុជា។ ដូច្នេះ ប្រាក់ចំណូលពីវិស័យប្រេង និងឧស្ម័នក្នុងសមុទ្រ ដែលរំពឹងថានឹងទទួលបានក្នុងប៉ុន្មានឆ្នាំខាងមុខ អាចយកមកប្រើក្នុងការសម្រួលដល់វិស័យជំរុញកំណើននានា និងវិស័យទើបផុសឡើងថ្មី។ ការងារនេះ គឺអាចអនុវត្តបានតាមរយៈអន្តរាគមន៍ទៅលើវិស័យជ្រើសរើសមួយចំនួន ដោយយោងតាមបញ្ជីផលិតផលទាំង ១៩មុខ កំណត់ដោយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានា។

**កម្ពុជាមានរបបសេដ្ឋកិច្ចប្រើប្រាក់ដុល្លារតិចជាងមុន៖** កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាល ដើម្បីកាត់បន្ថយដុល្លារូបនីយកម្មសេដ្ឋកិច្ច បានធ្វើឡើងដោយប្រុងប្រយ័ត្ន ប៉ុន្តែលូតលាស់ទៅមុខយឺតៗ។ វិធានការមួយចំនួនដែលបានដាក់អនុវត្ត រួមមាន ការប្រើប្រាក់រៀលសម្រាប់បើកប្រាក់ខែបុគ្គលិករដ្ឋ បង់ពន្ធ និងបង់ថ្លៃទឹកភ្លើង។ ប៉ុន្តែមកទល់ពេលនេះ រដ្ឋាភិបាលមិនទាន់ដែលបានហាមឃាត់ការប្រើប្រាក់ដុល្លារទេ ដោយពិនិត្យឃើញបទពិសោធអវិជ្ជមានរបស់ប្រទេសឡាវ នៅពេលអនុវត្តវិធីសាស្ត្រនេះនៅឆ្នាំ២០០៧។ Menon (2008) Duma (2010) និង Huot and Khan (2010) បានទទួលស្គាល់ថា បដិដុល្លារូបនីយកម្ម ត្រូវធ្វើឡើងដោយសន្សឹមៗក្នុងរយៈពេលវែង។ Zamaróczy and Sa (2002) Huot and Khan និង Menon បានផ្តល់យោបល់ឲ្យអនុវត្តតាម Currency Board Agreement (CBA)[៥] ប៉ុន្តែ លោក Menon បញ្ជាក់ថា វិធីនេះអាចលើសពីសមត្ថភាពហិរញ្ញវត្ថុរបស់កម្ពុជានាពេលបច្ចុប្បន្ន។ កម្ពុជាត្រូវអនុវត្តវិធានការជាច្រើនទៀត ដើម្បីអាចយកប្រាក់រៀលទៅជំនួសប្រាក់ដុល្លារបាននៅទសវត្សរ៍ខាងមុខ។

**កម្ពុជាជាសង្គមគ្មានភាពក្រីក្រ និងមានសមធម៌៖** ការកាត់បន្ថយថែមទៀតនូវភាពក្រីក្រ និងវិសមភាព ត្រូវមានវិនិយោគសាធារណៈកាន់តែច្រើន ក្នុងវិស័យបម្រើឲ្យជនក្រីក្រ ដូចជាការថែទាំសុខភាព ការអប់រំ និងអភិវឌ្ឍន៍ជនបទ។ ផ្អែកលើគោលដៅអភិវឌ្ឍន៍សហសវត្សរ៍កម្ពុជា (CMDG) សមាមាត្រប្រជាជនមានប្រាក់ចំណូលក្រោមខ្សែបន្ទាត់ភាពក្រីក្រជាតិ រំពឹងថានឹងធ្លាក់ចុះមកត្រឹម ១៩,៥% នៅឆ្នាំ២០១៥។ អនុបាតនៃវិនិយោគសាធារណៈ ជាមួយនឹង ផសស

៤ សម្រាប់បញ្ជីផលិតផល និងសេវាកម្ម ទាំង១៩មុខ សូមមើល UNDP (2007:4; 36-60)។

៥ កិច្ចព្រមព្រៀងតម្រូវឲ្យរក្សាអត្រាប្តូរប្រាក់ថេរជាមួយរូបិយវត្ថុបរទេស។

មានប្រមាណ ៥,៨% នៅចន្លោះឆ្នាំ១៩៩៣ និង ២០១០ ហើយរំពឹងថានឹងកើនដល់ ៦,៨% នៅចន្លោះឆ្នាំ២០១០ និង ២០១៥។

ប្រទេសថៃ និងវៀតណាម សម្រេចបានលទ្ធផលប្រហាក់ប្រហែលគ្នាក្នុងផ្នែកអប់រំ និងថែទាំសុខភាព ហើយនៅឆ្នាំ២០០៧ បានលៃចែកថវិកា ២០,៨% និង ១៩,៨% នៃចំណាយសរុបសម្រាប់ការអប់រំ និង ១៣,១% និង ៨,៧% រៀងគ្នា សម្រាប់ការថែទាំសុខភាព (World Bank 2011)។ ដូច្នេះ កម្ពុជាអាចលៃចែកថវិកាពី ១៦,៤% ទៅ ២១,៤% នៃចំណាយសរុបសម្រាប់ការអប់រំ និងពី ១១,៩% ទៅ ១៥,៦% សម្រាប់ការថែទាំសុខភាព ដើម្បីអាចកែលម្អដែនគ្របដណ្តប់ និងការផ្តល់សេវាសាធារណៈ បានច្រើនគួរសម ប្រសិនបើចេះប្រើធនធានទាំងនោះប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព។ ការលៃចែកថវិកាបន្ថែមនេះ អាចពន្លឿនដំណើរការឈានទៅសម្រេចតាមគោលដៅសហស្សវត្សរ៍លើផ្នែក (១) អក្ខរកម្ម និងការអប់រំនារី និងក្មេងស្រី (២) ការកាត់បន្ថយអត្រាមរណមាតាមកត្រឹម ១៤០នាក់ ក្នុងកំណើតរស់ ១០០.០០០នាក់ នៅឆ្នាំ២០១៥ និង ការលើកកម្ពស់លទ្ធភាពប្រើប្រាស់សេវាថែទាំសុខភាពរបស់នារី។ ប្រសិនបើប្រាក់ចំណូលពីធនធានប្រេង និងឧស្ម័ននៅក្នុងសមុទ្រ អាចទទួលបានតាមការគន់គូរនោះ រដ្ឋាភិបាលនឹងអាចបង្កើនចំណាយបានយ៉ាងច្រើនក្នុងវិស័យសុខាភិបាល និងអប់រំ។

## ៤. ការអភិវឌ្ឍប្រទេសកម្ពុជា និងបរិបទក្នុងតំបន់

ទីតាំងជាយុទ្ធសាស្ត្រ និងអំណោយផលខាងសេដ្ឋកិច្ចរបស់កម្ពុជា នៅក្នុង GMS និងតំបន់អាស៊ាន ព្រមទាំងស្ថានភាពនៅជិតប្រទេសចិន គឺជាសម្បត្តិដ៏សំខាន់មួយ ដែលបើកឱកាសឲ្យកម្ពុជាទាញយកអត្ថប្រយោជន៍ពីបណ្តាញផលិតកម្ម GMS ការពង្រីកទីផ្សារពីប្រទេសចិនភាគខាងត្បូងមកកាន់ GMS និងទៅកាន់ប្រទេសសមាជិកអាស៊ានដទៃទៀត ព្រមទាំងប្រទេសអូស្ត្រាលី និងនូវែលហ្សេឡង់ ដើម្បីជំរុញកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យឯកជន ការបង្កើតការងារ និងការកាត់បន្ថយភាពក្រីក្រ។ គេឃើញមានជាស្រេចហើយនូវសញ្ញាវិជ្ជមាននៃកំណើនផលិតផលនាំចេញទៅប្រទេសចិន ដូចជា អង្ករ កៅស៊ូ ដំឡូងឈើ ពោត សណ្តែកសៀង រ៉ែផ្សេងៗ និង កំណើនវិនិយោគលើកសិពាណិជ្ជកម្ម និងការកែច្នៃស្បៀងអាហារ។ ទំនាក់ទំនងពាណិជ្ជកម្ម និងវិនិយោគទុន ជាមួយប្រទេសវៀតណាម កូរ៉េខាងត្បូង និង ជប៉ុន ក៏កំពុងលូតលាស់យ៉ាងលឿនដែរ។

កម្ពុជា ក៏ជាប្រទេសទទួលផលចម្បងមួយពីគំនិតផ្តួចផ្តើមតភ្ជាប់ទំនាក់ទំនង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្តរបស់អាស៊ាន និង GMS ដែលមានគម្រោងកែលម្អផ្លូវថ្នល់ ផ្លូវដែក ស្ពាន ផ្លូវទឹក និងកំពង់ផែសំខាន់ៗជាច្រើន កំពុងបង្ហើយ ឬកំពុងជឿនលឿនទៅមុខ។ ប៉ុន្តែហេដ្ឋារចនាសម្ពន្ធ័ស្ថាប័ន ដូចជា ប្រព័ន្ធរដ្ឋបាល និងជំនាញសម្រាប់សម្រួលលំហូរទំនិញនិងប្រជាជនឆ្លងកាត់ព្រំដែន ជាដើម វានៅយឺតយ៉ាវ ហើយក្លាយជាឧបសគ្គដល់ចលនាប្រជាជន ការដឹកជញ្ជូន និងការសម្របសម្រួលពាណិជ្ជកម្ម។

នៅឆ្នាំ២០១២ នេះ ប្រទេសកម្ពុជាដល់វេណធ្វើប្រធានអាស៊ាន។ គួររំលឹកថា កម្ពុជាបានចូលជាសមាជិកសកម្មរបស់អាស៊ាន តាំងពីឆ្នាំ១៩៩៩ មក និងជាអ្នកគាំទ្រយ៉ាងសកម្មដល់អាស៊ាន អាស៊ានបូកបី (ចិន ជប៉ុន និង កូរ៉េខាងត្បូង) និង ដំណើរការសហប្រតិបត្តិការនិងកិច្ចចរចាជាទូទៅ។ កម្ពុជាត្រូវទទួលបានអត្ថប្រយោជន៍ជាច្រើន ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ានបូកមួយ ជាពិសេស កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន និង កម្មវិធីប្រមូលផល

ដើមដៃនៃកិច្ចព្រមព្រៀងនេះ (សម្រាប់ផលិតករផ្នែកកសិកម្ម) ហើយតទៅមុខទៀត គឺអត្ថប្រយោជន៍ពីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និង កិច្ចព្រមព្រៀងសហប្រតិបត្តិការសេដ្ឋកិច្ចនៅអាស៊ីបូព៌ា។

ការអភិវឌ្ឍធនធានមនុស្ស និងការពង្រឹងស្ថាប័នក្នុងរយៈពេលវែង មានសារៈសំខាន់ស្នូលសម្រាប់លើកកម្ពស់សមត្ថភាពប្រទេសកម្ពុជា និងប្រទេសលូតលាស់តិចជាងគេផ្សេងទៀតក្នុងអាស៊ាន ឲ្យឈានឡើងដល់ដំណាក់កាលបន្ទាប់នៃការអភិវឌ្ឍសេដ្ឋកិច្ច និង សមាហរណកម្មក្នុងអនុតំបន់ និងតំបន់។ កម្ពុជាមានការប្តេជ្ញាចិត្តខ្ពស់ចំពោះសហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC) ឆ្នាំ២០១៥ ប៉ុន្តែគេបារម្ភថា កម្ពុជាអាចមិនសម្រេចចំណុចនេះបានទាំងស្រុងទេ។ នាបច្ចុប្បន្នកម្ពុជាជាប់ចំណាត់ថ្នាក់លេខ៣ នៅអាស៊ាន លើការត្រៀមខ្លួនបំពេញកាតព្វកិច្ចក៏សំខាន់ៗទាំងឡាយ ប៉ុន្តែនៅមានបញ្ហាមិនទាន់ដោះស្រាយជាច្រើន ដូចជា ការជួញដូរឆ្លងកាត់ព្រំដែន និង បទបញ្ញត្តិជាក់លាក់សម្រាប់ប្រទេសលូតលាស់តិចជាងគេ។ ភាពត្រៀមខ្លួនស្រេចរបស់កម្ពុជា សម្រាប់ AEC ឆ្នាំ២០១៥ វាជាប់ទាក់ទងនឹងភាពបើកចំហនៃសេដ្ឋកិច្ចកម្ពុជា និងការអនុវត្តតាមគោលការណ៍ WTO និង AEC។ ទោះយ៉ាងណាក្តី ការចូលពាក់ព័ន្ធរបស់វិស័យឯកជន ក្នុងដំណើរការអាស៊ាន និងការយល់ដឹងពីអត្ថប្រយោជន៍ និងឱកាសល្អនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន និងសមាហរណកម្មក្នុងតំបន់ វាមានលក្ខណៈមិនស្មើគ្នា ឬក៏អន់ខ្សោយតែម្តង។

ក្នុងការធ្វើជាប្រធានអាស៊ាន អាទិភាពរបស់កម្ពុជា មានជាអាទិ៍ (១) ការសម្រេច AEC បានដោយជោគជ័យ នៅឆ្នាំ២០១៥ តាមរយៈការតភ្ជាប់ទំនាក់ទំនង និងការធ្វើសមាហរណកម្មសេដ្ឋកិច្ច កាន់តែជិតស្និទ្ធថែមទៀត (២) ការពង្រឹងយន្តការអាស៊ាន ដើម្បីធានាសន្តិភាព សន្តិសុខ និងស្ថិរភាពក្នុងតំបន់ ដូចជា វេទិកាតំបន់របស់អាស៊ាន (ARF) ជាដើម និង (៣) ការពង្រឹងអាស៊ានឲ្យក្លាយជាស្ថាប័នកម្រិតតំបន់មួយដ៏មានប្រសិទ្ធភាព និងមានសំឡេងខ្លាំងក្នុងកិច្ចការអន្តរជាតិ។ ជាការចាំបាច់ផងដែរសម្រាប់កម្ពុជា និងប្រទេសលូតលាស់តិចជាងគេឯទៀតក្នុងអាស៊ាន ដែលអាស៊ានត្រូវអនុវត្តតាមការប្តេជ្ញាចិត្តក្នុងធម្មនុញ្ញរបស់ខ្លួន លើការកាត់បន្ថយភាពក្រីក្រ និងគំលាតកម្រិតអភិវឌ្ឍន៍ក្នុងអាស៊ាន តាមរយៈកិច្ចសហប្រតិបត្តិការ និងការជួយគ្នាទៅវិញទៅមក។ គំនិតផ្តួចផ្តើមយ៉ាងច្រើននិងស្មុគស្មាញសម្រាប់ជំរុញទំនាក់ទំនង ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច និងការកាត់បន្ថយភាពក្រីក្រនៅក្នុងអាស៊ាន និង GMS គឺជាបញ្ហាប្រឈមមួយចំពោះសមត្ថភាពស្ថាប័ន និងវិស័យឯកជននៅកម្ពុជា។ ដូច្នេះ ការអភិវឌ្ឍសមត្ថភាពស្ថាប័នក្នុងរយៈពេលវែង និងក្នុងពេលស្របគ្នាល្អ សម្រាប់ប្រទេសលូតលាស់តិចជាងគេក្នុងអាស៊ាន និង GMS គឺជាអាទិភាពមួយសម្រាប់ទាំងកម្មវិធី GMS របស់ធនាគារអភិវឌ្ឍន៍អាស៊ី និង គំនិតផ្តួចផ្តើមនានារបស់អាស៊ាន ដើម្បីជំរុញសមាហរណកម្មក្នុងអាស៊ាន។

ទំនាក់ទំនងដ៏រឹងមាំនិងជ្រៀលជ្រៅរវាងកម្ពុជា និងចិន គឺសំខាន់បំផុតសម្រាប់អនាគតនៃអាស៊ាន និងអាស៊ីបូព៌ា យោងតាមការរីកធំធាត់នាពេលថ្មីៗនៃវិស័យពាណិជ្ជកម្ម ទេសចរណ៍ វិនិយោគ និងសហប្រតិបត្តិការអភិវឌ្ឍន៍។ នាបច្ចុប្បន្ន ចិនជាប្រភពផ្តល់វិនិយោគ និងជំនួយអភិវឌ្ឍន៍លំដាប់ទី១ របស់កម្ពុជា ហើយប្រទេសទាំងពីរក៏មានទំនាក់ទំនងរឹងមាំ និងជ្រៀលជ្រៅផងដែរ ខាងផ្នែកនយោបាយ សេដ្ឋកិច្ច និងយុទ្ធសាស្ត្រ។ កម្ពុជាកំពុងរក្សាឲ្យទំនាក់ទំនងដ៏សំខាន់នេះ មានតុល្យភាពជាមួយទំនាក់ទំនងដ៏ល្អជាមួយប្រទេសឯទៀត ដូចជា ជប៉ុន កូរ៉េខាងត្បូង វៀតណាម សហរដ្ឋអាមេរិក និង អូស្ត្រាលី ជាដើម ហើយទំនាក់ទំនងនេះអាចពង្រឹងឡើងតាមរយៈការធ្វើជាប្រធានអាស៊ាន។

## ៥. បញ្ហាប្រឈមធំៗមួយចំនួន ចំពោះដំណើរឆ្ពោះទៅមុខ

ទោះជាទទួលបានជោគជ័យគួរឲ្យកត់សម្គាល់ក្នុងកំណើនសេដ្ឋកិច្ច ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមកិច្ច ការកាត់បន្ថយភាពក្រីក្រ និងការលើកកម្ពស់ជីវភាពប្រជាពលរដ្ឋក្តី ក៏កម្ពុជានៅតែត្រូវប្រឈមនឹងបញ្ហាជាច្រើនក្នុងការសម្រេចបំណងប្រាថ្នារយៈពេលវែងរបស់ខ្លួន។ បញ្ហាប្រឈមទាំងនោះ រួមមាន៖

**ការអភិវឌ្ឍធនធានមនុស្ស៖** ការអភិវឌ្ឍធនធានមនុស្ស គឺជាកត្តាជំរុញមួយនៃការអភិវឌ្ឍសេដ្ឋកិច្ច និងជាមូលដ្ឋានគ្រឹះនៃការលើកកម្ពស់ជីវភាពប្រជាជន (World Bank 2006)។ ថ្វីបើកម្ពុជាទទួលបានជោគជ័យជាច្រើនក្នុងការកែលម្អប្រព័ន្ធអប់រំ និងលទ្ធផលអប់រំក្តី ប៉ុន្តែការអភិវឌ្ឍធនធានមនុស្សនៅតែជាឧបសគ្គចម្បងមួយ ហើយជារឿយៗនារីតែងស្ថិតក្នុងក្រុមចាញ់ប្រៀបគេ។ កង្វះខាតកម្លាំងពលកម្មមានការអប់រំ និងជំនាញ បានពន្យឺតដំណើរការផ្លាស់ប្តូរពីសង្គមពឹងផ្អែកខ្លាំងលើកសិកម្ម ទៅជាសេដ្ឋកិច្ចសម្បូរបែបជាងមុនដែលក្នុងនោះ វិស័យសេវាកម្ម និងផលិតកម្ម រួមចំណែកបានច្រើនជាងមុនដល់កំណើនសេដ្ឋកិច្ច។

បញ្ហាប្រឈមដទៃទៀតចំពោះការលើកកម្ពស់ធនធានមនុស្ស និងការផ្គត់ផ្គង់កម្លាំងពលកម្មមានសមត្ថភាពប្រកួតប្រជែងនឹងគេ រួមមាន៖ គុណភាពអន់នៃការអប់រំ អត្រាខ្ពស់នៃការរៀនត្រួតថ្នាក់និងការបោះបង់ការសិក្សា សមត្ថភាពស្រាវជ្រាវកម្រិតទាបនៅថ្នាក់ឧត្តមសិក្សា ភាពមិនស៊ីគ្នារវាងការផ្គត់ផ្គង់និងតម្រូវការកម្លាំងពលកម្ម ផលិតភាពទាបនៃកម្លាំងពលកម្ម និងកង្វះទាំងជំនាញខាងបច្ចេកទេស (hard skill) និងខាងវិទ្យាសាស្ត្រសង្គម (soft skill)។ ការកែលម្អវិស័យទាំងនេះ ជាកត្តាដ៏ចាំបាច់ដើម្បីជំរុញកំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍប្រកបដោយនិរន្តរភាព។ មានបញ្ហាធំៗជាច្រើនក្នុងប្រព័ន្ធអប់រំកម្រិតខ្ពស់ ដែលត្រូវដោះស្រាយជាពិសេសទាក់ទងនឹងការកែលម្អគុណភាពអប់រំ។ សមត្ថភាពស្រាវជ្រាវនៅតាមស្ថាប័នអប់រំកម្រិតខ្ពស់ ក៏នៅទន់ខ្សោយដែរ (Pith & Ford 2004; Chet 2009; DRF Cambodia 2010)។ ការកែលម្អគុណភាព និងសមត្ថភាពស្រាវជ្រាវនៅតាមសាកលវិទ្យាល័យនៅកម្ពុជា សំខាន់ខ្លាំងណាស់ ពីព្រោះ "ការស្រាវជ្រាវយ៉ាងហ្មត់ចត់និងឯករាជ្យនៅតាមសាកលវិទ្យាល័យ អាចចូលរួមយ៉ាងសំខាន់ដល់ការអភិវឌ្ឍប្រទេសក្នុងរយៈពេលវែង" (DRF 2010: 47)។

**កំណើនប្រកបដោយនិរន្តរភាពផ្អែកលើការអភិវឌ្ឍកសិកម្ម និងពិពិធកម្មសេដ្ឋកិច្ច៖** តួនាទីដ៏សំខាន់នៃកសិកម្មនៅក្នុងសេដ្ឋកិច្ចកម្ពុជា បានផុសឡើងច្បាស់ក្នុងអំឡុងពេលនិងក្រោយពេលមានវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាកល ប៉ុន្តែសក្តានុពលពេញលេញរបស់វិស័យនេះមិនទាន់សម្រេចបាននៅឡើយទេ ដោយសារផលិតភាពកសិកម្មទាប និងកង្វះពិពិធកម្ម ក្នុងនេះវិនិយោគសាធារណៈមិនគ្រប់គ្រាន់លើផ្នែកបច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធជនបទ ដូចជា ផ្លូវលំ និងប្រព័ន្ធធារាសាស្ត្រ គឺជាឧបសគ្គចម្បងកាត់បន្ថយផលិតភាពកសិកម្ម។ កសិកម្មក៏ត្រូវប្រឈមនឹងហានិភ័យនៃការផ្លាស់ប្តូរអាកាសធាតុ និងគ្រោះធម្មជាតិផងដែរ។ ទោះបីកម្ពុជាមិនសូវជួបគ្រោះមហន្តរាយទាំងនេះញឹកញាប់ដូចប្រទេសឯទៀតក្នុងតំបន់ក្តី ក៏វានៅតែជាការគំរាមកំហែងពិតៗចំពោះកសិកម្មដែរ។

ពិពិធកម្មសេដ្ឋកិច្ច នៅតែជាបញ្ហាប្រឈមចម្បងមួយ ចំពោះការព្យាយាមសម្រេចបានកំណើនជាប់លាប់ក្នុងរយៈពេលវែង។ នៅទសវត្សរ៍ចុងក្រោយនេះ វិស័យកាត់ដេរ សំណង់ ទេសចរណ៍ និង កសិកម្ម បានរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចកម្ពុជា បើទោះជាវាមិនសូវមានការធ្វើពិពិធកម្មក្តី។ ដើម្បីសម្រេចបានកំណើនក្នុងរយៈពេលវែង កម្ពុជាត្រូវពង្រីកនិងធ្វើពិពិធកម្ម

មូលដ្ឋានសេដ្ឋកិច្ចរបស់ខ្លួន ដោយបានគិតគូរដល់បញ្ហាប្រឈមធំៗ នៃការកែលម្អភាពប្រកួតប្រជែង និង វិនិយោគក្នុងផ្នែកបច្ចេកវិទ្យានិងហេដ្ឋារចនាសម្ព័ន្ធ ដែលជាធាតុចូលដ៏ចាំបាច់សម្រាប់ជំរុញផលិតភាព។

**ការកាត់បន្ថយភាពក្រីក្រ៖** ភាពក្រីក្រនៅតែជាបញ្ហាប្រឈមធំមួយនៅកម្ពុជា ទោះបីជាតួលេខភាពក្រីក្រជាតិបានថយចុះខ្លះក្តី។ ជាក់ស្តែង វិបត្តិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាកលអាចបង្កកំណើនភាពក្រីក្រក្នុងតំបន់ខ្លះ តាមការថយចុះប្រាក់ចំណូលដោយសារការបាត់បង់ការងារក្នុងវិស័យកាត់ដេរ សំណង់ និង ទេសចរណ៍ (សូមមើល Jalilian & Reyes 2010) ដែលអាចរុញច្រានប្រជាជនជាច្រើនឲ្យធ្លាក់ចូលក្នុងភាពក្រីក្រវិញ ឬ យ៉ាងហោចណាស់ក៏ធ្វើឲ្យគំលាតភាពក្រីក្រកាន់តែរីកធំដែរ។ ធនាគារពិភពលោក (២០០៩) វាយតម្លៃថា វិបត្តិហិរញ្ញវត្ថុសាកល អាចបង្កើនតួលេខភាពក្រីក្រពី ១ ទៅ ៤ ឯកតាភាគរយ ពីលើកម្រិតឆ្នាំ២០០៧។ ប្រសិនបើដូច្នេះមែន កម្ពុជាត្រូវការពី ២ ទៅ ៦ឆ្នាំ ដើម្បីទទួលបានអត្រានៃភាពក្រីក្រដូចកាលពីឆ្នាំ២០០៧វិញ ដោយសន្មតថាសេដ្ឋកិច្ចកម្ពុជាមានកំណើនជាមធ្យម ៧% ក្នុងមួយឆ្នាំ។

ដោយសារភាពក្រីក្រមួយចំនួនធំ ស្ថិតនៅតំបន់ជនបទដែលមានប្រជាជនភាគច្រើនប្រកបរបរកសិកម្ម ដូច្នេះ ការសម្រេចបានកំណើនវិស័យកសិកម្មមានមូលដ្ឋានធំទូលាយ វាមានសារៈសំខាន់បំផុតក្នុងការលុបបំបាត់ភាពក្រីក្រ។ ការលុបបំបាត់ភាពក្រីក្រ ទាមទារការលើកកម្ពស់លទ្ធភាពទទួលបានសេវាសង្គមសំខាន់ៗ ដូចជា តំហែទាំសុខភាព និងការអប់រំ ក៏ដូចជាសំណាញ់សុវត្ថិភាពសង្គម ដែលមានជាអាទិ៍ ការផ្ទេរប្រាក់ (មានលក្ខខណ្ឌ) និង គម្រោងខាងផ្នែកស្បៀងអាហារ ដែលអាចជួយឲ្យគ្រួសារក្រីក្រទប់ទល់នឹងការបាត់បង់ប្រាក់ចំណូលជាបណ្តោះអាសន្នផ្សេងៗ។ កម្ពុជាក៏ត្រូវដោះស្រាយផងដែរនូវបញ្ហាកង្វះខាតឥណទាននៅជនបទ ដែលតាមការប៉ាន់ស្មានមានទំហំពី ៦០លានដុល្លារ ទៅ ៧០លានដុល្លារ ក្នុងមួយឆ្នាំៗ (Hang 2009)។ កង្វះលទ្ធភាពទទួលបានឥណទាននេះ បានរារាំងគ្រួសារក្រីក្រក្នុងការធ្វើវិនិយោគលើដីធ្លី និងកម្លាំងពលកម្ម។

**ការគ្រប់គ្រងធនធានធម្មជាតិ៖** កម្ពុជាជាប្រទេសសម្បូរធនធានធម្មជាតិ ហើយធនធានឧស្ម័ននិងប្រេងកាតក្នុងសមុទ្រ អាចជាប្រភពដ៏ចម្បងមួយនៃប្រាក់ចំណូលទៅអនាគត។ កម្ពុជាក៏មានធនធានរ៉ែផ្សេងៗ ដូចជា រ៉ែមាស បុកស៊ីត រ៉ែដែក ត្បូងមានតម្លៃ និង ថ្មកែវ ហើយការរុករកនិងជីកយកវា កំពុងតែកើនឡើង។ កំណើនប្រជាជន និងតម្រូវការថាមពលខ្ពស់ បានដាក់សម្ពាធលើចីរភាពនៃការប្រើប្រាស់ធនធានទាំងនោះ ដូច្នេះត្រូវមានកិច្ចប្រឹងប្រែងសហការគ្នាពីសំណាក់អ្នកពាក់ព័ន្ធនានា។ បញ្ហាប្រឈមចំពោះការគ្រប់គ្រងធនធានធម្មជាតិ រួមមាន ការគ្រប់គ្រង និងសម្របសម្រួលប្រកបដោយប្រសិទ្ធភាពក្នុងចំណោមសហគមន៍មូលដ្ឋាន និង ការពង្រឹងស្ថាប័នរដ្ឋនិងសមត្ថភាពធនធានមនុស្ស។ ជាឧទាហរណ៍ អភិបាលកិច្ចក្នុងវិស័យឧស្ម័ននិងប្រេងកាតត្រូវការចំណេះដឹង ជំនាញបច្ចេកទេសកម្រិតខ្ពស់ក្នុងវិស័យខុសៗគ្នាជាច្រើន។ កត្តាសំខាន់មួយទៀត គឺ តម្រូវការបង្កើតគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងសារពើពន្ធដ៏មានប្រសិទ្ធភាពដើម្បីត្រួតពិនិត្យ និងគ្រប់គ្រងលើផលប៉ះពាល់ខាងម៉ាក្រូសេដ្ឋកិច្ច នៃការប្រមូលចំណូលនិងការចំណាយថវិកា។ ការគ្រប់គ្រងធនធានធម្មជាតិ ទាមទារនូវកម្លាំងចម្រុះរួមគ្នាពីសំណាក់អ្នកពាក់ព័ន្ធទាំងអស់ តាំងពីរដ្ឋាភិបាលថ្នាក់កណ្តាលដល់ថ្នាក់មូលដ្ឋាន និងវិស័យឯកជន។ គំរូសម្រាប់ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយនិរន្តរភាព មិនអាចដូចគ្នាទាំងអស់ទេ គឺគេត្រូវគិតគូរដល់បរិបទជាក់ស្តែង និងបញ្ហាប្រឈមនៅតាមមូលដ្ឋាន។

**ការតភ្ជាប់ទំនាក់ទំនង និងសមាហរណកម្មក្នុងតំបន់៖** កម្ពុជាបានជាប់ចំណាត់ថ្នាក់ល្អក្នុងការប្ដេជ្ញាចិត្តធ្វើសមាហរណកម្មក្នុងតំបន់ ប៉ុន្តែមិនទាន់ទទួលបានអត្ថប្រយោជន៍ពេញលេញពីសមាហរណកម្មនេះទេ។ ពាណិជ្ជកម្មកម្ពុជានៅក្នុងតំបន់ មានទំហំតូចណាស់ បើធៀបនឹងប្រទេសឯទៀតនៅតំបន់នេះ។ ពាណិជ្ជកម្មក្នុងតំបន់ក៏មានចោទបញ្ហា គំលាតកម្រិតអភិវឌ្ឍន៍រវាងប្រទេសលូតលាស់តិចជាងគេ (ដូចជា កម្ពុជា) ជាមួយនឹងបណ្ដាប្រទេសអាស៊ានមានកម្រិតអភិវឌ្ឍជឿនលឿនជាង ដែលគេតែងហៅថា អាស៊ាន៦។ តួយ៉ាង កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន បានដាក់សម្ពាធលើកម្ពុជា ឲ្យបង្កើនប្រាក់ចំណូលមិនមែនពន្ធគយ ក្នុងអំឡុងពេលពីរ-បីឆ្នាំខាងមុខ។ បញ្ហាប្រឈមដែលត្រូវដោះស្រាយផ្សេងៗទៀត រួមមាន ពិពិធកម្មមុខទំនិញនាំចេញ ការកសាងហេដ្ឋារចនាសម្ព័ន្ធមូលដ្ឋាន និង ការកែលម្អរបៀបរៀបចំស្ថាប័ននិងការកសាងសមត្ថភាព។ សមាហរណកម្មក្នុងតំបន់ ក៏អាចបង្កការគំរាមកំហែងដល់សន្តិសុខ និងបង្កើតបញ្ហាសង្គម ក្នុងចំណោមប្រទេសជាសមាជិកដែរ ជាពិសេសប្រទេសមានព្រំដែនជាប់គ្នា។ កំណើនចំណាកស្រុកខុសច្បាប់ និងទំហំសកម្មភាពជួញដូរមនុស្សនិងថ្នាំញៀន ក្នុងទសវត្សរ៍ចុងក្រោយនេះ បានបង្កើតបញ្ហាជាច្រើនដល់ទាំងប្រទេសដើម និងប្រទេសគោលដៅ។

**កំណែទម្រង់ និងការពង្រឹងនូវគោលនយោបាយ និងស្ថាប័ន៖** ប្រវត្តិសោកនាដកម្មកន្លងមកបានធ្វើឲ្យកម្ពុជាស្ថិតក្នុងស្ថានភាពចាញ់ប្រៀប ហើយត្រូវធ្វើការកសាងស្ថាប័ននានាឡើងវិញស្ទើរតែទាំងស្រុង។ ក្នុងការពង្រឹងស្ថាប័ន រដ្ឋាភិបាលបានផ្ដួចផ្ដើមធ្វើកំណែទម្រង់ស្ថាប័នជាច្រើន រួមមាន កំណែទម្រង់រដ្ឋបាលនិងហិរញ្ញវត្ថុសាធារណៈ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ (D&D) និង កំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ ប៉ុន្តែត្រូវជួបនឹងបញ្ហាប្រឈមជាច្រើនក្នុងការអនុវត្តជាក់ស្ដែង។ កញ្ចប់កំណែទម្រង់រដ្ឋបាលស៊ីវិល បានជួយកែលម្អប្រព័ន្ធគ្រប់គ្រងបុគ្គលិក និងការបង្កើតក្របខ័ណ្ឌច្បាប់ផ្សេងៗ ប៉ុន្តែការទាក់ទាញបុគ្គលិកមានសមត្ថភាពខ្ពស់ នៅតែជាបញ្ហាប្រឈមមួយ ដោយសារកញ្ចប់លាភការនៅមិនទាន់មានលក្ខណៈទាក់ទាញគ្រប់គ្រាន់។ កំណែទម្រង់វិមជ្ឈការនិងវិសហមជ្ឈការ ទទួលបានជោគជ័យមួយចំនួន ប៉ុន្តែត្រូវបន្តដោះស្រាយបញ្ហាគណនេយ្យភាពនិងការសម្របសម្រួលមិនបានល្អស្មើគ្នាក្នុងចំណោមស្ថាប័នសាធារណៈ កង្វះធនធានហិរញ្ញវត្ថុ និងការកសាងសមត្ថភាពមន្ត្រីនៅតាមមូលដ្ឋាន។ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌បានជឿនលឿនទៅមុខយ៉ាងច្បាស់ ពិនិត្យតាមការប្រកាសឲ្យប្រើច្បាប់ជាច្រើន ដូចជា ច្បាប់រដ្ឋប្បវេណី និងច្បាប់ព្រហ្មទណ្ឌ និង ការបង្កើតតុលាការគំរូ។ ទោះយ៉ាងនេះក្តី ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា គេនៅវាយតម្លៃទាបនៅឡើយ។ អំពើពុករលួយបានកើតមានឡើង មួយចំណែកដោយសារបញ្ហាប្រាក់បៀវត្សរ៍ទាប ហើយក៏មានចំណុចខ្សោយក្នុងការពង្រឹងអនុវត្តន៍ច្បាប់ផងដែរ។ កំណែទម្រង់ប្រព័ន្ធយុត្តិធម៌ ក៏ត្រូវរាំងស្ទះដោយសារបញ្ហាកង្វះបុគ្គលិកផ្នែកច្បាប់ដែលមានសមត្ថភាព និងកង្វះធនធានសម្រាប់ការកសាងសមត្ថភាព។ តុលាការពាណិជ្ជកម្មសំខាន់ខ្លាំងណាស់សម្រាប់ដោះស្រាយបញ្ហាពាណិជ្ជកម្មក្នុងវិស័យឯកជន ប៉ុន្តែមកទល់បច្ចុប្បន្នមិនទាន់បង្កើតបាននៅឡើយទេ។

## ៦. សេចក្តីសន្និដ្ឋានៈ អាទិភាពគោលនយោបាយមួយចំនួន

ស្របពេលកំពុងរីកលូតលាស់ទៅមុខនេះ កម្ពុជាគួរគិតគូរពីអាទិភាពខាងគោលនយោបាយមួយចំនួន ដែលមានសារៈសំខាន់បំផុត ដើម្បីសម្រេចគោលដៅអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ចរបស់ខ្លួនឲ្យបានៈ

- **ធ្វើពិពិធកម្មសេដ្ឋកិច្ច** តាមការពង្រីកប្រភពកំណើនបច្ចុប្បន្ន ការបន្តអភិវឌ្ឍវិស័យកសិកម្ម ការពង្រីកឧស្សាហកម្មផលិតកម្ម និងពិពិធកម្មមុខទំនិញនិងទីផ្សារនាំចេញ
- **អនុវត្តការប្តេជ្ញាចិត្តបន្តជំរុញកំណើនសម្រាប់គ្រប់គ្នាឲ្យបាន** តាមរយៈយុទ្ធសាស្ត្រជាតិអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គមកិច្ច ដើម្បីសម្រេចតាមគោលដៅនៃកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ ប៉ុន្តែត្រូវបង្រួមចុះវិញនូវកំណើនវិសមភាព
- **រក្សាស្ថិរភាពបរិយាកាសម៉ាក្រូសេដ្ឋកិច្ច** តាមការគ្រប់គ្រងអតិផរណាឲ្យស្ថិតនៅក្រោមអត្រាគោលដៅ ៥% ការធានាឲ្យការប្រើប្រាក់ចំណូលពីវិស័យប្រេងនិងឧស្ម័នមានលក្ខណៈប្រយ័ត្នប្រយែងនិងមានវិន័យ ការតាមដានដិតដល់លើការវិវត្តវិស័យអចលនទ្រព្យនិងវិស័យធនាគារ និង ការធានាឲ្យសេដ្ឋកិច្ចមានសមត្ថភាពស្រូបយកជនចំណូលថ្មីទៅក្នុងកម្លាំងពលកម្ម ជារៀងរាល់ឆ្នាំ
- **បង្កើនការប្រមូលប្រាក់ចំណូល** តាមការពង្រឹងសមត្ថភាពរដ្ឋបាលពន្ធដារ ការពង្រីកមូលដ្ឋានពន្ធក្នុងស្រុកបច្ចុប្បន្ន និងការលើកទឹកចិត្តដល់ជំនួញឯកជនក្រៅផ្លូវការឲ្យចុះឈ្មោះជាផ្លូវការ ដើម្បីពង្រឹងហិរញ្ញវត្ថុរបស់រដ្ឋាភិបាល និងកាត់បន្ថយការពឹងផ្អែកលើជំនួយអភិវឌ្ឍន៍ផ្លូវការ
- **បង្កើតមូលនិធិទ្រព្យអធិបតេយ្យមានការគ្រប់គ្រងល្អមួយ** ប្រសិនបើកម្ពុជាអាចសម្រេចបានចំណូលជាតិច្រើនគួរកត់សម្គាល់ ពីការធ្វើអាជីវកម្មលើធនធានឧស្ម័ននិងប្រេងកាត។ មូលនិធិនេះ គឺសម្រាប់ផ្តល់ធនធានដល់វិស័យជាអាទិភាពនានាក្នុងការអភិវឌ្ឍជាតិ និងជំរុញវិនិយោគវិស័យឯកជនក្នុងបំណងគាំទ្រពិពិធកម្មសេដ្ឋកិច្ច ព្រមទាំងការរៀនសូត្រពីបទពិសោធន៍សេដ្ឋកិច្ចនៃប្រទេសអាស៊ាននានា
- **ពង្រីកវិនិយោគសាធារណៈក្នុងវិស័យជាអាទិភាពនានា** ដើម្បីលើកកម្ពស់លទ្ធភាពទទួលបានសេវាថែទាំសុខភាពប្រកបដោយគុណភាព ការអប់រំ ការអភិវឌ្ឍកសិកម្មនិងជនបទ និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន
- **អភិវឌ្ឍមូលធនមនុស្ស** តាមការប្រើប្រាស់វិធីសាស្ត្ររួមបញ្ចូល ដើម្បីដោះស្រាយបញ្ហាគុណភាពនៃការអប់រំដើម្បីផ្តល់អត្ថប្រយោជន៍ស្មើៗគ្នាដល់បុរស និងនារីនៅគ្រប់កម្រិត និង បញ្ហាតម្រូវការបន្ទាន់នូវការបណ្តុះបណ្តាល និងអប់រំបច្ចេកទេសនិងវិជ្ជាជីវៈ និង តាមការបញ្ចូលនូវការស្រាវជ្រាវនិងអភិវឌ្ឍន៍ (R&D) (ជាបេសកកម្មមួយនៃស្ថាប័នអប់រំជាន់ខ្ពស់) ដើម្បីជួយដល់ការងារកសាងគោលនយោបាយ និងជួយឲ្យមានបច្ចេកវិទ្យាកាន់តែល្អប្រសើរឡើង
- **វិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងស្ថាប័នៈ** បង្កើនថវិកាចំណាយសំរាប់ការកសាងនិងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ (ដូចជា ផ្លូវថ្នល់ជនបទ ប្រព័ន្ធធារាសាស្ត្រ) និងលើកកម្ពស់សមត្ថភាពផលិតកម្ម និងប្រសិទ្ធភាពនៃការផលិតថាមពល ដើម្បីកាត់បន្ថយចំណាយ និងពង្រីកបណ្តាញផ្គត់ផ្គង់អគ្គិសនីនៅជនបទ

- **ជំរុញវិស័យកសិកម្ម៖** ប្រើប្រាស់ឲ្យអស់លទ្ធភាពនូវធនធានដែលមានស្រាប់ ដូចជា ដីធ្លី និងកម្លាំងពលកម្ម ព្រមទាំង បង្កើនផលិតភាពកសិកម្ម និងពិពិធកម្មនៃមូលដ្ឋានកសិកម្ម
- **អនុវត្តតាមការប្តេជ្ញាចិត្តប្រើប្រាស់ធនធានធម្មជាតិប្រកបដោយនិរន្តរភាព៖** លើកកម្ពស់អភិបាលកិច្ចធនធានធម្មជាតិ ដើម្បីធានាឲ្យការប្រើប្រាស់មាននិរន្តរភាព និងមានការបង្កើនតម្លៃបន្ថែម
- **ធានាឲ្យកម្មវិធីនានារបស់** GMS **និង គំនិតផ្តួចផ្តើមនានាដើម្បីសមាហរណកម្មអាស៊ាន មានគោលដៅជួយបំពេញឲ្យគ្នានិងគាំទ្រគ្នាទៅវិញទៅមក និងមានធនធានគ្រប់គ្រាន់** ដោយផ្តោតទៅលើសហប្រតិបត្តិការក្នុងតំបន់ ហើយឈានទៅសម្រេចបានការអភិវឌ្ឍធនធានមនុស្សរយៈពេលវែង និងការពង្រឹងស្ថាប័ន ដើម្បីភ្ជិតគំលាតអភិវឌ្ឍន៍ក្នុងតំបន់អាស៊ាន និងអាស៊ីបូព៌ា និងជំរុញសមាហរណកម្មក្នុងតំបន់ឲ្យកាន់តែស៊ីជម្រៅ
- **បង្កើនការចូលរួមពីវិស័យឯកជននៅក្នុងសមាហរណកម្មក្នុងតំបន់និងអនុតំបន់** និងការជ្រួតជ្រាបពីឱកាសល្អនានានៅក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងគំនិតផ្តួចផ្តើមតភ្ជាប់ទំនាក់ទំនងក្នុងតំបន់។

## គន្ថនិទ្ទេស


Chet, Chealy (2009), "Higher Education in Cambodia" in Yasushi Hirosato & Yuto Kitamura (eds.), *The Political Economy of Educational Reforms and Capacity Development in Southeast Asia: Cases of Cambodia, Laos and Vietnam* (Dordrecht; London: Springer)

Council for Development of Cambodia (2007), "The Cambodia Aid Effectiveness Report 2007" (Phnom Penh: CDC)

Council for Development of Cambodia (2008), "The Cambodia Aid Effectiveness Report 2008" (Phnom Penh: CDC)

Council for Development of Cambodia (2010), "The Cambodia Aid Effectiveness Report 2010" (Phnom Penh: CDC)

Development Research Forum in Cambodia (2010), *Scoping Study: Research Capacities of Cambodia's Universities: A Special Report* (Phnom Penh: CDRI)

Duma, Nombulelo (2010), *Dollarization in Cambodia: Causes and Policy Implications*, International Monetary Fund (IMF) Working Paper 11/49

Hang, Chuon Naron (2009), *Cambodia Economy: Charting the Course of a Brighter Future: A Survey of Progress, Problems and Prospects* (Phnom Penh: Preah Vihear Editions)

Huot, Pum & Khan,Vanak (2010), "Cambodia: Coping with Dollarization" in Giovanni Capannelli & Jayant Menon (eds.), *Dealing with Multiple Currencies in Transitional Economies* (Manila: ADB)

International Monetary Fund (2009), *Cambodia: Statistical Appendix*, IMF Country Report No.09/48 (Washington, DC: IMF)

Jalilian, Hossein & Glenda Reyes (2010), "Cambodia in the Sweep of the Global Financial and Economic Crisis", *Annual Development Review 2009-2010* (Phnom Penh: CDRI) pp. 21-44

Ministry of Economy and Finance (2010), *Cambodia Macroeconomic Framework 2000-2011* (Phnom Penh: MEF)

Menon, Jayant (2008), "Cambodia's Persistent Dollarization: Causes and Policy Options" ADB's Working Series on Regional Economic Integration No.19 (Manila: ADB)

NIS (2010), "2010 Poverty and Selected CMDGs Maps and Charts 2003-2009: Preliminary Findings from the Analysis of Commune Database" (Phnom Penh: NIS)

Pith, Chamnan & David Ford (2004), "Cambodian Higher Education: Mixed Visions" in G. Phillip Altbach & Tōru Umakoshi (eds.), *Asian Universities: Historical Perspectives and Contemporary Challenges* (Baltimore; London: Johns Hopkins University Press)

UNDP (2007a), "Cambodia's 2007 Trade Integration Strategy: Executive Summary and Action Matrix" (Phnom Penh: UNDP)

UNDP (2007b), *Review of Development Prospects for the Cambodian Oil and Gas Sectors* (Phnom Penh: UNDP Cambodia)

World Bank (2006), *Halving Poverty by 2015?* (Phnom Penh: World Bank Cambodia)

World Bank (2009), *Poverty Profile and Trends in Cambodia: Findings from the 2007 Cambodia Socio-Economic Survey* (Washington, DC: World Bank)

World Bank (2010), "Doing Business 2011: Making a Difference for Entrepreneurs" (Washington, DC: World Bank)

World Bank (2011), "World Development Indicators 2011" (Washington, DC: World Bank)

World Economic Forum (2011), "The Global Competitiveness Report 2010-11" (Geneva: WEF)

Zamaróczy, de Mario & Sa Sopanha (2002), *Macroeconomic Adjustment in a Highly Dollarized Economy: The Case of Cambodia*, IMF Working Paper 02/92

# ផ្នែកទី ១
# សេដ្ឋកិច្ច

-១-

# ការវិភាគរបាំងកំណើនសេដ្ឋកិច្ចដោយប្រើ វិធីសាស្ត្រវិភាគកំណើនៈ ករណីប្រទេសកម្ពុជា

*ដោយលោក សាំង ច័ន្ទហង្ស[១]*

## ១. សេចក្ដីផ្ដើម

បើទោះជាសេដ្ឋកិច្ចកម្ពុជា កំពុងស្ថិតក្នុងដំណាក់កាលក្រោយសង្គ្រាម និងពឹងផ្អែកលើអ្នកផ្ដល់ជំនួយ តែងជួបជារឿងមកនូវឧបសគ្គនៃអភិបាលកិច្ចទន់ខ្សោយ អំពើពុករលួយ និងកង្វះខាតសមត្ថភាពស្ថាប័នក្ដី (World Bank 2004) ក៏ដំណើរការអភិវឌ្ឍសេដ្ឋកិច្ចសម្រេចបានជោគជ័យគួរឲ្យកត់សម្គាល់ ក្នុងទសវត្សរ៍ចុងក្រោយនេះ លើកលែងតែក្នុងពេលមានវិបត្តិឆ្នាំ២០០៨ និង ២០០៩។ ពីឆ្នាំ១៩៩៨-២០០៨ ផសស ពិត មានកំណើនលឿនដល់ ៩,១% ជាមធ្យម ដោយសារស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងនយោបាយ ក៏ដូចជាការរីកចម្រើនធូរធារក្នុងតំបន់ និងសាកលលោកក្នុងអំឡុងពេលនោះ។ កំណើនសេដ្ឋកិច្ច ទទួលបានជាចម្បងពីការរីកធំធាត់នៃឧស្សាហកម្មកម្មន្តសាលកម្មក្នុងអត្រាប្រចាំឆ្នាំជាមធ្យម ១៤,៤% នៅអំឡុងឆ្នាំ១៩៩៨-២០០៨ ជាពិសេសផ្នែកវាយនភ័ណ្ឌនិងសម្លៀកបំពាក់ និងកំណើនគួរឲ្យកត់សម្គាល់នៃវិស័យទេសចរណ៍ ដោយសារកំណើនច្រើនៗ និងជាបន្តបន្ទាប់នៃភ្ញៀវទេសចរក្នុងអំឡុងពេលនោះ។

កំណើនរឹងមាំ និងរស់រវើកនេះ ទទួលរងការប៉ះទង្គិចជាខ្លាំងពីវិបត្តិសាកលទាំងពីរដែលបានធ្វើឲ្យប្រែប្រួលដល់កម្លាំងចលករនៃសេដ្ឋកិច្ចកម្ពុជា គឺធ្លាក់ចុះកំណើនភ្លាមៗពី ១០,២% ក្នុងឆ្នាំ២០០៧ មកត្រឹម 0,១% ក្នុងឆ្នាំ២០០៩ និងរួមចុះធ្ងន់ធ្ងរដល់វិស័យស្នូលទាំងបីនៃកំណើនពោលគឺ កាត់ដេរ សំណង់ និង ទេសចរណ៍។

អត្ថបទនេះ មានគោលបំណងចម្បងកំណត់ឧបសគ្គនានាដែលរារាំងកំណើនសេដ្ឋកិច្ចកម្ពុជា តាមរយៈវិធីសាស្ត្រវិភាគកំណើន (growth diagnostic approach) បង្កើតឡើងក្នុងឆ្នាំ២០០៥ ដោយ Hausmann, Rodrik និង Velasco និងដែលមានពិពណ៌នាក្នុងផ្នែកទី២។ កត្តារារាំងដល់កំណើនសេដ្ឋកិច្ច មានពិភាក្សាក្នុងផ្នែកទី៣ ហើយសេចក្ដីសន្និដ្ឋាន ស្ថិតក្នុងផ្នែកទី៤។

---

១ លោក សាំង ច័ន្ទហង្ស ជាអ្នកស្រាវជ្រាវ នៃវិទ្យាស្ថានបណ្ដុះបណ្ដាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI)។ អ្នកនិពន្ធសូមថ្លែងអំណរគុណដល់បណ្ឌិត តុង គឹមស៊ុន អ្នកសម្របសម្រួលកម្មវិធីសេដ្ឋកិច្ចពាណិជ្ជកម្ម និងសហប្រតិបត្តិការក្នុងតំបន់ និងលោក Larry Strange នាយកប្រតិបត្តិនៃវិទ្យាស្ថាន CDRI។

រូបភាព ១៖ កំណើន ផសស ប្រចាំឆ្នាំ គិតតាមថ្លៃថេរឆ្នាំ២០០០




*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឆ្នាំ២០១០*

## ២. ក្របខ័ណ្ឌនៃការវិភាគ

ដើម្បីកំណត់ពីឧបសគ្គរាំងនានា អត្ថបទនេះចាប់សិក្សាទៅតាមគំនូស ដើមឈើបញ្ហា (រូបភាព ២) បង្កើតឡើងក្នុងឆ្នាំ២០០៥ ដោយ Hausmann, Rodrik និង Velasco បន្ទាប់មក ព្យាយាមឆ្លើយនឹងសំណួរគោលថា តើប្រាក់ចំណូលទាបលើសកម្មភាពសេដ្ឋកិច្ច ឬចំណាយខ្ពស់ផ្នែកហិរញ្ញវត្ថុ ជាឧបសគ្គរាំងចម្បងគេដល់កម្រិតនៃវិនិយោគឯកជន និងកំណើនសេដ្ឋកិច្ច មែនឬយ៉ាងណា។

រូបភាព ២៖ គំនូសដើមឈើបញ្ហាសម្រាប់វិភាគកំណើន




*ប្រភព៖ Hausmann, Rodrik និង Valesco ឆ្នាំ២០០៥*

យោងតាមគំនូសដើមឈើបញ្ហា អ្នកនិពន្ធបានប្រើវិធីសាស្ត្រពីលើចុះក្រោម និងវិធីសាស្ត្រផ្អែកលើភស្តុតាង និងការនិទានប្រាប់ ដើម្បីកំណត់រកឧបសគ្គរាំងខ្លាំងៗជាងគេ។ ក្នុងកាលៈទេសៈភាគច្រើន កម្រិតគោល និងគំរូសម្រាប់ធៀបក្នុងតំបន់ ដូចជា បណ្តាប្រទេសអាស៊ានជាដើម ត្រូវបានយកមកប្រើ ដើម្បីកំណត់រកឧបសគ្គផ្សេងៗ។ គួរកត់សម្គាល់ដែរថា ដោយសារជួបកង្វះទិន្នន័យ ផ្នែកខ្លះនៃការសិក្សានេះ ត្រូវផ្អែកលើលទ្ធផលនៃការសិក្សាមួយពីមុននេះទៀតរបស់ធនាគារពិភពលោក ( World Bank 2009b ) ។

## ៣. ភស្តុតាងអំពីឧបសគ្គរាំងកំណើនសេដ្ឋកិច្ចនៅកម្ពុជា

### *៣.១. ចំណាយ និង លទ្ធភាពប្រើប្រាស់ហិរញ្ញវត្ថុ*

វិស័យហិរញ្ញវត្ថុនៅកម្ពុជា មានលក្ខណៈអន់ខ្សោយនៅឡើយ។ ឥណទានសម្រាប់វិស័យឯកជន មានប្រហែល ២៣,៥% នៃ ផសស ក្នុងឆ្នាំ២០០៨ ធៀបនឹង ៩,៥% នៅឡាវ ៩០,៦% នៅវៀតណាម និង ១១៣,១% នៅថៃ (World Bank's WDI 2011)។ តួលេខនេះ បង្ហាញថាការផ្តត់ផ្គង់ឥណទានហាក់ពិបាករកបាននៅឡើយ។

អត្រាការប្រាក់ពិតលើកម្ចី មានតួលេខអវិជ្ជមាននៅឆ្នាំ២០០៨ រីឯ វិនិយោគដុល គឺមានកម្រិតទាបនៅក្នុងតំបន់ ត្រឹម ១៧,៥% នៃ ផសស។ ដូច្នេះ ចំណាយ និងការផ្គត់ផ្គង់ឥណទានហាក់មិនមែនជាឧបសគ្គឡើយ ពិនិត្យតាមតម្រូវការឥណទានតិចតួចក្នុងឆ្នាំ២០០៨។ ចំណុចគួរភ្ញាក់ផ្អើលគឺ ក្នុងឆ្នាំ២០០៩ អត្រាការប្រាក់ពិតលើកម្ចី កើនដល់ ១៩,៥% ធៀបនឹង -៩% ក្នុងឆ្នាំ២០០៨ (World Bank's WDI 2011) ដែលជាអត្រាខ្ពស់បំផុតក្នុងចំណោមប្រទេសអាស៊ាន។ អត្រាការប្រាក់ពិតលើកម្ចី បានកើនឡើង តាមការធ្លាក់ចុះកម្រិតថ្លៃទំនិញប្រើប្រាស់សរុប ប៉ុន្តែចំណាយហិរញ្ញវត្ថុ ហាក់មិនមែនជាឧបសគ្គដល់លទ្ធភាពប្រើប្រាស់ហិរញ្ញវត្ថុរបស់វិនិយោគិនទេ ព្រោះឥណទានចំពោះវិស័យឯកជន បានកើនពី ២,៣៩ពាន់លានដុល្លារ នៅឆ្នាំ២០០៨ ដល់ ២,៥ពាន់លានដុល្លារ ក្នុងឆ្នាំ២០០៩ (NBC 2009:2)។

រូបភាព ៣៖ អត្រាការប្រាក់ពិតលើកម្ចី និង អត្រាវិនិយោគ ឆ្នាំ២០០៨-២០០៩




*ប្រភព៖ World Bank, WDI 2011 & IMF, IFS 2011*

ដូចមានបង្ហាញក្នុង តារាង ១ លទ្ធភាពប្រើប្រាស់ហិរញ្ញវត្ថុ ស្ថិតក្នុងលំដាប់ទី៥ នៃកត្តារារាំងទាំង១៥ ចំពោះការធ្វើអាជីវកម្មនៅកម្ពុជា បើផ្អែកតាមអង្កេតនៅឆ្នាំ២០០៩ និង ២០១០ លើអ្នកគ្រប់គ្រងអាជីវកម្មភាគច្រើន ដូច្នេះ លទ្ធភាពប្រើប្រាស់ហិរញ្ញវត្ថុ ហាក់មិនមែនជាឧបសគ្គធ្ងន់ធ្ងរលើកំណើនសេដ្ឋកិច្ចឡើយ។

តារាង ១៖ កត្តាចោទបញ្ហាធំៗជាងគេ ចំពោះការធ្វើអាជីវកម្មនៅកម្ពុជា ឆ្នាំ២០០៨-២០១០
(គិតតាមលំដាប់៖ ១=កត្តាចោទបញ្ហាធំជាងគេ ១៥=កត្តាចោទបញ្ហាតូចជាងគេ)

| ឆ្នាំនៃរបាយការណ៍ | 2008 | 2009 | 2010 |
|---|---|---|---|
| អំពើពុករលួយ | 1 | 1 | 1 |
| របបការិយាធិបតេយ្យអប្រសិទ្ធភាពរបស់រដ្ឋាភិបាល | 2 | 2 | 2 |
| កម្លាំងពលកម្មមានការចេះដឹងមិនគ្រប់គ្រាន់ | 4 | 3 | 3 |
| ការផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់ | 3 | 4 | 4 |
| លទ្ធភាពប្រើប្រាស់ហិរញ្ញវត្ថុ | 7 | 5 | 5 |
| អត្រាពន្ធ | 10 | 12 | 6 |
| បទបញ្ញត្តិពន្ធ | 8 | 8 | 7 |
| សីលធម៌ការងារអន់ខ្សោយក្នុងចំណោមកម្លាំងពលកម្ម | 9 | 9 | 8 |
| អតិផរណា | 5 | 7 | 9 |
| បទបញ្ញត្តិពលកម្មរឹតត្បិតខ្លាំង | 13 | 13 | 10 |
| អស្ថិរភាពគោលនយោបាយ | 6 | 6 | 11 |
| សេវាសុខភាពសាធារណៈអន់ខ្សោយ | 11 | 11 | 12 |
| បទបញ្ញត្តិរូបិយវត្ថុបរទេស | 15 | 14 | 13 |
| បទល្មើស និងចោរកម្ម | 12 | 10 | 14 |
| រដ្ឋប្រហារ/អស្ថិរភាពរដ្ឋាភិបាល | 14 | 15 | 15 |

*ប្រភព៖ WEF 2009-2011*

## ៣.២. លទ្ធភាពទាបក្នុងការប្រមូលផលចំណេញ

*ហានិភ័យកម្រិតម៉ាក្រូ*

សញ្ញារើបឡើងវិញនៃសេដ្ឋកិច្ច ចាប់ផ្តើមមើលឃើញច្បាស់តាំងពីត្រីមាសទី៤ ឆ្នាំ២០០៩ ជាមួយគ្នានឹងការងើបឡើងវិញនៃវិស័យជំរុញកំណើនសំខាន់ៗ ពោលគឺ កាត់ដេរ ទេសចរណ៍ និង សំណង់។ ការនាំចេញសំលៀកបំពាក់ កើនពី -១៤,៧% ក្នុងឆ្នាំ២០០៩ ដល់ ២៤,៥% ក្នុងឆ្នាំ២០១០។ ភ្ញៀវមកលំហែ និងមកធ្វើជំនួយនៅកម្ពុជា កើនដល់ ១៩% និង ៨,៤% នៅឆ្នាំ២០១០ ធៀបនឹង ៣,៤% និង -១០,២% នៅឆ្នាំ២០០៩។ វិស័យសំណង់ក៏មានសន្ទុះឡើងវិញដែរក្នុងឆ្នាំ២០១០ ដោយការនាំចូលបរិក្ខារសំណង់ មានកំណើនប្រចាំឆ្នាំ ១,១% ធៀបនឹង -២៦,៦% ក្នុងឆ្នាំ២០០៩។ គួរកត់សម្គាល់ជាសំខាន់ថា គម្រោងសាងសង់ភាគច្រើននៅកម្ពុជាប្រើបរិក្ខារសំណង់នាំចូលពីបរទេស។ ម្យ៉ាងទៀត អតិផរណាមិនបង្កការបារម្ភទៀតទេ បន្ទាប់ពីថ្លៃទំនិញប្រើប្រាស់ស្ទុះឡើងយ៉ាងខ្លាំងក្នុងឆ្នាំ២០០៨ (២៥,១%) និង បរិត្តផរណាក្នុងឆ្នាំ២០០៩ (-០,៤%)។ អតិផរណាជាមធ្យម ៤,១% ក្នុងឆ្នាំ២០១០ ហាក់ដូចអាចគ្រប់គ្រងបាន ដោយធ្លាក់ចុះមកត្រឹម ៣,៦% នៅត្រីមាសទី១ ឆ្នាំ២០១១។

រូបភាព ៤៖ អត្រាអតិផរណា និង អត្រាប្តូរប្រាក់ ឆ្នាំ២០០៤-២០១១




*ប្រភព៖ NIS & NBC, 2011*

*ហានិភ័យកម្រិតមីក្រូ*

ការសិក្សាថ្មីៗដោយ World Economic Forum (WEF 2010) និងគម្រោង World Governance Indicators (WGI) របស់ធនាគារពិភពលោក (World Bank 2011) បង្ហាញថា កម្ពុជាស្ថិតនៅយឺតយ៉ាវជាងប្រទេសឯទៀតក្នុងតំបន់លើផ្នែកគុណភាពស្ថាប័ន និងសិទ្ធិលើកម្មសិទ្ធិបញ្ញា។ អង្កេតរបស់ WEF ក្នុងឆ្នាំ២០១០ រកឃើញថា ក្នុងចំណោមប្រទេសជាគំរូសម្រាប់ការវាស់វែងក្នុងតំបន់ កម្ពុជាមានស្ថានភាពប្រសើរជាងប្រទេសហ្វីលីពីនតែមួយប៉ុណ្ណោះ លើផ្នែកដោះស្រាយទំនាស់ និងកម្រិតឯករាជ្យនៃប្រព័ន្ធយុត្តិធម៌។ កម្ពុជាក៏មានចំណាត់ថ្នាក់ទាបដែរ ចំពោះគុណភាពបទបញ្ញត្តិទូទៅ ប៉ុន្តែផ្នែកនេះមានលក្ខណៈប្រសើរជាងនៅវៀតណាម និងឡាវ។ កង្វះយន្តការដោះស្រាយទំនាស់ និងការពង្រឹងអនុវត្តន៍ច្បាប់ អាចបង្កឧបសគ្គបង្ករដែរដល់កំណើនសេដ្ឋកិច្ច។

សរុបមក មានតែ ១០% នៃ ៥០០ សហគ្រាសដែលបានអង្កេតក្នុងឆ្នាំ២០០៧ ប៉ុណ្ណោះ ដែលគិតថា សិទ្ធិលើដីធ្លី ជាឧបសគ្គចម្បងមួយដល់កំណើន (World Bank 2009a)។ គំនិតនេះអាចពិនិត្យឃើញតាមការធ្លាក់ចុះចំនួនក្រុមហ៊ុនដែលមានដីធ្លី (ពី ៥៤% ក្នុងឆ្នាំ២០០៣ មកត្រឹម ៣៦% ក្នុងឆ្នាំ២០០៧) និងចំនួនក្រុមហ៊ុនដែលមានអគារ (ពី ៥៣% នៅឆ្នាំ២០០៣ មកត្រឹម ២៩% នៅឆ្នាំ២០០៧) ដោយសារគេជ្រើសយកវិធីជួលប្រើវិញ។ សិទ្ធិលើដីធ្លីហាក់មិនមែនជាឧបសគ្គច្បាស់លាស់មួយចំពោះដំណើរការអាជីវកម្មទេ។

តារាង ៣ បង្ហាញថា នៅឆ្នាំ២០១០ កម្ពុជាមានអត្រាពន្ធសរុបកម្រិតទាបបំផុត ក្នុងចំណោមបណ្តាប្រទេសអាស៊ាន (WEF 2011: Heritage Foundation 2010) និងមានអត្រាពន្ធលើប្រាក់ចំណូល និងអត្រាពន្ធលើប្រាក់ចំណេញក្រុមហ៊ុន កម្រិតទាបជាងគេក្នុងតំបន់ លើកលែងតែអត្រាពន្ធលើប្រាក់ចំណេញក្រុមហ៊ុននៅប្រទេសសិង្ហបុរីមួយចេញ។ ចំពោះឥទ្ធិពល និង

ទំហំនៃការយកពន្ធ កម្ពុជាស្ថិតនៅលំដាប់ទីពីររាប់ពីក្រោម បន្ទាប់ពីប្រទេសហ្វីលីពីន។ ចំណុចនេះ ហាក់ផ្ទុយគ្នានឹងការយល់ឃើញរបស់វិស័យឯកជនលើរដ្ឋបាលពន្ធនៅឆ្នាំ២០០៧ ដែលថា វាមិនមែនជាក្តីបារម្ភចម្បងមួយចំពោះសកម្មភាពអាជីវកម្មនោះទេ (World Bank 2009a)។ តាមនេះ រដ្ឋបាលពន្ធអាចជាឧបសគ្គរាំងដល់កំណើន។

តារាង ២៖ សូចនាករនៃគុណភាពស្ថាប័ន និងបទបញ្ញត្តិ ឆ្នាំ២០០៩-២០១០

| ប្រទេស | សិទ្ធិលើទ្រព្យសម្បត្តិ* | ការការពារកម្មសិទ្ធិបញ្ញា | ការដោះស្រាយទំនាស់* | ឯករាជ្យភាពនៃប្រព័ន្ធយុត្តិធម៌* | គុណភាពបទបញ្ញត្តិ+ |
|---|---|---|---|---|---|
| ព្រុយនេ | 52 | 55 | 36 | 43 | 82.9 |
| កម្ពុជា | 110 | 99 | 72 | 108 | 39.0 |
| ឥណ្ឌូនេស៊ី | 84 | 58 | 60 | 67 | 42.9 |
| ឡាវ | - | - | - | - | 14.3 |
| ម៉ាឡេស៊ី | 41 | 33 | 30 | 52 | 60.0 |
| មីយ៉ាន់ម៉ា | - | - | - | - | 1.0 |
| ហ្វីលីពីន | 99 | 103 | 122 | 111 | 52.4 |
| សិង្ហបុរី | 3 | 3 | 1 | 21 | 100 |
| ថៃ | 89 | 84 | 46 | 54 | 61.9 |
| វៀតណាម | 81 | 109 | 61 | 64 | 31.0 |

*ប្រភព៖ World Economic Forum 2011; World Bank's World Governance Indicators 2011*

*កំណត់សម្គាល់៖ * ចំណាត់ថ្នាក់របស់ WEF គិតក្នុង ១៣៩ប្រទេស នៅឆ្នាំ២០១០*

*+ WGI ក្នុងឆ្នាំ២០០៩ កំណត់ថា ពិន្ទុ 0 តំណាងឲ្យគុណភាពទាបបំផុត ហើយ ១០០ តំណាងឲ្យគុណភាពខ្ពស់បំផុត*

កម្រិតទាបនៃរបកគំហើញថ្មី អាចអង្កេតឃើញតាមរយៈបម្រែបម្រួលចំនួនផលិតផលនាំចេញ និងអត្រារស់រាននៃទំនិញទើបនាំចេញថ្មី។ តារាង ៤ បង្ហាញកំណើនគួរកត់សម្គាល់ (ជាមធ្យម ៤១,១%) នៃចំនួនផលិតផលនាំចេញនៅអំឡុងឆ្នាំ ២០០០-០៩។ អត្រារស់រាននៃទំនិញទើបនាំចេញថ្មី មានប្រហែល ៣៩,៩% ដែលបង្ហាញពីលទ្ធភាពមានកម្រិតនៃផលិតករក្នុងស្រុកក្នុងការរក្សាផលិតផលទើបនាំចេញថ្មី ព្រោះជិត ៦០% នៃផលិតផលទាំងនោះ ត្រូវបាត់មុខទៅវិញក្រោយពេលនាំចេញបាន១ឆ្នាំ។

អង្កេតពីយោបល់អ្នកគ្រប់គ្រងអាជីវកម្មនានាដែលមានបង្ហាញក្នុង តារាង ១ បានចាត់ថ្នាក់ អំពើពុករលួយ របបការិយាធិបតេយ្យអប្រសិទ្ធភាពរបស់រដ្ឋាភិបាល និងកង្វះការផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធ ថាជាកត្តាបង្កបញ្ហាច្រើនបំផុតដល់ការធ្វើអាជីវកម្មនៅកម្ពុជា ក្នុងអំឡុងឆ្នាំ២០០៨-២០១០ ។ ចំណាត់ថ្នាក់នេះបង្ហាញពីភាពងាយរងគ្រោះនៃសេដ្ឋកិច្ច ដោយសារការសម្របសម្រួលអន់ខ្សោយ។ បញ្ហាសម្របសម្រួលអន់ខ្សោយនេះ ក៏អាចសង្កេតឃើញផងដែរ ក្នុងការសិក្សារបស់ធនាគារពិភពលោក លើផ្នែកបី គឺ កាត់ដេរ ស្រូវអង្ករ និង សត្វចិញ្ចឹម (World Bank 2009b)។

តារាង ៣៖ ការចាត់ថ្នាក់នៃទំហំ និងឥទ្ធិពលនៃការយកព័ន្ធ និងអត្រាពន្ធ នៅអាស៊ី

| ប្រទេស | ទំហំ និងឥទ្ធិពលនៃការយកពន្ធ * | អត្រាពន្ធសរុប * | អត្រាពន្ធលើប្រាក់ចំណូល+ (%) | អត្រាពន្ធលើប្រាក់ចំណេញក្រុមហ៊ុន+ (%) |
|---|---|---|---|---|
| ព្រុយនេ | 15 | 31 | - | - |
| កម្ពុជា | 61 | 15 | 20 | 20 |
| ឥណ្ឌូនេស៊ី | 17 | 60 | 30 | 25 |
| ឡាវ | - | - | 25 | 35 |
| ម៉ាឡេស៊ី | 28 | 47 | 26 | 25 |
| មីយ៉ាន់ម៉ា | - | - | 30 | 30 |
| ហ្វីលីពីន | 77 | 99 | 32 | 30 |
| សិង្ហបុរី | 3 | 24 | 20 | 17 |
| ថៃ | 53 | 58 | 37 | 30 |
| វៀតណាម | 58 | 67 | 35 | 25 |

*ប្រភព៖ World Economic Forum 2011; Heritage Foundation 2010; The Wall Street Journal 2010*

*កំណត់សម្គាល់៖ * ចំណាត់ថ្នាក់របស់ WEF គិតក្នុង ១៣៩ប្រទេស ក្នុងឆ្នាំ២០១០*

*+ Heritage Foundation 2010; The Wall Street Journal 2010*

តារាង ៤៖ សូចនាករនៃការរកឃើញផលិតផលនៅកម្ពុជា

| ឆ្នាំ | ចំនួនទំនិញនាំចេញ | ចំនួនទំនិញទើបនាំចេញថ្មី | ចំនួនទំនិញនាំចេញត្រូវផ្អាកក្រោយពេល១ឆ្នាំ | ចំនួនទំនិញទើបនាំចេញថ្មីត្រូវផ្អាកក្រោយពេល១ឆ្នាំ | អត្រារស់រាននៃទំនិញទើបនាំចេញថ្មីក្រោយពេល១ឆ្នាំ |
|---|---|---|---|---|---|
| 2000 | 569 | - | - | - | - |
| 2001 | 659 | 292 | 202 | 179 | 38.7 |
| 2002 | 715 | 293 | 237 | 175 | 40.3 |
| 2003 | 683 | 237 | 269 | 144 | 39.2 |
| 2004 | 701 | 235 | 217 | 134 | 43.0 |
| 2005 | 738 | 252 | 215 | 152 | 39.7 |
| 2006 | 777 | 273 | 234 | 149 | 45.4 |
| 2007 | 836 | 284 | 225 | 167 | 41.2 |
| 2008 | 754 | 201 | 283 | 137 | 31.8 |
| 2009 | 803 | 276 | 227 | - | - |

*ប្រភព៖ ការគណនារបស់អ្នកនិពន្ធ ផ្អែកលើទិន្នន័យរបស់ UN COMTRADE, HS 5 digits (SITC-Rev.3)*

*កំណត់សម្គាល់៖ ទិន្នន័យពី WITS របស់ World Bank នៅគេហទំព័រ http://wits.worldbank.org/wits/ (accessed 14 July 2011)*

អវត្តមាន ឬភាពទន់ខ្សោយនៃការសម្របសម្រួលរវាងអ្នកពាក់ព័ន្ធនានាក្នុងទីផ្សារពលកម្ម ដូចជា ក្រុមហ៊ុនឯកជន ស្ថាប័នសាធារណៈ (ក្រសួងអប់រំ យុវជន និងកីឡា និង ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ) សាកលវិទ្យាល័យឯកជននិងសាធារណៈ និង ស្ថាប័នបណ្តុះបណ្តាលវិជ្ជាជីវៈ (ផ្លូវការ និងមិនផ្លូវការ) បានបង្កើតនូវចន្លោះប្រហោង និងភាពមិនស៊ីគ្នាក្នុងជំនាញសំខាន់ៗ។ អង្កេតរបស់ធនាគារពិភពលោក លើអ្នកផ្តល់ការបណ្តុះបណ្តាល ២១នាក់ និងនិយោជក ៤៨នាក់ ក្នុងវិស័យទេសចរណ៍ កាត់ដេរ និង សំណង់ នៅទីក្រុងភ្នំពេញ និងខេត្តសៀមរាប នៅចន្លោះខែធ្នូ ២០០៨ និង ខែមីនា ២០០៩ បានរកឃើញ និយោជកភាគច្រើន (៧៦%) គេយល់ថា និស្សិតទើបបញ្ចប់ការសិក្សាថ្មីៗ មិនមានជំនាញចាំបាច់សម្រាប់អនុវត្តការងាររបស់ពួកគេឡើយ (World Bank 2010b:52, 54)។

សរុបមក ទីផ្សារអាចទទួលបរាជ័យ ដោយសារកម្ពុជាហាក់ត្រូវប្រឈមមុខនឹងកង្វះការរកឃើញដោយខ្លួនឯង និងការសម្របសម្រួលទន់ខ្សោយ។ ទោះយ៉ាងនេះក្តី បញ្ហាភាពមានកម្រិតនៃការរកឃើញដោយខ្លួនឯង ប្រហែលមិនបានរារាំងដល់កំណើនសេដ្ឋកិច្ចទេ ពីព្រោះអត្រារស់រានប្រមាណ ៤០% នៃទំនិញទើបនាំចេញថ្មី មិនមែនអាក្រក់នោះទេ រីឯបញ្ហាការសម្របសម្រួលទន់ខ្សោយអាចបង្កជាឧបសគ្គដល់កំណើន ដោយសារវាកើតមានចំពោះច្រើនវិស័យ។

## ៣.៣. ផលចំណេញពីសន្ទម

កម្ពុជាធ្លាប់ឆ្លងកាត់បម្រែបម្រួលប្រជាសាស្ត្រខ្លាំងគួរឲ្យកត់សម្គាល់ កាលពីទសវត្សរ៍កន្លងទៅ ដែលបង្កើតបានទាំងឱកាស និងបញ្ហាប្រឈមជាច្រើនដល់សេដ្ឋកិច្ចកំពុងមានសន្ទុះ។ ជំរឿនចុងក្រោយក្នុងឆ្នាំ២០០៨ អនុវត្តដោយវិទ្យាស្ថានជាតិស្ថិតិ (NIS) នៃក្រសួងផែនការបង្ហាញថា កម្ពុជាមានសមាមាត្រប្រជាជនវ័យក្មេងច្រើនជាងគេក្នុងតំបន់អាស៊ីប៉ាស៊ីហ្វិក ក្នុងនោះប្រជាជនអាយុក្រោម ២៤ឆ្នាំ មានជិត ៦០% ធៀបនឹងប្រទេសឡាវដែលមាន ៦១% និង ប្រទេសថៃ និងវៀតណាម ដែលមានអត្រាប្រជាជនវ័យចំណាស់កំពុងកើនឡើងយ៉ាងលឿន (World Bank 2010b:32)។ លទ្ធផលចុងក្រោយបានពីអង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៩ បង្ហាញថា អត្រាចូលរួមការងារ មាន ៨៤,៤% នៃកម្លាំងពលកម្មសរុប ធៀបនឹង ៨២,២% ក្នុងឆ្នាំ២០០៤ (NIS 2010:59)។ លទ្ធផលនេះបង្ហាញថា ការផ្គត់ផ្គង់កម្លាំងពលកម្មមិនមែនជាឧបសគ្គចំពោះកំណើនទេ។

តារាង ៥ បង្ហាញថា ធៀបនឹងប្រទេសឯទៀតក្នុងតំបន់ កម្ពុជាអនុវត្តបានល្អលើការចុះឈ្មោះចូលរៀនសិស្សថ្នាក់បឋមសិក្សា ប៉ុន្តែនៅអន់ខ្សោយលើការចុះឈ្មោះចូលរៀនថ្នាក់មធ្យម និងឧត្តម។ កម្លាំងពលកម្មគុណភាពអន់ និងភាពមិនស៊ីគ្នាខាងជំនាញរវាងការផ្គត់ផ្គង់ និងតម្រូវការពលកម្ម បានបន្ទាបកម្រិតផលចំណេញនៃការអប់រំចំពោះកម្លាំងពលកម្មនៅកម្ពុជា។ ប៉ុន្តែក្រៅតែពីបញ្ហាភាពមិនស៊ីគ្នាខាងជំនាញនេះ ការផ្គត់ផ្គង់កម្លាំងពលកម្មនៅតែសម្បូរដដែលនៅឆ្នាំក្រោយៗទៀត ហើយអត្រាចូលរួមការងារខ្ពស់នៃកម្លាំងពលកម្ម ជាពិសេសក្រុមពលកររមានការអប់រំទាបបង្ហាញថា ផលចំណេញកម្រិតទាបទទួលបានពីមូលធនមនុស្ស មិនមែនជាឧបសគ្គចំពោះកំណើនទេ។

តារាង ៥៖ អត្រាចុះឈ្មោះចូលរៀនសរុបតាមបណ្ដាប្រទេសសមាជិកអាស៊ាន

| ប្រទេស | ការចូលរៀនថ្នាក់បឋមសិក្សាសរុប(%) | | | ការចូលរៀនថ្នាក់មធ្យមសិក្សាសរុប(%) | | | ការចូលរៀនថ្នាក់ឧត្ដមសិក្សាសរុប(%) | | |
|---|---|---|---|---|---|---|---|---|---|
| | 2007 | 2008 | 2009 | 2007 | 2008 | 2009 | 2007 | 2008 | 2009 |
| ព្រុយនេ | 107.8 | 106.7 | 106.5 | 96.9 | 96.7 | 98.2 | 15.4 | 16.0 | 17.1 |
| កម្ពុជា | 119.7 | 115.9 | 116.5 | 40.4 | - | - | 5.4 | 7.0 | 10.0 |
| ឥណ្ឌូនេស៊ី | 120.9 | 119.5 | 120.8 | 75.8 | 74.4 | 79.5 | 18.2 | 21.3 | 23.5 |
| ឡាវ | 108.9 | 111.8 | 121.0 | 44.0 | 43.9 | - | 11.5 | 13.4 | - |
| ម៉ាឡេស៊ី | 96.6 | 94.6 | - | 68.2 | 68.7 | - | 32.1 | 36.5 | - |
| មីយ៉ាន់ម៉ា | 115.0 | 116.9 | 115.8 | 49.3 | 52.7 | 53.1 | 10.7 | - | - |
| ហ្វីលីពីន | 108.2 | 110.1 | - | 81.4 | 82.5 | - | - | 28.7 | - |
| សិង្ហបុរី | - | - | - | - | - | - | - | - | - |
| ថៃ | 94.7 | 93.4 | 91.1 | 74.8 | 74.3 | 75.6 | 46.0 | 44.7 | 44.6 |
| វៀតណាម | - | - | - | - | - | - | - | - | - |

*ប្រភព៖ World Bank's WDI Online (retrieved 14 July 2011)*

តារាង ៦៖ សូចនាករសំខាន់ៗនៃហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់ក្នុងបណ្ដាប្រទេសអាស៊ាន (តួលេខតាមឆ្នាំ)

| ប្រទេស | ប្រវែងផ្លូវ (គម) | ប្រវែងផ្លូវក្រាលកៅស៊ូហើយ (គម) | ផ្លូវក្រាលកៅស៊ូហើយធៀបនឹងផ្លូវសរុប (%) | ដង់ស៊ីតេផ្លូវ (គម) |
|---|---|---|---|---|
| ព្រុយនេ | 3728 (2006) | 2843 (2006) | 76.3 (2006) | 63 (2005) |
| កម្ពុជា | 11494 (2007) | 2376 (2007) | 20.7 (2007) | 21 (2004) |
| ឥណ្ឌូនេស៊ី | 396362 (2007) | 221905 (2007) | 56.0 (2007) | 23 (2008) |
| ឡាវ | 73323 (2007) | 5133 (2007) | 7.0 (2007) | 15 (2008) |
| ម៉ាឡេស៊ី | 90127 (2006) | 71292 (2006) | 79.1 (2006) | 30 (2004) |
| មីយ៉ាន់ម៉ា | -- | 55157 (2007) | -- | 4 (2005) |
| ហ្វីលីពីន | 29650 (2008) | 21677 (2008) | 73.1 (2008) | 67 (2003) |
| សិង្ហបុរី | 3325 (2008) | 3325 (2008) | 100 (2008) | 475 (2008) |
| ថៃ | 98053 (2007) | 97988 (2007) | 99.9 (2007) | 35 (2006) |
| វៀតណាម | 137359 (2004) | 53610 (2004) | 39.0 (2004) | 48 (2007) |

*ប្រភព៖ ASEAN Statistical Yearbook 2008; World Bank's WDI 2011*

*កំណត់សម្គាល់៖ ភាគរយនៃផ្លូវក្រាលកៅស៊ូ = ប្រវែងផ្លូវក្រាលកៅស៊ូ (គ.ម) ចែកនឹងប្រវែងផ្លូវសរុប (គ.ម)*
*ដង់ស៊ីតេផ្លូវ (គ.ម) = ប្រវែងផ្លូវ (គ.ម) គិតក្នុងផ្ទៃដី ១០០គ.ម²*

អង្កេតពីយោបល់ថ្នាក់គ្រប់គ្រងអាជីវកម្ម ធ្វើឡើងដោយ WEF បានដាក់ "ការផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធមិនគ្រប់គ្រាន់" នៅលំដាប់ទី៣ ក្នុងចំណោមឧបសគ្គចម្បងៗដល់ការធ្វើអាជីវកម្មនៅកម្ពុជា សម្រាប់ឆ្នាំ២០០៨ និងលំដាប់ទី៤ សម្រាប់ឆ្នាំ២០០៩ និង ២០១០ (តារាង ១)។ ចំណុចនេះបង្ហាញថា វិស័យឯកជនខ្វះទំនុកចិត្តលើការផ្គត់ផ្គង់ហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជា ដើម្បីបំពេញតម្រូវការរបស់ផ្នែកអាជីវកម្ម។ តារាង ៦ បង្ហាញថា ភាគរយផ្លូវថ្នល់ក្រាលកៅស៊ូនៅកម្ពុជា ឈរនៅលំដាប់ថ្នាក់ទាបបំផុតទីពីរ ក្នុងចំណោមប្រទេសសមាជិកអាស៊ាន បន្ទាប់ពីប្រទេសឡាវ។ កម្ពុជាមានផ្លូវថ្នល់ក្រាលកៅស៊ូតិចជាងប្រទេសអាស៊ានឯទៀត ពីរដង ឬ ដល់ទៅ ប្រាំដង ដែលឆ្លុះបញ្ចាំងពីការតភ្ជាប់កម្រិតទាប និងហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់គុណភាពអន់នៅកម្ពុជា។ ស្ថិតិដង់ស៊ីតេផ្លូវក្នុងតំបន់ ក៏បង្ហាញអំពីរូបភាពនេះដែរ (តារាង ៦)។ ស្ថានភាពអន់ខ្សោយនៃបណ្តាញផ្លូវថ្នល់ បានរួមចំណែកមួយភាគនៅក្នុងបន្ទុកចំណាយដ៏ខ្ពស់នៃការដឹកជញ្ជូននៅក្នុងប្រទេស។ កង្វះបណ្តាញផ្លូវថ្នល់សម្រាប់ការដឹកជញ្ជូន អាចក្លាយជាឧបសគ្គរារាំងដល់កំណើនសេដ្ឋកិច្ច។

មជ្ឈដ្ឋានអាជីវកម្មឯកជន បានទទួលស្គាល់ជាទូទៅថា កម្ពុជាស្ថិតក្នុងចំណោមប្រទេសមានថ្លៃអគ្គិសនីខ្ពស់បំផុត នៅក្នុងតំបន់ និងនៅក្នុងពិភពលោក ទោះបីជារដ្ឋាភិបាលបានប្រឹងប្រែងជាប់រហូតធ្វើកំណែទម្រង់ និងកែលម្អវិស័យថាមពលរបស់ប្រទេសក្តី។ តារាង ៧ បង្ហាញថា ចំណាយជាមធ្យមលើអគ្គិសនីនៅកម្ពុជា មានមានកម្រិតខ្ពស់ជាងប្រទេសអាស៊ានដទៃទៀត លើកលែងតែសិង្ហបុរីមួយចេញ។ កម្ពុជាក៏មានបន្ទុកចំណាយខ្ពស់ដែរសម្រាប់ចំណាយប្រើប្រាស់គ្រប់ប្រភេទ ជាអាទិ៍ ចំណាយនៅតាមផ្ទះ ចំណាយផ្នែកពាណិជ្ជកម្ម និងចំណាយផ្នែកឧស្សាហកម្ម។ កត្តានេះអាចកាត់បន្ថយសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា ទល់នឹងដៃគូក្នុងតំបន់របស់ខ្លួន ជាពិសេស ឡាវ ថៃ និងវៀតណាម។ ប្រាកដណាស់ ថ្លៃអគ្គិសនីអាចជាឧបសគ្គដល់កំណើនសេដ្ឋកិច្ច។

តារាង ៧៖ ពន្ធលើអគ្គិសនីនៅបណ្តាប្រទេសសមាជិកអាស៊ាន ឆ្នាំ២០១០ (សេនដុល្លារ/គីឡូវ៉ាត់ម៉ោង)

| ប្រទេស | ចំណាយនៅតាមផ្ទះ | ចំណាយផ្នែកពាណិជ្ជកម្ម | ចំណាយផ្នែកឧស្សាហកម្ម |
|---|---|---|---|
| ព្រុយនេ | 3.82-19.11 | 3.82-15.29 | 3.82 |
| កម្ពុជា | 8.54-15.85 | 11.71-15.85 | 11.71-14.63 |
| ឥណ្ឌូនេស៊ី | 4.60-14.74 | 5.93-12.19 | 5.38-10.14 |
| ឡាវ | 3.34-9.59 | 8.80-10.36 | 6.23-7.34 |
| ម៉ាឡេស៊ី | 7.26-11.46 | 9.67-11.10 | 7.83-10.88 |
| មីយ៉ាន់ម៉ា | 3.09 | 6.17 | 6.17 |
| ហ្វីលីពីន | 6.65-10.52 | -- | -- |
| សិង្ហបុរី | 19.76 | 10.95-18.05 | 10.95-18.05 |
| ថៃ | 5.98-9.90 | 5.55-5.75 | 8.67-9.43 |
| វៀតណាម | 2.91-9.17 | 4.38-15.49 | 2.30-8.32 |

*ប្រភព៖ យកពី http://talkenergy.files.wordpress.com/2011/02/asean-electricity-tariff-2011.pdf (accessed July 11 2011)*

## ៤. សេចក្តីសន្និដ្ឋាន

សរុបមក ការសិក្សានេះបានរកឃើញថា បន្ទុកចំណាយហិរញ្ញវត្ថុនៅឆ្នាំ២០០៩ ហាក់មិនមែនជាឧបសគ្គដល់កំណើនទេ។ ម្យ៉ាងទៀត ក៏មិនមានសញ្ញាអ្វីបង្ហាញពីឧបសគ្គលើលទ្ធភាពប្រើប្រាស់ហិរញ្ញវត្ថុអន្តរជាតិដែរ ផ្អែកតាមរបាយការណ៍របស់ WEF ពីលទ្ធផលអង្កេតថ្នាក់គ្រប់គ្រងអាជីវកម្ម ដែលបានដាក់ "បទបញ្ញត្តិរូបិយវត្ថុបរទេស" ក្នុងលំដាប់ទី ១៤ ក្នុងចំណោមកត្តាចម្បងៗ ១៥មុខ ដែលបង្កបញ្ហាដល់ការធ្វើអាជីវកម្មនៅកម្ពុជា សម្រាប់ឆ្នាំ២០០៩ និងលំដាប់ទី១៣ សម្រាប់ឆ្នាំ២០១០។ ក្នុងឆ្នាំ២០១០ ហានិភ័យម៉ាក្រូសេដ្ឋកិច្ច លែងជាក្តីបារម្ភចំពោះលទ្ធភាពរកប្រាក់ចំណេញរបស់សហគ្រាសទៀតហើយ ដោយអតិផរណាបានថយចុះដល់អត្រាដូចមុនពេលមានវិបត្តិ ហើយអត្រាប្តូរប្រាក់ក៏ឡើងចុះក្នុងកម្រិតដែលអាចគ្រប់គ្រងបានដែរ។ អត្រាពន្ធលើប្រាក់ចំណេញក្រុមហ៊ុន និងសិទ្ធិកាន់កាប់ដីធ្លី ហាក់មិនមែនជាឧបសគ្គទេ ប៉ុន្តែកង្វះវិធីសាស្ត្រដោះស្រាយទំនាស់ ការពង្រឹងអនុវត្តន៍ច្បាប់និងរដ្ឋបាលពន្ធមានកម្រិត ទំនងជាឧបសគ្គចំពោះកំណើន។ កង្វះការរកឃើញដោយខ្លួនឯង ក៏ឃើញមានយ៉ាងច្បាស់ដែរ ប៉ុន្តែហាក់មិនបង្កឧបសគ្គដល់កំណើនទេ ព្រោះជាក់ស្តែង អត្រារស់រាននៃផលិតផលនាំចេញថ្មី មានដល់ប្រហែល ៣៩,៩% ក្នុងឆ្នាំ២០០០-២០០៩។ ទោះយ៉ាងនេះក្តី បញ្ហាការសម្របសម្រួលអន់ខ្សោយ អាចក្លាយជាឧបសគ្គដល់កំណើន ដូចមានបញ្ជាក់ដោយភស្តុតាងជាច្រើនទទួលបានពីអង្កេតតាមអនុវិស័យសេដ្ឋកិច្ចនានា។ ទោះបីមានភាពមិនស៊ីគ្នាខាងជំនាញក្នុងទីផ្សារការងារ និងកម្រិតអប់រំទាបនៃកម្លាំងពលកម្ម ដែលបង្កដោយការអប់រំផ្តល់ផលចំណេញតិចក្តី ក៏មូលធនមនុស្សកម្រិតទាប មិនមែនជាឧបសគ្គដល់កំណើនសរុបដែរ ព្រោះកម្ពុជាសម្បូរកម្លាំងពលកម្ម។ សម្រាប់ផ្នែកហេដ្ឋារចនាសម្ព័ន្ធវិញ មានភស្តុតាងបង្ហាញថា កង្វះផ្លូវថ្នល់ដឹកជញ្ជូន និងចំណាយខ្ពស់លើអគ្គិសនី ទំនងជាឧបសគ្គរាំងដល់កំណើនសេដ្ឋកិច្ច។

## គន្ថនិទ្ទេស


ASEAN (2008), "ASEAN Statistical Year Book" (Jakarta: The ASEAN Secretariat)

Guimber, S. (2010), "Cambodia 1998-2008: An Episode of Rapid Growth", Policy Research Working Paper No. 5271 (Washington, DC: World Bank)

Hausmann, R., D. Rodrik & A. Velasco (2005), "Growth Diagnostics" (Cambridge, MA: Harvard University)

IFC (2010), "Understanding Cambodian Small and Medium Enterprise Needs for Financial Services and Products" (Phnom Penh: IFC)

IMF (2011), "International Financial Statistics" (Washington: IMF)

MAFF (2010), "Annual Report for the Agriculture, Forestry and Fisheries 2009-2010" (Phnom Penh: MAFF)

MAFF (2009), "Annual Report for the Agriculture, Forestry and Fisheries 2008-2009" (Phnom Penh: MAFF)

MEF (2010), "Cambodia Macroeconomic Framework 2000-2011" (Phnom Penh: Ministry of Economy and Finance)

NBC (2011), "Economic and Monetary Statistics" (Phnom Penh: NBC)

NBC (2009), "Annual Report 2009", Report of the Banking Supervision Department (Phnom Penh: NBC)

NBC (2008), "Annual Report 2008", Report of the Banking Supervision Department (Phnom Penh: NBC)

NIS (2011), "Consumer Price Index Report" (Phnom Penh: MOP)

NIS (2010), "Cambodia Socio-Economic Survey 2009" (Phnom Penh: MOP)

World Bank (2011), "World Development Indicators" (World Bank's Online Database: accessed on April 22, 2011 at http://data.worldbank.org/data-catalog/world-development-indicators)

World Bank (2010a), "Doing Business 2011: Making a Difference for Entrepreneurs" (Washington, DC: World Bank)

World Bank (2010b), "Providing Skills for Equity and Growth: Preparing Cambodia's Youth for the Labour Market" (Washington, DC: World Bank)

World Bank (2009a), "Second Investment Climate Assessment: A Better Investment Climate to Sustain Growth in Cambodia" (Phnom Penh: World Bank)

World Bank (2009b), "Sustaining Rapid Growth in a Challenging Environment: Cambodia Country Economic Memorandum" (Phnom Penh: World Bank)

World Bank (2004), "Cambodia at the Crossroads: Strengthening Accountability to Reduce Poverty" (Phnom Penh: World Bank)

World Economic Forum (2011), "Global Competitiveness Report" (Geneva: WEF)

World Economic Forum (2010), "Global Competitiveness Report" (Geneva: WEF)

World Bank (2011), "World Governance Indicators" (Washington: World Bank)

# -២-
# សមាសភាពតាមវិស័យនៃកំណើនសេដ្ឋកិច្ច ការកាត់បន្ថយភាពក្រីក្រ និងវិសមភាព នៅប្រទេសចិន៖ បទពិសោធន៍ខាងគោលនយោបាយ និងអភិវឌ្ឍន៍ សម្រាប់ប្រទេសកម្ពុជា

*ដោយលោក រ័ត្ន វឌ្ឍនា*[១]

## សង្ខេបអត្ថបទ

ទាក់ទិននឹងបទពិសោធន៍អភិវឌ្ឍន៍របស់ប្រទេសចិន កម្ពុជាអាចរៀនសូត្រពីការកាត់បន្ថយភាពក្រីក្រតាមពីររបៀបរបស់ចិន ពោលគឺ ១) គោលនយោបាយកាត់បន្ថយភាពក្រីក្រដោយផ្ដោតលើកំណើន ជាមួយនឹងកម្មវិធីជាច្រើនដែលមានទាំងយន្តការផ្សេងៗសម្រាប់ធានាឲ្យមានការបែងចែកចំណូលឡើងវិញ និង ២) កំណើនសេដ្ឋកិច្ចគាំទ្រនិងរាប់បញ្ចូលទាំងជនក្រីក្រ។ ខាងផ្នែកសេដ្ឋកិច្ច កម្ពុជាអាចទាញយកបទពិសោធន៍ទាក់ទងនឹងសេរីភាវូបនីយកម្មពាណិជ្ជកម្ម ឧស្សាហូបនីយកម្មផ្ដោតលើពិពិធកម្ម សមត្ថភាពប្រកួតប្រជែងខាងអាជីវកម្ម និងការភ្ជាប់ទំនាក់ទំនងរវាងទីក្រុងនិងជនបទ ការអភិវឌ្ឍជនបទនិងកសិកម្ម និង តួនាទីរដ្ឋក្នុងការដឹកនាំនិងសម្របសម្រួលរបៀបវារៈអភិវឌ្ឍន៍។ នៅក្នុងសមាសភាពតាមវិស័យនៃកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ និង ស្ថិតក្នុងចំណោមសរសរគ្រឹះទាំងបួននៃសេដ្ឋកិច្ចដែលមានវិស័យកាត់ដេរ ទេសចរណ៍ សំណង់ និង កសិកម្មនោះផង ការអភិវឌ្ឍវិស័យកសិកម្មនៅតែសំខាន់បំផុតសម្រាប់ការកាត់បន្ថយភាពក្រីក្រ។ ដូច្នេះ ក្នុងរយៈពេលខ្លី និងមធ្យម ការលុបបំបាត់ឧបសគ្គរាំងកំណើនកសិកម្មដែលជួយឲ្យការអភិវឌ្ឍជនបទអាចមាននិរន្តរភាព ផលិតភាព និងការគាំទ្រដល់ជនក្រីក្រ គួរតែជាអាទិភាពកំពូលសម្រាប់រដ្ឋាភិបាលកម្ពុជា។ កម្មវិធីផ្ដោតលើភាពក្រីក្រ ជាជម្រើសមួយដែលកម្ពុជាអាចធ្វើការស្រាវជ្រាវបន្ថែមពាក់ព័ន្ធនឹងការកាត់បន្ថយភាពក្រីក្រ និងការបែងចែកប្រាក់ចំណូលឡើងវិញនេះ។

## ១. សេចក្ដីផ្ដើម

ទន្ទឹមគ្នានឹងអត្រាកំណើន ផសស យ៉ាងលឿនដល់ ៨% ជាមធ្យមក្នុងមួយឆ្នាំ នៅចន្លោះឆ្នាំ១៩៩៤-២០០៩ កម្ពុជាក៏សម្រេចបានលទ្ធផលបង្គួរក្នុងការកាត់បន្ថយអត្រាភាពក្រីក្រ[២] គឺចាប់ពីប្រហែល ៥០% នៅឆ្នាំ១៩៩៧ មកត្រឹម ៣០% នៅឆ្នាំ២០០៧ (World Bank 2009)។

---

១ លោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

២ ជោគជ័យរបស់កម្ពុជាក្នុងការកាត់បន្ថយភាពក្រីក្រ មានមិនសូវធំទេ ដោយសារភាពរួញលូតនៃកំណើននៃភាពក្រីក្រមានកម្រិតទាប (growth elasticity of poverty is small) ដែលបង្ហាញថា កំណើនប្រាក់ចំណូលជាមធ្យមនៃបញ្ចភាគក្រោមបំផុត វាយឺតយ៉ាវជាងកំណើនប្រាក់ចំណូលមធ្យមនៃសេដ្ឋកិច្ចទាំងមូល។

ជោគជ័យនេះ បានពង្រឹងឡើងថែមទៀត ឆ្លងតាមកំណើនចំណាយប្រើប្រាស់គិតក្នុងមនុស្សម្នាក់ និងសូចនាករសង្គមផ្សេងៗជាច្រើន ទាក់ទងនឹងការផ្តល់សេវាកម្ម និងការអភិវឌ្ឍមនុស្ស។ ប្រាក់ចំណូលជាមធ្យមក្នុងប្រជាជនកម្ពុជាម្នាក់ បានកើនក្នុងអត្រាប្រចាំឆ្នាំ ៥,៣% ពី ២០៩ដុល្លារ នៅឆ្នាំ១៩៩៣ ដល់ ៥៥០ដុល្លារ នៅឆ្នាំ២០១០ (World Bank 2011a)។ របាយការណ៍អភិវឌ្ឍន៍ធនធានមនុស្សចុងក្រោយបង្អស់ បង្ហាញថា កម្ពុជាឈរនៅលំដាប់ទី១២៤ ក្នុងចំណោម ១៦៩ប្រទេស ដោយមានសន្ទស្សន៍អភិវឌ្ឍន៍មនុស្ស ០,៤៩៤ គឺកើនឡើងបានមួយពិន្ទុ បើធៀបនឹងឆ្នាំ២០០៥ (UNDP 2010)។ កម្ពុជាក៏បានជឿនលឿនទៅមុខក្នុងដំណើរការឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDG) ដែរ។

ចំពោះរបៀបវារៈអភិវឌ្ឍន៍ វានៅឃ្លាតឆ្ងាយពីគោលដៅនៅឡើយ ពីព្រោះកម្ពុជាត្រូវផ្តោតកម្លាំងខំសម្រេចគោលដៅដែលមានស្រាប់ និងដោះស្រាយផងដែរនូវបញ្ហាទើបផុសឡើងថ្មី ដូចជា អតិផរណា ភាពប្រកួតប្រជែងផ្នែកជំនួញ កង្វះខាតឱកាសការងារសម្រាប់ប្រជាជន ការចុះខ្សោយប្រព័ន្ធសុវត្ថិភាពសង្គម និង វិសមភាពសង្គម។ ការបារម្ភមួយបានផុសឡើង គឺការប្រែប្រួលខ្លាំងក្នុងការរួមចំណែកនៃកំណើនសេដ្ឋកិច្ចនៅក្នុងការកាត់បន្ថយភាពក្រីក្រ (poverty elasticity of economic growth)។ សន្ទស្សន៍ភាពក្រីក្រគិតក្នុងមនុស្សម្នាក់ បានធ្លាក់ចុះពី ៣៤,៨% នៅឆ្នាំ២០០៤ មកត្រឹម ៣០,១% នៅឆ្នាំ២០០៧ ប៉ុន្តែវិសមភាពសរុបដែលវាស់វែងដោយប្រើមេគុណ Gini បានកើនឡើង ពី ០,៣៩៦ (៣៩,៦%) ដល់ ០,៤៣១ (៤៣,១%) ក្នុងអំឡុងពេលដូចគ្នា (World Bank 2009)។

ការសិក្សានេះ មានគោលបំណងវិភាគលើសមាសភាពសេដ្ឋកិច្ចបច្ចុប្បន្ន (កសិកម្ម ឧស្សាហកម្ម និង សេវាកម្ម) នៅក្នុងប្រទេសចិន និងកម្ពុជា និង វាយតម្លៃពីភាពសក្តិសមសម្រាប់កម្ពុជា ដើម្បីរៀនសូត្រពីគោលនយោបាយគាំទ្រអ្នកក្រដែលប្រទេសចិនបានដាក់បញ្ចូលក្នុងកំណែទម្រង់សេដ្ឋកិច្ច និងគោលនយោបាយរបស់ខ្លួន សំដៅជួយធ្វើការបែងចែកប្រាក់ចំណូលឡើងវិញទៅឲ្យគ្រួសារនានានៅតាមទីក្រុង និងជនបទ។

## ២. ការសិក្សាពីប្រទេសចិនលើការកាត់បន្ថយភាពក្រីក្រ និងកំណើនសម្រាប់គ្រប់គ្នា

### ២.១. កត្តាកំណត់មួយចំនួននៃការកាត់បន្ថយភាពក្រីក្រផ្អែកលើកំណើន

#### *២.១.១. សេរីភាវូបនីយកម្មពាណិជ្ជកម្ម*

ចំណុចដ៏សំខាន់មួយក្រោយការធ្វើកំណែទម្រង់នៅប្រទេសចិន គឺ ការបើកចំហទីផ្សារចំពោះពិភពលោក តាមរយៈការពង្រីកពាណិជ្ជកម្ម និងលើកទឹកចិត្តឲ្យមានវិនិយោគបរទេសច្រើនថែមទៀត (Winter *et al.* 2004)។ ការថយចុះជាបណ្តើរៗនៃអត្រាពន្ធគយសរុប ជាលក្ខណៈពិសេសមួយនៃកំណែទម្រង់នៅប្រទេសចិន ហើយអត្រាពន្ធនេះមានកម្រិតទាបជាងអត្រារបស់ប្រទេសកំពុងអភិវឌ្ឍមួយចំនួនទៀតផង។ យោងតាមរបាយការណ៍គយ ចិនមានលទ្ធភាពកាត់បន្ថយអត្រាពន្ធគយសរុបពី ១៥,៦% នៅឆ្នាំ២០០០ មកត្រឹម ៩,៨% នៅឆ្នាំ២០០៩ ស្របពេលដែលអត្រាពន្ធជាមធ្យមលើផលិតផលកសិកម្មមាន ១៥,២% និង លើទំនិញឧស្សាហកម្ម មាន ៨,៩%។

ប្រទេសចិន បានល្បីឈ្មោះចំពោះជោគជ័យរបស់ខ្លួនក្នុងការអភិវឌ្ឍតំបន់សេដ្ឋកិច្ចពិសេស (SEZs) និង គ្រឿងសម្រួលការនៅតាមផែ ក៏ដូចជា ការកែលម្អទម្រង់ការនាំចេញ និងនាំចូល។ វិនិយោគិនបរទេសទទួលបានការលើកទឹកចិត្តឲ្យបង្កើតរោងចក្រនៅតំបន់ SEZs

ដែលនៅទីនោះមានផ្តល់នូវការអនុគ្រោះផ្សេងៗ ដូចជា ការលើកលែងពន្ធនាំចូលលើសម្ភារៈបរិក្ខារផលិតកម្មជាច្រើនប្រភេទ ការបញ្ចុះពន្ធលើប្រាក់ចំណូលសហគ្រាសពី ២៥% មកត្រឹម ១៥% ការអនុគ្រោះពិសេសចំពោះប្រាក់ផ្ញើទៅបរទេស និង ទម្រង់ការសាមញ្ញនិងងាយស្រួលសម្រាប់ការចេញចូល។ ចិនក៏បានធ្វើកំណែទម្រង់ជារឿយៗលើរបបគ្រប់គ្រងអាជីវកម្មរបស់ខ្លួន ដោយធ្វើឲ្យសាមញ្ញនូវទម្រង់ការក្នុងវិស័យសំខាន់ៗជាច្រើន ដូចជា ការបង់ពន្ធ ពាណិជ្ជកម្មឆ្លងកាត់ព្រំដែន ការទទួលឥណទាន ការពង្រឹងអនុវត្តន៍កិច្ចសន្យា ការដោះស្រាយលិខិតអនុញ្ញាតសាងសង់ និង ការបិទជំនួញ។ ឯកសារត្រូវមាន និងពេលវេលាត្រូវចំណាយសម្រាប់ការនាំចេញ និងនាំចូល នៅចិន និង កម្ពុជា មានលក្ខណៈប្រហាក់ប្រហែលគ្នា គឺ ចិនគិតថ្លៃប្រហែល ៥០០ដុល្លារសម្រាប់កុងតឺនឺរផ្ទុកទំនិញនាំចេញ និង ៥៤៥ដុល្លារសម្រាប់កុងតឺនឺរផ្ទុកទំនិញនាំចូល ចំណែកឯកម្ពុជា គិតថ្លៃ ៧៣២ដុល្លារសម្រាប់កុងតឺនឺរនាំចេញ និង ៨៧២ដុល្លារសម្រាប់កុងតឺនឺរនាំចូល (World Bank 2010a)។

ជាគោលការណ៍ មកទល់បច្ចុប្បន្ន របបពាណិជ្ជកម្មនៅកម្ពុជា មានលក្ខណៈបើកចំហ និងសេរីដូចនៅចិនដែរ។ ទោះជាយ៉ាងនេះក្តី រដ្ឋាភិបាលគួរពង្រឹង និងប្តេជ្ញាចិត្តថែមទៀត ក្នុងការកែលម្អគ្រឿងសម្រួលការកំពង់ផែ និងការធ្វើឲ្យទម្រង់ការពាណិជ្ជកម្មកាន់តែមានលក្ខណៈងាយស្រួល ដើម្បីបង្កើនល្បឿនការនាំចូលនាំចេញ និងលើកទឹកចិត្តពាណិជ្ជករ។ កម្ពុជាបាននិងកំពុងព្យាយាមធ្វើកំណែទម្រង់នីតិវិធីពាណិជ្ជកម្ម តាមការកាត់បន្ថយទម្រង់ការ ឯកសារ និងបន្ទុកចំណាយនានា ប៉ុន្តែវានៅតែមានកម្រិតខ្ពស់នៅឡើយ បើធៀបនឹងប្រទេសចិន។ កំណែទម្រង់នេះមិនសុទ្ធតែត្រូវតាក់តែងជាគោលនយោបាយអ្វីស្មុគស្មាញនោះទេ ប៉ុន្តែទាមទារឲ្យមានការរៀបចំរចនាសម្ព័ន្ធអង្គការចាត់តាំងឡើងវិញ ដោយមានការបែងចែកកម្លាំងពលកម្ម និងទំនួលខុសត្រូវឲ្យបានច្បាស់លាស់ និងមានប្រសិទ្ធភាព។

*២.១.២. ឧស្សាហូបនីយកម្ម*

បទពិសោធន៍បី ដែលកម្ពុជាអាចស្រាវជ្រាវបន្ថែមយកពីចិន គឺ (១) ពិពិធកម្មឧស្សាហកម្ម (២) សមត្ថភាពប្រកួតប្រជែង និង (៣) លទ្ធភាពនៃតំបន់ទីក្រុងក្នុងការស្រូបយកកម្លាំងពលកម្មជនបទ។

**ពិពិធកម្មឧស្សាហកម្ម**

កម្ពុជាធ្លាប់សម្រេចបានកំណើនឧស្សាហកម្មខ្លាំងក្នុងទសវត្សរ៍១៩៦០ នៅពេលដែលរោងចក្រផ្សេងៗផលិតបានទំនិញចម្រុះជាច្រើន មានតាំងពីដែកគោលរហូតដល់គ្រឿងសង្ហារឹម។ សកម្មភាពឧស្សាហកម្មបានធ្លាក់ចុះនៅទសវត្សរ៍១៩៧០ និងលែងមានសកម្មភាពសោះក្នុងរបបខ្មែរក្រហម (១៩៧៥-១៩៧៩) ហើយនៅដើមទសវត្សរ៍១៩៨០ បានចាប់ដំណើរការវិញ តែមានសមត្ថភាពផលិតតិចណាស់។ ពិតហើយ បើសិនមិនរាប់បញ្ចូលឧស្សាហកម្មកាត់ដេរនោះទេ ឧស្សាហូបនីយកម្មនៅកម្ពុជា មានការលូតលាស់ច្រើនជាងនៅទសវត្សរ៍១៩៦០ និង ១៩៨០។

មកទល់បច្ចុប្បន្ន សហគ្រាសឧស្សាហកម្មភាគច្រើននៅកម្ពុជា គឺជាកម្មន្តសាលកម្មធុនស្រាល មានមូលដ្ឋានតូចចង្អៀត និងពឹងផ្អែកជាចម្បងលើវិស័យកាត់ដេរ និងសំណង់ ដែលបង្កើតតម្លៃបន្ថែមតិចតួចដល់ ផសស និងងាយរងគ្រោះខ្លាំងពីវិបត្តិផ្នែកខាងក្រៅ។ ឧស្សាហកម្មកាត់ដេរ បានចូលរួមយ៉ាងច្រើនដល់កំណើនកម្មន្តសាលកម្ម និងគោលដៅអភិវឌ្ឍន៍ឧស្សាហកម្ម

អតិពលកម្ម ប៉ុន្តែអនុវិស័យនេះបានដំណើរការក្រោមលក្ខខណ្ឌអនុគ្រោះ (លក្ខខណ្ឌអនុគ្រោះបំផុតផ្នែកពាណិជ្ជកម្ម និង ប្រព័ន្ធអនុគ្រោះទូទៅ) ដែលផ្តល់ឲ្យដោយប្រទេសជាច្រើន ដូចជា សហរដ្ឋអាមេរិក និងបណ្តាប្រទេសសហភាពអឺរ៉ុប។ ម្យ៉ាងទៀត វិស័យនេះ បាននិងកំពុងប្រឈមមុខនឹងការប្រកួតប្រជែងយ៉ាងខ្លាំងពីប្រទេសផលិតសំលៀកបំពាក់ ដូចជា ចិន បង់ក្លាដេស វៀតណាម និង ឥណ្ឌា ជាដើម។ ភាពខ្វះខាតនៃពិពិធកម្ម ក៏អាចពិនិត្យឃើញផងដែរ តាមការឡើងចុះនៃអត្រាកំណើនប្រចាំឆ្នាំនៃផលិតកម្មឧស្សាហកម្ម (រូបភាព ១)។

លក្ខណៈពិសេសមួយនៅក្នុងឧស្សាហកម្មរបស់ប្រទេសចិន គឺ ការធ្វើពិពិធកម្មអនុវិស័យផ្សេងៗ។ បណ្តាអនុវិស័យ ដូចជា ផលិតកម្មឱសថ គ្រឿងអេឡិចត្រូនិក និង សម្ភារៈនិងគ្រឿងចក្រអគ្គិសនី បានកើនឡើងទាំងទំហំ សមត្ថភាព និងភាពប្រកួតប្រជែង ធ្វើឲ្យប្រទេសចិនអាចបង្កើតបានមូលដ្ឋានរឹងមាំសម្រាប់ឧស្សាហូបនីយកម្មបន្ថែមទៀត។ ទោះបីជាកម្ពុជាមើលឃើញថា បទពិសោធន៍នេះល្អក្តី ប៉ុន្តែការផ្លាស់ប្តូរទៅកាន់ឧស្សាហកម្មធុនធ្ងន់ ដូចជា គ្រឿងម៉ាស៊ីន និងគ្រឿងអេឡិចត្រូនិក ជាដើម វាទាមទារការខំប្រឹងប្រែងក្នុងរយៈពេលវែង និងការប្តេជ្ញាចិត្តប្រឹងកែលម្អហេដ្ឋារចនាសម្ព័ន្ធ សមត្ថភាពខាងបច្ចេកទេសនិងគ្រប់គ្រងរបស់បុគ្គលិកនិងសហគ្រាស និងវិនិយោគជាដុំកំភួនក្នុងការអប់រំ និងបណ្តុះបណ្តាលវិជ្ជាជីវៈ/បច្ចេកទេសប្រកបដោយគុណភាព ហើយនេះជាចំណុចដែលកម្ពុជាកំពុងខ្វះខាត។

រូបភាព ១៖ កំណើនផលិតកម្មនៅកម្ពុជា ការប្រែប្រួលប្រចាំឆ្នាំជា % គិតពីឆ្នាំ១៩៩០-២០០៨




រូបភាព ២៖ កំណើនផលិតកម្មនៅចិន ការប្រែប្រួលប្រចាំឆ្នាំជា % គិតពីឆ្នាំ១៩៩០-២០០៩




*ប្រភព៖ ADB 2010*

## សមត្ថភាពប្រកួតប្រជែងផ្នែកឧស្សាហកម្ម

ហេតុផលសំខាន់មួយ ដែលប្រទេសចិនអាចអភិវឌ្ឍប្រព័ន្ធរចនាសម្ព័ន្ធឧស្សាហកម្មដ៏រស់រវើក គឺ បរិយាកាសអាជីវកម្មអំណោយផល និងបន្ទុកចំណាយផលិតកម្មទាប ដែលជាលទ្ធផលនៃហេដ្ឋារចនាសម្ព័ន្ធមានគុណភាពល្អនិងអាចទុកចិត្តបាន ដូចជា អគ្គិសនី ផ្លូវថ្នល់ ស្ពាន ផ្លូវដែក ទម្រង់ការពាក់ព័ន្ធនឹងរដ្ឋាភិបាល និង កម្លាំងពលកម្មថោកនិងមានសមត្ថភាព។ ទោះបីចិនត្រូវធ្វើការកែលម្អបន្ថែមលើទិដ្ឋភាពមួយចំនួនទៀតក្តី ក៏ប្រទេសចិនទទួលបានចំណាត់ថ្នាក់លេខ ៧៩ ក្នុងចំណោម ១៨៣ប្រទេស លើភាពងាយស្រួលក្នុងការធ្វើជំនួញ ដែលវាជាលទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការសម្រួលទម្រង់ការពាក់ព័ន្ធនឹងអាជីវកម្ម។ តួយ៉ាង ការចាប់ផ្តើមអាជីវកម្មមួយនៅប្រទេសចិន ត្រូវការពេល ១៤ថ្ងៃ និងត្រូវចំណាយអស់ស្មើនឹង ៤,៥% នៃប្រាក់ចំណូលក្នុងមនុស្សម្នាក់។ ខាងផ្នែកច្បាប់វិញ ចិនជាប់ចំណាត់ថ្នាក់លេខ ១៥ ក្នុងការពង្រឹងអនុវត្តន៍

កិច្ចសន្យា ហើយមានបន្ទុកចំណាយស្មើនឹង ១១,១% នៃសំណងត្រូវទាមទារ ធៀបនឹង ១០២,៧% នៅកម្ពុជា ២៨,៥% នៅវៀតណាម និង ២៧,៥% នៅម៉ាឡេស៊ី។ ម្យ៉ាងទៀត ការអភិវឌ្ឍ និងស្ថានភាពហេដ្ឋារចនាសម្ព័ន្ធនៅចិន មានលក្ខណៈល្អសម្រាប់ជំនួញ និងពាណិជ្ជកម្ម (World Bank 2010a)។

ការធ្វើជំនួញនៅកម្ពុជា នៅតែស្មុគស្មាញ ប្រើពេលយូរ និងមានបន្ទុកចំណាយខ្ពស់។ ក្រុមហ៊ុន ត្រូវឆ្លងកាត់ដំណើរការចុះឈ្មោះ និងបែបបទផ្នែកច្បាប់ ដ៏វែងអន្លាយ ដែលជួនកាលមិនទាំងចាំបាច់ទៀតផង។ កម្ពុជាស្ថិតនៅចំណាត់ថ្នាក់លេខ១៤៧ ក្នុងចំណោម ១៨៣ប្រទេស លើភាពងាយស្រួលក្នុងការធ្វើជំនួញ ហើយចិនជាប់លេខ៧៩ ថៃជាប់លេខ១៩ វៀតណាមជាប់លេខ ៧៨ និង ម៉ាឡេស៊ីជាប់លេខ២១។ ក្រុមហ៊ុននៅកម្ពុជា ត្រូវបំពេញឯកសារជាចាំបាច់ចំនួន៩ ក្នុងរយៈពេល ៨៥ថ្ងៃ និង ត្រូវចំណាយអស់ ១២៨,៣% នៃប្រាក់ចំណូលក្នុងមនុស្សម្នាក់ ដើម្បីចាប់ផ្តើមជំនួញមួយ។ ក្រុមហ៊ុននៅវៀតណាម ត្រូវការពេលតែពាក់កណ្តាលនៃចំនួនថ្ងៃនៅកម្ពុជាប៉ុណ្ណោះ និង ចំណាយអស់ ១២,១% នៃចំណូលក្នុងមនុស្សម្នាក់ ដើម្បីចាប់ផ្តើមជំនួញមួយដូចគ្នា (World Bank 2010a)។

ការធ្វើជំនួញតាមមធ្យោបាយក្រៅផ្លូវការនៅកម្ពុជា នៅឃើញមានជាទូទៅនៅឡើយៈ ក្រុមហ៊ុននៅកម្ពុជា ៦១,២% បានឆ្លើយប្រាប់ថា ពួកគេត្រូវបង់ប្រាក់កម្រៃក្រៅផ្លូវការដល់មន្ត្រីរដ្ឋាភិបាល ដើម្បីដោះស្រាយការងារអ្វីមួយ ធៀបនឹងក្រុមហ៊ុននៅវៀតណាម ៥២,៥% និង នៅឡាវ ៤០%។ ម្យ៉ាងទៀត នៅកម្ពុជាមានសហគ្រាស ៦០% រាយការណ៍ថា មានការជូនអំណោយនៅពេលជួបជាមួយមន្ត្រីពន្ធដារ ធៀបនឹងនៅចិនមាន ៣៩% នៅវៀតណាមមាន ៣៤% និង នៅឡាវមាន ២៦% ។ បញ្ហាគួរបារម្ភជាងនេះទៀត គឺ ការទទួលបានកិច្ចសន្យាពីរដ្ឋាភិបាល ព្រោះមានសហគ្រាស ៧៧% ប្រាប់ថា ពួកគេបានជូនអំណោយដល់មន្ត្រីរដ្ឋាភិបាល ដើម្បីទទួលបានកិច្ចសន្យា ធៀបនឹងត្រឹម ២៧% នៅចិន។ បញ្ហានេះបានប៉ះពាល់ដោយផ្ទាល់ទៅលើការរីកលូតលាស់របស់សហគ្រាស ព្រោះវាជាប់ទាក់ទងនឹងភាពប្រកួតប្រជែងខាងផ្នែកបន្ទុកចំណាយក៏ដូចជា ឆន្ទៈ និងទឹកចិត្តវិនិយោគលើផ្នែកជំនួញ (World Bank 2007)។

**សមត្ថភាពស្រូបយក**

ការបែងចែកកម្លាំងពលកម្មតាមវិស័យ "កសិកម្ម ឧស្សាហកម្ម និង សេវាកម្ម" ទាំងនៅចិន និងកម្ពុជា មានភាពស្រដៀងគ្នា ក្រោយពេលធ្វើកំណែទម្រង់បាន ៥-៦ឆ្នាំ។ ប៉ុន្តែសម្រាប់ប្រាំឆ្នាំចុងក្រោយនេះ ជាពិសេសនៅពេលកំណែទម្រង់មានដំណើរការពេញលេញ ភាពស្រដៀងគ្នាបានចាប់ផ្តើមរលុបបាត់បន្តិចម្តងៗ ដោយឧស្សាហកម្មនៅចិន មានចំណែកកម្លាំងពលកម្មធំណាស់បើធៀបនឹងកម្ពុជា។ ដូចមានបង្ហាញក្នុងរូបភាព ៣ ចាប់ពីឆ្នាំ១៩៩៣ ដល់ ២០០២ វិស័យកសិកម្មនៅចិន ប្រើកម្លាំងពលកម្មជាមធ្យមក្នុងមួយឆ្នាំអស់ ៥៣% នៃកម្លាំងពលកម្មសរុប ធៀបនឹង ១៣% ក្នុងឧស្សាហកម្ម និង ៣៤,៣% ក្នុងសេវាកម្ម។ ប៉ុន្តែពីឆ្នាំ២០០៣ ដល់ ២០០៩ កម្លាំងពលកម្មក្នុងវិស័យឧស្សាហកម្មបានចាប់កើនឡើង ហើយនៅឆ្នាំ២០០៤ បានកើនខ្ពស់ជាងក្នុងវិស័យកសិកម្ម ពោលគឺ ឧស្សាហកម្ម មាន ៥១,៣% និង កសិកម្ម មាន ៤៣,១%។

រូបភាព ៣៖ ចំណែកកម្លាំងពលកម្មតាមវិស័យ នៅចិន ឆ្នាំ១៩៩៣-២០០៨




រូបភាព ៤៖ ចំណែកកម្លាំងពលកម្មតាមវិស័យនៅ កម្ពុជា ឆ្នាំ១៩៩៣-២០០៨




*ប្រភព៖ ADB 2010*

នៅចិន ក្នុងចន្លោះឆ្នាំ ១៩៩០ និង ២០០៩ អត្រាកំណើនការប្រើប្រាស់កម្លាំងពលកម្មក្នុងវិស័យកសិកម្មបានធ្លាក់ចុះតាមអត្រាប្រចាំឆ្នាំ ១,៤% ចំណែកឯការប្រើប្រាស់កម្លាំងពលកម្មក្នុងឧស្សាហកម្មបានកើនឡើង ៩,៥%។ ចំណុចនេះក៏អាចមើលឃើញតាមអត្រាធ្លាក់ចុះប្រចាំឆ្នាំ ១,៤% នៃចំនួនប្រជាជននៅជនបទក្នុងប្រទេសចិន ឬពី ៧៣% នៃចំនួនប្រជាជនសរុបក្នុងឆ្នាំ១៩៩០ មកត្រឹម ៥៦% ក្នុងឆ្នាំ២០០៩ ធៀបនឹងអត្រាធ្លាក់ចុះប្រចាំឆ្នាំ ០,៦% នៅកម្ពុជា គឺពី ៨៧% ដល់ ៧៨% ក្នុងអំឡុងពេលដូចគ្នា (World Bank 2011a)។ តួលេខនេះបង្ហាញពីកំណើនចំនួនភាគរយនៃប្រជាជននៅទីក្រុង និងនិន្នាការមានពលករនៅជនបទកាន់តែច្រើនឡើងធ្វើចំណាកស្រុកទៅធ្វើការងារឧស្សាហកម្មនៅទីក្រុង ដែលផ្តល់អត្ថប្រយោជន៍បានច្រើនជាងការងារកសិកម្ម។

ផ្ទុយទៅវិញ បញ្ហាប្រឈមជាមូលដ្ឋានមួយនៅកម្ពុជា គឺ ការបង្កើនផលិតភាព និង ការធានាថា កំណើនផលិតភាពជួយបង្កើតនូវលក្ខខណ្ឌការងារល្អ និងប្រាក់ឈ្នួលខ្ពស់សម្រាប់ពលករ។ ផលិតភាពពលកម្មសរុប បានកើនឡើងពី ២,៤លានរៀល (៦៣១ដុល្លារ) ក្នុងឆ្នាំ១៩៩៨ ដល់ ៤,២លានរៀល (១០៣០ដុល្លារ) ក្នុងឆ្នាំ២០០៨ ឬមានកំណើន ៥,៧% ក្នុងមួយឆ្នាំគិតជាប្រាក់រៀល ឬ ៤,៩% គិតជាប្រាក់ដុល្លារ។ ចាប់ពីឆ្នាំ១៩៩៥ ដល់ ២០០៨ វិស័យកាត់ដេរបានផ្តល់ការងារជាមធ្យមដល់ពលករ ២០២.៩៥៥នាក់ជារៀងរាល់ឆ្នាំ ដែលមួយភាគធំជានារីមានការអប់រំទាបនិងមកពីជនបទ។ ប៉ុន្តែអនុវិស័យនេះងាយរងគ្រោះដោយការប៉ះទង្គិចពីខាងក្រៅ ព្រោះផលិតផលកាត់ដេរស្ទើរតែទាំងអស់ សុទ្ធតែសម្រាប់នាំចេញទៅកាន់ទីផ្សារសហរដ្ឋអាមេរិក និង សហភាពអឺរ៉ុប ជាសំខាន់ (Nutsuda *et al.* 2009)។ ចំនួនអ្នកធ្វើចំណាកស្រុកក្នុងស្រុកបានកើនឡើងបន្តិច ដល់ ២,៥លាននៅឆ្នាំ២០០៨ ធៀបនឹង ២,៣លានកាលពីមួយទសវត្សរ៍មុន។ ទោះបីជាជនចំណាកស្រុកដែលរកការងារធ្វើបានក្នុងឧស្សាហកម្ម បានកើនដល់ ១៣,៦% ក្នុងឆ្នាំ២០០៨ ធៀបនឹង ៧,៣% ក្នុងឆ្នាំ១៩៩៨ ក្តី ក៏ភាគច្រើន (៥១,៥%) តែងត្រឡប់មកធ្វើការងារក្នុងកសិកម្មវិញ (ILO 2010)។ តួលេខនេះបង្ហាញពីមូលដ្ឋានតូចចង្អៀតនៃវិស័យឧស្សាហកម្ម និងសមត្ថភាពទាបក្នុងការបង្កើតការងារថ្មី។

### ២.១.៣. *កសិកម្ម និងការអភិវឌ្ឍជនបទ*

កសិកម្មនៅកម្ពុជា នៅតែមានចំណែកធំនៅក្នុង ផសស និង ជាប្រភពចម្បងនៃការងារនៅជនបទ។ ប៉ុន្តែវិស័យនេះនៅតែមានការអភិវឌ្ឍអន់ខ្សោយ ដោយមានវិនិយោគជាទ្រព្យជាប់លាប់តិច និង ការប្រើបច្ចេកទេសបុរាណជាទូទៅ (Guimbert 2010)។ មានចំណុចបីដែលគួរពិចារណានៅពេលពិនិត្យពីកសិកម្មនិងការអភិវឌ្ឍជនបទនៅកម្ពុជា ធៀបនឹងជោគជ័យក្នុងការអភិវឌ្ឍវិស័យកសិកម្មនៅចិន៖ ១) ការបន្តចំណាយរបស់រដ្ឋាភិបាលសម្រាប់កសិកម្ម ២) វិនិយោគប្រើដើមទុនខ្ពស់ និង ៣) ចំណងទាក់ទងរវាងវិស័យឧស្សាហកម្ម និងសេវាកម្ម តាមរយៈការស្រូបយកកម្លាំងពលកម្ម និង ខ្សែចង្វាក់កំណត់តម្លៃ។

តាំងពីពេលធ្វើកំណែទម្រង់មក ចំណាយរបស់រដ្ឋាភិបាលចិនសម្រាប់វិស័យកសិកម្មនៅតែខ្ពស់ដដែល។ ពីឆ្នាំ១៩៧៨ ដល់ ១៩៨៩ ចំណាយលើកសិកម្ម កើន ៥,៣% ក្នុងមួយឆ្នាំ និង តំណាងឲ្យ ១០,៧% នៃចំណាយសរុបរបស់រដ្ឋាភិបាល ហើយពីឆ្នាំ១៩៩០ ដល់ ២០០៣ វាមានអត្រាកំណើនកាន់តែខ្ពស់ដល់ ១៤,៣% ប៉ុន្តែបើគិតជាភាគរយចំណាយសរុបវិញ វាបានថយចុះមកត្រឹម ៩%។ ចំណាយនេះបានផ្តោតលើសកម្មភាពពាក់ព័ន្ធកសិកម្មជាច្រើន ដូចជាការគាំទ្រផលិតកម្មកសិកម្ម ការបង្កើតមូលធន ការជំរុញវិទ្យាសាស្ត្រនិងបច្ចេកវិទ្យា និងមូលនិធិជំនួយសង្គ្រោះជនបទ។ និន្នាការវិជ្ជមាននៃចំណាយសម្រាប់កសិកម្ម ការអភិរក្សព្រៃឈើ និងទឹកនេះ នៅតែបន្ត ដោយតំណាងឲ្យប្រមាណ ៨,៨% នៃចំណាយជាតិសរុបក្នុងឆ្នាំ២០០៩ ធៀបនឹង ៧,៣% កាលពីមួយឆ្នាំមុន (China's NBS 2010)។

តារាង ១៖ ទិន្នផលដំណាំ ការប្រើប្រាស់បច្ចេកវិទ្យា និងហេដ្ឋារចនាសម្ព័ន្ធនៅកម្ពុជានិងក្នុងតំបន់

| | កម្ពុជា | ចិន | វៀតណាម | ឡាវ | ថៃ | ឥណ្ឌូណេស៊ី | ហ្វីលីពីន | មីយ៉ាន់ម៉ា |
|---|---|---|---|---|---|---|---|---|
| ទិន្នផលដំណាំ (គក្រ/ហិកតា) | | | | | | | | |
| 1990 | 1362 | 4323 | 3073 | 2268 | 2009 | 3800 | 2065 | 2762 |
| 2009 | 2947 | 5460 | 5075 | 3808 | 2954 | 4813 | 3229 | 3585 |
| បច្ចេកវិទ្យាទំនើប | | | | | | | | |
| ត្រាក់ទ័រ (ក្នុង ១ហិកតា) | | | | | | | | |
| 1990 | 3.3 | 66.6 | 47.0 | ... | 33.0 | 2.2 | 65.2 | 13.6 |
| 2008 | 11.8 | 277.1 | .... | ... | ... | ... | ... | 10.9 |
| ជីគីមី (គក្រ/ហិកតា, 2008) | 22.7 | 468.0 | 286.6 | ... | 130.9 | 189.1 | 131.2 | 3.3 |
| ហេដ្ឋារចនាសម្ព័ន្ធ | | | | | | | | |
| ផ្លូវក្រាលកៅស៊ូ (% ផ្លូវសរុប, 2000-08) | 6.3 | 53.5 | 47.6 | 13.5 | 98.5 | 59.1 | 9.9 | 11.9 |
| ការជាវសេវាទូរសព្ទចល័ត (ក្នុងមនុស្ស 100 នាក់, 2009) | 38 | 56 | 101 | 51 | 123 | 69 | 81 | 1 |
| ការប្រើប្រាស់អគ្គិសនី (kWh ក្នុងមនុស្សម្នាក់, 2008) | 113 | 2455 | 799 | ... | 2079 | 591 | 588 | 97 |

*ប្រភព៖ World Bank 2011b*

ក្នុងការព្យាយាមកែលម្អផលិតភាពកសិកម្ម ប្រទេសចិនកំពុងផ្លាស់ប្តូរពីកសិកម្មប្រើពលកម្មច្រើន ជាលក្ខណៈគ្រួសារ និងប្រើបច្ចេកទេសបុរាណ ទៅជា កសិកម្មផ្អែកលើមូលធន និង សម្រាប់បម្រើពាណិជ្ជកម្ម។ លក្ខណៈនេះ អាចមើលឃើញនៅក្នុងកំណើនជាបន្តនៃការបង្កើតមូលធនកសិកម្ម និង កំណើនទិន្នផល តាំងពីឆ្នាំ១៩៧៨ មក។ ផ្ទៃដីកសិកម្មតំណាងឲ្យប្រហែល ៥៨% នៃផ្ទៃដីសរុប និងគ្រឿងមាស៊ីនកសិកម្ម គិតជាចំនួនត្រាក់ទ័រមួយក្នុង ១០០គីឡូម៉ែត្រការ៉េនៃផ្ទៃដីដាំដុះ កើនឡើង ៧,៨% ក្នុងមួយឆ្នាំ នៅចន្លោះឆ្នាំ១៩៩៣ និង ២០០៧ ឬកើនពី ៦៦,៦ ត្រាក់ទ័រក្នុងឆ្នាំ១៩៩០ ដល់ ២៧៧,១ត្រាក់ទ័រក្នុងឆ្នាំ២០០៨ (តារាង ១)។ ការវិវត្តក៏អាចឃើញច្បាស់តាមកំណើនការងារកសិកម្ម និងផលិតកម្ម។ ទោះបីចំនួនអ្នកធ្វើការក្នុងកសិកម្ម បានធ្លាក់ចុះតាមអត្រាប្រចាំឆ្នាំ ១,៤% ពីឆ្នាំ១៩៩៣ ដល់ ២០០៩ ក្តី ក៏វាមិនមែនសុទ្ធតែមានន័យថា ផលិតកម្មបានថយកំណើននោះទេ ហើយជាក់ស្តែង ផលិតកម្មកសិកម្ម កើនឡើង ៤,០% ក្នុងមួយឆ្នាំ ក្នុងអំឡុងពេលជាមួយគ្នានោះ (China's NBS 2010)។

ផ្ទុយទៅវិញ ចំណាយរបស់រដ្ឋាភិបាលកម្ពុជាសម្រាប់សេវាសេដ្ឋកិច្ច ដូចជា កសិកម្ម ឧស្សាហកម្ម និង សេវាកម្ម នៅមានកម្រិតទាប គឺជាមធ្យមត្រឹម ៨,៦% នៃចំណាយសរុប ចាប់ពីឆ្នាំ១៩៩៤ ដល់ ២០០៩ ធៀបនឹង ៣៤,៨% សម្រាប់ការការពារប្រទេស និង ១៥,៤% សម្រាប់សេវាកម្មសាធារណៈទូទៅ។ កសិកម្មមានចំណែកធំជាងគេក្នុងចំណាយលើសេវាកម្មសេដ្ឋកិច្ច គឺជាមធ្យម ២២,៧% ធៀបនឹងការដឹកជញ្ជូននិងទូរគមនាគមន៍ (៣៣,៨%) និង ឧស្សាហកម្ម (៥,២%) ក្នុងអំឡុងពេលដដែល។ ទោះយ៉ាងនេះក្តី ការរីកចម្រើនក្នុងការវិនិយោគ ការបង្កើតមូលធន បច្ចេកទេសកសិកម្ម និង ការស្រាវជ្រាវនិងអភិវឌ្ឍន៍ក្នុងវិស័យកសិកម្ម វានៅតែយឺតយ៉ាវ។

*២.១.៤. តួនាទីរដ្ឋ*

រដ្ឋាភិបាលចិន មានសកម្មភាពយ៉ាងល្អក្នុងការដឹកនាំ ការប្រមូលពន្ធ ការរៀបចំគោលនយោបាយនិងយុទ្ធសាស្ត្រ ការផ្តល់ទំនិញសាធារណៈ (ការអប់រំ សុខភាព ហេដ្ឋារចនាសម្ព័ន្ធ) និង ការសម្របសម្រួលនិងគ្រប់គ្រងការបែងចែកធនធានទីផ្សារ។ ពីឆ្នាំ១៩៨០ ដល់ ២០០៩ ប្រាក់ចំណូលពន្ធ និងមិនមែនពន្ធរបស់រដ្ឋាភិបាល កើនជាមធ្យម ១៦,៦% ក្នុងមួយឆ្នាំ រីឯចំណាយមានអត្រាកំណើន ១៧,០% ក្នុងអំឡុងពេលជាមួយគ្នា។ អត្រាកំណើនឱនភាពថវិកាមានប្រមាណ ០,៤% ក្នុងមួយឆ្នាំ ដែលជាអត្រាមួយល្អសម្រាប់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច (China's NBS)។ ពីឆ្នាំ១៩៩០-២០០៩ ចំណាយរបស់រដ្ឋាភិបាលគិតជាភាគរយនៃ ផសស មានជាមធ្យម ១៤,៧% (ថ្លៃនៅទីផ្សារបច្ចុប្បន្ន) ហើយបានបែងចែកដល់សេវាកម្មសេដ្ឋកិច្ចជាច្រើន ដូចជា ការកសាងសេដ្ឋកិច្ច ការអភិវឌ្ឍសង្គម វប្បធម៌និងការអប់រំ ការការពារជាតិ និង ចំណាយរដ្ឋបាល។ ចាប់តាំងពីពេលធ្វើកំណែទម្រង់ ចំណាយលើការកសាងសេដ្ឋកិច្ច និង ចំណាយលើការអភិវឌ្ឍសង្គម វប្បធម៌និងការអប់រំ មានអាទិភាពខ្ពស់បំផុត ដោយតំណាងឲ្យជាមធ្យម ៤៤,៧% និង ២៤,០% នៃចំណាយសរុបរបស់រដ្ឋាភិបាលក្នុងមួយឆ្នាំៗ ធៀបនឹងចំណាយការពារប្រទេស (៩,៩%) និង ចំណាយរដ្ឋបាល (១២,៧% )។

ផ្ទុយទៅវិញ ចំណាយសាធារណៈនៅកម្ពុជា មានទំហំតូច គឺជាមធ្យមប្រមាណ ៦,៦% នៃ ផសស ក្នុងមួយឆ្នាំ (ថ្លៃនៅទីផ្សារបច្ចុប្បន្ន) ធៀបនឹង ៨៥,៥% សម្រាប់ចំណាយប្រើប្រាស់ឯកជន។ តួលេខនេះបង្ហាញថា ចំណាយប្រើប្រាស់ឯកជនមានកម្រិតខ្ពស់ និង រួមចំណែកយ៉ាងសំខាន់

នៅក្នុងកំណើនសេដ្ឋកិច្ច។ ទោះយ៉ាងនេះក្តី វិនិយោគឯកជន និងចំណាយប្រើប្រាស់សារធាណៈ នៅតែមានកម្រិតខ្សោយ។ ចំណាយទាបរបស់រដ្ឋាភិបាលនេះ បង្ហាញមួយផ្នែកពី កង្វះសមត្ថភាព របស់រដ្ឋាភិបាល និងកង្វះយន្តការមានប្រសិទ្ធភាព ដើម្បីប្រមូល និងប្រើប្រាស់ប្រាក់ចំណូល។ ម៉្យាងទៀត ក៏នៅមានវិស័យក្រៅផ្លូវការយ៉ាងធំមួយ ដែលមិនទាន់បានធ្វើឲ្យរៀបរយ (Guimbert 2010:6)។

ដូចមានបង្ហាញក្នុងរូបភាព៥រដ្ឋាភិបាលបានចំណាយថវិកាយ៉ាងច្រើនក្នុងចន្លោះឆ្នាំ១៩៩៤ និង ២០០៩ លើការការពារប្រទេស (៣៤,៨%) សេវាកម្មសាធារណៈទូទៅ (១៥,៤%) និង ចំណាយរបស់មន្ទីរក្រសួងរដ្ឋ និងចំណាយឥតព្រៀងទុក (១៦,៥%) ធៀបនឹងការអប់រំ ១៣,៥% សុខភាព ៧,៧% សេវាកម្មសេដ្ឋកិច្ច ៨,៦% និង សន្តិសុខនិងសុខុមាលភាពសង្គម ៣,៥%។ ទោះ បីមានរបៀបរបបនយោបាយបែបសង្គមនិយម និងមានគណបក្សតែមួយក្តី ប្រទេសចិនបានរីក ចម្រើនយ៉ាងខ្លាំង ផ្អែកតាមសូចនាករអភិបាលកិច្ចមួយចំនួន ដូចជា ការគ្រប់គ្រងលើអំពើពុករលួយ នីតិរដ្ឋ និងគុណភាពច្បាប់ បើធៀបនឹងប្រទេសកម្ពុជា។ ឧទាហរណ៍ ក្នុងឆ្នាំ២០០៩ ការគ្រប់គ្រង លើអំពើពុករលួយនៅចិន ទទួលបាន ៣៦,២ពិន្ទុ ចំណែកឯកម្ពុជាបាន ៨,៦ពិន្ទុ (រូបភាព ៦)។

រូបភាព ៥៖ ចំណាយរបស់រដ្ឋាភិបាលកម្ពុជាតាមមុខងារ




*ប្រភព៖ ADB 2010*

រូបភាព ៦៖ សូចនាករអភិបាលកិច្ចនៅប្រទេសចិន និងកម្ពុជា លំដាប់ថ្នាក់ជា % (0-១០០)




*ប្រភព៖ World bank 2010b*

*កំណត់សម្គាល់៖ លំដាប់ថ្នាក់ជា % ចំនួន ៦ បានយកមកប្រើក្នុងការបែងចែកចំណាត់ថ្នាក់៖ 0-១0 ១0-២៥ ២៥-៥0 ៥0-៧៥ ៧៥-៩0 ៩0-១00 (លេខជា %)*

## ២.២. បទពិសោធន៍រៀនសូត្របាន៖ យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ

តាំងពីចាប់ផ្តើមកំណែទម្រង់មក ចិនបានប្រឹងប្រែងយ៉ាងខ្លាំងក្លា និងមុតមាំ ដើម្បីសម្រាលភាពក្រីក្រ ជាពិសេសនៅតាមតំបន់ដែលអ្នកក្រ និងជនងាយរងគ្រោះរស់នៅ។ ក្របខ័ណ្ឌកាត់បន្ថយភាពក្រីក្រនៅចិន មាន ៤សមាសភាគ៖ កំណែទម្រង់រចនាសម្ព័ន្ធ ដើម្បីជំរុញការជួយសង្គ្រោះពីភាពក្រីក្រ (១៩៧៨-១៩៨៥) ការកាត់បន្ថយភាពក្រីក្រទ្រង់ទ្រាយធំផ្តោតលើការអភិវឌ្ឍ (១៩៨៦-១៩៩៣) គម្រោងកាត់បន្ថយភាពក្រីក្រ ៨/៧[៣] និង កម្មវិធីកាត់បន្ថយភាពក្រីក្រ (២000-២0១0) (see, for example, Wu & Cheng 2010; China's government 2006)។ ដំណាក់កាលទី១ មានភាពងាយយល់ដូចមានបង្ហាញតាមឈ្មោះនៃសមាសភាគនេះ ព្រោះចិនបានផ្តល់អាទិភាពលើការសម្រេចកំណើនសេដ្ឋកិច្ចខ្ពស់ និងប្រកបដោយនិរន្តរភាព តាមរយៈកំណែទម្រង់រចនាសម្ព័ន្ធ និងស្ថាប័នផ្សេងៗ ដោយចាប់ផ្តើមពីកំណែទម្រង់លើការគ្រប់គ្រងដីធ្លី និងប្រព័ន្ធធ្វើការសម្រេចចិត្ត ("ទំនួលខុសត្រូវគ្រួសារ" និង "ការលុបចោលសហគមន៍") ដើម្បីបង្កើនផលិតកម្មកសិកម្ម (Johnson 1990)។ ក្នុងដំណាក់កាលទី១ នេះ ពុំមានស្ថាប័នផ្នែកកាត់បន្ថយភាពក្រីក្រ សម្រាប់សម្របសម្រួលសកម្មភាពផ្សេងៗទេ។ ក្រុមដឹកនាំក្រុមប្រឹក្សារដ្ឋនៃការសម្រាលភាពក្រីក្រ និងអភិវឌ្ឍន៍ ដែលជាអង្គភាពមួយស្ថិតក្រោមក្រុមប្រឹក្សារដ្ឋ មានភារកិច្ចសម្របសម្រួលអង្កេត និងគម្រោងស្រាវជ្រាវនានា តាក់តែងសេចក្តីណែនាំ គោលនយោបាយ និងផែនការទាំងឡាយ សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចនៅតំបន់ក្រីក្រ សម្របសម្រួលការស្វែងរកដំណោះស្រាយបញ្ហាសំខាន់ៗក្នុងដំណើរការកាត់បន្ថយភាពក្រីក្រ និង គ្រប់គ្រងលើការងារសម្រាលភាពក្រីក្រ។

រដ្ឋាភិបាលកម្ពុជា អាចរៀនសូត្រពីបទពិសោធន៍កាត់បន្ថយភាពក្រីក្ររបស់ចិន តាមការរៀបចំឲ្យស្ថាប័នដែលមានស្រាប់ (បច្ចុប្បន្ន គឺ CARD) ឲ្យក្លាយជាស្ថាប័នឯកទេសជាតិមានភារកិច្ច

---

៣ (ផែនការជាតិអនុម័តនៅឆ្នាំ១៩៩៤ ដើម្បីកាត់បន្ថយភាពក្រីក្រកម្រិតខ្ពស់នៅចិន៖ ៨ មានន័យថា នៅឆ្នាំ១៩៩៤ នៅចិនមានប្រជាជនជនបទរស់នៅក្រោមបន្ទាត់ក្រីក្រកំណត់ដោយរដ្ឋាភិបាល ចំនួន ៨0លាននាក់ ហើយ ៧ មានន័យថា រដ្ឋាភិបាលត្រូវជួយ ៨0លាននាក់នេះ ឲ្យឡើងផុតបន្ទាត់ក្រីក្រក្នុងរយៈពេល ៧ឆ្នាំ)

សម្របសម្រួលកម្មវិធីកាត់បន្ថយភាពក្រីក្រផ្សេងៗ ជាមួយក្រសួងពាក់ព័ន្ធ និងអ្នកផ្តល់ជំនួយគ្រប់គ្នា ដើម្បីធានាឲ្យមានការគ្របដណ្តប់ពេញប្រទេស និងកុំឲ្យមានការគងគ្នា។ ដោយហេតុថាជនក្រីក្រមានដល់ ៣៤,៧% នៃប្រជាជនសរុប ហើយកសិកម្មនៅតែមានចំណែកដល់ ៣៩% នៃ ផសស និង ៧០,៣% នៃចំនួនការងារសរុប ក្នុងអំឡុងឆ្នាំ១៩៩៣-២០០៩ ក្តី (see World Bank 2006; CDRI 2011) កម្មវិធីកាត់បន្ថយភាពក្រីក្រអាចចាប់ផ្តើមពីសហគ្រាសជនបទខ្នាតតូច (ផ្លូវការ និងក្រៅផ្លូវការ) ដំណើរការដោយកសិករតាមមូលដ្ឋាននៅតំបន់ក្រីក្រ ដែលមានបច្ចេកទេស និង ជំនាញគ្រប់គ្រងកម្រិតទាប។ ការគាំទ្រហិរញ្ញវត្ថុ គួរតែបំពេញបន្ថែមដោយការបណ្តុះបណ្តាល បច្ចេកទេស និងជំនាញគ្រប់គ្រង (Wu & Cheng 2010)។ បទពិសោធន៍មួយទៀតបានពីកម្មវិធីកាត់បន្ថយភាពក្រីក្រនៅចិន គឺ ការចូលរួមជាលក្ខណៈវិមជ្ឈការពីសំណាក់មន្ត្រីនៅគ្រប់កម្រិត ហើយក្នុងនោះខេត្តជាតួអង្គចម្បងនៅក្នុងដំណើរការធ្វើផែនការ និងការបែងចែកធនធាន។

## ៣. សេចក្តីសន្និដ្ឋាន និងគោលនយោបាយពាក់ព័ន្ធ

ចិន និង កម្ពុជា បានធ្វើកំណែទម្រង់គោលនយោបាយ និងស្ថាប័នជាច្រើន ក្នុងកិច្ចប្រឹងប្រែងអភិវឌ្ឍសេដ្ឋកិច្ចជាបណ្តើរៗ និងប្រកបដោយនិរន្តរភាព។ ទោះបីមានបរិបទ និងអំណោយទានខាងសេដ្ឋកិច្ចខុសប្លែកគ្នាដែលត្រូវយកមកគិតគូរពិចារណាក្តី ក៏កម្ពុជា អាចពិនិត្យទៅលើបទពិសោធន៍អភិវឌ្ឍន៍របស់ចិនជាទូទៅ និងការកាត់បន្ថយភាពក្រីក្រជាពិសេស នៅក្នុងសេរីភាវូបនីយកម្ម និងការបើកទូលាយពាណិជ្ជកម្ម ឧស្សាហូបនីយកម្ម កសិកម្មនិងការអភិវឌ្ឍជនបទ និង តួនាទីរដ្ឋក្នុង "ការកំណត់ឲ្យសហគ្រាសរដ្ឋអនុវត្តតាមគោលការណ៍ទីផ្សារ" ជាជាង ការធ្វើឯកជនភាវូបនីយកម្មយ៉ាងគំហុក។ គំរូស្ថាប័នដឹកនាំដោយរដ្ឋាភិបាល ដែលបានចូលរួមយ៉ាងច្រើនក្នុងការកាត់បន្ថយភាពក្រីក្រនៅចិន (ឧទាហរណ៍ តាមរយៈគម្រោង និងកម្មវិធីផ្សេងៗ ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធជនបទ ផ្តល់ឥណទានខ្នាតតូច និងកសាងសមត្ថភាពរបស់អ្នកក្រឲ្យបង្កើនប្រាក់ចំណូល និងលើកកម្ពស់ជីវភាព) អាចឲ្យកម្ពុជាយកមកអនុវត្តបានភ្លាមៗ ដើម្បីពង្រឹងស្ថាប័នផ្នែកកាត់បន្ថយភាពក្រីក្ររបស់ខ្លួនថែមទៀត។

ការបន្តពង្រឹងកិច្ចសហប្រតិបត្តិការរវាងចិន និង កម្ពុជា មានសារៈសំខាន់ណាស់។ ជាមួយនឹងការបង្កើនជំនួយអភិវឌ្ឍន៍ផ្លូវការ (ODA) និង វិនិយោគផ្ទាល់ពីបរទេស (FDI) ចិនគួរផ្តល់នូវការផ្តួចផ្តើមគំនិត និងកម្មវិធីកាត់បន្ថយភាពក្រីក្រ ច្រើនថែមទៀតដល់កម្ពុជា តាមរយៈការបណ្តុះបណ្តាលបុគ្គលិកនិងមន្ត្រីរាជការដែលធ្វើការក្នុងស្ថាប័នកាត់បន្ថយភាពក្រីក្រ ការរួមសហការខាងស្រាវជ្រាវសំដៅផ្តល់ជាយុទ្ធសាស្ត្រនិងគម្រោងបន្ថែមសម្រាប់ការកាត់បន្ថយភាពក្រីក្រ និងកម្មវិធីផ្លាស់ប្តូរបទពិសោធន៍សម្រាប់មន្ត្រីរដ្ឋាភិបាល អ្នកបង្កើតគោលនយោបាយ និងអ្នកស្រាវជ្រាវនៃប្រទេសទាំងពីរ ដើម្បីរៀនសូត្រពីគ្នាទៅវិញទៅមក និងចែករំលែកចំណេះដឹង។ ចំណាយ ODA របស់ចិននាបច្ចុប្បន្ន លើការដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធ គួរតែបន្ត ហើយវិនិយោគិនចិន គួរតែពង្រីកការយកចិត្តទុកដាក់ទៅខាងកសិ-ពាណិជ្ជកម្ម។ ចិនក៏គួរពិចារណាផ្ទេរចំណេះធ្វើផ្នែកបច្ចេកទេស និងគ្រប់គ្រង មកដល់សមភាគីកម្ពុជា តាមរយៈការជួលជនកម្ពុជាឲ្យធ្វើការក្នុងមុខតំណែងថ្នាក់ខ្ពស់ និងកណ្តាល មិនមែនត្រឹមតែជាបុគ្គលិកសាមញ្ញនោះទេ។

## គន្ថនិទ្ទេស


Acemoglu, Daron (2005), "Politics and Economics in Weak and Strong States", *Journal of Monetary Economics*, 52 (7), pp. 1199-1226

Asian Development Bank (2011), "Asian Development Outlook: South-South Economic Links", (Manila: ADB)

Asian Development Bank (2010), "Key Indicators" (Manila: ADB)

Besley, Timothy & Torsten Persson (2010), "State Capacity, Conflict, and Development", *Econometrica*, 78 (1), pp. 1-34

Cambodia Development Resource Institute (forthcoming), *Poverty Dynamics Study: Evidence from Nine Villages in Cambodia, forthcoming* (Phnom Penh: CDRI)

China's National Bureau of Statistics (2010), *Statistical Yearbook* (China: Beijing)

China's National Bureau of Statistics (1996), *Statistical Yearbook* (China: Beijing)

Chinese Government's Official Web Portal (2006), *The Development-oriented Poverty Reduction Program for Rural China 2001* (Beijing: PRC Government)

Dollar, David (2007), *Poverty, Inequality, and Social Disparities during China's Economic Reform*, World Bank Policy Research Working Paper No. 4253 (Washington, DC: World Bank)

Dollar, David (2008), *Lessons from China for Africa*, World Bank Policy Research Working Paper No. 4531 (Washington, DC: World Bank)

Evans, Peter B. (2010), "Constructing the 21st Century Developmental State: Potentialities and Pitfalls", in Omano Edigheji (ed.), *Constructing a Democratic Developmental State in Africa: Potentials and Challenges* (Cape Town: HSRC Press)

Guimbert, Stephane (2010), *Cambodia 1998-2008: An Episode of Rapid Growth*, World Bank Policy Research Working Paper No. 5271, (Washington DC: World Bank)

International Labour Organisation (Sep 2010), *"Labour and Social Trends in Cambodia 2010"* (Phnom Penh: ILO)

Johnson, D. Gale (1990), "The People's Republic of China: 1978-1990", *International Centre for Economic Growth* (San Francisco, California: ICP Press)

Lin, Justin Yifu (1994), *China's Economic Reform: Pointers for other Economies in Transition?* World Bank Policy Research Working Paper No. 1310 (Washington DC: World Bank)

Maddison, Angus (2010), "Historical Statistics of the World Economy: 1–2008 AD" (Excel file), http://www.ggdc.net/MADDISON/Historical_Statistics/horizontalfile_02-2010.xls (accessed 28 October 2010)

Mauro, Paolo (1995), "Growth and Corruption", *Quarterly Journal of Economics*, 110 (3), pp.681-712

Ministry of Commerce of People's Republic of China (2010a), "China's Import of Trade in Services by Categories of Service: 1997-2009", http://english.mofcom.gov.cn/aarticle/statistic/ieindicators/201102/20110207396937.html (accessed June 2011)

Ministry of Commerce of People’s Republic of China (2010b), “China’s Export of Trade in Services by Categories of Service: 1997-2009”, http://english.mofcom.gov.cn/aarticle/statistic/ieindicators/201102/20110207402414.html (accessed June 2011)

Ministry of Planning (2010), *Achieving Cambodia’s Millennium Development Goals* (Phnom Penh: MOP)

Montalvo, Jose, G. & Martin Ravallion (2010), “The pattern of growth and poverty reduction in China”, *Journal of Comparative Economics*, 38, pp. 2-16

National Institute of Statistics (2008), *Statistical Yearbook 2008* (Phnom Penh: MOP)

National People’s Congress of the People’s Republic of China (2011), *“Resolution of the Standing Committee of the National People's Congress on Approving the Regulations on Special Economic Zones in Guangdong Province”*, http://www.npc.gov.cn/englishnpc/Law/2007-12/13/content_1384060.htm (accessed June 2011)

Natsuda, Kaoru, Kenta Goto & John Thoburn (2009), *“Challenges to the Cambodian Garment Industry in the Global Garment Value Chain”*, Working Paper, No. 09-3, Ritsumeikan Center for Asia Pacific Studies (RCAPS), Ritsumeikan Asia Pacific University, Japan

Ravallion, Martin (2009), “Are There Lessons for Africa from China’s Success Against Poverty?” *World Development*, 37 (2), pp. 303-313

Ravallion, Martin & Chen Shaohua (2007), “China’s (uneven) progress against poverty”, *Journal of Development Economics*, 82, pp. 1-42

RGC (2011), “National Social Protection Strategy 2011-2015”, draft (Phnom Penh: RGC)

RGC (2009), “National Strategic Development Plan Update 2009–2013” (Phnom Penh: RGC)

RGC (2008), “Rectangular Strategy for Growth, Employment, Equity and Efficiency Phase II” (Phnom Penh: RGC)

RGC (2005), “National Strategic Development Plan 2006–2010” (Phnom Penh: RGC)

RGC (2003), “The Cambodia Millennium Development Goals” (Phnom Penh: RGC)

RGC (2002), “National Poverty Reduction Strategy 2003-2005”, (Phnom Penh: RGC)

Tiffin, Richard & Xavier Irz (2006), “Is agriculture the engine for growth?” *Agricultural Economics*, 35, pp. 79-89

Tong Kimsun & Hem Socheth (2010), “Chinese Investment in Cambodia”, *Annual Development Review* (Phnom Penh: CDRI) pp. 179-198

United Nations Development Programme (2006), “SWOT Analysis of the Cambodian Economy”, UNDP Discussion Paper No. 1 (Phnom Penh: UNDP)

United Nations Development Programme (2010), “The Real Wealth of Nations: Pathways to Human Development”, Human Development Report (New York: UNDP)

Winter, L. Alan, Neil McCulloch & Andrew McKay (2004), “Trade Liberalization and Poverty: The Evidence so Far”, *Journal of Economic Literature*, vol. 42, no. 1, pp. 72-115

World Bank (2011a), World Bank Open Data, http://databank.worldbank.org/ddp/home.do?Step=2&id=4&DisplayAggregation=N&Sdmxupported=Y&CNO=2&SET_BRANDING=YES (accessed May 2011)

World Bank (2011b), World Development Indicators (Washington, DC: World Bank)

World Bank (2010a), "Doing Business 2011: Making a difference for entrepreneurs", http://www.doingbusiness.org/reports/global-reports/doing-business-2011 (accessed May 2011)

World Bank (2010b), "Worldwide Governance Indicators", http://info.worldbank.org/governance/wgi/index.asp (accessed June 2011)

World Bank (2009), "Poverty Profile and Trend in Cambodia: Findings from the 2007 CSES" (Phnom Penh: World Bank)

World Bank (2007), World Bank Enterprises Survey, https://www.enterprisesurveys.org/Portal/elibrary.aspx?libid=14 (accessed May 2011)

World Bank (2006), *"Halving Poverty by 2015? Cambodia Poverty Assessment 2006"*, Report 35213-KH (Phnom Penh: World Bank)

Wu, Zhong & Cheng Enjiang (2010), "Poverty Alleviation in the People's Republic of China: The Implications for Sino—African Cooperation in Poverty Reduction", *African Development Review*, Vol. 22, No. S1, pp. 629-643

Yao, Shujie (2000), "Economic Development and Poverty Reduction in China over 20 Years of Reforms", *Economic Development and Cultural Change*, 48 (3), pp. 447-474

# ផ្នែកទី ២
# ធនធានធម្មជាតិ និងបរិស្ថាន

# -៣-
# និន្នាការដំណាំកសិកម្មក្នុងតំបន់អេក្វូឡូស៊ីផ្សេងៗ និងបម្រែបម្រួលអាកាសធាតុនៅកម្ពុជា

*ដោយលោក រស់ បានសុខ លោក ណាំង ភិរុណ និងលោក ឈឹម ឈុន*[១]

## ១. សេចក្តីផ្តើម

វិស័យកសិកម្មកម្ពុជា ពិសេសដំណាំស្រូវ បានរីកលូតលាស់ផលិតកម្មគួរឲ្យកត់សម្គាល់ក្នុងប៉ុន្មានឆ្នាំនេះ ដោយបានចូលរួមចំណែកដល់សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ។ ដំណាំចម្បងៗផ្សេងទៀត ដូចជា ពោត ដំឡូងឈើ សណ្តែកសៀង សណ្តែកដី និងកៅស៊ូ ក៏ជាប្រភពចំណូលសំខាន់សម្រាប់លើកស្ទួយជីវភាពដែរ។ ជារួម ភាពក្រីក្រនៅកម្ពុជាបានថយចុះពី ៣៤,៨% នៅឆ្នាំ២០០៤ មកត្រឹម ៣០,១% នៅឆ្នាំ២០០៧ (World Bank 2009: 27)។ វិស័យកសិកម្មបន្តចូលរួមចំណែកយ៉ាងសំខាន់ដល់ការរីកលូតលាស់សេដ្ឋកិច្ច និងផ្តល់ការងារដល់ជាង ៦៧% នៃកម្លាំងពលកម្មនៅទូទាំងប្រទេស។

ផ្ទៃដីដាំស្រូវបានកើនពីជិត ១,៥លានហិកតាក្នុងឆ្នាំ១៩៨០ ដល់ ២,៧៩លានហិកតាក្នុងឆ្នាំ២០១០ ហើយផលស្រូវបានកើនឡើងពីជិត ២លានតោន ដល់ ៨,២៥លានតោន (MAFF 2011a)។ ទោះបីការប្រើប្រាស់ជី និងសម្ភារៈកសិកម្មទំនើបៗ ដូចជា ត្រាក់ទ័រ គោយន្ត និងម៉ាស៊ីនច្រូត បានកើនឡើងជាបណ្តើរៗក៏ដោយ ក៏បច្ចេកទេសកសិកម្ម និងពូជស្រូវបែបបុរាណនៅតែមានប្រើប្រាស់យ៉ាងទូលំទូលាយ។

ស្រូវគេដាំដុះភាគច្រើនសម្រាប់ដោះស្រាយការប្រើប្រាស់ក្នុងស្រុក និងតម្រូវការទីផ្សារ។ ផលិតកម្មស្រូវប្រចាំឆ្នាំ កើនឡើងដោយសារការពង្រីកផ្ទៃដីដាំដុះ ជាជាងការកែលម្អផលិតភាព។ ទោះបីស្រូវប្រាំងទទួលបានទិន្នផលខ្ពស់ជាងស្រូវវស្សាក៏ដោយ ក៏ជាទូទៅ ត្រូវពឹងទៅលើទឹកពីប្រព័ន្ធធារាសាស្ត្រ ហើយមានចំណែកតែ ១៤% នៃផ្ទៃដីដាំដុះស្រូវសរុបប៉ុណ្ណោះ។ ទិន្នផលជាមធ្យមក្នុងឆ្នាំ២០១០ គឺ ២,៧៦តោនក្នុងមួយហិកតាសម្រាប់ស្រូវវស្សា និង ៤,២តោនក្នុងមួយហិកតាសម្រាប់ស្រូវប្រាំង (MAFF 2011a)។

បន្ទាប់ពីដំណាំស្រូវ ត្រីជាស្បៀងសំខាន់លំដាប់ទី២ ដែលផ្តល់ជីវជាតិប្រូតេអ៊ីនក្នុងអាហារ ៧៥%។ ប៉ុន្តែនាបច្ចុប្បន្ន ការរេចរឹលតំបន់ដីសើម និងជម្រកមច្ឆជាតិ គួបផ្សំនឹងការអភិវឌ្ឍនានា ដូចជា ទំនប់វារីអគ្គិសនី ហើយនិងឥទ្ធិពលបម្រែបម្រួលអាកាសធាតុ ទំនងក្លាយជាឧបសគ្គដល់ការគ្រប់គ្រងធនធានជលផលប្រកបដោយនិរន្តរភាព និងបណ្តាលឲ្យថយចុះទិន្នផលត្រីទៀតផង។ ដូចគ្នាដែរ ព្រៃឈើមានសារៈសំខាន់ក្នុងការទ្រទ្រង់ជីវភាពរស់នៅ និងបរិស្ថាន ក៏ប៉ុន្តែធនធានទាំងនេះលែងផ្តល់ប្រយោជន៍បានច្រើន ដូចកាលពីមុនទៀតហើយ។ ការពង្រីកដីកសិកម្ម បានបង្រួមដីព្រៃបន្តិចម្តងៗ ធ្វើឲ្យមានសម្ពាធកាន់តែធ្ងន់ធ្ងរឡើងទៅលើប្រព័ន្ធអេកូឡូស៊ីព្រៃឈើ និងជីវភាពរស់នៅ។ បម្រែបម្រួលអាកាសធាតុ អាចបង្កឲ្យមានការហូរច្រោះដីស្រទាប់លើ ដែលប៉ះពាល់មិនល្អដល់ទិន្នផលដំណាំកសិកម្ម។

---

១ លោក រស់ បានសុខ និងលោក ណាំង ភិរុណ ជាអ្នកស្រាវជ្រាវ ហើយលោក ឈឹម ឈុន ជាជំនួយការកម្មវិធី នៅវិទ្យាស្ថាន CDRI។

កំណើនរបបទឹកភ្លៀងមិនទៀងទាត់ គួបផ្សំជាមួយបម្រែបម្រួលអាកាសធាតុ វាជះឥទ្ធិពលអាក្រក់ទៅលើផលិតកម្មកសិកម្ម។ កំណើនភាពញឹកញាប់នៃគ្រោះរាំងស្ងួត និងទឹកជំនន់ ក្នុងបីទសវត្សរ៍កន្លងមកនេះ បានបំផ្លាញដំណាំស្រូវរាប់សិបម៉ឺនហិកតា។ កង្វះខាតទឹក បណ្ដាលឲ្យមានទំនាស់ពិបាកដោះស្រាយក្នុងចំណោមកសិករ (Nang *et al.* 2011: 37-39)។ ការប្រែប្រួលពិបាកព្យាករណ៍បាននូវលក្ខណៈអាកាសធាតុ វាមានផលប៉ះពាល់អាក្រក់ដល់ផលិតកម្មស្រូវ។ ការបាត់បង់ព្រៃឈើ ធ្វើឲ្យមានគ្រោះរាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះ កាន់តែធ្ងន់ធ្ងរឡើង ដែលអាចបង្កមហន្តរាយដល់អាយុជីវិត ទ្រព្យសម្បត្តិ និងផលដំណាំ។

ឯកសារនេះផ្ដោតលើបម្រែបម្រួលអាកាសធាតុ និងការអភិវឌ្ឍកសិកម្មនៅកម្ពុជា តាមរយៈការប្រមូលព័ត៌មានដែលមានស្រាប់ អង្កេតជាក់ស្ដែង ការពិភាក្សានៅតាមតំបន់អេកូឡូស៊ីនៃដំណាំកសិកម្ម និងការពិគ្រោះយោបល់ក្នុងសិក្ខាសាលា។ ឯកសារក៏បានពិចារណាលើលទ្ធផលរកឃើញ ដើម្បីផ្ដល់ព័ត៌មានដល់កិច្ចប្រឹងប្រែងអភិវឌ្ឍកសិកម្មថ្នាក់ជាតិ ដូចជា អំពីផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ និងការកំណត់ដំណោះស្រាយនៅក្នុងគោលនយោបាយរដ្ឋាភិបាល ស្ដីពីការបន្សាំបម្រែបម្រួលអាកាសធាតុថ្នាក់ជាតិ។

## ២. គោលបំណងស្រាវជ្រាវ និងវិធីសាស្ត្រ

គោលបំណងសំខាន់ៗក្នុងការសិក្សាមានដូចតទៅ៖

- ប្រមូលផ្ដុំព័ត៌មាន តាមការពិនិត្យស៊ីជម្រៅទៅលើឯកសារនានា ដើម្បីឆ្លុះបញ្ចាំងពីទំហំនៃកិច្ចប្រឹងប្រែងអភិវឌ្ឍកសិកម្មនៅកម្ពុជា សំដៅបង្កើនសន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្រ។
- កំណត់បញ្ហាផុសចេញពីបម្រែបម្រួលអាកាសធាតុ តាមការពិនិត្យទៅលើតំបន់អេកូឡូស៊ីនៃដំណាំកសិកម្មទាំងបួន គឺមានតំបន់ទន្លេសាប តំបន់ទន្លេមេគង្គ តំបន់ខ្ពង់រាប/ភ្នំ និងតំបន់ឆ្នេរសមុទ្រ ។

ការសិក្សាផ្ដោតជាពិសេសលើការវិភាគព័ត៌មាន និងបំផុសការយល់ដឹងស៊ីជម្រៅអំពីទំហំនៃការប្រឹងប្រែងអភិវឌ្ឍកសិកម្មនាពេលបច្ចុប្បន្ន ក្នុងបរិបទនៃបម្រែបម្រួលអាកាសធាតុ សំដៅលើកកម្ពស់សន្តិសុខស្បៀង និងកាត់បន្ថយភាពក្រីក្រ ហើយជួយផ្ដល់ជាយោបល់ដល់យុទ្ធសាស្ត្របន្សាំ នៅក្នុងគោលនយោបាយអភិវឌ្ឍកសិកម្ម។

ការសិក្សានេះផ្ដោតលើប្រធានបទបម្រែបម្រួលអាកាសធាតុ និងកសិកម្ម ដើម្បីបានយល់ដឹងស៊ីជម្រៅពីស្ថានភាពក្នុងតំបន់អេកូឡូស៊ីផ្សេងៗនៃដំណាំកសិកម្ម។ ការសិក្សាបានកំណត់ជាគោលរឿងមួយចំនួន មានជាអាទិ៍ ដំណាំចម្បងៗ ធនធានជលផល ព្រៃឈើ ការប្រើប្រាស់ដី បម្រែបម្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ដោយរំពឹងថា អាចផ្ដល់នូវព័ត៌មានសម្រាប់ការវិភាគពីកំណើនផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុទៅលើការអភិវឌ្ឍកសិកម្ម។ ទីតាំងសិក្សាមានទាំងអស់ ១៥កន្លែងដែលបានជ្រើសរើស នៅក្នុងតំបន់អេកូឡូស៊ីទាំងបួននៃដំណាំកសិកម្ម (តារាង ១)។

តារាង ១៖ ទីតាំងសិក្សាបែងចែកតាមតំបន់អេកូឡូស៊ីនៃដំណាំកសិកម្ម

| ល.រ | តំបន់អេកូឡូស៊ីនៃដំណាំកសិកម្ម | | ទីតាំងសិក្សា | | | គោលរឿងស្រាវជ្រាវ |
|---|---|---|---|---|---|---|
| | តំបន់ | ចំនួននៃការពិភាក្សា | ខេត្ត | ស្រុក | ឃុំ | |
| ១ | តំបន់ឆ្នេរ | ២ | ព្រះសីហនុ<br>កោះកុង | ព្រៃនប់<br>ស្រែអំបិល | សាមគ្គី<br>ជីខក្រោម | ជលផលសមុទ្រ កសិកម្ម ការជ្រៀតចូលទឹកប្រៃ ការប្រើប្រាស់ដី គ្រោះធម្មជាតិ ជីវភាពរស់នៅ ឥណទាន និង ហេដ្ឋារចនាសម្ព័ន្ធ |
| ២ | ទន្លេសាប | ៦ | កំពង់ឆ្នាំង<br>កំពង់ធំ<br>ពោធិសាត់<br>ពោធិសាត់<br>បាត់ដំបង<br>សៀមរាប | ទឹកផុស<br>សន្ទុក<br>សំពៅមាស<br>បាកាន<br>បាណន់<br>សូត្រនិគម | ទួលខ្ពស់<br>ក្រយា<br>លលកស<br>ស្វាយដូនកែវ<br>តាគ្រាម<br>កំពង់ឃ្លាំង | ជលផល កសិកម្ម ព្រៃឈើ ការប្រើប្រាស់ដី ធារាសាស្ត្រ បញ្ហាទាក់ទងនឹងអាកាសធាតុ ជីវភាព ឥណទាន និង ហេដ្ឋារចនាសម្ព័ន្ធ |
| ៣ | ទន្លេមេគង្គ | ៤ | ព្រៃវែង<br>កំពង់ចាម<br>តាកែវ<br>ក្រចេះ | ពាមរ៍<br>ស្ទឹងត្រង់<br>គិរីវង្ស<br>ឆ្លូង | ពាមរ៍<br>អូរម្លូ<br>ភ្នំដិន<br>កញ្ជោ | កសិកម្ម ធារាសាស្ត្រ ព្រៃឈើ ការប្រើប្រាស់ដី ជលផល បញ្ហាទាក់ទងនឹងអាកាសធាតុ ទីផ្សារ ឥណទាន ជីវភាព |
| ៤ | ខ្ពង់រាប/ភ្នំ | ៣ | ស្ទឹងត្រែង<br>រតនគិរី<br>មណ្ឌលគិរី | សេសាន<br>អូរជុំ<br>ពេជ្រចិន្តា | ស្រែគរ<br>អូរជុំ<br>ពូជ្រៃ | កសិកម្ម ព្រៃឈើ ការប្រើប្រាស់ដី បញ្ហាទាក់ទងនឹងអាកាសធាតុ ទីផ្សារ ឥណទាន និង ហេដ្ឋារចនាសម្ព័ន្ធ |

វិធីសាស្ត្រសិក្សា រួមមានការប្រមូលទិន្នន័យមានស្រាប់ ការពិភាក្សាជាមួយកសិករនៅតាមតំបន់គោលដៅចំនួន ១៥ទីតាំង ការពិគ្រោះយោបល់ក្នុងសិក្ខាសាលាចំនួនពីរលើក ជាមួយអ្នកពាក់ព័ន្ធនានានៅកម្រិតការងារបច្ចេកទេស និងការបង្កើតគោលនយោបាយ ដើម្បីវាយតម្លៃពីធនធានចំណេះដឹង និងបទពិសោធន៍របស់កសិករទាក់ទងនឹងបម្រែបម្រួលអាកាសធាតុ និងការអភិវឌ្ឍកសិកម្ម។

ការសិក្សានេះក៏ផ្ដោតផងដែរលើការផ្ដល់អនុសាសន៍ពីឥទ្ធិពលនៃគោលនយោបាយទៅលើស្ថានភាពបច្ចេកវិទ្យាកសិកម្មនៅកម្ពុជានាបច្ចុប្បន្ន ដើម្បីលើកស្ទួយផលិតកម្ម និងធានាសន្តិសុខស្បៀង។ ដើម្បីស្វែងយល់ថែមទៀតពីស្ថានភាពកសិកម្ម និងបម្រែបម្រួលអាកាសធាតុនៅកម្ពុជា ក្រុមស្រាវជ្រាវទទួលបានឯកសារជាច្រើន ដោយផ្ដោតពិសេសទៅលើគោលនយោបាយពាក់ព័ន្ធផ្នែកកសិកម្ម និងបម្រែបម្រួលអាកាសធាតុ។

## ៣. ការអភិវឌ្ឍកសិកម្មនាបច្ចុប្បន្ន

កម្ពុជាជាប្រទេសកសិកម្ម ដែលមានប្រជាជន ប្រហែល ៨០% មានប្រពៃណីពឹងទៅលើកសិកម្មដំណាំស្រូវជាសំខាន់។ គោលនយោបាយរួមលើវិស័យកសិកម្ម មានគោលដៅ "ធានាសន្តិសុខស្បៀង បង្កើនចំណូលគ្រួសារ បង្កើតឱកាសការងារ តាមរយៈការកែលម្អផលិតកម្ម

និងពិពិធកម្មដំណាំ និងពាណិជ្ជកម្ម ព្រមទាំងការការពារធនធានធម្មជាតិ និងបរិស្ថាន ដើម្បីសម្រេចបានការអភិវឌ្ឍប្រកបដោយនិរន្តរភាព" (MAFF 2011a:9)។ មានការទទួលស្គាល់ថា ការអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ជាធាតុចូល (ទុន) យ៉ាងសំខាន់ សម្រាប់ជួយលើកស្ទួយផលិតកម្មស្រូវ ហើយរដ្ឋាភិបាលបាននឹងកំពុងប្រឹងប្រែងថែមទៀត ដើម្បីជំរុញការអភិវឌ្ឍវិស័យធនធានទឹកនេះ។

សកម្មភាពកសិកម្មចម្បងៗ រួមមានដំណាំស្រូវវស្សា ដំណាំកៅស៊ូ ដំឡូងឈើ ពោត សណ្តែកសៀង និងដំណាំផ្សេងៗទៀត។ ការពិភាក្សាជាបន្តបន្ទាប់ពីកសិកម្មនៅកម្ពុជា ផ្តោតទៅលើផ្នែកជាច្រើន ដូចជា ស្រូវ កៅស៊ូ ការប្រើជី ផ្នែកជលផល និងព្រៃឈើ។ ការពាក់ព័ន្ធជាមួយនឹងបម្រែបម្រួលអាកាសធាតុ ក៏បានយកមកគិតគូរផងដែរ ដើម្បីពិភាក្សាពីផលវិបាកចម្បងៗ ហើយលើកជាអនុសាសន៍ និងផ្តល់ព័ត៌មាន ដល់ការកសាងគោលនយោបាយទៅអនាគត។

## *៣.១. ដំណាំស្រូវ*

ផ្ទៃដីដំណាំស្រូវសរុបក្នុងឆ្នាំ២០១០ មាន ២.៧៩៥.៨៩២ហិកតា (MAFF 2011a)។ ទោះបីមានគ្រោះទឹកជំនន់ ក្នុងឆ្នាំ១៩៨៤ ១៩៩៦ ២០០០ និង ២០០១[២] និងគ្រោះរាំងស្ងួតក្នុងឆ្នាំ១៩៨៣ ១៩៩១ ១៩៩៤ ១៩៩៧ ១៩៩៨ និង ២០០៤ ដែលបានបំផ្លាញផលដំណាំអស់រាប់សិបម៉ឺនហិកតាក៏ដោយ ក៏ដំណាំស្រូវបានកើនរៀងរាល់ឆ្នាំ ទាំងផ្ទៃដីដាំដុះ ផ្ទៃដីប្រមូលផល និងផលស្រូវប្រចាំឆ្នាំ ចាប់តាំងពីឆ្នាំ១៩៨០ រៀងមក។ ការប្រមូលផ្តុំផលប៉ះពាល់នៃគ្រោះទឹកជំនន់ គ្រោះរាំងស្ងួត បម្រែបម្រួលអាកាសធាតុ និងគ្រោះធម្មជាតិដទៃទៀត ទំនងជានឹងបង្កផលវិបាកដល់ផលិតកម្មស្រូវប្រចាំឆ្នាំ ក៏ដូចជាផលដំណាំផ្សេងៗដែរ។

រូបភាព ១៖ ដំណាំស្រូវ ពីឆ្នាំ១៩៨០-២០១០




*ប្រភព៖ MAFF 2010a, 2011a; NIS 2008*

រូបភាព ២៖ ដំណាំស្រូវប្រាំង ពីឆ្នាំ១៩៨០-២០១០




*ប្រភព៖ MAFF 2010a, 2011a; NIS 2008*

កង្វះខាតទឹកសម្រាប់ស្រែប្រាំងជាឧបសគ្គចម្បងមួយ ដែលបង្កជាជម្លោះរឿយៗក្នុងចំណោមកសិករ (CDRI 2010a, 2010b, 2010c)។ ការបែងចែកទឹកមិនគ្រប់គ្រាន់ពីប្រព័ន្ធធារាសាស្ត្រ នៅក្នុងពេលមានការរាំងស្ងួត បានបង្កឧបសគ្គដល់ការធ្វើប្រពលវប្បកម្មដំណាំស្រូវ

---

២ សូមមើលរូបភាព ៨ ទាក់ទងនឹងគ្រោះទឹកជំនន់ និងរូបភាព ៩ ទាក់ទងនឹងគ្រោះរាំងស្ងួត

(រូបភាព ២)។ នាបច្ចុប្បន្ន ការធ្វើស្រែប្រាំងចូលរួមចំណែកបានត្រឹម ១៤% នៃដំណាំស្រូវសរុបប៉ុណ្ណោះ ទោះបីវាមានទិន្នផលខ្ពស់ជាងស្រូវវស្សាក្តី។ ទិន្នផលស្រូវក្នុងឆ្នាំ២០១០ មានជាមធ្យម ២,៧៦តោនក្នុងមួយហិកតាស្រូវវស្សា និង ៤,២តោនក្នុងមួយហិកតាស្រូវប្រាំង (MAFF 2011a)។ ការធ្វើកសិកម្មបែបបុរាណដោយពឹងអាស្រ័យលើទឹកភ្លៀង ធ្វើឲ្យកសិករភាគច្រើនធ្វើស្រែបានតែម្តងក្នុងមួយឆ្នាំ។

## ៣.២. ដំណាំផ្សេងៗ

ផលដំណាំផ្សេងៗ ដូចជា ដំឡូងឈើ ពោត សណ្តែកសៀង ដំឡូងផ្វា និងអំពៅ បានកើនឡើងតិចតួច ហើយត្រូវពឹងអាស្រ័យទៅលើតម្រូវការទីផ្សារ។ ផ្ទៃដីដាំ ពោត សណ្តែកសៀង និងដំឡូងឈើ បានកើនឡើងគួរឲ្យកត់សម្គាល់ក្នុងទសវត្សរ៍កន្លងទៅនេះ ប៉ុន្តែសម្រាប់ដំណាំដំឡូងឈើ និងសណ្តែកសៀង វាបានថយចុះ ក្នុង ២-៣ឆ្នាំចុងក្រោយ ដោយសារតម្រូវការទីផ្សារធ្លាក់ចុះ (រូបភាព ៣)។ ការពង្រីកផ្ទៃដីដាំដុះជួយឲ្យផលិតផលកើនឡើង ប៉ុន្តែកត្តាសំខាន់ៗជាងគេដែលប៉ះពាល់ដល់ផលិតផលទាំងនេះ គឺតម្រូវការទីផ្សារ និងគ្រោះធម្មជាតិ។ កត្តាសំខាន់ឯទៀត ដែលប៉ះពាល់ដល់ផលិតផល គឺភាពមិនអាចទុកចិត្តពីកត្តាអាកាសធាតុ ពិសេសរបាយទឹកភ្លៀងមិនគ្រប់គ្រាន់។ កំណើនភាពមិនទៀងទាត់នៃរបបទឹកភ្លៀង គួបផ្សំជាមួយនឹងគ្រោះធម្មជាតិនានា (ដូចជា គ្រោះរាំងស្ងួត ទឹកជំនន់ និងខ្យល់ព្យុះ) អាចបង្កផលប៉ះពាល់អាក្រក់ដល់ដំណាំនានា (ឧ. ទឹកជំនន់នៃខ្យល់ព្យុះកេតសាណាក្នុងឆ្នាំ២០០៩ បានបង្កការខូចខាតយ៉ាងដំណំដល់ដំណាំនានា)។ គ្រោះរាំងស្ងួត ទឹកជំនន់ ឬក៏ខ្យល់ព្យុះ វាប៉ះពាល់ដល់ដំណាំកសិកម្មក្នុងកម្រិតផ្សេងៗពីគ្នា។

រូបភាព ៣៖ ផលិតកម្មដំណាំផ្សេងៗប្រចាំឆ្នាំ ពីឆ្នាំ១៩៨០-២០១០




*ប្រភព៖ MAFF 2010a, 2011a; NIS 2008*

ដំណាំនានាត្រូវតែផ្សារភ្ជាប់ទៅនឹងទីផ្សារ ដែលជាកម្លាំងជំរុញមួយដ៏សំខាន់។ ផលិតកម្មនៃមុខដំណាំនីមួយៗ ត្រូវពឹងអាស្រ័យជាសំខាន់ទៅលើតម្រូវការទីផ្សារ ដែលធ្វើឲ្យថ្លៃរបស់វាឡើងចុះមិនទៀងទាត់ ពោលគឺនៅពេលផលដំណាំមួយឡើងថ្លៃ ផលដំណាំឯទៀតក៏អាចទៅជាចុះថ្លៃ។

ជាឧទាហរណ៍ ការពង្រីកផ្ទៃដីដាំដំឡូងឈើ ដោយសារកសិករប្តូរទៅដាំដំណាំដំឡូងឈើតែមួយមុខ ធ្វើឲ្យផលិតកម្មដំណាំឯទៀតថយចុះ។ ដោយសារផលិតកម្ម និងការផ្គត់ផ្គង់ផលដំណាំឯទៀតមានកម្រិត វាក៏ឡើងថ្លៃខ្ពស់ជាងធម្មតា។ ថ្លៃផលដំណាំ អាចឈ្មួញកណ្តាលបំប៉ោងវាឡើងជារឿយៗក្នុងអំឡុងពេលដាំដុះ ប៉ុន្តែថ្លៃដែលកសិករលក់បានជាក់ស្តែងនៅពេលប្រមូលផលវាទាបជាងនោះទេ។ ដូច្នេះ គួរគិតគូរប្រឹងប្រែងជំរុញពិពិធកម្មដំណាំ និងកំណត់ឲ្យសន្តិសុខស្បៀងមានអាទិភាពខ្ពស់ជាងដំណាំសម្រាប់បម្រើផ្នែកពាណិជ្ជកម្ម និងថាមពលឥន្ធនៈ។

### ៣.៣. ដំណាំកៅស៊ូ

ដំណាំកៅស៊ូភាគច្រើន ដាំនៅតំបន់ខ្ពង់រាប ភាគឦសាន្ត ដែលមានដីក្រហមសម្បូរជីវជាតិ។ ចំការកៅស៊ូភាគច្រើនគ្រប់គ្រងដោយក្រុមហ៊ុនឯកជន ឬក៏គ្រប់គ្រងជាលក្ខណៈគ្រួសារ។ កសិករភាគច្រើន ដាំដំណាំផ្សេងៗនៅចន្លោះដើមកៅស៊ូ (ដូចជា សណ្តែកផ្សេងៗ ដំឡូងឈើ និងពោត) រហូតដល់ពេលកៅស៊ូផ្តល់ជ័រ (ដើមកៅស៊ូអាចផ្តល់ជ័រ ក្រោយពេលដាំបាន ៤ឆ្នាំ)។ ផ្ទៃដីដាំកៅស៊ូ កើនឡើងយ៉ាងឆាប់រហ័ស ក្នុង ពីរបីឆ្នាំកន្លងមកនេះ។ ចំការកៅស៊ូថ្មីក្នុងឆ្នាំ២០១០ មានដល់ ១៤៣.០២៨ហិកតា ហើយផ្ទៃដីដាំដុះសរុបមានដល់ ១៨១.៤៣៣ហិកតា (MAFF 2011a)។ ការនាំចេញកៅស៊ូក្នុងឆ្នាំ២០១០ កើនដល់ ៤២.០០០តោន ឯកាលពីឆ្នាំ២០០៦ មានត្រឹម ៣១.១៨៤តោន (MAFF 2011a) ប៉ុណ្ណោះ។ គេរំពឹងថា ផលិតផលកៅស៊ូនឹងកើនឡើងមួយជាពីរ ឬជាបី ក្នុងពីរបីឆ្នាំខាងមុខនេះ នៅពេលដើមកៅស៊ូដាំថ្មីអាចផ្តល់ជ័រ ហើយនឹងបង្កើតការងារបានច្រើន ប៉ុន្តែតម្លៃពលកម្ម នៅតែជាឧបសគ្គចម្បងក្នុងការងារនេះ។ ដីសម្បទានសេដ្ឋកិច្ច[៣] ភាគច្រើន គឺសម្រាប់ដំណាំកៅស៊ូ ហើយវាបង្កើតជាក្តីកង្វល់អំពីការថយចុះទំហំដីព្រៃ។ ការប្រែក្លាយបែបនេះ ចូលរួមចំណែកបង្កការហូរបាក់ដី និងការហូរច្រោះដីស្រទាប់លើ ដែលអាចធ្វើឲ្យដីខ្សោះជីវជាតិ។ ឯកសារនានាបានប៉ាន់ស្មានថា ការបាត់បង់ ឬប្រែក្លាយដីព្រៃ នឹងបង្កើនការសាយភាយឧស្ម័នកាបូនិក[៤] (Greenpeace, 2012)។

### ៣.៤. សត្វពាហនៈ

គ្រួសារភាគច្រើនទទួលអត្ថប្រយោជន៍ពីការចិញ្ចឹមសត្វពាហនៈ ដែលបានក្លាយជាប្រភពប្រាក់ចំណូល និងជីវភាពរស់នៅ (រូបភាព ៤)។ កសិករដែលចូលរួមក្នុងការពិភាក្សាបានលើកថាពួកគាត់បានលក់គោក្របី ដើម្បីទិញគោយន្ត។ សត្វពាហនៈមួយក្បាល អាចលក់បានពី ២៥០ដុល្លារទៅ ៣៥០ដុល្លារ។ សត្វពាហនៈ និងមាន់ទា ជាប្រភពចំណូលមួយដ៏សំខាន់។ ការចិញ្ចឹមមាន់ទា មានប្រមាណ ១៥លានក្បាល ក្នុងមួយឆ្នាំៗ កាលពីឆ្នាំ២០០០ រហូតដល់ឆ្នាំ២០០៨ (NIS, 2008 & MAFF, 2010a, 2011a)។ ការផ្ទុះជំងឺគ្រុនផ្តាសាយបក្សីក្នុងឆ្នាំ២០០៤ បានធ្វើឲ្យការចិញ្ចឹមមាន់ទាថយចុះ ប៉ុន្តែវាបានងើបឡើងវិញដល់ ២៩លានក្បាលក្នុងឆ្នាំ២០០៩ ហើយបានថយចុះមកត្រឹម ២១លានក្បាលវិញក្នុងឆ្នាំ២០១០។

បញ្ហាចម្បងចំពោះសត្វពាហនៈ គឺ កង្វះការត្រួតពិនិត្យជំងឺឆ្លង អត្រាស្លាប់ខ្ពស់ ចំណីខ្វះ

៣ សូមមើលព័ត៌មានបន្ថែម នៅក្នុងសៀវភៅ Ros Bansok *et al.* 2011: 67

៤ Wikipedia (2012), 'Climate Change Mitigation', http://wikipedia.org/wiki/Climate_change_mitigation #Reforestation_and_avoided_deforestation (accessed 25 January 2012)

ជីវជាតិ សត្វមាឌតូចដោយសារកង្វះបច្ចេកទេសបង្កាត់ពូជ សេវាកម្មពេទ្យនៅមានកម្រិត និង កង្វះវ៉ាក់សាំង (ADB 2008)។

រូបភាព ៤៖ សត្វពាហនៈ ឆ្នាំ១៩៨០-២០១០ (ពាន់ក្បាល)




*ប្រភព៖ MAFF 2010a, 2011a; NIS 2008*

រូបភាព ៥៖ ការនាំចូលជី ឆ្នាំ១៩៩៨-២០០៨ (តោន)




*ប្រភព៖ MoE 2010*

## ៣.៥. ការប្រើប្រាស់ជី

ការប្រើប្រាស់ជីនៅកម្ពុជា នៅមានកម្រិតទាបជាងប្រទេសជិតខាង (ADB 2008) ទោះបីជាវាបានកើនពី ៨០.០០០តោនក្នុងឆ្នាំ១៩៩៥ ដល់ ២៤៥.៨៥៤តោនក្នុងឆ្នាំ២០១០ ក្តី។ យោងតាម ADB (2008) ជីនាំចូលពីប្រទេសវៀតណាម និងថៃ មានប្រមាណ ៧០% នៃការផ្គត់ផ្គង់សរុប (រូបភាព ៥) ។ ការពិភាក្សាបានបង្ហាញថា កសិករភាគច្រើនប្រើប្រាស់ជីក្នុងកម្រិតពី ១បាវ (៥០គក្រ) រហូតដល់ ៧បាវ សម្រាប់ដំណាំស្រូវមួយហិកតា ដោយអាស្រ័យទៅលើលទ្ធភាពដែលគាត់អាចលៃលករកបាន ជាជាងទៅតាមគុណភាព ឬប្រភេទជី និងដី និងតម្រូវការនៃដំណាំ ចំណែកឯកសិករក្រីក្រមិនអាចលៃលកទិញជីបានទេ។ ដោយសារមានការបណ្តុះបណ្តាល ការណែនាំ និងចំណេះដឹងតិចតួច ពីរបៀបប្រើជីសមស្រប កសិករភាគច្រើនរៀនប្រើទៅតាមការពន្យល់ផ្ទាល់មាត់ពីអ្នកលក់ជី ជាជាងតាមការអនុវត្តបង្ហាញ។ យោងតាម ADB (2008) កសិករប្រើប្រាស់ជីមិនសូវបានសមស្របតាមពេលវេលា និងកម្រិតត្រូវប្រើនោះទេ។ ចំណុចមិនចំណេញមួយ គឺគេប្រើជីលើសកម្រិតក្នុងរដូវប្រាំង នៅចំពេលដែលថ្លៃស្រូវធ្លាក់ចុះនៅមូលដ្ឋាន។ វិទ្យាស្ថានស្រាវជ្រាវអភិវឌ្ឍន៍កសិកម្មកម្ពុជា បានផ្សព្វផ្សាយនូវសេចក្តីណែនាំពីការប្រើជីទៅតាមតំបន់អេកូឡូស៊ីនៃដំណាំកសិកម្ម និងប្រភេទដី ប៉ុន្តែមិនមានការអនុវត្តតាមទេ ដោយសារកសិករនៅខ្វះចំណេះដឹង និងព័ត៌មាន (ADB 2008)។

ដូចបានបរិយាយរួចហើយ ការពង្រីកផ្ទៃដីកសិកម្មបង្កើននូវការប្រើប្រាស់ជី។ កំណើនការប្រើប្រាស់ជី អាចបង្កនូវការបំពុល និងចោទបញ្ហាដល់បរិស្ថាន។ ការបំពុលទាំងនោះ អាចបង្កការប៉ះពាល់ដល់ជីវិតវារីសត្វ ដោយសារការហូរច្រោះសារធាតុផ្សេងៗពីដីគោកចូលទៅក្នុងទឹក។ ទោះជាយ៉ាងនេះក្តី ផលប៉ះពាល់ពីបម្រែបម្រួលអាកាសធាតុ (ដូចជា បរិមាណទឹកភ្លៀងតិចបណ្តាលឲ្យខ្វះខាតទឹកសម្រាប់កសិកម្ម ជាដើម) ធ្វើឲ្យពូជដំណាំនានាដែលត្រូវការទឹកតិចក្នុងការដុះលូតលាស់ អាចក្លាយជាមធ្យោបាយបន្សាំនឹងបម្រែបម្រួលអាកាសធាតុ។ ទន្ទឹមគ្នានេះ ការប្រើជី ក៏អាចជាកម្លាំងបង្កើន (កាតាលីករ) ផលិតកម្មដំណាំដែរ។

## ៣.៦. ធនធានជលផល

ធនធានជលផល គឺជាស្បៀងសំខាន់លំដាប់ទី២ សម្រាប់ប្រជាជនកម្ពុជា។ សកម្មភាពមនុស្ស គួបផ្សំនឹងផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ អាចធ្វើឲ្យប្រែប្រួលរបបជលសាស្ត្រ ដែលបណ្តាលឲ្យធ្លាក់ចុះផលិតផលត្រី។ បច្ចុប្បន្ននេះ ការរេចរឹលតំបន់ដីសើម និងជម្រកនានា គួបផ្សំនឹងផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ ពិសេស របបទឹកភ្លៀងមិនទៀងទាត់ និងការប្រែប្រួលជលសាស្ត្រ នឹងទំនងជាមានផលប៉ះពាល់ដល់និរន្តរភាពនៃការគ្រប់គ្រងធនធានជលផល។

ការប្រែក្លាយតំបន់ព្រៃលិចទឹក ការរេចរឹលតំបន់ដីសើម និងការបំផ្លាញជម្រកមច្ឆជាតិសមុទ្រ ដូចជា ព្រៃកោងកាង ស្មៅសមុទ្រ ផ្កាថ្ម ដោយការនេសាទ វាជាឧបសគ្គចំពោះនិរន្តរភាពនៃការគ្រប់គ្រងធនធានជលផល។ ម្យ៉ាងទៀត ផលប៉ះពាល់ពីបម្រែបម្រួលអាកាសធាតុ រួមជាមួយផលប៉ះពាល់ពីកិច្ចប្រឹងប្រែងអភិវឌ្ឍ (ដូចជា វារីអគ្គិសនី) អាចបង្កការប្រែប្រួលក្នុងលំហូរជលសាស្ត្រ និងគុណភាពទឹកផងដែរ។

កម្ពុជាសម្បូរទៅដោយធនធានមច្ឆជាតិសមុទ្រ និងទឹកសាប។ តាមការប៉ាន់ស្មានផលនេសាទក្នុងឆ្នាំ២០០៦ មានប្រមាណ ៣៦០.០០០តោន មានតម្លៃប្រហែល ២៥២លានដុល្លារអាមេរិក ឬ ៨,៤% នៃ ផសស[៥] (MoE/Danida 2007:37) ហើយក្នុងឆ្នាំ២០០៩ ផលនេសាទសរុបប៉ាន់ស្មានមានចំនួន ៤៦៥.០០០តោន (FiA 2009) (រូបភាព ៦)។

រូបភាព ៦៖ ផលនេសាទប្រចាំឆ្នាំ (តោន) ពីឆ្នាំ១៩៨០-២០១០




*ប្រភព៖ FiA 2009, 2010*

៥ E. Baran *et al.* (2009:3) រាយការណ៍ថា ផលនេសាទប្រមូលបាន និង វារីវប្បកម្ម ចូលរួមចំណែក ១០% នៃ ផសស។

*៣.៦.១ នេសាទសមុទ្រ*

ការនេសាទត្រីប្រចាំឆ្នាំបានកើនឡើងគួរឲ្យកត់សម្គាល់ (រូបភាព ៦) ប៉ុន្តែផលចាប់តាមប្រភេទឧបករណ៍ បានថយចុះ ដោយសារតែកំណើនប្រជាជន ជាពិសេសកំណើនចំនួនអ្នកនេសាទ ដែលដាក់សម្ពាធទៅលើធនធានធម្មជាតិ ប្រព័ន្ធអេកូឡូស៊ី និងកំណើនសេដ្ឋកិច្ច ព្រមទាំងការរីកចម្រើនបច្ចេកវិទ្យានេសាទ (MoE/Danida 2005: 187)។ ផលស្តុកត្រី មិនមានការសិក្សាវាយតម្លៃទេ តាំងពីពាក់កណ្តាលឆ្នាំ១៩៨០ មក ដែលនៅពេលនោះ អ្នកវិទ្យាសាស្ត្ររុស្ស៊ីបានប៉ាន់ស្មានថា ផលស្តុកត្រីក្នុងសមុទ្រកម្ពុជា មានប្រមាណ ៥០.០០០តោន។ ទោះជាយ៉ាងណាក្តី ការចាប់ត្រីក្នុងពេលបច្ចុប្បន្ន វាធំលើសពីផលស្តុកត្រី ដែលអាចកកើតឡើងវិញ ហើយវាជាសញ្ញាមួយនៃការរេចរឹលធនធានមច្ឆជាតិសមុទ្រ។ ផលត្រីចាប់បានអាចប្រើជាមូលដ្ឋានសម្រាប់វាយតម្លៃពីផលស្តុកត្រី និងគណនាច្បាស់លាស់ពីបរិមាណត្រី ដើម្បីកំណត់ជាកូតានៃការចាប់ប្រចាំឆ្នាំ។ វារីវប្បកម្ម ដូចជា ការចិញ្ចឹមគ្រែងងាវ មានធ្វើឡើងនៅតាមបណ្តោយឆ្នេរក្នុងខេត្តកោះកុង។ ការចិញ្ចឹមត្រីតុកកែ ត្រីឆ្តុង មានអនុវត្តក្នុងខេត្តកោះកុង និងខេត្តព្រះសីហនុ។

*៣.៦.២ នេសាទទឹកសាប*

ធនធានត្រីទឹកសាបដើរតួនាទីសំខាន់ច្រើនជាងធនធានត្រីសមុទ្រ ក្នុងការទ្រទ្រង់ជីវភាពរស់នៅ។ ធនធានត្រីទឹកសាប ជាស្បៀងសំខាន់ទី២ បន្ទាប់ពីដំណាំស្រូវ និងផ្តល់ប្រមាណ ៧៥% នៃប្រូតេអ៊ីនអាហារនៅកម្ពុជា។ ទន្លេមេគង្គ ទន្លេឯទៀតៗ និងតំបន់ទន្លេសាប គេចាត់ទុកជាជង្រុកស្បៀងរបស់ប្រទេសកម្ពុជា។ មួយភាគធំនៃផ្ទៃប្រទេសកម្ពុជា គឺជាតំបន់ផ្ទៃរងទឹកភ្លៀងនៃប្រព័ន្ធទន្លេ-បឹងខាងលើ ដែលជួយទ្រទ្រង់ដល់ធនធានកកើតឡើងវិញដ៏ធំសម្បើមនេះ (ដូចជា ធនធានទឹក ព្រៃឈើ មច្ឆជាតិ) ជាពិសេស ត្រីទឹកសាប និងដំណាំស្រូវ នៃតំបន់ទំនាបបឹងទន្លេសាប។ តំបន់បឹងទន្លេសាប ជាប្រព័ន្ធអេកូឡូស៊ីដីសើមមួយដែលសម្បូរជីវចម្រុះជាងគេក្នុងពិភពលោក ហើយវាបានចូលរួមចំណែកច្រើនណាស់ដល់សេដ្ឋកិច្ចជាតិ សន្តិសុខស្បៀង និងជីវភាពរស់នៅ (FiA 2009; Noeu 2001)។

ទន្លេមេគង្គលើ ទន្លេឯទៀតៗ ព្រមទាំងផ្នែកខ្លះនៃតំបន់បឹងទន្លេសាប ត្រូវបានបម្រុងជាជម្រកមច្ឆជាតិ ពោលគឺមិនអនុញ្ញាតឲ្យធ្វើអាជីវកម្មនេសាទបែបពាណិជ្ជកម្មឡើយ។ ឡូនេសាទភាគច្រើនស្ថិតក្នុងតំបន់ទន្លេមេគង្គក្រោម ទន្លេសាប និងបឹងទន្លេសាប ហើយការចាប់ត្រីប្រចាំឆ្នាំមានដល់ទៅជាង ២០០.០០០តោន (Yeam & McKenney 2003)។ ការនេសាទជាលក្ខណៈអាជីវកម្មពាណិជ្ជកម្ម អាចអនុវត្តបានចាប់ពីខែតុលា ដល់ ឧសភា ឯការនេសាទក្នុងរដូវវស្សាគឺត្រូវបានហាមឃាត់។

## ៣.៧. ធនធានព្រៃឈើ

ធនធានព្រៃឈើ[៦] មានសក្តានុពលធំធេងណាស់ បើសិនមានការគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព ហើយសហគមន៍ជនជាតិដើមនានា នៅតែពឹងផ្អែកស្ទើរតែទាំងស្រុងទៅលើធនធាន

---

៦ គោលដៅអភិវឌ្ឍន៍សហសវត្សរ៍របស់ប្រទេសកម្ពុជា គឺរក្សាឲ្យមានព្រៃឈើ ៦០%នៃផ្ទៃដីទូទាំងប្រទេស នៅឆ្នាំ២០១៥ និងមានចែងក្នុងគោលនយោបាយព្រៃឈើថ្នាក់ជាតិ ហើយមានកំណត់នៅក្នុង ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រថ្នាក់ជាតិ ឆ្នាំ២០០៦-១០។

ព្រៃឈើ និងដីព្រៃ (Schweithelm *et al.* 2006)។ ព្រៃឈើមានប្រយោជន៍ជួយទ្រទ្រង់ដល់ជីវភាពរស់នៅ និងបរិស្ថាន ប៉ុន្តែវាលែងផ្តល់ផលប្រយោជន៍បានច្រើនដូចពេលមុនទៀតហើយ។ ការពង្រីកដីកសិកម្ម គួបផ្សំនឹងដីសម្បទានសេដ្ឋកិច្ច បានបង្រួមដីព្រៃបន្តិចម្តងៗ ធ្វើឲ្យមានសម្ពាធកាន់តែធ្ងន់ធ្ងរទៅលើប្រព័ន្ធអេកូឡូស៊ី និងជីវភាពរស់នៅ។

មានការលើកឡើងថា ក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចបង្កើតឱកាសជាច្រើនសម្រាប់ការរកចំណូល ក៏ប៉ុន្តែជីវភាពពឹងអាស្រ័យលើការលក់ពលកម្មឲ្យអ្នកអភិវឌ្ឍន៍ដីសម្បទានសេដ្ឋកិច្ចវាមិនប្រសើរជាងការពឹងអាស្រ័យទៅលើការប្រមូលផលអនុផលព្រៃឈើនោះទេ[៧]។ អ្នកភូមិដែលចូលរួមក្នុងការពិភាក្សានៅខេត្តកំពង់ធំ បានសំដែងនូវកង្វល់យ៉ាងធំពីការហាមឃាត់មិនឲ្យពួកគាត់ចូលទៅក្នុងព្រៃ។ តំបន់ព្រៃដែលពួកគាត់ធ្លាប់ពឹងអាស្រ័យ បានក្លាយជាដីសម្បទានសេដ្ឋកិច្ចដំណាំកៅស៊ូ ហើយពួកគាត់ត្រូវគេហាមឃាត់មិនឲ្យចូលចាប់តាំងពីឆ្នាំ២០១០ មក។

តារាង ២៖ បម្រែបម្រួលគម្របព្រៃ ពីឆ្នាំ១៩៦៥-២០១០

| ឆ្នាំ | តំបន់មានគម្របព្រៃ | | តំបន់គ្មានគម្របព្រៃ | |
|---|---|---|---|---|
| | ហិកតា | ភាគរយ | ហិកតា | ភាគរយ |
| 1965 | 13,227,100 | 73.04 | 4,883,400 | 26.96 |
| 1992/93 | 10,859,695 | 59.82 | 7,293,290 | 40.18 |
| 1996/97 | 10,638,209 | 58.60 | 7,514,776 | 41.40 |
| 2002 | 11,104,293 | 61.15 | 7,056,383 | 38.85 |
| 2005/06 | 10,730,781 | 59.09 | 7,429,893 | 40.91 |
| 2010 | 10,339,826 | 56.94 | 7,820,848 | 43.91 |

*ប្រភព៖ រដ្ឋបាលព្រៃឈើ ឆ្នាំ២០១០*

អវត្តមានព្រៃឈើ អាចបង្កនូវផលប៉ះពាល់ជាច្រើន ដូចជា ការហូរច្រោះដីស្រទាប់លើ ការហូរបាក់ដី និងការប្រែប្រួលមុខងារប្រព័ន្ធអេកូឡូស៊ី និងការបាត់បង់សត្វព្រៃ ហើយទាំងអស់នេះអាចជះឥទ្ធិពលកាន់តែអាក្រក់ បើសិនជាមានផលប៉ះពាល់បន្ថែមពីបម្រែបម្រួលអាកាសធាតុ។ បម្រែបម្រួលអាកាសធាតុ ដូចជា គ្រោះរាំងស្ងួត ទឹកជំនន់ និងខ្យល់ព្យុះ នឹងបង្កការខូចខាតធ្ងន់ធ្ងរដល់ជីវិតមនុស្ស សត្វ និងទ្រព្យសម្បត្តិនានា លើកលែងតែមានព្រៃឈើមកជួយកាត់បន្ថយឥទ្ធិពលរបស់វា។

ជាសង្ខេប ការពារព្រៃឈើមានន័យថា សេវាប្រព័ន្ធអេកូឡូស៊ី អាចផ្តល់ឲ្យបានក្នុងរយៈពេលយូរអង្វែង។ ព្រៃឈើមិនត្រឹមតែចូលរួមចំណែកដល់ចំណូលជាតិ និងទ្រទ្រង់ជីវភាពផ្ទាល់របស់ប្រជាជននោះទេ ប៉ុន្តែថែមទាំងជួយរក្សាជីវចម្រុះ និងបរិស្ថានទៀតផង។ ការកែប្រែដីព្រៃតាមរូបភាពនៃការអភិវឌ្ឍ ដូចជា ដីសម្បទានសេដ្ឋកិច្ច ជាដើម នាំឲ្យមានបម្រែបម្រួលការប្រើប្រាស់ដី។ បើសិនដីសម្បទានបានអភិវឌ្ឍពេញលេញមែន វានឹងក្លាយជាកម្លាំងចលករដ៏សំខាន់ ជួយជំរុញកសិកម្ម បម្រើសេដ្ឋកិច្ចជាតិ។

---

៧ ប្រជាសហគមន៍ បានបញ្ចេញមតិបង្ហាញកង្វល់របស់ខ្លួនអំពីធនធានព្រៃឈើ ដោយតវ៉ាប្រឆាំងនឹងក្រុមហ៊ុនដាំកៅស៊ូ ក្នុងតំបន់ព្រៃឡង់ ក្នុងឃុំទំរីង ស្រុកសន្ទុក ខេត្តកំពង់ធំ (Radio Free Asia, 3 March 2011)។

## ៣.៨. ឥណទាន

ធនាគារពិភពលោក រាយការណ៍ថា ការពិបាករកបានឥណទាន បង្ខំឲ្យកសិករភាគច្រើន ត្រូវពឹងផ្អែកទៅលើប្រភពឥណទានក្រៅផ្លូវការ ដែលមានអត្រាការប្រាក់ខ្ពស់ (Guimbert 2010)។ ទីផ្សារឥណទានសម្រាប់ផលិតកម្មដំណាំ ស្ទើរស្ថិតក្នុងកណ្តាប់ដៃឈ្មួញកណ្តាល ដែលគ្រប់គ្រងលើជាងពាក់កណ្តាលនៃជំនួញនៅជនបទ (ADB 2008)។ ស្ថាប័នមីក្រូហិរញ្ញវត្ថុ អេស៊ីលីដា និង អម្រឹត ធ្វើប្រតិបត្តិការផ្តល់ប្រាក់កម្ចីដល់កសិករជនបទ ក៏ប៉ុន្តែត្រូវប្រជែងជាមួយឥណទានក្រៅផ្លូវការ។ ឈ្មួញកណ្តាល យកការប្រាក់ពី ៥% ទៅ ៧% ក្នុងមួយខែ ដូច្នេះ ស្ថាប័នមីក្រូហិរញ្ញវត្ថុផ្តល់កម្ចីមានតម្លៃថោកជាង ប៉ុន្តែស្ថាប័នទាំងនេះមានលក្ខខណ្ឌឲ្យដាក់ទ្រព្យធានា និងខ្វះភាពបត់បែនក្នុងការផ្តល់កម្ចី (UNDP 2007)។ ការពិភាក្សាជាមួយកសិករបានបង្ហាញថា ពួកគាត់តែងសងបំណុលនៅរដូវច្រូតកាត់ប្រមូលផល ឬក៏សងបំណុលភ្លាមៗនៅពេលលក់ស្រូវ។ បញ្ហាដែលកសិករម្នាក់ៗត្រូវជំពាក់បំណុល[៨] មានមូលហេតុជាច្រើនទាក់ទងនឹងការងារកសិកម្ម ដូចជា ការទិញគ្រាប់ពូជ សម្ភារៈភ្ជួររាស់ និងជី ជាដើម។

## ៣.៩. ហេដ្ឋារចនាសម្ព័ន្ធ

ការស្តារបនា ជួសជុលប្រព័ន្ធផ្លូវជាតិបានអនុវត្តរួចរាល់ ហើយផ្លូវផ្សេងៗទៀតក៏គ្រោងបញ្ចប់នៅត្រឹមឆ្នាំ២០១១ (World Bank 2009)។ ការសង្កេតផ្ទាល់បានបង្ហាញថា សព្វថ្ងៃនេះស្រុក និងភូមិភាគច្រើនមានផ្លូវប្រើប្រាស់ និងតភ្ជាប់ទៅទីផ្សារ។ ប្រព័ន្ធផ្លូវថ្នល់ល្អប្រសើរឡើងនេះ ជួយឲ្យអ្នកភូមិអាចចេញចូលទៅដល់ទីផ្សារ និងស្វែងរកការងារនៅកន្លែងផ្សេងៗ ជាពិសេសនៅតំបន់ខ្ពង់រាប។ ទីរួមស្រុកភាគច្រើន គឺស្ថិតនៅតាមបណ្តោយផ្លូវជាតិ និងផ្លូវខេត្តសំខាន់ៗ។ ស្រុកនានាដែលនៅជិត ឬអាចចេញចូលទៅដល់ព្រំដែន ដូចជា ព្រំដែនថៃ វៀតណាម ឬឡាវ អាចមានឱកាសធ្វើពាណិជ្ជកម្ម ពិសេសការដោះដូរទំនិញកសិកម្ម (រូបភាព ៧)។

កំពង់ផែសមុទ្រមួយក្នុងខេត្តព្រះសីហនុ នៅចម្ងាយ ២២៦គម ពីក្រុងភ្នំពេញ បានតភ្ជាប់ប្រទេសកម្ពុជា ជាមួយការដឹកជញ្ជូនអន្តរជាតិនៅក្នុងតំបន់។ ចំពោះផ្លូវដែក រដ្ឋាភិបាលកម្ពុជាបានចុះកិច្ចសន្យារយៈពេល ៣០ឆ្នាំ ផ្តល់សិទ្ធិគ្រប់គ្រងធ្វើអាជីវកម្មទៅឲ្យ ក្រុមហ៊ុន[៩] Toll (Cambodia) Co., Ltd។ ធនាគារអភិវឌ្ឍន៍អាស៊ី និងទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ (AusAID) បានផ្តល់មូលនិធិ ១៤០លានដុល្លារ សម្រាប់ការស្តារបណ្តាញផ្លូវដែកពីរខ្សែ គឺមានខ្សែទិសខាងត្បូងប្រវែង ២៦៤គម ចេញពីភ្នំពេញ កាត់តាមខេត្តកែប កំពត ហើយតភ្ជាប់ទៅកំពង់ផែសមុទ្រក្រុងព្រះសីហនុ និងខ្សែទិសខាងជើង ប្រវែង ៣៨៦គម ពីភ្នំពេញទៅប៉ោយប៉ែត កាត់តាមខេត្តកំពង់ស្ពឺ កំពង់ឆ្នាំង ពោធិសាត់ បាត់ដំបង និងបន្ទាយមានជ័យ ហើយតភ្ជាប់ទៅនឹងបណ្តាញផ្លូវដែកប្រទេសថៃ។

---

៨ ជារឿយៗ កសិករខ្ចីទុន ឬរបស់របរផ្សេងៗ ដូចជា គ្រាប់ពូជ ម៉ាស៊ីនភ្ជួរ ម៉ាស៊ីនបូមទឹក។ល។ ដែលត្រូវគិតជាប្រាក់ដើម្បីសងគេវិញ។ កសិករក៏មានខ្ចីប្រាក់ពីឈ្មួញកណ្តាល អ្នកជិតខាង ឬសាច់ញាតិក្នុងអត្រាការប្រាក់ខ្ពស់ជាងស្ថាប័នមីក្រូហិរញ្ញវត្ថុដែរ ដោយមានលក្ខខណ្ឌទន់ភ្លន់ច្រើនសម្រាប់ការសងវិញពោលគឺ បំណុលអាចត្រូវសងក្នុងរយៈពេលខ្លី ឬវែង។ ទោះយ៉ាងនេះក្តី កសិករអាចលំបាកសងបំណុលគេវិញ ឬត្រូវខ្វះខាតស្បៀងអាហារ បើសិនគាត់ទទួលបានទិន្នផលទាប ឬជួបនឹងគ្រោះធម្មជាតិ។

៩ គេហទំព័រ www.tollroyalrailway.com (accessed 15 August 2011)

រូបភាព ៧៖ បណ្ដាញផ្លូវថ្នល់ក្នុងប្រទេសកម្ពុជា ឆ្នាំ២០០៨




| ប្រភេទផ្លូវ | ប្រវែងផ្លូវ (គីឡូម៉ែត្រ) |
|---|---|
| ផ្លូវជាតិ ១លេខ | 2097 |
| ផ្លូវជាតិ ២លេខ | 2705 |
| ផ្លូវខេត្ត | 6692 |

## ៤. ឧបសគ្គបម្រែបម្រួលអាកាសធាតុ ចំពោះវិស័យកសិកម្ម

បម្រែបម្រួលអាកាសធាតុ បានក្លាយជាប្រធានបទសាកល និងយុទ្ធសាស្ត្របន្សាំ ក្នុងការដោះស្រាយផលប៉ះពាល់នានា និងកំពុងត្រូវបានដាក់បញ្ចូលទៅក្នុងគោលនយោបាយអភិវឌ្ឍ។ ការយល់ដឹងពីកត្តាផ្សេងៗដែលបង្កបម្រែបម្រួលអាកាសធាតុ និងផលប៉ះពាល់របស់វា មានសារៈសំខាន់ណាស់ ពីព្រោះវិស័យកសិកម្មចូលរួមចំណែកយ៉ាងសំខាន់ដល់សេដ្ឋកិច្ច សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ នៅក្នុងប្រទេសកំពុងអភិវឌ្ឍភាគច្រើន។ រដ្ឋាភិបាលកម្ពុជាបានរៀបចំយុទ្ធសាស្ត្រឆ្លើយតបស្ដីពីការបន្សាំបម្រែបម្រួលអាកាសធាតុ ឲ្យក្លាយជាកម្មវិធីជាតិបន្សាំបម្រែបម្រួលអាកាសធាតុថ្នាក់ជាតិ ដែលអនុម័តក្នុងឆ្នាំ២០០៦ ដើម្បីឆ្លើយតបនឹងតម្រូវការបន្ទាន់ និងផលប៉ះពាល់នៅថ្នាក់មូលដ្ឋាន ព្រមទាំងផ្ដល់ជាគោលការណ៍អនុវត្តនូវគំនិតផ្ដួចផ្ដើមបន្សាំនានា។ កសិករក៏ទទួលស្គាល់ដែរថា ការខូចខាតដំណាំរបស់ពួកគាត់ក្នុងពេលកន្លងមកវាមានជាប់ទាក់ទងនឹងបម្រែបម្រួលអាកាសធាតុ ដូចជា ភ្លៀងមិនទៀងទាត់ គ្រោះរាំងស្ងួត ទឹកជំនន់ ជាដើម។ ការយល់ដឹងនៅមូលដ្ឋានពីបម្រែបម្រួលទាំងនេះ និងតម្រូវការទីផ្សារ បានបង្ខំកសិករឲ្យប្រើប្រាស់ពូជស្រូវនានា ដែលផ្ដល់ផលក្នុងរយៈពេលខ្លី (៩០ ទៅ ១០០ថ្ងៃ) និងធ្វើពិពិធកម្មដំណាំរបស់ខ្លួន។

ប្រទេសកម្ពុជាទទួលរងគ្រោះធម្មជាតិជាញឹកញយ ដូចជា ការរាំងស្ងួត ទឹកជំនន់ ខ្យល់ព្យុះ (ឧទាហរណ៍ ព្យុះកេតសាណាក្នុងឆ្នាំ២០០៩)។ កម្ពុជាមានអាកាសធាតុមូសុង ដែលមានរដូវវស្សា និងរដូវប្រាំង។ សីតុណ្ហភាពមធ្យមស្ថិតក្នុងចន្លោះពី ២៧ ទៅ ៣៥អង្សាសេ។ សីតុណ្ហភាពខ្ពស់បំផុតក្នុងចន្លោះពី ២៩ ទៅ ៣៨អង្សាសេ កើតមានក្នុងខែមីនា ដល់ខែឧសភា (Khun 2002)។ ទឹកភ្លៀងប្រចាំឆ្នាំជាមធ្យមមានកម្រិតពី ២០០០មម ទៅ ៣០០០មម។ កម្រិតទឹកភ្លៀង

ខ្ពស់បំផុតដល់ ៤០០០មម មាននៅតំបន់ឆ្នេរ (Khun 2002)។ យុទ្ធសាស្ត្រកសិកម្ម និងទឹក (SAW 2007: 6) សង្កត់ធ្ងន់ថា គ្រោះធម្មជាតិ ជាកត្តាចម្បងមួយ ក្នុងចំណោមកត្តាគំរាមកំហែងទាំង ៩ ចំពោះវិស័យកសិកម្ម និងធនធានទឹកនៅកម្ពុជា (TWGAW 2007)។

គណៈកម្មាធិការទន្លេមេគង្គ បានគណនាថា សីតុណ្ហភាពមធ្យមនៅកម្ពុជា បានកើនឡើង ០,៨អង្សាសេ ពីឆ្នាំ១៩៦០ ដល់ឆ្នាំ២០០៥ (MRC 2010) ហើយប្រមើលឃើញថា សីតុណ្ហភាពមធ្យមអាចកើនថែម ពី ០,៣អង្សាសេ ទៅ ០,៦អង្សាសេ នៅត្រឹមឆ្នាំ២០២៥ និងកើនថែមពី ១,៤អង្សាសេ ទៅ ៤,៣អង្សាសេ នៅត្រឹមឆ្នាំ២០៩០។ កំដៅរំពឹងថានឹងកើនឡើង ចាប់ពីខែធ្នូ ដល់មិថុនា។

ទឹកជំនន់ជារឿយៗបានបំផ្លាញដំណាំ សត្វពាហនៈ ហេដ្ឋារចនាសម្ព័ន្ធ និងជីវិតមនុស្ស និងទ្រព្យសម្បត្តិ ហើយតាមរបាយការណ៍ទទួលបាន ជារៀងរាល់ឆ្នាំកម្ពុជាត្រូវខាតបង់អស់ពី ១០០លាន ទៅ ១៧០លានដុល្លារអាមេរិក (RGC 2009)។ តាមការប៉ាន់ស្មាន ការខូចខាតដោយព្យុះកេតសាណាក្នុងឆ្នាំ២០០៩ មានតម្លៃប្រមាណ ១៣២លានដុល្លារអាមេរិក។

រូបភាព ៨៖ ដំណាំស្រូវបំផ្លាញដោយទឹកជំនន់




*ប្រភព៖ MAFF 2010b*

រូបភាព ៩៖ ដំណាំស្រូវបំផ្លាញដោយគ្រោះរាំងស្ងួត




*ប្រភព៖ MAFF 2010b*

រូបភាព ៩ បង្ហាញពីដំណាំស្រូវរាប់សិបម៉ឺនហិកតា ដែលត្រូវបំផ្លាញដោយគ្រោះរាំងស្ងួតក្នុងពីរទសវត្សរ៍កន្លងមកនេះ។ ប្រជាជនរស់នៅក្រោមបន្ទាត់ភាពក្រីក្រ មានដល់ ៣៦% ក្នុងឆ្នាំ១៩៩៧ (RGC 2002b) ហើយបានថយចុះមកត្រឹម ៣៤,៨% ក្នុងឆ្នាំ២០០៤ និង ៣០,១% ក្នុងឆ្នាំ២០០៧ (World Bank 2009: 27)។ ម្យ៉ាងទៀត ការកើតមានជាញឹកញាប់នូវគ្រោះរាំងស្ងួត ទឹកជំនន់ និងខ្យល់ព្យុះ បានបង្កហានិភ័យបន្ថែមទៅលើផលិតភាពកម្រិតទាបនៃប្រព័ន្ធកសិកម្មដែលមានស្រាប់ ហើយទាំងអស់នេះឆ្លុះបញ្ចាំងមួយផ្នែកពីទំនាក់ទំនងរវាងគ្រោះរាំងស្ងួត និងភាពក្រីក្រ។

## ៥. ក្របខ័ណ្ឌច្បាប់ និងគោលនយោបាយ ស្ដីពីបម្រែបម្រួលអាកាសធាតុ និងកសិកម្ម

កម្ពុជាជាប្រទេសហត្ថលេខីនៃសន្ធិសញ្ញាក្របខ័ណ្ឌអង្គការសហប្រជាជាតិស្ដីពីបម្រែបម្រួលអាកាសធាតុ។ គណៈកម្មាធិការបម្រែបម្រួលអាកាសធាតុថ្នាក់ជាតិ ដែលត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០០៦ បានដំណើរការជាយន្តការសម្របសម្រួលគោលនយោបាយ តម្រង់ទិសអភិវឌ្ឍន៍ និងអនុវត្តគោលនយោបាយជាប់ទាក់ទងនឹងបញ្ហាបម្រែបម្រួលអាកាសធាតុ។ បច្ចុប្បន្ននេះ កម្ពុជាមានក្របខ័ណ្ឌគោលនយោបាយ និងយុទ្ធសាស្ត្រជាច្រើន ពាក់ព័ន្ធនឹងវិស័យកសិកម្ម និងបម្រែបម្រួលអាកាសធាតុ ដូចជា៖

- ផែនការសកម្មភាពថ្នាក់ជាតិស្ដីពីការបន្សាំនឹងបម្រែបម្រួលអាកាសធាតុ
- គោលនយោបាយព្រៃឈើថ្នាក់ជាតិ ច្បាប់ព្រៃឈើ និងកម្មវិធីព្រៃឈើថ្នាក់ជាតិ
- ច្បាប់ស្ដីពីធនធានធម្មជាតិ និងការការពារបរិស្ថាន
- ផែនការអភិវឌ្ឍសេដ្ឋកិច្ចសង្គម ដំណាក់កាលទី១ (១៩៩៥-២០០០) និងដំណាក់កាលទី២ (២០០១-២០០៥)
- យុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រថ្នាក់ជាតិ (២០០៣-២០០៥)
- យុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី១ (២០០៤) និងដំណាក់កាលទី២ (២០០៨)
- ផែនការអភិវឌ្ឍយុទ្ធសាស្ត្រថ្នាក់ជាតិ (២០០៦-១០) និងបច្ចុប្បន្នភាពផែនការ (២០១០-២០១៣)
- ក្របខ័ណ្ឌផែនការយុទ្ធសាស្ត្រស្ដីពីវិស័យជលផល (២០០៩-២០១៨)

## ៦. ការពិភាក្សា និងសេចក្ដីសន្និដ្ឋាន

ជាការច្បាស់ហើយដែលថា បម្រែបម្រួលអាកាសធាតុនៅក្នុងពិភពលោក នឹងមានផលប៉ះពាល់អវិជ្ជមានដល់សេដ្ឋកិច្ច សង្គម ក្នុងនោះមានទាំងធនធានទឹក កសិកម្ម ព្រៃឈើ ជលផល លំនៅដ្ឋានមនុស្ស ប្រព័ន្ធអេកូឡូស៊ី និងសុខភាព។ បណ្ដាប្រទេសកំពុងអភិវឌ្ឍ គឺងាយរងគ្រោះខ្លាំងជាងគេ (IPCC[១០] 2000a)។ UNDP (2011) បានកត់សម្គាល់ថា បម្រែបម្រួលអាកាសធាតុ គឺជាការពិត ហើយគ្រប់វិស័យទាំងអស់នៅក្នុងប្រទេសកម្ពុជាកំពុងរៀបចំបញ្ចូលវាទៅក្នុងផែនការ។ លើសពីនេះទៀត បម្រែបម្រួលអាកាសធាតុក៏បណ្ដាលមកពីសកម្មភាពមនុស្សដែលបំភាយឧស្ម័នផ្ទះកញ្ចក់ តាមការដុតថាមពល ការបាត់បង់ព្រៃឈើ និងការធ្វើកសិកម្ម (NASA, 2011[១១])។

ដូចបានរៀបរាប់ខាងលើ កំណើនរបបទឹកភ្លៀងមិនទៀងទាត់ និងកំណើនភាពញឹកញាប់នៃគ្រោះរាំងស្ងួត ទឹកជំនន់ និងខ្យល់ព្យុះ បានប៉ះពាល់មិនល្អដល់កិច្ចប្រឹងប្រែងអភិវឌ្ឍនៅកម្ពុជា ក្នុងបីទសវត្សរ៍កន្លងមកនេះ។ ការគួបផ្សំគ្នានៃផលប៉ះពាល់ទាំងនេះ អាចជះឥទ្ធិពលទៅលើរាល់កិច្ចប្រឹងប្រែង ដូចជា ការប្រឹងប្រែងបង្កើនដំណាំកសិកម្ម និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ ជាដើម។

---

១០ Intergovernmental Panel on Climate Change

១១ Posted in the www.mongbay.com (accessed 24 January 2012)

- កំណើនផលិតផលស្រូវ ក្នុងពីរ-បីទសវត្សរ៍ចុងក្រោយ កើតមានជាសំខាន់ដោយសារការពង្រីកផ្ទៃដីដាំដុះ ជាជាងការប្រឹងប្រែងធ្វើប្រពលវប្បកម្មដើម្បីបង្កើនផលិតកម្ម ដែលមានទិន្នផលទាបជាងគេនៅក្នុងតំបន់។ បច្ចេកវិទ្យាកសិកម្មនៅមានកម្រិត ការប្រើប្រាស់ទុន និងសម្ភារៈមិនទាន់សមស្រប (ដូចជា គ្រាប់ពូជ ជី ថ្នាំសម្លាប់សត្វល្អិត) និងការទទួលទឹកស្រោចស្រពមិនទាន់គ្រប់គ្រាន់ គឺជាឧបសគ្គចម្បងដែលរារាំងកំណើនផលិតកម្ម។ មានការគិតគូរថា បច្ចេកវិទ្យាកសិកម្មសមស្រប និងហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធស្រោចស្រព ជាកត្តាដ៏ចាំបាច់សម្រាប់បង្កើនផលិតកម្ម និងជួយប៉ះប៉ូវការខូចខាតដោយសាររបាយទឹកភ្លៀងមិនទៀងទាត់។ កង្វះខាតទាំងអស់នេះ អាចញ៉ាំងឲ្យកសិករភាគច្រើនជួបការលំបាក និងរាំងស្ទះដល់កិច្ចប្រឹងប្រែងកាត់បន្ថយភាពក្រីក្រ និងធានាសន្តិសុខស្បៀងនៅថ្នាក់ជាតិ។
- បម្រែបម្រួលអាកាសធាតុ អាចប៉ះពាល់ដល់គ្រប់វិស័យទាំងអស់ ដូចជា កសិកម្មជាដើម។ ផលដំណាំកសិឧស្សាហកម្ម ពិសេសផលិតផលកៅស៊ូ រំពឹងថានឹងកើនឡើងក្នុងអំឡុងពេលពីរ-បីឆ្នាំខាងមុខនេះ។ ថ្លៃដំឡូងឈើដែលឡើងចុះនៅលើទីផ្សារ បានបង្ហាញសញ្ញាប្រសើរឡើងវិញនៅពាក់កណ្តាលឆ្នាំ២០១១ ហើយបណ្តាលឲ្យមានការពង្រីកផ្ទៃដីដាំដុះ។ ទោះជាយ៉ាងនេះក្តី បរិមាណនៃដំណាំដំឡូងឈើ វាអាស្រ័យទៅលើតម្រូវការទីផ្សារ។
- ធនធានមច្ឆជាតិ ទាំងទឹកសាប និងសមុទ្រ សំខាន់ខ្លាំងណាស់សម្រាប់ជីវភាពរស់នៅ និងការរីកចម្រើនក្នុងវិស័យកសិកម្ម។ ប៉ុន្តែផលប៉ះពាល់គួបផ្សំគ្នានៃការនេសាទហួសកម្រិត បម្រែបម្រួលអាកាសធាតុ (របបទឹកភ្លៀង) និងការប្រែប្រួលរបបជលសាស្ត្រ ក៏ដូចជាការរេចរឹលសារធាតុចិញ្ចឹមនៅក្នុងទន្លេមេគង្គ និងបឹងទន្លេសាប ទំនងជានឹងបណ្តាលឲ្យធនធានជលផលធ្លាក់ចុះ។ ដូច្នេះ ត្រូវមានការគិតគូរជាបន្ទាន់ ដើម្បីធានានិរន្តរភាពនៃការគ្រប់គ្រងធនធានជលផល។ ការនេសាទសមុទ្រលើសពីផលស្តុកត្រីសមុទ្រ (ដែលជាលទ្ធភាពនៃការកកើតឡើងវិញ) កំពុងបង្កជាក្តីកង្វល់។ ដូច្នេះ ត្រូវមានការវាយតម្លៃឡើងវិញជាចាំបាច់ និងការពិនិត្យតាមដានពីផលស្តុក និងកូតានេសាទក្នុងពេលបច្ចុប្បន្ន។ ការបង្កើតបច្ចេកវិទ្យានេសាទនៅសមុទ្រទឹកជ្រៅ និងការអនុវត្តវិធីនេសាទប្រកបដោយការទទួលខុសត្រូវ អាចជួយកាត់បន្ថយសម្ពាធសព្វថ្ងៃទៅលើធនធានជលផលក្នុងតំបន់សមុទ្រទឹករាក់។
- ធនធានព្រៃឈើមានសារៈសំខាន់សម្រាប់ជីវភាពរស់នៅ និងបរិស្ថាន បើទោះបីវាលែងផ្តល់ផលបានច្រើនដូចមុនក៏ដោយ។ ចំពោះព្រៃឈើដែលបាត់បង់ គេត្រូវចំណាយពេលវែងដើម្បីស្តារវាឡើងវិញ។ ការប្រើប្រាស់ដីមិនសមស្រប មិនត្រឹមតែធ្វើឲ្យរេចរឹលធនធានព្រៃឈើប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងប៉ះពាល់អាក្រក់ដល់បរិស្ថាន និងជីវភាពរស់នៅទៀតផង។
- គ្រោះធម្មជាតិ ដូចជា ទឹកជំនន់ ការរាំងស្ងួត ខ្យល់ព្យុះ កើតមានឡើងជាញឹកញយ ដោយអាចបំផ្លាញដំណាំកសិកម្ម ពិសេសដំណាំស្រូវ។ គ្រោះធម្មជាតិទាំងនេះតែងប៉ះពាល់ខ្លាំងជាងគេដល់ប្រជាជនក្រីក្រនៅជនបទ។ ដូច្នេះ គួរលើកទឹកចិត្តកសិករឲ្យខំសម្របការដាំដុះរបស់ខ្លួន ដើម្បីអាចទប់ទល់កាន់តែប្រសើរនឹងផលប៉ះពាល់នៃបាតុភូតធម្មជាតិ។ ភាពមិនទៀងទាត់នៃរបបទឹកភ្លៀង ជាឧបសគ្គយ៉ាងធំរាំងការ

លើកស្ទួយផលិតកម្មដំណាំ ហើយទឹកពីប្រព័ន្ធស្រោចស្រពត្រូវតែមានជាចាំបាច់ ដើម្បីជម្នះវា។

ជាទូទៅ គ្រប់ការប្រឹងប្រែងសំដៅបង្កើនផលិតផលកសិកម្ម សុទ្ធតែសំខាន់សម្រាប់ការកាត់បន្ថយភាពក្រីក្រ និងសន្តិសុខស្បៀង។ ប៉ុន្តែការប្រឹងប្រែងបង្កើនផលិតកម្មដំណាំឲ្យបានច្រើនជាអតិបរមានេះ មិនត្រូវប៉ះពាល់អវិជ្ជមានដល់បរិស្ថានទេ ជាពិសេសត្រូវអនុវត្តតាមកសិកម្មប្រពលវប្បកម្ម ជាជាងការពង្រីកផ្ទៃដីដាំដុះ។ ការឡើងចុះថ្លៃផលិតផលនៅទីផ្សារ វាជំរុញកសិករឲ្យផ្លាស់ប្តូរការដាំដុះ។ ភាពមិនទៀងទាត់នៃរបបទឹកភ្លៀង គួបផ្សំនឹងគ្រោះធម្មជាតិផ្សេងៗទៀត កំពុងបង្កការខូចខាតកាន់តែខ្លាំងដល់កសិកម្ម ទ្រព្យសម្បត្តិ និងជីវិតមនុស្ស។ ផលិតភាពទាបនៃដំណាំស្រូវ គួបផ្សំនឹងការឡើងចុះថ្លៃផលិតផលនៅទីផ្សារ អាចជាឧបសគ្គមួយយ៉ាងធំដល់ការលើកស្ទួយជីវភាពរស់នៅរបស់កសិករ។ ជាការរំពឹងដែរថា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តជារាសាស្រ្តថែមទៀត នឹងបង្កើតបានឱកាសជាច្រើនសម្រាប់កសិកម្មប្រពលវប្បកម្ម ពិសេសការដាំដុះឲ្យបានដល់ពីរឬបីដងក្នុងមួយឆ្នាំ។

## ៧. អនុសាសន៍

ការពិភាក្សាខាងលើ បានគូសបញ្ជាក់ពីការពិចារណាមួយចំនួន ក្នុងន័យឆ្លើយតបភ្លាមៗ ឬក្នុងអំឡុងពេលវែង ទៅនឹងការបន្សាំបម្រែបម្រួលអាកាសធាតុ។ លទ្ធផលនៃការពិភាក្សា និងរបកគំហើញនានា អាចមានសារៈសំខាន់សម្រាប់ធ្វើការពិចារណា និងឆ្លើយតបទៅនឹងភាពមិនប្រក្រតីនៃអាកាសធាតុ។ ការសិក្សាមានផ្តល់ជាអនុសាសន៍មួយចំនួន ដូចតទៅ៖

- ការគ្រប់គ្រងដី និងការអភិរក្សដ៏សមស្រប គួរតែមានការគិតគូរ ដើម្បីធានាឲ្យការអភិវឌ្ឍកសិកម្មមិនបង្កការខូចខាតដល់បរិស្ថាន ជួយរក្សាការពារប្រព័ន្ធអេកូឡូស៊ីព្រៃឈើ និងជួយទ្រទ្រង់ចង្វាក់ប្រព័ន្ធកសិកម្មនៅក្នុងប្រទេស។
- គួរច្នៃបង្កើត និងអនុវត្តយន្តការផ្សេងៗ ដើម្បីពិនិត្យតាមដាន វាយតម្លៃ ត្រួតពិនិត្យជាទៀងទាត់នូវការអភិវឌ្ឍដំណាំកសិឧស្សាហកម្ម ដើម្បីធ្វើការបន្សាំជាអតិបរមា ទៅនឹងកត្តាបម្រែបម្រួលអាកាសធាតុ។
- កសិករគួរទទួលបានការអប់រំបណ្តុះបណ្តាលដ៏សមស្របអំពី ប្រព័ន្ធស្រូវប្រពលវប្បកម្ម និងការគ្រប់គ្រងថ្នាំកសិកម្ម និងជីកសិកម្ម ដើម្បីបង្កើនផលិតកម្មកសិកម្ម និងកាត់បន្ថយជាអតិបរមានូវការប៉ះពាល់ដល់សុខភាព និងប្រព័ន្ធអេកូឡូស៊ី។
- សមត្ថភាពកសិករគួរតែលើកស្ទួយថែមទៀត។ បច្ចេកវិទ្យាកសិកម្មសមស្រប ដូចជាគ្រឿងយន្តកសិកម្ម គ្រាប់ពូជផ្សេងៗ និងទុនចាំបាច់នានា ដូចជាជី និងចំណេះដឹងរបស់កសិករសម្រាប់ធ្វើពិពិធកម្មដំណាំដាំដុះ និងបង្កើនផលិតកម្ម គួរតែដោះស្រាយសម្រាប់កសិករ។
- គួរអនុម័តចេញនូវវិធានការដ៏សមស្របទាំងឡាយ ដើម្បីអនុវត្តគំនិតផ្តួចផ្តើមនានាឲ្យបានសក្តិសិទ្ធិ និងមានប្រសិទ្ធភាព សំដៅសម្រេចបានទៅតាមទិសដៅនៃគោលនយោបាយជាតិ ពិសេសគោលនយោបាយគ្រប់គ្រងព្រៃឈើ និងយុទ្ធសាស្រ្តបន្សាំរយៈពេលវែង សម្រាប់ការអភិវឌ្ឍកសិកម្ម។

- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធធារាសាស្ត្ររូបវ័ន្ត ត្រូវធ្វើឡើងជាបន្ទាន់ ដើម្បីដោះស្រាយទប់ទល់នឹងភាពមិនប្រក្រតីនៃបម្រែបម្រួលអាកាសធាតុ (ដូចជា ភ្លៀងមិនទៀងទាត់ និងការប្រែប្រួលកម្រិតកំពស់ទឹក) និងកំណើនភាពញឹកញាប់នៃគ្រោះធម្មជាតិ(ទឹកជំនន់ ការរាំងស្ងួត ខ្យល់ព្យុះ) និងដើម្បីពង្រីកផ្ទៃដីដាំដុះសំដៅធានាសន្តិសុខស្បៀងនៅថ្នាក់ជាតិ តាមរយៈការពង្រីកប្រពលវប្បកម្មផលិតកម្មកសិកម្ម។

## គន្ថនិទ្ទេស


Asian Development Bank (2008), "Issues and Options in Agriculture and Natural Resources Sector in Cambodia" (Manila: ADB)

Balgis Osman Elasha, Nagmeldin Goutbi Elhassan, Hanafi Ahmed and Sumaya Zakieldin (2005), Sustainable Livelihood Approach for Assessing Community Resilience to Climate Change: Case Studies from Sudan, Working Paper No. 17 (Washington: AIACC)

Baran, E., H. Schwartz & Y. Kura (2009), "Climate Change and Fisheries: Vulnerability and Adaptation in Cambodia" (Penang: WorldFish Center)

CDRI (2010a), proceedings from the WRMRCDP Provincial Dissemination and Consultation Workshop (Khmer version), Kompong Chhnang province, February 2010

CDRI (2010b), proceedings from the WRMRCDP Provincial Dissemination and Consultation Workshop (Khmer version), Pursat province, April 2010

CDRI (2010c), proceedings from the WRMRCDP Provincial Dissemination and Consultation Workshop (Khmer version), Kompong Thom province, October 2010

Chheng, K. (2010), presentation at the International Conference on "Managing Forest Resources for Multiple Ecosystem Services under Robust and Fragile Environment" (Phnom Penh: FA)

DAP (2011), Cambodian Prime Minister announced the cancellation of 14 Economic Land Concessions, www.dap-news.com (accessed 7April 2011)

Fisheries Administration (2010), "Overall Annual Report on Fisheries to 2010 and Targeting to 2011" (Khmer version) (Phnom Penh: FiA)

Fisheries Administration (2009a), "Overall Annual Report on Fisheries to 2009 and targeting for 2010" (Khmer version) (Phnom Penh: FiA)

Fisheries Administration (2009b), "Series of Overall Annual Reports on Fisheries from 2000 to 2009" (Khmer version) (Phnom Penh: FiA)

Fisheries Administration (2008), "Overall Annual Report on Fisheries to 2008 and targeting for 2009" (Khmer version) (Phnom Penh: FiA)

Fisheries Office (2000), "A Study of Downstream Impacts of the Yali Fall Dam in the Se San River Basin Ratanakiri Province" (Ratanakiri: Department of Fisheries)

Fitzgerald, Ingrid, So Sovannarith, Chan Sophal, Kem Sithen & Tout Sophally (2007),"Moving Out Of Poverty? Trends in Community Well-Being and Household Mobility in Nine Cambodian Villages" (Phnom Penh: CDRI)

Food and Agriculture Organisation of the United Nations, www.faostat.fao.org (accessed 3 June 2011)

Forestry Administration (2004a), "Independent Forest Review: The Forest Sector in Cambodia, Policy Choices, Issues and Options" (Phnom Penh: FA)

Forestry Administration (2004b), "The Forest Sector in Cambodia-Policy Choices, Issues and Options" (Phnom Penh: FA).

Greenpeace, UK (2012), "Deforestation and climate Change", http://www.greenpeace.org.uk /forests/climate-change (accessed 26 January 2012)

Guimbert, S. (2010), Cambodia 1998-2008: *An Episode of Rapid Growth*, Working Paper No. 5271, www.worldbank.org/kh/growth (accessed June 2011)

Hansen, Kasper & Neth Top (2006), *Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia*, Working Paper No. 33 (Phnom Penh: CDRI)

Hing, V. & Thun V. (2009), *Agricultural Trade in the Greater Mekong Sub-region: The Case of Cassava and Rubber in Cambodia*, Working Paper No. 43 (Phnom Penh: CDRI)

International Monetary Fund (2009), *Cambodia: Statistical Appendix* (Washington: IMF)

Khun, S. (2002), "Country Report 2002 on Disaster Management in Cambodia" (Phnom Penh: National Committee for Disaster Management)

Kubota, Tsuyoshi (2008), "Presentation on Road Infrastructure and Agricultural Development in Cambodia at the Cambodia-Japan Cooperation Centre during the seminar to mark the 55th Anniversary of Diplomatic Relations between Cambodia and Japan, 28 November 2008" (unpublished)

MAFF (2011a), "Annual Development Report for 2010-2011 and Target for 2011-2012" (Phnom Penh: MAFF)

MAFF (2011b), "Significant Selection of Seed Variety-10 Selected Seeds" (Khmer language) (Phnom Penh: MAFF)

MAFF (2010a), "Annual Report of Ministry of Agriculture, Fishery and Forestry for 2009-2010 and direction for 2010-2011" (Phnom Penh: MAFF)

MAFF (2010b), Conference handout on the Assessment of Vulnerability and Adaptation to Climate change, Sunway Hotel on 26 May 2010 (Phnom Penh: MAFF)

MAFF (2010c), "Economic Land Concession Company Profile", http//www.maff.gov.kh (accessed 17 March 2011)

MAFF (2008), Annual Conference on Agriculture, Fisheries and Forestry (Phnom Penh: MAFF)

MAFF (2007), Annual Conference on Agriculture, Fisheries and Forestry (Phnom Penh: MAFF)

MAFF (2005), "Cambodia Agricultural Sector Strategic Development Plan 2006-10" (Phnom Penh: MAFF)

MAFF (2000), "Overall Annual Report on Agriculture, Forestry and Fisheries" (in Khmer) (Phnom Penh: MAFF)

MAFF & MoWRAM (2008), "Strategy on Agriculture and Water" (Phnom Penh: MAFF)

Melnyk, M. & J. Schweithelm (2006), "Cambodia: The Human Impact of Forest Conflict" (ARD, Inc: USAID)

MoE (2010), Unsustainable Agricultural Practices (unpublished handout, on Cambodia National Environmental Performance Assessment (EPA) at Sunway Hotel, Phnom Penh, Cambodia, 18-19 February 2010

MoE & UNDP (2010), "Building Resilience: *The Future of Rural Livelihoods in the Face of Climate Change*", Cambodia Human Development Report (Phnom Penh: MoE & UNDP)

MoE & Danida (2007), "State of Coastal Environment and Socioeconomic Report" (Phnom Penh: MoE)

MRC (2002), Cambodia Flood Maps, http://www.mrcmekong.org/ download/free_ download/ Social-Atlas/additional_maps.pdf (accessed 10 June 2011)

NANG Phirun, KHIEV Daravy, Philip HIRSCH and Isabelle WHITEHEAD, 2011: Improving the Governance of Water Resources in Cambodia: A Stakeholder Analysis, Working Paper Series No. 54 (Phnom Penh: CDRI)

National Institute of Statistics (2009), *General Population Census of Cambodia 2008: National Report on Final Census Results* (Phnom Penh: MoP)

Neou B. (2001), "Tonle Sap Ecosystem and Value" (Phnom Penh: MoE)

NIS (2008), *Statistical Yearbook of Cambodia 2008* ( Phnom Penh: MoP)

NASA (2011), "Ninth Warmest Year Yet", http://www.mongabay.com (accessed 23 January 2012)

Radio Free Asia (2011), "Communities Concern the Loss of Non-Timber Forest Product; Prey Long, Sandan district, Kompong Thom Province", www.rfa.org (accessed 3 March 2011)

RGC (2009), "Post Disaster Needs Assessment at a Glance 2009: Ketsana storm and floods, September and October 2009", http://www.gfdrr.org/gfdrr/sites/gfdrr.org/files/ Cambodia_ PDNA_GLANCE.pdf (accessed 16 March 2011)

Ros B. (2003), Toward Sustainable Management of Natural Resources for Community Livelihood in Peam Krasoab Wildlife Sanctuary, Koh Kong province, Cambodia (Bangkok: Asian Institute of Technology)

ROS Bansok, NANG Phirun, CHHIM Chhun (2011), Agricultural Development and Climate Change: the Case of Cambodia, Working Paper 65 (Phnom Penh: CDRI)

Thuok N. (2009), FUTURE: A Strategic Planning Framework for Fisheries 2009-2018. Fisheries Administration (Phnom Penh: FiA)

UNDP (2009), "Promoting Climate Resilience Water Management and Agricultural Practices In Rural Cambodia", http://www.un.org.kh/what-we-do/projects/climate-resilience -in-agriculture-and water (accessed 15 March 2011)

UNDP (2011), "Building Resilience: the Future for Rural Livelihoods in the Face of Climate Change" (Phnom Penh: UNDP)

Wokker, C., Santos, P., Ros Bansok & K. Griffiths (2011a), *Irrigation Water Productivity in Cambodian Rice System*, Working Paper Series No. 51 (Phnom Penh: CDRI)

Wokker, C., P. Santos, Ros Bansok & K. Griffiths (2011b), "The Value of Irrigation to Productivity in Cambodian Rice Systems," Policy Brief No. 3 (Phnom Penh: CDRI)

World Bank (2009), "Sustaining Rapid Growth in a Challenging Environment, Cambodia Country Economic Memorandum" www.worldbank.org/kh (Phnom Penh: World Bank)

-៤-

# បទពិសោធន៍រៀនបានពីកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក

*ដោយលោក គឹម សួ*[១]


## សេចក្តីសង្ខេប

អត្ថបទនេះ ព្យាយាមចែករំលែកនូវមេរៀនបទពិសោធន៍ ដែលទទួលបានពីការគ្រប់គ្រង និងអនុវត្ត នូវកម្មវិធីអភិវឌ្ឍន៍សមត្ថភាពស្រាវជ្រាវនិងគ្រប់គ្រងធនធានទឹក (WRMRCDP) អស់រយៈពេលប្រាំឆ្នាំ ចំពោះ ប្រព័ន្ធធារាសាស្ត្រ ១០កន្លែង ក្នុងបីខេត្តនៅជុំវិញបឹងទន្លេសាប។ កម្មវិធីនេះមានគោលដៅស្នូលបី គឺ៖ ១) ធ្វើការសិក្សាស្រាវជ្រាវប្រកបដោយគុណភាពខ្ពស់ ២) លើកកម្ពស់សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក និង ៣) ផ្សព្វផ្សាយចំណេះដឹង និងព័ត៌មានដែលទទួលបានពីការសិក្សា។

កម្មវិធីនេះមិនត្រឹមតែទទួលបាននូវផលិតផលជាច្រើន សមិទ្ធផលយូរអង្វែង និង អត្ថប្រយោជន៍មាននិរន្តរភាព ប៉ុណ្ណោះទេ ប៉ុន្តែ វាថែមទាំងឆ្លុះបញ្ចាំងនូវបញ្ហាប្រឈម និងការលំបាកមួយចំនួនទៀត ដែលអាចយកមកធ្វើជាមេរៀន សម្រាប់ជួយដល់អ្នកធ្វើគោលនយោបាយ វិស័យធនធានទឹកបានទៀតផង។

ដើម្បីធានាបាននូវចីរភាព ប្រសិទ្ធភាព និងស្មើភាព នៃការគ្រប់គ្រងនិងបែងចែកធនធានទឹកនៅក្នុងប្រទេស ក៏ដូចដើម្បីអនុវត្តកម្មវិធីឬគម្រោងការមួយឲ្យបានជោគជ័យ អនុសាសន៍ពីកម្មវិធី WRMRCDP សម្រាប់សកម្មភាពទៅអនាគត រួមមាន៖ ការបន្តការសិក្សាវាយតម្លៃផ្នែកសេដ្ឋកិច្ច-សង្គមក្នុងរយៈពេលវែង ការសិក្សាតាមរបៀបម៉ូដែលសម្រាប់វិភាគជលសាស្ត្រ ការចម្លងយកវិធីសាស្ត្រសិក្សារបៀបនេះទៅប្រើក្នុងផ្ទៃរងទឹកភ្លៀងផ្សេងទៀត ដែលមានលក្ខណៈស្រដៀងគ្នា ការអនុវត្តនូវវិធីសាស្ត្រសកម្មភាពសិក្សាដោយមានការចូលរួម ការជួយឧបត្ថម្ភគាំទ្របន្ថែមដល់សហគមន៍កសិករប្រើប្រាស់ទឹកក្នុងការពង្រឹងសមត្ថភាព ដើម្បីអភិវឌ្ឍប្រព័ន្ធធារាសាស្ត្រ ការបង្កើតស្ថាប័នគ្រប់គ្រងដែនរងទឹកភ្លៀងចម្រុះ និងការបង្កើតនូវយុទ្ធសាស្ត្រទំនាក់ទំនងដ៏មានន័យមួយ។


## ១. សេចក្តីផ្តើម

កម្មវិធី WRMRCDP ទទួលបានមូលនិធិពី ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ (AusAID) ហើយត្រូវបានអនុវត្តឡើងពីឆ្នាំ២០០៦ ដល់ ២០១១ ក្រោមកិច្ចសហការយ៉ាងជិតស្និទ្ធរវាង វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) សាកលវិទ្យាល័យភូមិន្ទភ្នំពេញ (RUPP) និង សាកលវិទ្យាល័យស៊ីដនី (UoS) ព្រមទាំងមានការចូលរួមពីក្រសួងមន្ទីររដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក៏ដូចជា អាជ្ញាធរមូលដ្ឋាន (ឧទាហរណ៍ ក្រុមប្រឹក្សាឃុំ) និង សហគមន៍កសិករប្រើប្រាស់ទឹក (FWUCs) ផងដែរ។

អត្ថបទនេះ មានបំណងចែករំលែកបទពិសោធន៍ដែលទទួលបានពីកម្មវិធី WRMRCDP

---

១ លោក គឹម សួ ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

ដោយផ្តោតលើ ផលិតផលសម្រេចបាន និងលទ្ធផលស្រាវជ្រាវ ព្រមទាំងបញ្ហាប្រឈម និងមេរៀនបទពិសោធន៍ដែលទទួលបាន សម្រាប់អនុវត្តគម្រោងនិងកម្មវិធីរបៀបនេះនៅពេលក្រោយ។

## ២. គោលដៅ និងកម្មវត្ថុ

គោលដៅធំបំផុតនៃ WRMRCDP គឺ "លើកកម្ពស់ការប្រើប្រាស់និងអភិបាលកិច្ចធនធានទឹក ដើម្បីបង្កើនផលិតកម្មកសិកម្ម និងការប្រើប្រាស់ធនធានធម្មជាតិនៅកម្ពុជាប្រកបដោយនិរន្តរភាព"។ កម្មវិធីនេះ ក៏ដើម្បីជួយគាំទ្រដល់ការអភិវឌ្ឍសមត្ថភាពក្នុងការស្រាវជ្រាវនិងគ្រប់គ្រងធនធានទឹក និងគោលនយោបាយធនធានទឹក ដោយរៀបចំឲ្យមានការចូលរួមពីកសិករ អ្នកស្រាវជ្រាវ អ្នកគ្រប់គ្រង និងអ្នកធ្វើគោលនយោបាយតាំងពីកម្រិតថ្នាក់ជាតិ រហូតដល់កម្រិតមូលដ្ឋាន។

ដើម្បីឲ្យសម្រេចគោលដៅខាងលើ កម្មវិធី WRMRCDP បានកំណត់នូវកម្មវត្ថុចម្បងៗបី ៖ (១) បង្កើតទិន្នន័យ និងចំណេះដឹងប្រកបដោយគុណភាព លើការស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹកនៅកម្ពុជា (២) លើកកម្ពស់សមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹកនៅកម្ពុជា និង (៣) បង្កើត និងចែកចាយចំណេះដឹង និងព័ត៌មានប្រកបដោយគុណភាពខ្ពស់និងគួរឲ្យជឿជាក់ស្តីពីការគ្រប់គ្រងធនធានទឹក។

## ៣. វិធីសាស្ត្រ សកម្មភាព និងទីតាំងសិក្សា

សកម្មភាពទាំងអស់ក្នុងកម្មវិធីនេះ បានអនុវត្តចាប់ពីថ្ងៃទី១ កក្កដា ២០០៦ ដល់ថ្ងៃទី៣០ កញ្ញា ២០១១ លើប្រព័ន្ធធារាសាស្ត្រចំនួន ១០កន្លែង ក្នុងបីខេត្ត ដែលរួមមាន កំពង់ធំ ពោធិ៍សាត់ និង កំពង់ឆ្នាំង។ ការស្រាវជ្រាវស៊ីជម្រៅ បានអនុវត្តឡើងក្នុងដែនផ្ទៃរងទឹកភ្លៀងបីកន្លែង នៅតំបន់បឹងទន្លេសាប គឺមាន អាងស្ទឹងជ្រៃបាក់ ស្ទឹងពោធិ៍សាត់និងស្ទឹងជីនិត និង រលួស (ស្ទឹងសែន)។

ការស្រាវជ្រាវដែលជាសកម្មភាពស្នូលក្នុងកម្មវត្ថុទី១ នៃកម្មវិធី មានចែកចេញជាបីសមាសភាគ គឺ សមាសភាគអភិបាលកិច្ចធនធានទឹក (ការវិភាគអភិបាលកិច្ចធនធានទឹក) សមាសភាគសេដ្ឋកិច្ច (ការវិភាគសេដ្ឋកិច្ចលើការគ្រប់គ្រងធនធានទឹក) និង សមាសភាគធារាសាស្ត្ររូបវន្ត (ការវិភាគកត្តារូបវន្តនៃការគ្រប់គ្រងធនធានទឹក)។

សកម្មភាពនានាក្នុងបីសមាសភាគខាងលើ បានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវជាច្រើន ដូចជា ការសិក្សាឯកសារមានស្រាប់ ការវាយតម្លៃសង្គម/ស្ថាប័ន បច្ចេកទេសវាយតម្លៃតំបន់ជនបទដោយមានការចូលរួម (PRA)/បច្ចេកទេសសកម្មភាពរៀនសូត្រដោយមានការចូលរួម (PLA) ដែលមានជាអាទិ៍ ការគូរផែនទីធនធានទឹកដោយមានការចូលរួម ការប្រមូលព័ត៌មានផ្ទាល់នៅច្រើនកន្លែងដើម្បីផ្ទៀងផ្ទាត់ ការសម្ភាសអ្នកផ្តល់ព័ត៌មានគន្លឹះ (KII) និង ការពិភាក្សាតាមក្រុមស្នូល (FGD)។ ឧបករណ៍សិក្សាផ្នែកជាតិពន្ធសាស្ត្រ ការបង្កើតម៉ូដែលវិភាគជលសាស្ត្រ និង អង្កេតគ្រួសារដើម្បីវាយតម្លៃផ្នែកសេដ្ឋកិច្ច ក៏បានយកមកប្រើប្រាស់ផងដែរ។

កម្មវិធីនេះ ក៏មានគោលដៅជួយកសាងសមត្ថភាពអ្នកស្រាវជ្រាវ មន្ត្រីរដ្ឋាភិបាលជាដៃគូ មន្ត្រីស្ថាប័នខេត្ត និង អាជ្ញាធរមូលដ្ឋាន ផងដែរ។ សកម្មភាពកសាងសមត្ថភាពនេះ រួមមាន ការអប់រំថ្នាក់ក្រោយឧត្តមជាផ្លូវការ វគ្គបណ្តុះបណ្តាលជាផ្លូវការរយៈពេលខ្លី ទស្សនកិច្ចសិក្សា និងការចុះសិក្សាដល់កន្លែងជាច្រើនលើក។

សកម្មភាពចម្បងមួយទៀតក្នុងកម្មវិធីនេះ គឺ ការផ្សព្វផ្សាយព័ត៌មាននិងលទ្ធផលស្រាវជ្រាវ

ដើម្បីលើកកម្ពស់ការយល់ដឹង និងជូនយោបល់ដល់អ្នកធ្វើសេចក្តីសម្រេចចិត្តលើគោលនយោបាយរបស់រដ្ឋាភិបាល ស្តីពីការគ្រប់គ្រងប្រព័ន្ធធារាសាស្ត្រ និងធនធានទឹកនៅកម្ពុជា។

## ៤. លទ្ធផលសំខាន់ៗ

ជាបឋម ក្នុងការកសាងសមត្ថភាពស្រាវជ្រាវ និងធនធានមនុស្ស មានអ្នកស្រាវជ្រាវពីររូប មកពីកម្មវិធីធនធានធម្មជាតិ និងបរិស្ថាន នៃវិទ្យាស្ថាន CDRI បានទៅសិក្សាថ្នាក់ក្រោយឧត្តមសិក្សានៅសាកលវិទ្យាល័យស៊ីដនី ប្រទេសអូស្ត្រាលី ក្នុងនោះ មានម្នាក់បានបញ្ចប់ថ្នាក់អនុបណ្ឌិត និងម្នាក់ទៀតបានបញ្ចប់ថ្នាក់បណ្ឌិត។ អ្នកស្រាវជ្រាវម្នាក់ទៀតមកពី សាកលវិទ្យាល័យភូមិន្ទភ្នំពេញ បានបញ្ចប់ថ្នាក់អនុបណ្ឌិតនៅសាកលវិទ្យាល័យស៊ីដនី លើជំនាញប្រព័ន្ធព័ត៌មានភូមិសាស្ត្រ និងរូបភាពផ្កាយរណប (GIS and Remote Sensing)។ វគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងវគ្គបណ្តុះបណ្តាលភ្ជាប់នឹងការងារចំនួនប្រាំ បានអនុវត្តឡើង គឺមាន ១) សេដ្ឋកិច្ចមាត្រសាស្ត្រ និងការវិភាគទិន្នន័យ STATA ២) ឧបករណ៍សិក្សាផ្នែកជាតិពន្ធុសាស្ត្រ និងបច្ចេកទេស ៣) ប្រព័ន្ធព័ត៌មានភូមិសាស្ត្រនិងរូបភាពផ្កាយរណប (Basic GIS and Remote Sensing) ៤) សកម្មភាពស្រាវជ្រាវដោយមានការចូលរួម និង ៥) បច្ចេកទេសអង្កេតគ្រួសារ (FGD, PRA[២] និង KII)។

មួយចំណែកទៀត កម្មវិធីធនធានធម្មជាតិ និងបរិស្ថាន (NRE) នៃវិទ្យាស្ថាន CDRI ក៏បានទទួលនិស្សិតពីសាកលវិទ្យាល័យស៊ីដនី មកហាត់ការចំនួនប្រាំរូប ដើម្បីចែករំលែកបទពិសោធន៍នៃកម្មវិធី WRMRCDP ជាមួយអ្នកស្រាវជ្រាវជនជាតិអូស្ត្រាលីវ័យក្មេងទាំងនោះ។ ការកសាងសមត្ថភាព និងបំផុសការយល់ដឹង ក៏បានធ្វើឡើងតាមរយៈសិក្ខាសាលានិងកិច្ចប្រជុំផ្សេងៗ ជាពិសេស សិក្ខាសាលាថ្នាក់ខេត្តដែលបានផ្តល់ជា វេទិកាដ៏មានប្រយោជន៍សម្រាប់ការចែករំលែកព័ត៌មាន និងផ្សព្វផ្សាយលទ្ធផលស្រាវជ្រាវទៅដល់អ្នកពាក់ព័ន្ធនៅតាមខេត្ត និងតាមមូលដ្ឋាននានា។

ឯកសារពិភាក្សា និងអត្ថបទសង្ខេបគោលនយោបាយចំនួន ២៥ ដែលទាក់ទងនឹងការគ្រប់គ្រង និងប្រើប្រាស់ធនធានទឹកនៅកម្ពុជា បានបោះពុម្ពផ្សាយជាភាសាខ្មែរ និងភាសាអង់គ្លេស។ លើសពីនេះទៀត និក្ខេបបទបញ្ចប់ថ្នាក់ក្រោយឧត្តមសិក្សាចំនួនបី (ថ្នាក់អនុបណ្ឌិត ពីរ និងថ្នាក់បណ្ឌិត មួយ) បានបោះពុម្ពផ្សាយដោយកម្មវិធីនេះ ហើយកម្រងវីដេអូសង្ខេបរយៈពេល ៣០នាទីមួយ អំពីប្រតិបត្តិការ និងភាពជោគជ័យនៃកម្មវិធីនេះ ក៏បានបង្កើតឡើងផងដែរ។ កម្មវិធី WRMRCDP ក៏បានតាក់តែងជាអត្ថបទចុះផ្សាយក្នុង ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា និង របាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ របស់វិទ្យាស្ថាន CDRI និងបានធ្វើការផ្សព្វផ្សាយនៅក្នុងសិក្ខាសាលា និងកិច្ចប្រជុំនានា ជាពិសេសតាមរយៈ ការជួបប្រស្រ័យដោយផ្ទាល់ជាមួយសហគមន៍មូលដ្ឋាន ដោយមានការបង្ហាញផ្ទាំងរូបភាព និងការបកស្រាយនូវគោលគំនិតសំខាន់ៗមួយចំនួន។

អ្នកស្រាវជ្រាវ និងសាស្ត្រាចារ្យនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ដែលជាដៃគូសហការក្នុងកម្មវិធីនេះ បានបង្កើតម៉ូឌុលសិក្សាចំនួនប្រាំ គឺមាន ១) អភិបាលកិច្ចធនធានទឹក ២) ប្រព័ន្ធនិងការគ្រប់គ្រងធនធានទឹក ៣) ប្រព័ន្ធព័ត៌មានភូមិសាស្ត្រនិងរូបភាពផ្កាយរណប (Fundamental GIS and Remote Sensing) ៤) ទឹកនិងជីវភាពរស់នៅ និង ៥) ការចូលរួមធ្វើផែនការដែនដីប្រើប្រាស់។

---

២ ការវាយតម្លៃនៅជនបទដោយមានការចូលរួម

## ៥. សមិទ្ធផលយុរអង្វែងសំខាន់ៗ

សមត្ថភាពសិក្សាស្រាវជ្រាវរបស់អ្នកស្រាវជ្រាវកម្ពុជា បានរីកលូតលាស់យ៉ាងខ្លាំង ឆ្លងតាមការអនុវត្តសកម្មភាពទាំងឡាយរបស់កម្មវិធី WRMRCDP។ វគ្គបណ្តុះបណ្តាលរយៈពេលខ្លី និងវគ្គបណ្តុះបណ្តាលភ្ជាប់នឹងការងារអនុវត្ត បានធ្វើឡើងសម្រាប់អ្នកចូលរួមដែលចុះដាប់ផ្ទាល់នឹងការសិក្សាដល់កន្លែង។

លទ្ធផលស្រាវជ្រាវ និងអនុសាសន៍សម្រាប់ការគ្រប់គ្រងធនធានទឹកទៅអនាគត ក្នុងនោះមានទាំងការគ្រប់គ្រងអាងស្ទឹង/ទន្លេផងដែរ បានជួយបំពេញចន្លោះខ្វះខាតផ្នែកចំណេះដឹង ហើយផ្នែកខ្លះ គឺអ្នកធ្វើគោលនយោបាយបានទទួលយកក្នុងការបង្កើតគោលនយោបាយវិស័យទឹក។ ក្នុងដំណើរការអនុវត្តប្រាំឆ្នាំនេះ កម្មវិធី WRMRCDP បានធ្វើការជួបប្រជុំជាច្រើន ដូចជា កិច្ចប្រជុំគណៈកម្មាធិការពិគ្រោះយោបល់ សិក្ខាសាលាថ្នាក់ជាតិនិងថ្នាក់ខេត្ត និង កិច្ចសន្ទនាគោលនយោបាយជាមួយមន្ត្រីជាន់ខ្ពស់នៃក្រសួងធនធានទឹក និងឧតុនិយម និងក្រុមការងារបច្ចេកទេសស្តីពីកសិកម្មនិងទឹក ជាដើម ដើម្បីផ្សព្វផ្សាយ និងពិភាក្សាពីលទ្ធផលស្រាវជ្រាវដែលជាប់ទាក់ទងដល់គោលនយោបាយ។

អ្នកពាក់ព័ន្ធនានា មានការយល់ដឹងកាន់តែប្រសើរពីតម្លៃនិងសារៈសំខាន់នៃធនធានទឹកចំពោះសេដ្ឋកិច្ច និងជីវភាពរស់នៅ។ ប្រជាជននៅតាមមូលដ្ឋានភាគច្រើនតែងតែគិតថា ទឹកបានមកពីភ្លៀងធ្លាក់ពីលើមេឃ ដូច្នេះគួរតែប្រើប្រាស់បានដោយគ្មានបង់ថ្លៃ។ ទន្ទឹមគ្នានេះ កសិករនៅតំបន់ខ្សែទឹកខាងក្រោមក្នុងឃុំតាំងក្រសាំង មិនមានទឹកគ្រប់គ្រាន់សម្រាប់ស្រោចស្រពដំណាំស្រូវរបស់ខ្លួនទេ។ តាមរយៈសកម្មភាពក្នុងកម្មវិធី WRMRCDP ពួកគាត់បានចាប់ផ្តើមទទួលស្គាល់និងយល់ដឹងពីតម្លៃ និងផលប្រយោជន៍នៃធនធានទឹក ហើយពេញចិត្តចំពោះកិច្ចប្រឹងប្រែងរបស់អាជ្ញាធរថ្នាក់មូលដ្ឋាន និងរដ្ឋាភិបាលថ្នាក់ជាតិ ក្នុងការជួយដល់ពួកគាត់កសាងប្រព័ន្ធធារាសាស្ត្រដើម្បីឲ្យមានទឹកគ្រប់គ្រាន់សម្រាប់ការប្រើប្រាស់ក្នុងផ្ទះ និងដំណាំស្រូវ ជាពិសេសស្រូវប្រាំង។

ឆ្លងតាមសិក្ខាសាលា និងកិច្ចប្រជុំជាច្រើន មានការទទួលស្គាល់ពីតម្លៃនៃការគ្រប់គ្រងទឹកប្រកបដោយការសម្របសម្រួលល្អ ដែលបំផុសការចូលរួមយ៉ាងសកម្ម ក្នុងការប្រើប្រាស់ទឹកឲ្យមានប្រសិទ្ធភាពជាអតិបរមា លើផ្ទៃដីគិតបញ្ចូលគ្នាទាំងអស់ របស់អ្នកប្រើប្រាស់ទឹកនៅតំបន់ខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម។ សកម្មភាពនេះ រួមមាន ការភ្ជាប់ទំនាក់ទំនង ភាពជាដៃគូ និងកិច្ចសហប្រតិបត្តិការរវាងអ្នកប្រើប្រាស់ និងតួអង្គសំខាន់ៗ ជាពិសេសសមាជិកសហគមន៍កសិករប្រើប្រាស់ទឹក និងកសិករទាំងអស់។ ដោយយល់ឃើញពីសារៈសំខាន់ដ៏ខ្លាំងក្លានៃលទ្ធភាពប្រើប្រាស់ទឹកប្រកបដោយសមធម៌នៅតំបន់ខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម និងកម្រិតលំហូរតាមស្ទឹង (e-flow) អ្នកពាក់ព័ន្ធនានាបានស្នើឡើងនៅក្នុងសិក្ខាសាលាថ្នាក់ខេត្តកាលពីឆ្នាំ២០១០ និង ២០១១ នូវយន្តការគ្រប់គ្រងធនធានទឹកមួយ ដែលត្រូវធ្វើការសម្របសម្រួលតាមរយៈគណៈកម្មាធិការគ្រប់គ្រងផ្ទៃរងទឹកភ្លៀងចម្រុះ (Chem *et al.* 2010)។

ការយល់ដឹង និងការទទួលស្គាល់ពីតម្លៃ និងសារៈសំខាន់នៃចំណេះដឹងជលសាស្ត្រក្នុងការគ្រប់គ្រងធនធានទឹក បានកើនឡើងគួរឲ្យកត់សម្គាល់ ឆ្លងតាមការចូលរួមយ៉ាងសកម្មរបស់អ្នកពាក់ព័ន្ធថ្នាក់ខេត្ត និងថ្នាក់តំបន់ក្នុងសកម្មភាពនានារបស់កម្មវិធី។ ទិន្នន័យ និងព័ត៌មានស្តីពីកម្រិតនិងលំហូរទឹកស្ទឹង បានប្រគល់ទៅឲ្យមន្ទីរធនធានទឹក និងឧតុនិយមខេត្តកំពង់ឆ្នាំង រួចហើយ ដើម្បីឲ្យមន្ទីរអាចយកទៅប្រើប្រាស់បានទៅអនាគត។

កម្មវិធី WRMRCDP ក៏បានប្រមូលផ្តុំចំណេះដឹងផ្នែកជលសាស្ត្រ និងសង្គមសាស្ត្រ ហើយដាក់បញ្ចូលទៅក្នុងគោលគំនិតនៃការគ្រប់គ្រង និងបែងចែកធនធានទឹក។ ឧទាហរណ៍ នៅឆ្នាំ២០០៥ ស្រូវប្រាំងប្រមាណ ៣០០ហិកតា បានរងការខូចខាតនៅតំបន់ដែនរងទឹកភ្លៀងស្ទឹងជ្រៃបាក់ ដោយសារកង្វះទឹកជាក់ស្តែងផង និងកង្វះយន្តការបែងចែកទឹកផង។ ដោយសារមានតំបន់ជាច្រើនត្រូវប្រឈមនឹងកង្វះខាតទឹកនៅរដូវប្រាំង កសិករ និងអាជ្ញាធរមូលដ្ឋាន ក៏បានជ្រួតជ្រាបថា ការកសាងប្រព័ន្ធធារាសាស្ត្រមិនមែនជាដំណោះស្រាយតែមួយគ្រប់គ្រាន់នោះទេ គឺត្រូវមានអន្តរកម្មក្នុងសង្គមរវាងអ្នកប្រើប្រាស់ ក្នុងការធ្វើផែនការ និងការបែងចែកធនធានទឹកទៀតផង។

ម្យ៉ាងទៀត ការចូលរួមរបស់អ្នកប្រើប្រាស់ទឹកក្នុងការបង្កើតនិងប្រើប្រាស់ចំណេះដឹងស្តីពីការគ្រប់គ្រងធនធានទឹក ក៏បានល្អប្រសើរឡើងដែរ។ សមាជិកសហគមន៍កសិករប្រើប្រាស់ទឹកបានចូលរួមយ៉ាងសកម្មក្នុងការប្រមូលទិន្នន័យក្រោមកម្មវិធី WRMRCDP មានជាអាទិ៍ ការវាស់កម្រិតកម្ពស់ទឹកជាប្រចាំ និង រំហួតទឹក ដោយប្រើឧបករណ៍វាស់វែងផ្សេងៗ (water gauges and Lycimeters)។ ទិន្នន័យកម្រិតកម្ពស់ទឹកស្ទឹង មានសារៈសំខាន់ខ្លាំងណាស់សម្រាប់ការធ្វើផែនការដាំដុះ និងការស្រោចស្រព។ កសិករអាចទស្សន៍ទាយពីលទ្ធភាពមានទឹកប្រើប្រាស់ (ការផ្គត់ផ្គង់ទឹក) ដោយផ្អែកលើទិន្នន័យកម្រិតកម្ពស់ទឹកក្នុងអាងស្តុកទឹករបស់ពួកគាត់។

អ្នកប្រើប្រាស់ទឹក មិនមែនជាក្រុមតែមួយគត់ដែលបានចូលរួមយ៉ាងសកម្មក្នុងការបង្កើតចំណេះដឹងនោះទេ ព្រោះមានអ្នកពាក់ព័ន្ធជាច្រើនទៀត ដូចជា សហគមន៍កសិករប្រើប្រាស់ទឹក អាជ្ញាធរមូលដ្ឋាន មន្ទីរក្រសួងថ្នាក់ខេត្ត និងថ្នាក់ជាតិជាប់ពាក់ព័ន្ធនឹងការគ្រប់គ្រងធនធានទឹក ក៏បានចូលរួមចំណែកផងដែរ។ សមាជិកសហគមន៍កសិករប្រើប្រាស់ទឹក និងមន្ត្រីរបស់មន្ទីរធនធានទឹក និងឧតុនិយម មកពីខេត្តទាំងបី បានចែករំលែកបទពិសោធន៍ និងផ្តល់មតិពីបញ្ហាប្រឈមនានាទាក់ទងនឹងការគ្រប់គ្រងធនធានទឹក នៅក្នុងសិក្ខាសាលាថ្នាក់ខេត្ត និងក្នុងពេលធ្វើទស្សនកិច្ចដល់តំបន់គ្រប់គ្រងប្រព័ន្ធធារាសាស្ត្រក្នុងខេត្តតាកែវ ហើយសកម្មភាពនេះបានបង្កើតជាក្របខ័ណ្ឌមួយសម្រាប់ការពិភាក្សាក្នុងស្មារតីសហការគ្នា។

## ៦. អត្ថប្រយោជន៍មាននិរន្តរភាពទៅអនាគត

អត្ថប្រយោជន៍មាននិរន្តរភាពទៅអនាគតដ៏សំខាន់បំផុតមួយនៃកម្មវិធី WRMRCDP គឺការលើកកម្ពស់សមត្ថភាពពហុវិស័យ និងជំនាញផ្នែកធារាសាស្ត្រ និងធនធានទឹក របស់អ្នកឯកទេសកម្ពុជានៅវិទ្យាស្ថាន CDRI និងសាកលវិទ្យាល័យ RUPP ដែលអាចក្លាយជាធនធានមនុស្សសម្រាប់ការស្រាវជ្រាវប្រកបដោយនិរន្តរភាព និង ការអភិវឌ្ឍធនធានទឹក នាពេលអនាគត។ អ្នកស្រាវជ្រាវបានបញ្ចប់ការសិក្សាពីសាកលវិទ្យាល័យស៊ីដនី នឹងបន្តការងារជាអ្នកស្រាវជ្រាវ និងជាទីប្រឹក្សាដ៏មានគុណភាពខ្ពស់ សម្រាប់វិទ្យាស្ថាន CDRI សាកលវិទ្យាល័យ RUPP ស្ថាប័នរដ្ឋាភិបាល និងអង្គការមិនមែនរដ្ឋាភិបាលនានា។

កម្មវិធីនេះ បានពង្រឹងវប្បធម៌ដែលមានស្រាប់នៃភាពជាដៃគូ និងការភ្ជាប់ទំនាក់ទំនងរវាងសហគមន៍កសិករប្រើប្រាស់ទឹក រវាងតំបន់ខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម និងទំនាក់ទំនងជាមួយអាជ្ញាធរមូលដ្ឋាន (អាជ្ញាធរស្រុក និងក្រុមប្រឹក្សាឃុំ) និងស្ថាប័នជំនាញក្នុងតំបន់សិក្សា ដើម្បីដោះស្រាយទំនាស់ផ្សេងៗទាក់ទងនឹងតម្រូវការទឹក និងការប្រជែងក្នុងការប្រើប្រាស់ទឹក។

បណ្ដាញ និងភាពជាដៃគូទាំងនេះ ផ្ដល់អត្ថប្រយោជន៍ដល់អ្នកស្រាវជ្រាវ និងសហគមន៍មូលដ្ឋាន ទាំងសម្រាប់ពេលបច្ចុប្បន្ន និងតទៅអនាគត ព្រោះដៃគូអភិវឌ្ឍន៍ដែលចាប់អារម្មណ៍លើវិស័យនេះ នឹងអាចប្រើប្រាស់បណ្ដាញនេះបានជារៀងរហូត។

ទិន្នន័យ និងលទ្ធផលនៃការវិភាគជលសាស្ត្រ និងការបង្កើតម៉ូដែលសម្រាប់វិភាគពីតម្រូវការ និងការផ្គត់ផ្គង់ទឹកដ៏ប្រសើរក្នុងតំបន់ផ្ទៃរងទឹកភ្លៀងស្ទឹងជ្រៃបាក់ នឹងទទួលបានការអនុម័តយក និងដាក់ឲ្យអនុវត្តនៅទូទាំងតំបន់ផ្ទៃរងទឹកភ្លៀង ឬនៅក្នុងគម្រោងធារាសាស្ត្រនីមួយៗ ដើម្បីសម្រេចបាននូវការចែកចាយទឹកប្រកបដោយសមធម៌ និងយុត្តិធម៌។ ម៉្យាងវិញទៀត លទ្ធផលបានមកពីសមាសភាគទាំងបីនៃកម្មវិធី WRMRCDP គឺត្រូវបាន និងកំពុងបន្តដកស្រង់យកទៅប្រើប្រាស់ដោយស្ថាប័ន និងបុគ្គលនានា ដែលធ្វើការងារដោយផ្ទាល់ ឬដោយប្រយោល ក្នុងវិស័យអភិវឌ្ឍន៍ធនធានទឹកនៅប្រទេសកម្ពុជា។

យោងតាមអនុសាសន៍ក្នុងលទ្ធផលស្រាវជ្រាវនៃកម្មវិធី WRMRCDP ជាពិសេសអនុសាសន៍ស្ដីពី អភិបាលកិច្ចដែនរងទឹកភ្លៀង គេគួរបង្កើតនូវគណៈកម្មាធិការអាងស្ទឹងចម្រុះមួយឡើង (សម្រាប់ផ្ទៃរងទឹកភ្លៀង) ក្នុងតំបន់ស្ទឹងជ្រៃបាក់ខេត្តកំពង់ឆ្នាំង ស្ទឹងពោធិ៍សាត់ខេត្តពោធិ៍សាត់ និងផ្ទៃរងទឹកភ្លៀងស្រដៀងគ្នាដទៃទៀត នៅទូទាំងប្រទេស។

ការបញ្ជ្រាបនៃម៉ូឌុលសិក្សាថ្នាក់ឧត្តមសិក្សាទាំងប្រាំ ដែលបង្កើតឡើងនៅក្នុងកម្មវិធី WRMRCDP ដោយដៃគូនៅ RUPP ទៅក្នុងកម្មវិធីសិក្សាផ្នែកបរិស្ថានវិទ្យា នៃសាកលវិទ្យាល័យនេះ អាចផ្ដល់អត្ថប្រយោជន៍ជាបន្តបន្ទាប់ និងប្រកបដោយនិរន្តរភាព ដល់និស្សិតកម្ពុជាដែលចាប់អារម្មណ៍លើការគ្រប់គ្រងធនធានធម្មជាតិ ជាពិសេសធនធានទឹក។

## បទពិសោធន៍រៀនបាន និងការយល់ឃើញ

ការកសាងសមត្ថភាពប្រកបដោយជោគជ័យ ក្នុងរចនាសម្ព័ន្ធគ្រប់គ្រងវិស័យទឹកដ៏ស្មុគស្មាញនេះ ទាមទារនូវការវិនិយោគរយៈពេលវែង ជាពិសេស នៅពេលមានអ្នកពាក់ព័ន្ធជាច្រើនមកពីស្ថាប័ន និងអង្គការផ្សេងៗគ្នាចូលរួម។ ការវិភាគពីទស្សនៈ និងកម្លាំងចម្រុះរួមគ្នារបស់អ្នកពាក់ព័ន្ធនានា អាចផ្ដល់ជាគំនិតដ៏មានប្រយោជន៍សម្រាប់ការកសាងសមត្ថភាពរបស់អ្នកពាក់ព័ន្ធនៅពេលចាប់ផ្ដើមកម្មវិធី។

កម្មវិធី WRMRCDP អាចកំណត់ន័យបានថា ជា "ការគ្រប់គ្រងធនធានទឹកដោយសម្របសម្រួល" ពីព្រោះការដោះស្រាយតម្រូវការឲ្យយកលទ្ធផលដែលស្រាវជ្រាវឃើញទៅអនុវត្តជាក់ស្ដែង ហើយធ្វើការឆ្លុះបញ្ចាំងពីអ្វីដែលមាន ឬគ្មានប្រសិទ្ធភាព ដើម្បីកែតម្រូវនិងកែលម្អរបៀបរបបអនុវត្តនិងគោលនយោបាយជាបន្តទៅទៀត គឺជាគោលដៅដ៏សំខាន់ដែលកម្មវិធីត្រូវអនុវត្ត និងសម្រេចឲ្យបាន។

វិធីសាស្ត្រសកម្មភាពស្រាវជ្រាវរៀនសូត្រដោយមានការចូលរួម គឺជា ការលើកទឹកចិត្តអ្នកពាក់ព័ន្ធនានា ជាពិសេសកសិករ និងសហគមន៍មូលដ្ឋាន ឲ្យចូលរួមចំណែកច្រើនៗក្នុងការសម្រេចគោលដៅនៃកម្មវិធី។

ការជះឥទ្ធិពលទៅលើគោលនយោបាយ ជាពិសេសការប្រស្រ័យទាក់ទងជាមួយអ្នកធ្វើសេចក្ដីសម្រេចចិត្តលើគោលនយោបាយរដ្ឋាភិបាលនៅកម្រិតជាតិ គឺជាការពិបាក និងត្រូវចំណាយពេលច្រើន ដើម្បីទទួលបានលទ្ធផល។ ក្នុងន័យនេះ ការកសាងទំនាក់ទំនងឲ្យបានជិតស្និទ្ធប្រកបដោយទំនុកចិត្ត ជាមួយអ្នកធ្វើការសម្រេចចិត្តទាំងនោះ និងការផ្ដល់ព័ត៌មានច្បាស់លាស់

គ្រប់គ្រាន់ដល់ពួកគាត់ គឺមានសារៈសំខាន់បំផុត ដើម្បីសម្រេចគោលដៅធ្វើឲ្យលទ្ធផលស្រាវជ្រាវមានឥទ្ធិពលទៅលើគោលនយោបាយ។

បញ្ហាសង្គម និងការបារម្ភផ្សេងៗ ត្រូវតែយកមកគិតគូរ ដោយត្រូវដាក់បញ្ចូលស្ថាប័នទាំងអស់ដែលពាក់ព័ន្ធដោយផ្ទាល់ ឬដោយប្រយោលក្នុងការគ្រប់គ្រងធនធានទឹកនៅតំបន់គម្រោង ជាអ្នករួមចំណែកផង (អ្នកពាក់ព័ន្ធក្នុងកម្មវិធី) និងជាគោលដៅផង (ការវាយតម្លៃស្ថាប័ន និងសង្គម) នៃកម្មវិធី។

## ៧. អនុសាសន៍

ការវាយតម្លៃសេដ្ឋកិច្ចសង្គម និងការបង្កើតម៉ូដែលវិភាគជលសាស្ត្រនៅតំបន់ផ្ទៃរងទឹកភ្លៀងស្ទឹងជ្រៃបាក់ គួរតែអនុវត្តជាបន្តពីមួយឆ្នាំទៅមួយឆ្នាំ ដើម្បីទទួលបានទិន្នន័យ និងព័ត៌មានលម្អិតបន្ថែម។ សកម្មភាពនេះ ជួយពង្រឹងការយល់ដឹងពីផ្នែកជលសាស្ត្រ ធារាសាស្ត្រ បរិបទសេដ្ឋកិច្ចសង្គមកិច្ច និងការវិវត្តពីមួយឆ្នាំទៅមួយឆ្នាំ ដែលអាចឆ្លុះបញ្ចាំងពីភាពជាក់ស្តែងក្នុងការគ្រប់គ្រង និងបែងចែកធនធានទឹកប្រកបដោយនិរន្តរភាព។

វិធីសាស្ត្រសកម្មភាពរៀនសូត្រដោយមានការចូលរួម សម្រាប់ការស្រាវជ្រាវពហុវិស័យ និងការបង្កើតម៉ូដែលវិភាគជលសាស្ត្រ ត្រូវបានអនុវត្តក្នុងការសិក្សាពីសមាសភាគទាំងបី ជាពិសេសនៅតំបន់ដែនរងទឹកភ្លៀងស្ទឹងជ្រៃបាក់ ហើយវិធីសាស្ត្រនេះមានអត្ថប្រយោជន៍ខ្លាំងណាស់ ពីព្រោះវាអាចចម្លងតាមនិងយកទៅអនុវត្តក្នុងគ្រប់បរិបទនៃផ្ទៃរងទឹកភ្លៀងផ្សេងៗទៀតនៅទូទាំងប្រទេស ជាពិសេសនិងបន្ទាន់បំផុត នៅផ្ទៃរងទឹកភ្លៀងស្ទឹងពោធិ៍សាត់។ ដែនរងទឹកភ្លៀងនេះ មានលក្ខណៈភូមិសាស្ត្រ ជលសាស្ត្រ និងសង្គម ប្រហាក់ប្រហែលគ្នានឹងផ្ទៃរងទឹកភ្លៀងស្ទឹងជ្រៃបាក់ដែរ ជាពិសេសលើកំណើនតម្រូវការទឹកប្រើប្រាស់ និងការផ្គត់ផ្គង់ទឹកកាន់តែមានកំហិតសម្រាប់ស្រូវប្រាំង ដែលអាចបង្កភាពតានតឹងខ្លាំងរវាងគម្រោងធារាសាស្ត្រនៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម ក៏ដូចជា រវាងកសិករប្រើប្រាស់ទឹកនាពេលអនាគតដ៏ខ្លី។

ដោយស្ថិតក្នុងដំណាក់កាលដំបូងទើបកកើតឡើងនោះ សហគមន៍កសិករប្រើប្រាស់ទឹកនៅមិនទាន់រឹងមាំទេទាំងផ្នែកសមត្ថភាព និងការប្តេជ្ញាចិត្ត ហើយទាមទារការគាំទ្រ និងការកសាងពង្រឹងតទៅទៀត។ ទន្ទឹមគ្នានឹងការបណ្តុះបណ្តាលជាផ្លូវការនោះ ការស្រាវជ្រាវគួរបន្តទៅមុខទៀតដោយដាក់ឲ្យមានបុគ្គលិកមន្ទីរធនធានទឹក និងឧតុនិយម និង សហគមន៍កសិករប្រើប្រាស់ទឹកនៅតាមគម្រោងធារាសាស្ត្រទាំងអស់ក្នុងតំបន់ផ្ទៃរងទឹកភ្លៀង បានចូលរួមចំណែកផង ដើម្បីអាចទទួលបានការកសាងសមត្ថភាពផ្សារភ្ជាប់នឹងការងារ និងមានអារម្មណ៍ជាម្ចាស់កាន់តែខ្លាំងឡើង។

"គណៈកម្មការ ផ្ទៃរងទឹកភ្លៀងចម្រុះនៃស្ទឹងជ្រៃបាក់" ដែលមានសមាជិកអចិន្ត្រៃយ៍ជាអ្នកតំណាងមកពីសហគមន៍កសិករប្រើប្រាស់ទឹកនានាក្នុងតំបន់ដែនរងទឹកភ្លៀងនោះ គួរតែបង្កើតឡើងឲ្យបានឆាប់បំផុត ដើម្បីឲ្យគណៈកម្មការនោះអាចមានពេលច្រើនបំពេញតួនាទីដ៏សំខាន់ក្នុងការសម្របសម្រួលតម្រូវការ និងការផ្គត់ផ្គង់ទឹក ការដោះស្រាយទំនាស់ ជាពិសេសទំនាស់រវាងគម្រោងធារាសាស្ត្រនៅខ្សែទឹកខាងលើ និងខ្សែទឹកខាងក្រោម ព្រមទាំង ការធ្វើផែនការ និងបង្កើតយុទ្ធសាស្ត្រដើម្បីជួយដល់សហគមន៍កសិករប្រើប្រាស់ទឹកនីមួយៗ ក៏ដូចជា ការកសាងសមត្ថភាពរបស់សមាជិក និងគណៈកម្មការនៃសហគមន៍ទាំងនោះ។

ដើម្បីរក្សាសកម្មភាពស្រាវជ្រាវឲ្យមាននិរន្តរភាព ដៃគូរដ្ឋាភិបាលគួរពិចារណាឲ្យបានម៉ត់ចត់លើការដាក់បញ្ចូលលទ្ធផលស្រាវជ្រាវ និងអនុសាសន៍នានា ដែលមានចុះក្នុងអត្ថបទ

សង្ខេបគោលនយោបាយ និងឯកសារពិភាក្សានានារបស់កម្មវិធី WRMRCDP ទៅក្នុងសេចក្តីព្រាងអនុក្រឹត្យ ព្រមទាំងការកែសម្រួលថ្មីផ្សេងៗ នៅក្នុងគោលនយោបាយទាក់ទងនឹងវិស័យទឹក។

ពេលវេលាអាចយូរជាងមួយទសវត្សរ៍ ទម្រាំកិច្ចប្រឹងប្រែងជះឥទ្ធិពលទៅលើគោលនយោបាយទទួលបានលទ្ធផលខ្លះ ហើយអ្នកធ្វើគោលនយោបាយក៏បានជ្រួតជ្រាប និងទទួលស្គាល់ពីសារៈសំខាន់នៃអនុសាសន៍គោលនយោបាយបានមកពីលទ្ធផលស្រាវជ្រាវ។ ដូច្នេះ គួរមានបង្កើតជាយុទ្ធសាស្ត្រប្រស្រ័យទាក់ទងគ្រប់ជ្រុងជ្រោយរយៈពេលវែងមួយ ដែលគ្របដណ្តប់លើរាល់បណ្តាញ និងអាទិភាពនៃការប្រស្រ័យទាក់ទង ជាពិសេសតាមរយៈការកសាងទំនាក់ទំនងល្អ និងស្និទ្ធស្នាលជាមួយអ្នកធ្វើសេចក្តីសម្រេចចិត្តលើគោលនយោបាយរបស់រដ្ឋាភិបាល អ្នកមានឥទ្ធិពល និងមន្ត្រីរាជការថ្នាក់ខ្ពស់ៗ ឲ្យបានច្រើនតាមដែលអាចធ្វើបាន។

## គន្ថនិទ្ទេស


Chann Sopheak, Nathan Wales, Tim Frewer (2011), *An Investigation of Land Cover and Land Use Change in Stung Chrey Bak Catchment, Cambodia*. Working Paper Series No. 53 (Phnom Penh: CDRI)

Chea Chou, Nang Phirun, Anna Thomson, Isabelle Whitehead & Philip Hirsch (2011), *Decentralised Governance of Irrigation Water in Cambodia: Matching Principles to Local Realities,* Working Paper Series No. 62 (Phnom Penh: CDRI)

Chem Phalla, Kim Sean Somatra, Khiev Daravy (2010), *Empirical Evidence of Irrigation Management in the Tonle Sap Basin: Issues and Challenges,* Working Paper Series No. 48 (Phnom Penh: CDRI)

Chem Phalla, Someth Paradis, Philip Hirsch & Jessie Connell (2011), "Working with Hydrological Knowledge of Catchment to Improve Irrigation Management", Policy Brief Series No. 1 (Phnom Penh: CDRI) Chem Phalla and SOMETH Paradis, (2011), *Use of Hydrological Knowledge and Community Participation for Improving Decision-making on Irrigation Water Allocation*. Working Paper Series No. 49 (Phnom Penh: CDRI)

Khiev Daravy (2010), Challenges of Participatory Irrigation Management in Cambodia. (Phnom Penh: CDRI)

Nang Phirun, Khiev Daravy, Isabelle Whitehead & Philip Hirsch (2011), *Improving the Governance of Water Resources in Cambodia: A Stakeholder Analysis,* Working Paper Series No. 54 (Phnom Penh: CDRI)

Ros Bandeth, Ly Tem & Anna Thompson (2011), *Catchment Governance and Cooperation Dilemmas*, Working Paper Series No. 61 (Phnom Penh:  CDRI)

Tong Kimsun, Hem Socheth & Paulo Santos (2011a), *What Limits Agricultural Intensification in Cambodia? The Role of Emigration, Agricultural Extension Services and Credit Constraints*, Working Paper Series No. 56 (Phnom Penh: CDRI)

Tong Kimsun, Hem Socheth & Paulo Santos (2011b), *The Impact of irrigation on Household Assets*, Working Paper Series No. 57 (Phnom Penh: CDRI)

Wokker, Chris, Paulo Santos & Ros Bansok (2011), *Irrigation Water productivity in Cambodian Rice Systems*, Working Paper Series No. 51 (Phnom Penh: CDRI)

# ផ្នែកទី ៣
# សុខាភិបាល

# -៥-
# ហិរញ្ញប្បទានសុខភាព និងធនធានមនុស្ស សម្រាប់វិស័យសុខាភិបាលៈ ការវិភាគស្ថានភាពក្នុងប្រទេស

*ដោយលោក នេត នាថ និង លោកស្រី ហួន ចន្ទ្រា*[១]

## ១. សេចក្តីផ្តើម

នៅដើមទសវត្សរ៍១៩៩០ ភាគីទំនាស់នយោបាយទាំងអស់បានយល់ព្រមបទឈប់បាញ់មួយ និងចូលរួមក្នុងការបោះឆ្នោតថ្នាក់ជាតិដែលរៀបចំដោយអង្គការសហប្រជាជាតិហៅកាត់ថា អ៊ុនតាក់ (UNTAC)។ វិស័យសាធារណៈមួយចំនួនត្រូវបានកសាងឡើងវិញជាបណ្តើរៗ ក្នុងនោះ មានទាំងវិស័យសុខាភិបាលផងដែរ។ ដោយមានកិច្ចប្រឹងប្រែងពីរាជរដ្ឋាភិបាលកម្ពុជា ហេដ្ឋារចនាសម្ព័ន្ធប្រព័ន្ធសុខាភិបាល កាន់តែបានល្អប្រសើរឡើង ជាពិសេសក្នុងប៉ុន្មានឆ្នាំថ្មីៗ។ ការផ្តល់សេវា និងគុណភាពការថែទាំសុខភាព ក៏បានកែលម្អឡើងជាបណ្តើរៗផងដែរ។ អត្រាមរណមាតា ទារក និង កុមារក្រោមអាយុ៥ឆ្នាំ បានថយចុះ។ អត្រាមរណទារក ធ្លាក់ចុះពី ៩៥នាក់ មកត្រឹម ៦៦នាក់ ក្នុង ១០០០កំណើតរស់ ហើយអត្រាមរណកុមារក្រោមអាយុ៥ឆ្នាំ ធ្លាក់ចុះពី ១២៤នាក់ មកត្រឹម ៨៣នាក់ ក្នុង ១០០០កំណើតរស់ នៅឆ្នាំ២០១០។ ទោះជាមានការរីកចម្រើនយ៉ាងនេះក្តី សូចនាករសំខាន់ៗមួយចំនួនទៀតដូចជា អត្រាមរណមាតា ជាដើម នៅតែមានអត្រាខ្ពស់នៅឡើយ។ រីឯចំណាយថែទាំសុខភាពប្រចាំគ្រួសារនៅតែជាបញ្ហាចម្បង សម្រាប់គ្រួសារក្រីក្រនៅឡើយ។ រាជរដ្ឋាភិបាលកម្ពុជា ជាពិសេសក្រសួងសុខាភិបាល បានអនុវត្តកំណែទម្រង់ជាច្រើនសំដៅពន្លឿនការកែលម្អប្រព័ន្ធសុខាភិបាលនៅកម្ពុជា។ កំណែទម្រង់នេះតម្រូវឲ្យមានការផ្លាស់ប្តូរ និងការកែលម្អផ្នែកផ្សេងៗនៃប្រព័ន្ធសុខាភិបាល មានជាអាទិ៍ អ្នកពាក់ព័ន្ធនានា ដំណើរការបង្កើតគោលនយោបាយសុខាភិបាល និងសកម្មភាពផ្សេងៗផ្នែកសុខាភិបាល។

## ២. គោលបំណង

ការវិភាគស្ថានភាពក្នុងប្រទេសនេះ មានបំណងចូលរួមចំណែកកំណត់នូវអាទិភាពសំណួរស្រាវជ្រាវរបស់វិទ្យាស្ថាន CDRI ក្នុងបរិបទជាក់ស្តែង តាមរយៈការកំណត់តួអង្គថ្មីៗ របៀបវារៈ និងចន្លោះខ្វះខាត ដើម្បីផ្តល់ព័ត៌មានដល់ការស្រាវជ្រាវរបស់វិទ្យាស្ថានឲ្យអនុវត្តបានប្រកបដោយប្រសិទ្ធភាពខ្ពស់ និងអាចតាមដានពីឥទ្ធិពលនៃការស្រាវជ្រាវទៅលើប្រព័ន្ធសុខាភិបាលពីមួយឆ្នាំទៅមួយឆ្នាំ។

---

១ លោក នេត នាថ ជាអ្នកស្រាវជ្រាវ និង លោកស្រី ហួន ចន្ទ្រា ជាជំនួយការស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

## ៣. វិធីសាស្ត្រ

វិធីសាស្ត្រសិក្សាស្រាវជ្រាវ រួមមាន៖ ការពិនិត្យឯកសារផ្សេងៗលើផ្នែកធនធានមនុស្សក្នុងវិស័យសុខាភិបាល និងហិរញ្ញប្បទានផ្នែកសុខភាព។ ឯកសារទាំងនោះ រួមមាន ច្បាប់ បទបញ្ញត្តិ ផែនការ យុទ្ធសាស្ត្រ គោលនយោបាយ របាយការណ៍ អត្ថបទ និងឯកសារស្រាវជ្រាវនានា។ ការសម្ភាសអ្នកផ្តល់ព័ត៌មានសំខាន់ៗដែលរួមមានបុគ្គលិកក្រសួងសុខាភិបាល អ្នកផ្តល់ជំនួយ អង្គការមិនមែនរដ្ឋាភិបាល និងអ្នកស្រាវជ្រាវនានា បានផ្តល់នូវទិន្នន័យសម្រាប់យកមកសំយោគ និងវិភាគ ដើម្បីស្វែងយល់ពីស្ថានភាពបច្ចុប្បន្ននៃធនធានមនុស្សក្នុងវិស័យសុខាភិបាល និងហិរញ្ញប្បទានសុខភាពនៅកម្ពុជា។

## ៤. លទ្ធផល

### *៤.១. អ្នកពាក់ព័ន្ធ*

*៤.១.១. អ្នកពាក់ព័ន្ធសំខាន់ៗ*

ការវិភាគអំពីអ្នកពាក់ព័ន្ធក្នុងការអភិវឌ្ឍប្រព័ន្ធសុខាភិបាលនេះ ផ្តោតតែលើ ស្ថាប័នសាធារណៈប៉ុណ្ណោះ ពីព្រោះវិស័យឯកជនមិនបានជះឥទ្ធិពលដោយផ្ទាល់ទៅលើ គោលនយោបាយផ្នែកសុខាភិបាលទេ។ ក្នុងអត្ថបទនេះ វិស័យឯកជនសំដៅលើប្រព័ន្ធថែទាំសុខភាពឯកជនដែលផ្តល់សេវាថែទាំសុខភាព។ ដូច្នេះ អ្នកពាក់ព័ន្ធសំខាន់ៗ រួមមាន ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងដៃគូអភិវឌ្ឍន៍ក្រៅប្រទេស។

**ក្រសួងសុខាភិបាល** ទទួលខុសត្រូវលើគ្រប់ផ្នែកនៃសេវាសុខភាពសាធារណៈនៅកម្ពុជា មានជាអាទិ៍ ការកសាង ការអនុវត្ត និងការវាយតម្លៃគោលនយោបាយ ផែនការ បទបញ្ញត្តិ គោលការណ៍ណែនាំ និងអន្តរាគមន៍ ដើម្បីញ៉ាំងឲ្យមានការផ្តល់សេវាសុខភាពយ៉ាងសក្តិសិទ្ធិ និងមានប្រសិទ្ធភាពជូនដល់ប្រជាជន។ ក្រសួងសុខាភិបាល មានរចនាសម្ព័ន្ធចាត់តាំងមួយដែលមាន ថ្នាក់កណ្តាល ថ្នាក់ខេត្ត និងថ្នាក់ស្រុក និងមានការបញ្ជាក់ពីតួនាទី និងការទទួលខុសត្រូវរបស់នាយកដ្ឋាន ឬមន្ទីរផ្សេងៗ។

រូបភាព ១៖ រចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងសុខាភិបាល




*កំណត់សម្គាល់៖ រចនាសម្ព័ន្ធនេះ កំពុងរង់ចាំការអនុម័តពីក្រសួងសុខាភិបាល*
*ប្រភព៖ ក្រសួងសុខាភិបាល 2007*

**ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ** មានតួនាទីចម្បងក្នុងការបែងចែកថវិកាទៅឲ្យក្រសួងសុខាភិបាលសម្រាប់ចំណាយបច្ចុប្បន្ន និងសម្រាប់ចំណាយនាពេលអនាគត តាមរយៈក្របខ័ណ្ឌយុទ្ធសាស្ត្ររយៈពេលមធ្យម។ ដៃគូផ្នែកសុខាភិបាលអន្តរជាតិ បានទទួលស្គាល់ថា ក្រសួងសុខាភិបាល និង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានប្រឹងប្រែងជាខ្លាំង ដើម្បីកែលម្អការធ្វើ

ផែនការហិរញ្ញវត្ថុ និងការអនុវត្ត សំដៅបង្កើនប្រសិទ្ធភាព និងសមត្ថភាពក្នុងការបែងចែកធនធានដែលមាន ដើម្បីសម្រេចគោលដៅរបស់ក្រសួងសុខាភិបាល។ គេអង្កេតឃើញថា ថវិការបស់រដ្ឋាភិបាលសម្រាប់វិស័យសុខាភិបាល មានការកើនឡើងជាលំដាប់។

**ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស** នៅឆ្នាំ១៩៩១ កម្ពុជាចាប់ផ្តើមធ្វើកំណែទម្រង់វិស័យសុខាភិបាល ដើម្បីផ្តល់សេវាថែទាំសុខភាពមូលដ្ឋានប្រកបដោយគុណភាព សមត្ថភាព និងបង្កលក្ខណៈងាយស្រួលជូនដល់ប្រជាជនទាំងអស់។ ដៃគូអភិវឌ្ឍន៍ក្រៅប្រទេសជាច្រើន បានផ្តល់ជាជំនួយផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុ ដើម្បីជួយលើកកម្ពស់គុណភាពសេវាថែទាំសុខភាពនៅកម្ពុជា។ ម្ចាស់ជំនួយសំខាន់ៗ រួមមាន អង្គការសុខភាពពិភពលោក (WHO) អង្គការយូនីសេហ្វ ធនាគារពិភពលោក ទីភ្នាក់ងារអាល្លឺម៉ង់សម្រាប់សហប្រតិបត្តិការអភិវឌ្ឍន៍អន្តរជាតិ (GIZ) អង្គការមូលនិធិសហប្រជាជាតិបម្រើប្រជាជន (UNFPA) ក្រសួងសម្រាប់ការអភិវឌ្ឍអន្តរជាតិនៃចក្រភពអង់គ្លេស (DFID) ទីភ្នាក់ងារអូស្ត្រាលីសម្រាប់ការអភិវឌ្ឍអន្តរជាតិ (AusAID) និងធនាគារអភិវឌ្ឍន៍អាស៊ី (ADB)។ ទីភ្នាក់ងារផ្តល់ជំនួយផ្សេងទៀត មានដូចជា ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ (USAID) និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) ជាដើម ។

### *៤.១.២. អ្នកពាក់ព័ន្ធផ្សេងៗ*

**អាជ្ញាធរក្នុងស្រុក** ដើរតួនាទីសម្របសម្រួលក្នុងការបញ្ជូនសេវាសុខភាពដល់សហគមន៍តាមរយៈតួនាទីក្នុងការអភិវឌ្ឍសហគមន៍។ សម្រាប់កំណែទម្រង់វិស័យសុខាភិបាលនាពេលថ្មីៗ ដោយមានការឧបត្ថម្ភពីម្ចាស់ជំនួយជាតិ និងអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា (NGOs) រដ្ឋាភិបាលបានណែនាំពី គម្រោងធានារ៉ាប់រងសុខភាពសង្គម (SHI) និងមូលនិធិសមធម៌សុខភាព (HEF) ដើម្បីឲ្យប្រជាជនក្រីក្រគ្រប់ៗគ្នាអាចប្រើប្រាស់សេវាថែទាំសុខភាពប្រកបដោយគុណភាព ជាពិសេសឲ្យមានកិច្ចគាំពារសម្រាប់ប្រជាជនក្រីក្រខ្លាំង និងជនងាយរងគ្រោះបំផុត។ មេភូមិមានភារកិច្ចផ្តល់ការបញ្ជាក់ពីអត្តសញ្ញាណប្រជាជនក្រីក្រក្នុងសហគមន៍របស់ខ្លួន និងចេញប័ណ្ណថែទាំសុខភាពជូនពួកគាត់។ ម៉្យាងទៀត ក្រុមទ្រទ្រង់សុខភាពភូមិ (VHSG) ត្រូវសហការជាមួយបុគ្គលិកនៅមណ្ឌលសុខភាព ដើម្បីលើកកម្ពស់ការផ្តល់សេវាសុខភាព។ ក្នុងភូមិនីមួយៗត្រូវបោះឆ្នោតជ្រើសអ្នកតំណាង២រូប ឲ្យចូលជាសមាជិកក្រុមទ្រទ្រង់សុខភាពភូមិ។ ក្រុមទ្រទ្រង់សុខភាពភូមិជួយដល់មណ្ឌលសុខភាពក្នុងការពិនិត្យតាមដានបញ្ហាសុខភាព ដូចជាការចាក់ថ្នាំបង្ការ ការពន្យាកំណើត និងការបង្ការជំងឺផ្សេងៗ។

**សង្គមស៊ីវិល/អង្គការមិនមែនរដ្ឋាភិបាល** ក្រោយកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីសឆ្នាំ១៩៩១ ត្រូវបានចុះហត្ថលេខា ចំនួនអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក បានកើនឡើងយ៉ាងច្រើនរហូតដល់ជាង ១៥០០ ដែលបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ ធៀបនឹងអង្គការមិនមែនរដ្ឋាភិបាលអន្តរជាតិ មានត្រឹមតែ ៣៤០ ដែលបានចុះបញ្ជីនៅក្រសួងការបរទេស។ គួរកត់សម្គាល់ដែរថា អង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជា ដើរតួនាទីយ៉ាងសកម្មក្នុងវិស័យសុខាភិបាល ដោយមានធ្វើប្រតិបត្តិការលើសកម្មភាពជាច្រើន ដូចជាចូលរួមផ្តល់សេវានៅមណ្ឌលសុខភាព តាមរយៈកិច្ចសន្យាលើការផ្តល់សេវាសុខភាព កសាងសមត្ថភាពរបស់បុគ្គលិកសុខាភិបាល ផ្តល់ការទ្រទ្រង់ផ្នែកបច្ចេកទេសតាមរយៈការបណ្តុះបណ្តាល និងអប់រំ ជួយជាមតិលើគោលនយោបាយ/កម្មវិធីសុខភាពនានា និងបង្កើតបណ្តាញទំនាក់ទំនង។

## ៤.២. គោលនយោបាយ ផែនការ និងកម្មវិធី

### ៤.២.១. ធនធានមនុស្ស

នៅកម្ពុជា ដង់ស៊ីតេគ្រូពេទ្យពិនិត្យ និងព្យាបាលជំងឺ មានទាបនៅឡើយ[២] (មាន ១នាក់សម្រាប់ប្រជាជន ១០០០នាក់)។ លើសពីនេះទៀត របាយបុគ្គលិកសុខាភិបាល មិនទាន់មានតុល្យភាពនៅឡើយរវាងជនបទ និងទីក្រុង។ ក្រសួងសុខាភិបាល បានព្យាយាមដោះស្រាយបញ្ហានេះ តាមរយៈការកសាង និងការផ្តួចផ្តើមនូវផែនការគោលនយោបាយ និងគម្រោងជាច្រើន ដូចជា ផែនការជាតិអភិវឌ្ឍន៍បុគ្គលិកសុខាភិបាលលើកទី១ (១៩៩៦-២០០៥) ដែលបានកសាងឡើង ដើម្បីតាមដានស្ថានភាពបុគ្គលិកសុខាភិបាល និងកំណត់ពីតម្រូវការផ្លាស់ប្តូរគោលនយោបាយបុគ្គលិក ការធ្វើផែនការនិងគ្រប់គ្រងបុគ្គលិក ព្រមទាំងកម្រិតគោលដៅសម្រាប់ការបែងចែកនិងបណ្តុះបណ្តាលបុគ្គលិក។ ផែនការយុទ្ធសាស្ត្រសុខាភិបាលជាតិលើកទី១ ឆ្នាំ២០០៣-២០០៧ បានកំណត់ឡើង ដើម្បីផ្តល់ទិសដៅរួមមួយដល់វិស័យសុខាភិបាល។ ផែនការជាតិអភិវឌ្ឍន៍បុគ្គលិកសុខាភិបាលលើកទី២ (២០០៦-២០១៥) និងផែនការយុទ្ធសាស្ត្រសុខាភិបាលជាតិលើកទី២ (២០០៨-២០១៥) បានកំណត់ឡើង ដើម្បីណែនាំពីទំហំ សមាសភាពនៃបុគ្គលិកទៅថ្ងៃមុខ ការជ្រើសរើសបុគ្គលិក ការផ្តល់ការងារនិងការបែងចែកបុគ្គលិក ផលិតភាព និងបៀវត្សរ៍របស់បុគ្គលិក ដូចមានលើកឡើងក្នុងផ្នែកបញ្ហាប្រឈមសំខាន់ៗនៅក្នុងផែនការយុទ្ធសាស្ត្រសុខាភិបាលជាតិលើកទី១។

រាជរដ្ឋាភិបាលបានបង្កើតគ្រោងការណ៍ថ្នាក់ជាតិជាច្រើន ដូចជា គ្រឿងលើកទឹកចិត្តផ្អែកលើគុណសម្បត្តិការងារ ក្រុមបេសកកម្មអាទិភាព ចំណាយលើប្រតិបត្តិការជាអាទិភាព និងភ្នាក់ងារប្រតិបត្តិការពិសេស ជាដើម។ គម្រោងទាំងនេះហាក់ដើរទន្ទឹមគ្នានឹងការផ្តល់ការគាំទ្រដល់ការអនុវត្តគោលនយោបាយ។ ក្រៅពីគ្រោងការណ៍ថ្នាក់ជាតិទាំងនេះ នៅមានគំនិតថ្មីៗ និងគម្រោងផ្នែកសុខាភិបាលជាច្រើនទៀតដែលមានគោលដៅលើកទឹកចិត្តបុគ្គលិកសុខាភិបាល និងលើកកម្ពស់គុណភាពការថែទាំសុខភាព ព្រមទាំងកាត់បន្ថយឥទ្ធិពលអវិជ្ជមាននៃចំណាយខ្ពស់ពីហោប៉ៅរបស់ជនក្រីក្រក្នុងការថែទាំសុខភាព។ គម្រោងទាំងនោះ រួមមាន ការលើកលែងបង់ថ្លៃព្យាបាលជំងឺចំពោះជនក្រីក្រ កិច្ចសន្យា (ក្នុង និងក្រៅ) និងគ្រឿងលើកចិត្តផ្អែកលើការអនុវត្តការងារ។

### ៤.២.២. ហិរញ្ញប្បទានសុខភាព

ក្រោយពេលប្រទេសកម្ពុជាបានបញ្ចប់សង្គ្រាម គោលនយោបាយ ផែនការ និងគម្រោងជាច្រើន ក៏បានអនុម័តឡើង ដូចជាបទបញ្ញត្តិជាតិស្តីពីហិរញ្ញប្បទានសុខភាពឆ្នាំ១៩៩៦ ជាដើម។ ក្របខ័ណ្ឌយុទ្ធសាស្ត្រហិរញ្ញប្បទានសុខភាពឆ្នាំ២០០៨-២០១៥ បានបង្កើតឡើង ដើម្បីក្តាប់ព័ត៌មានវិភាគ និងបង្កើនប្រសិទ្ធភាពប្រភពហិរញ្ញប្បទានទាំងអស់ ព្រមទាំងប្រើប្រាស់ធនធានទាំងនោះក្នុងវិស័យសុខាភិបាល។ ផែនការគោលមួយស្តីពីការការពារសុខភាពសង្គម បានបង្កើតឡើងនៅឆ្នាំ២០០៩ ដោយកសាងចេញពីផែនការគោលស្តីពីការធានារ៉ាប់រងសុខភាពសង្គមឆ្នាំ២០០៥ និងផ្អែកលើក្របខ័ណ្ឌយុទ្ធសាស្ត្រហិរញ្ញប្បទានសុខភាព។ ផែនការនេះមានសារៈសំខាន់ក្នុងការសម្របសម្រួលប្រព័ន្ធការពារសុខភាពសង្គមនៅកម្ពុជា ដោយបានផ្តល់ជា

---

២ មាន វេជ្ជបណ្ឌិត គ្រូពេទ្យមធ្យម ឆ្មប និងគិលានុបដ្ឋាក

គ្រោងការណ៍មួយសម្រាប់ផ្តល់ប្រសិទ្ធភាព និងសមធម៌ដល់លទ្ធភាពប្រើប្រាស់សេវាថែទាំសុខភាព ប្រកបដោយគុណភាពរបស់ប្រជាជនកម្ពុជាគ្រប់គ្នា។ ព្រមទាំងផ្តល់ជាសេចក្តីណែនាំមួយសម្រាប់ការធ្វើផែនការរួមគ្នា និងការអនុវត្តចុះសម្រុងគ្នានូវគម្រោងហិរញ្ញប្បទានស្រដៀងៗគ្នានៅតាមក្រសួងផ្សេងៗ។

មានគម្រោងជាច្រើនទៀត ក៏ត្រូវបានបង្កើតឡើងផងដែរ។ នៅឆ្នាំ១៩៩៧ ការព្យាបាលឲ្យបង់ថ្លៃ ត្រូវបានដាក់អនុវត្តជាលើកដំបូងនៅក្នុងមណ្ឌលសុខភាពសាធារណៈពីរបីកន្លែងនៅតាមខេត្តក្រុងមួយចំនួន នៅកម្ពុជា ហើយបន្ទាប់មក ក៏បានពង្រីកទៅដល់មន្ទីរពេទ្យ និងមណ្ឌលសុខភាពនានា នៅតាមខេត្តឯទៀតៗ។ នៅឆ្នាំ១៩៩៨ គម្រោងធានារ៉ាប់រងសុខភាពសហគមន៍បានដាក់អនុវត្តសាកល្បងលើកដំបូង ដោយអង្គការ GRET របស់បារាំង នៅបួនកន្លែង ក្នុងខេត្តកណ្តាល។ នៅឆ្នាំ២០០០ មូលនិធិសមធម៌សុខភាព (HEFs) ផ្តល់ហិរញ្ញប្បទានដោយអង្គការសុខភាពពិភពលោក និងប្រទេសអង់គ្លេស បានអនុវត្តសាកល្បងលើកដំបូងនៅទីក្រុងភ្នំពេញ និងទីប្រជុំជន ចំនួនពីរកន្លែង ។ នាពេលថ្មីៗនេះ គម្រោងប័ណ្ណសុខភាព កំពុងអនុវត្តសាកល្បងចំពោះស្ត្រីមានគភ៌ក្រីក្រ ដោយក្រសួងសុខាភិបាល និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បីជួយបង់ថ្លៃព្យាបាល និងថ្លៃធ្វើដំណើរទៅមជ្ឈមណ្ឌលពិនិត្យផ្ទៃពោះបីលើក ការសម្រាលកូន និងការថែទាំសុខភាពក្រោយពេលសម្រាលកូនរួច នៅតាមមណ្ឌលសុខភាព ក្នុងស្រុកប្រតិបត្តិប្រាំកន្លែង។ គម្រោងឧបត្ថម្ភធនមួយរបស់រដ្ឋាភិបាល ក៏បានផ្តួចផ្តើមធ្វើឡើង ដើម្បីផ្តល់ជំនួយឧបត្ថម្ភដល់ប្រជាជនដែលស្ថិតនៅក្រោមបន្ទាត់ភាពក្រីក្រជាតិ ហើយដាក់អនុវត្តនៅមន្ទីរពេទ្យជាតិចំនួនប្រាំមួយ មន្ទីរពេទ្យបង្អែកចំនួន ១០ និងមណ្ឌលសុខភាពចំនួន ៨៩។

## ៤.៣. ការស្រាវជ្រាវប្រព័ន្ធសុខាភិបាល

ជាទូទៅ ការស្រាវជ្រាវប្រព័ន្ធសុខាភិបាលតែងអនុវត្តក្នុងទម្រង់ជាការវាយតម្លៃកម្មវិធី និងប្រើប្រាស់ក្នុងដំណើរបង្កើតគោលនយោបាយ។ ការស្រាវជ្រាវប្រព័ន្ធសុខាភិបាលភាគច្រើនបានអនុវត្ត តាមរយៈហិរញ្ញប្បទានរបស់រដ្ឋាភិបាល និងម្ចាស់ជំនួយ ដើម្បីផ្តល់ព័ត៌មានដល់ការបង្កើតគោលនយោបាយ។ ក្រសួងសុខាភិបាលដើរតួនាទីសំខាន់ណាស់ក្នុងការកំណត់ និងកសាងរបៀបវារៈអនុវត្តការស្រាវជ្រាវសម្រាប់ការធ្វើផែនការ និងការកែលម្អគោលនយោបាយផ្នែកសុខាភិបាល ក៏ដូចជាធ្វើកិច្ចសន្យាជាមួយស្ថាប័នស្រាវជ្រាវក្នុងស្រុក ឬក្រុមហ៊ុនផ្តល់ប្រឹក្សាអន្តរជាតិ ឲ្យអនុវត្តការស្រាវជ្រាវនោះ។ វិទ្យាស្ថានជាតិសុខភាពសាធារណៈ (NIPH) ជាវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវរបស់ក្រសួងសុខាភិបាល។ វិទ្យាស្ថាននេះផ្តោតសំខាន់លើការបណ្តុះបណ្តាលសុខភាពសាធារណៈ។ មានវិទ្យាស្ថានស្រាវជ្រាវឯកជនជាតិ និងអន្តរជាតិ និងទីភ្នាក់ងារមិនស្វែងរកចំណេញជាច្រើនបានធ្វើការស្រាវជ្រាវពីប្រព័ន្ធសុខាភិបាល ដើម្បីផ្តល់ព័ត៌មានដល់ការបង្កើតគោលនយោបាយ។ ឧទាហរណ៍ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) កំពុងធ្វើការស្រាវជ្រាវលើហិរញ្ញប្បទានសុខភាព និងធនធានមនុស្សវិស័យសុខាភិបាល ដើម្បីស្វែងរកព័ត៌មាន និងការយល់ដឹង ហើយជួយផ្តល់មតិយោបល់លើបញ្ហាប្រឈម សម្រាប់ជាការពិចារណារបស់ក្រសួងសុខាភិបាលក្នុងការបង្កើតគោលនយោបាយនាពេលអនាគត។

## ៤.៤. បណ្តាញជួយទ្រទ្រង់ការពង្រឹងប្រព័ន្ធសុខាភិបាល

ដើម្បីសម្របសម្រួលការអនុវត្តគោលនយោបាយ នៅឆ្នាំ១៩៩១ ក្រសួងសុខាភិបាល បានបង្កើតគណៈកម្មាធិការជាតិសម្របសម្រួលផ្នែកសុខភាព (CoCom) ដែលក្រោយមកប្តូរឈ្មោះជាក្រុមការងារបច្ចេកទេសផ្នែកសុខភាព (TWGH) ដើម្បីដោះស្រាយបញ្ហានានាក្នុងប្រព័ន្ធសុខាភិបាល ដំណើរការអភិវឌ្ឍន៍គោលនយោបាយ និងការកសាងសមត្ថភាព។ ក្រុមការងារនេះធ្វើការសិក្សា និងការពិនិត្យឡើងវិញជាច្រើន (តាមរយៈអនុគណៈកម្មាធិការ និងក្រុមការងារនានា) ព្រមទាំងជួយសម្រួលការប្រើប្រាស់មតិយោបល់បច្ចេកទេសឲ្យបានសមស្របដល់ក្រសួង។ ក្រុមការងារនេះ ក៏ផ្តល់ព័ត៌មានអំពីសកម្មភាពបច្ចុប្បន្ន និងសកម្មភាពក្នុងគម្រោងរបស់អង្គការអន្តរជាតិទ្វេភាគីនិងពហុភាគី និងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការក្នុងវិស័យសុខាភិបាល និងវិស័យពាក់ព័ន្ធជាមួយសុខាភិបាល ព្រមទាំងពិនិត្យមើលឡើងវិញនូវរាល់សំណើហិរញ្ញប្បទានសុខភាពពីក្រៅប្រទេស ដើម្បីធានាឲ្យស្របទៅតាមគោលនយោបាយជាតិផ្នែកសុខាភិបាល។ ក្រុមការងារបច្ចេកទេសនេះ មានអ្នកតំណាងថ្នាក់ខ្ពស់មកពី ក្រសួងសុខាភិបាល និងទីភ្នាក់ងារមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ។

## ៤.៥. ឱកាសស្រាវជ្រាវ

### ៤.៥.១. បម្រែបម្រួលបរិបទនាពេលថ្មីៗបង្កើតនូវតម្រូវការស្រាវជ្រាវមិនទាន់ដោះស្រាយ

ប្រជាជនប្រមាណ ៣០% ពុំមានលទ្ធភាពបង់ចំណាយលើការថែទាំសុខភាពទេ ទាំងចំពោះផ្នែកសាធារណៈ និងចំពោះផ្នែកឯកជន។ នៅឆ្នាំ២០០៥ ចំណាយលើការថែទាំសុខភាពប្រចាំឆ្នាំរបស់ក្រុមគ្រួសារនីមួយៗក្នុងមនុស្សម្នាក់គឺ ២៥ដុល្លារ។ នៅកម្ពុជា ការឈឺថ្កាត់ និងភាពក្រីក្រមានទំនាក់ទំនងគ្នា។ មានករណីគ្រួសារក្រីក្រដែលពុំមានលទ្ធភាពបង់ថ្លៃថែទាំសុខភាព ហើយក៏សម្រេចចិត្តស្វែងរកការព្យាបាលដោយគ្រូពេទ្យបុរាណ ឬអ្នកផ្តល់សេវាសុខភាពឯកជនដែលគ្មានអាជ្ញាប័ណ្ណត្រឹមត្រូវ (មានគ្រោះថ្នាក់ជារឿយៗ)។ មានការសិក្សាខ្លះបង្ហាញថា គួរតែមានការស្រាវជ្រាវជាបន្ទាន់មួយ ដើម្បីកសាងយុទ្ធសាស្ត្រដ៏មានប្រសិទ្ធភាពសម្រាប់ពន្លឿនវិស័យថែទាំសុខភាពសាធារណៈ នៅតាមតំបន់ជនបទ ជាពិសេសទាក់ទងនឹងហិរញ្ញប្បទានផ្អែកលើការអនុវត្តមូលនិធិសមធម៌សុខភាព និងផ្នែកផ្សេងៗនៃការផ្តល់សេវាថែទាំសុខភាព ។

ទោះបីក្រសួងសុខាភិបាលព្យាយាមដោះស្រាយបញ្ហាគ្រប់គ្រង និងបែងចែកធនធានមនុស្សក្តី ក៏បុគ្គលិកផ្នែកសុខាភិបាល នៅតែមិនទាន់មានតុល្យភាពនៅឡើយរវាងទីក្រុង និងជនបទ។ គោលនយោបាយ ផែនការ និងគម្រោងមួយចំនួន បានបង្កើតឡើងរួចហើយ។ ប៉ុន្តែក៏គួរពិនិត្យពីបញ្ហាប្រឈមផ្សេងៗដែរ ដើម្បីសម្រេចបានគោលនយោបាយល្អមួយដែលធានាបានតុល្យភាពរបាយបុគ្គលិកផ្នែកសុខាភិបាលរវាងជនបទនិងទីក្រុង និងតួនាទីរបស់វិស័យឯកជនក្នុងការផ្តល់សេវាសុខភាព ព្រោះវិស័យនេះកំពុងលូតលាស់និងទាក់ទាញបុគ្គលិកសុខាភិបាលសាធារណៈ។

*៤.៥.២. បញ្ហាភាពក្រីក្រ យេនឌ័រ និងអភិបាលកិច្ចក្នុងការស្រាវជ្រាវ*

ទាក់ទងនឹងអភិបាលកិច្ចផ្នែកសុខាភិបាល មានការលើកឡើងពីបញ្ហាប្រឈមជាច្រើន។ អង្គការសុខភាពពិភពលោក និងធនាគារពិភពលោក បានបង្ហាញពីតម្រូវការយល់ដឹងពីវិធីកាត់បន្ថយកំណើនភាពលំអៀងក្នុងការផ្តល់សេវាថែទាំសុខភាពរវាងក្រុមប្រជាជនផ្សេងៗ ជាពិសេសនារី និងកុមារ។ ការសិក្សាខ្លះ បានបង្ហាញពីតម្រូវការដោះស្រាយបញ្ហាផលប៉ះពាល់នៃវិមជ្ឈការទៅលើនិរន្តរភាពផ្នែកហិរញ្ញវត្ថុក្នុងរយៈពេលវែងនៃកម្មវិធីនានា ក្នុងនេះ មានទាំងកម្មវិធីចាក់ថ្នាំបង្ការផងដែរ។ មានការយល់ស្របជាទូទៅថា បើសិនជាគ្មានបែបបទផ្តល់គ្រឿងលើកទឹកចិត្តឲ្យបានត្រឹមត្រូវនោះទេ ការផ្លាស់ប្តូររចនាសម្ព័ន្ធអង្គភាព ដែលកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការបានតម្រូវឡើង នឹងត្រូវជួបការលំបាក។ ម្យ៉ាងទៀត មានការបារម្ភជាខ្លាំងពីការបែងចែកមិនស្មើភាពនូវសេវាសម្ភព និងសេវាថែទាំសុខភាពទារក នៅតាមតំបន់ផ្សេងៗក្នុងទូទាំងប្រទេស ពីតម្រូវការបង្កើនគុណភាពការថែទាំសុខភាពបន្តពូជ សុខភាពមាតា សុខភាពទារក និងសុខភាពកុមារ។ អត្រាមរណមាតា នៅខ្ពស់នៅឡើយ ដែលត្រូវមានវិនិយោគច្រើនថែមទៀតទៅលើសេវាផ្តល់កំណើត និងអន្តរាគមន៍បន្ទាន់។ ប៉ុន្តែគេទទួលស្គាល់ថា អត្រាមរណមាតា ជាបញ្ហាពាក់ព័ន្ធច្រើនវិស័យ និងរងឥទ្ធិពលពីការអប់រំ និងកម្រិតអក្ខរកម្មរបស់ស្ត្រី ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ កម្រិតនៃការចូលរួមរបស់ស្ត្រី និងសមភាពយេនឌ័រ។

*៤.៥.៣. តម្រូវការស្រាវជ្រាវក្នុងប្រព័ន្ធសុខាភិបាល*

ដូចបានបង្ហាញខាងលើ តម្រូវការស្រាវជ្រាវក្នុងប្រព័ន្ធសុខាភិបាលភាគច្រើន មានទម្រង់ជាការប៉ាន់ស្មាន ឬវាយតម្លៃពីកម្មវិធីឬគោលនយោបាយផ្សេងៗ។ ទោះយ៉ាងនេះក្តី មានការពិភាក្សាមួយចំនួនក្នុងផែនការយុទ្ធសាស្ត្រផ្នែកសុខាភិបាលឆ្នាំ២០០៨-២០១៥ អំពីតម្រូវការស្រាវជ្រាវក្នុងប្រព័ន្ធសុខាភិបាល។ ផែនការយុទ្ធសាស្ត្រនេះ ទាមទារឲ្យមានការស្រាវជ្រាវដើម្បីបង្កើតជាកញ្ចប់គោលនយោបាយដែលគ្រប់ជ្រុងជ្រោយ ផ្អែកលើភស្តុតាង អាចអនុវត្តបាន និងស្របទៅតាមច្បាប់និងគោលនយោបាយណែនាំរបស់រដ្ឋាភិបាល។ ការសិក្សាស្រាវជ្រាវសំខាន់ៗ មានដូចជាប្រព័ន្ធសុខាភិបាល ជាពិសេស វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យសុខាភិបាល។ ម្យ៉ាងទៀត ឯកសារជាច្រើន ក៏ទាមទារនូវការស្រាវជ្រាវបន្ថែមដែរ ដូចជាការយល់ដឹងកាន់តែប្រសើរពីកត្តារាំងលទ្ធភាពប្រជាជនក្រីក្រ ក្នុងការប្រើប្រាស់សេវាថែទាំសុខភាព និងការឆ្លើយតបរបស់វិស័យឯកជនចំពោះបម្រែបម្រួលប្រព័ន្ធគ្រប់គ្រងសុខភាពសាធារណៈ និងថ្លៃព្យាបាល។

## ៥. សេចក្តីសន្និដ្ឋាន

ប្រព័ន្ធសុខាភិបាលកម្ពុជា ជាពិសេស ហេដ្ឋារចនាសម្ព័ន្ធអង្គការចាត់តាំង និងធនធានមនុស្សផ្នែកសុខាភិបាល បានខូចខាតយ៉ាងធ្ងន់ធ្ងរដោយសារសង្គ្រាមស៊ីវិលអស់ជាច្រើនទសវត្សរ៍។ បន្ទាប់ពីទំនាស់បានបញ្ចប់ ប្រព័ន្ធសុខាភិបាលត្រូវបានស្តារឡើងវិញក្រោមទំនួលខុសត្រូវរបស់ក្រសួងសុខាភិបាលដែលជាស្ថាប័នឈានមុខក្នុងការអនុវត្ត និងធ្វើកំណែទម្រង់ប្រព័ន្ធសុខាភិបាល ដោយមានការជួយឧបត្ថម្ភទាំងបច្ចេកទេស និងហិរញ្ញវត្ថុពីដៃគូអភិវឌ្ឍន៍។ ការវិវត្តឥតឈប់ឈរក្នុងវិស័យហិរញ្ញប្បទានសុខភាព ដោយសារតែមានគំនិតច្នៃប្រឌិតថ្មីៗ និងមានការកែប្រែផែនការនិងគោលនយោបាយ ទាមទារឲ្យមានការសិក្សាពីឥទ្ធិពលរយៈពេលខ្លី និងរយៈពេលវែងនៃគំនិតច្នៃប្រឌិតថ្មីៗនោះ ទៅលើការកាត់បន្ថយចំណាយថែទាំសុខភាពរបស់គ្រួសារ។ រីឯការកែប្រែ

ផែនការនិងគោលនយោបាយទាំងនោះ ត្រូវឲ្យមានការសិក្សាអំពីប្រភព និងកម្លាំងចលករដែលជំរុញឲ្យមានការកែប្រែក្នុងបរិបទ និងកាលៈទេសៈនីមួយៗ។ ក្រសួងសុខាភិបាល និងដៃគូអភិវឌ្ឍន៍នានា កំពុងអនុវត្តគោលនយោបាយមួយចំនួន ដើម្បីដោះស្រាយបញ្ហាអតុល្យភាពរបាយបុគ្គលិកផ្នែកសុខាភិបាល។ ទោះយ៉ាងនេះក្តី ផែនការ និងការងារសំខាន់នាពេលបច្ចុប្បន្ន គឺត្រូវវិភាគពីបញ្ហាប្រឈម និងជោគជ័យនានាក្នុងការអនុវត្តផែនការ និងគោលនយោបាយទាំងនោះជាពិសេសផលប៉ះពាល់នៃគ្រឿងលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងមិនមែនហិរញ្ញវត្ថុ ព្រោះវាមានទំនាក់ទំនងជិតស្និទ្ធនឹងសន្ទុះចិត្តរបស់បុគ្គលិកផ្នែកសុខាភិបាល។

## គន្ថនិទ្ទេស


Annear, Peter Leslie, Maryam Bigdeli, Ros Chhun Eang & Bart Jacobs (2008), "Providing Access to Health Services for the Poor: Health Equity in Cambodia", in Bruno Meesson, Xiaomei Pei, Bart Criel & Gerald Bloom (eds.) "Health and Social Protection: Experiences from Cambodia, China and Lao PDR", *Studies in Health Services Organization and Policy*, 23, pp. 189-225

Bureau of Health Economics and Financing (2008), Annual Health Financing Report 2007 (Phnom Penh: Department of Planning and Health Information, Ministry of Health)

Ek, Sok Hach (2008), Aid Effectiveness in Cambodia (Washington, DC: The Brookings Institute)

Eldon, J. & D. Gunby (2009), States in Development: State Building and Service Delivery Final Report (London: HLSP)

International Health Partnership (2008), Taking Stock Report Cambodia (Geneva: International Health Partnership)

Jacobs, Bart, Neil Lewis Price & Sam Oeun (2007), "Do Exemptions from User Fees Access to Health Service? A Case Study from a Rural Cambodian Hospital", Tropical Medicine and International Health, Vol. 12, No.11, pp. 1-11

Meessen B., K. Decoster, P. Ir, C. Rithy Men & K. Chheng (2010), "Do Health Equity Funds Improve Access to Hospital Services?" Presented at Public Health Forum on Poverty and Illness, Himawari Hotel, 1 April 2010, Phnom Penh, Cambodia

Ministry of Economy and Finance (2011), Introduction of MoEF, www.mef.gov.kh/about.php (accessed in June 2011)

Ministry of Health (2006), National Charter on Health Financing in the Kingdom of Cambodia (Phnom Penh: Ministry of Health)

Ministry of Health (2007), Cambodia Health Information System: Review and Assessment (Phnom Penh: Department of Planning and Health Information)

Ministry of Health (2008), Health Strategic Plan 2008 – 2015 (Phnom Penh: Ministry of Health)

Örtendahl C., M. Donoghue, M. Pearson, C. Taylor & J. Lau (2007), Health Sector Review 2003 – 2007 (London: HSLP) Royal Government of Cambodia (2000), Cambodia Demographic and Health Survey 2000: (Phnom Penh: National Institute of Statistics, Ministry of Planning)

Royal Government of Cambodia (2005), Cambodia Demographic and Health Survey 2005: (Phnom Penh: National Institute of Statistics, Ministry of Planning)

Royal Government of Cambodia (2009), National Strategic Development Plan 2009–2013, (Phnom Penh: Ministry of Planning)

Sann, C., John Grundy, Jim Maynard, Alan Brooks, Marian Boreland, Duong Sorak, Karl Jenkinson & Beverley-Ann Briggs (2006), Financial Sustainability Planning for Immunization Services in Cambodia (London: Oxford University Press in association with the London School of Hygiene and Tropical Medicine)

Sida (2003), Mapping of Health Sector Wide Approaches in Health (London: Institute for Health Sector Development)

Soa, C. (2010), "Health Equity Funds and Equality Access: the Case of Health Equity the Case with Reproductive Health Focus", presented at Public Health Forum on Poverty and Illness, Himawari Hotel, 1 April 2010, Phnom Penh, Cambodia

Song, Jurgen Hohmann, Christoph Lankers, Bun Samnang, Chhim Sarath & Penh Vanny (2003), "Report of the Appraisal Mission: Developing Health Insurance in Cambodia" (Phnom Penh: MoH & GTZ)

United Nations Development Programme (1997), Health Sector Reform (Phnom Penh: UNDP)

Vaux, T. & E. Visman (2005), Service Delivery in Countries Emerging from Conflict, Report for DFiD (Bradford: Centre for International Co-operation and Security (CICS), University of Bradford)

World Bank (2007), Sharing Growth: Equity and Development in Cambodia, Equity Report 2007, Report No. 39809-KH (Washington, DC: World Bank)

World Health Organisation and Ministry of Health (2007), A Strategic Assessment of Three Integrated Health Projects in Cambodia, funded by USAID (Geneva: WHO)

# -៦-

# គោលនយោបាយ និងការអភិវឌ្ឍ
# បុគ្គលិកសុខាភិបាលនៅកម្ពុជា៖ ការពិនិត្យជាទូទៅ

*ដោយលោកស្រី សុខ សិទ្ធា[១]*

## ១. សេចក្តីផ្តើម

ការខូចខាតបន្សល់ទុកពីរបបខ្មែរក្រហម បានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើធនធានមនុស្ស និងហេដ្ឋារចនាសម្ព័ន្ធសង្គមទូទាំងប្រទេស។ ប្រជាជនប្រមាណ ២លាននាក់ មានទាំងគ្រូពេទ្យ គិលានុបដ្ឋាក និងពេទ្យឆ្មបមានជំនាញ និងបទពិសោធន៍ជាច្រើននាក់ ត្រូវបានសម្លាប់ដោយគ្មានហេតុផលក្នុងអំឡុងពេលនោះ។ ក្រោយពីសង្គ្រាមស៊ីវិលបានបញ្ចប់ទៅនៅទសវត្សរ៍ ១៩៩០ កម្ពុជាបានប្រឹងប្រែងកសាងវិស័យសាធារណៈទាំងអស់ឡើងវិញ ដោយផ្តោតជាពិសេសលើវិស័យសុខាភិបាល។

## ២. ការអភិវឌ្ឍវិស័យសុខាភិបាល

មកទល់ឆ្នាំ១៩៧៥ រដ្ឋាភិបាលកម្ពុជាបានបណ្តុះបណ្តាលវេជ្ជបណ្ឌិតបានប្រហែល ១០០០នាក់ ប៉ុន្តែមានវេជ្ជបណ្ឌិតប្រហែល ៥០នាក់ប៉ុណ្ណោះ ដែលរួចរស់ជីវិតពីរបបខ្មែរក្រហម (MoH 2001)។ ការអភិវឌ្ឍវិស័យសុខាភិបាល មានច្រើនដំណាក់កាល៖

**ពីឆ្នាំ១៩៨០ ដល់ ១៩៨៩៖** ក្រសួងសុខាភិបាល បានចាប់ផ្តើមកសាងប្រព័ន្ធសុខាភិបាលឡើងវិញដូចជា ផ្តល់ហិរញ្ញប្បទានសាធារណៈ សេវាកម្មផ្នែកបុគ្គលិក និងការគ្រប់គ្រង ជាប្រាំកម្រិត៖ កម្មវិធីជាតិគ្រប់គ្រងដោយថ្នាក់កណ្តាល មន្ទីរពេទ្យជាតិចំនួនប្រាំបី មន្ទីរពេទ្យខេត្តចំនួន ២២ មន្ទីរពេទ្យស្រុក ១៧៤ និង គ្លីនិកផ្តល់សេវាសុខភាពបឋមនៅតាមឃុំ។ កម្មវិធីរយៈពេលខ្លីនានាក៏បានអនុវត្តឡើង ដើម្បីផ្តល់ការបណ្តុះបណ្តាលឆាប់រហ័សដល់បុគ្គលិកផ្នែកសុខាភិបាល។ ទោះយ៉ាងនេះក្តី គុណភាពសេវាសុខភាព នៅមានកម្រិតអន់ខ្សោយនៅឡើយ (MoH, 2001)។

**ពីឆ្នាំ១៩៨៩ ដល់ ១៩៩៥៖** មានការវិនិយោគច្រើនគួរឲ្យកត់សម្គាល់ពីរដ្ឋាភិបាល និងម្ចាស់ជំនួយនានា។ កំណែទម្រង់គម្រោងសេវាកម្មសុខភាពដំណាក់កាលទី១ បានចាប់អនុវត្តដោយផ្តោតលើការកែលម្អសេវាថែទាំសុខភាពបឋមនៅតាមតំបន់ជនបទ។ មានតែកម្មវិធីព្យាបាលជំងឺរបេងប៉ុណ្ណោះ ដែលបានទទួលការយកចិត្តទុកដាក់ និងមានសកម្មភាពក្នុង ១០ខេត្ត នៅកម្ពុជា។ ចំពោះសេវាថែទាំសុខភាពឯកជនវិញ សកម្មភាពនេះបានចាប់ផ្តើមឡើង ដោយសារជាចម្បងមកពីគ្រូពេទ្យចង់បានប្រាក់បន្ថែមលើ ប្រាក់កម្រៃទាបដែលខ្លួនទទួលបានពីរដ្ឋាភិបាល (MoH 2001)។

**ពីឆ្នាំ១៩៩៦ ដល់ ២០០០៖** មានការកសាង និងអនុវត្ត ផែនការគ្របដណ្តប់លើវិស័យសុខាភិបាលដើម្បីផ្តល់សេវាសុខភាពទូទាំងប្រទេស ដោយផ្អែកលើដង់ស៊ីតេប្រជាជន និង

---

១ លោកស្រី សុខ សិទ្ធា ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។ អ្នកនិពន្ធសូមថ្លែងអំណរគុណដល់លោកស្រី Ann Robins ទីប្រឹក្សាផ្នែកធនធានមនុស្សសម្រាប់សុខភាព នៃអង្គការសុខភាពពិភពលោក (WHO) ដែលបានជួយផ្តល់មតិ លើសេចក្តីព្រាងដំបូងនៃអត្ថបទនេះ។

តាមរយៈស្រុកប្រតិបត្តិដែលខុសប្លែកពីរដ្ឋបាលថ្នាក់ស្រុក។ ផែនការនេះបានជួយកាត់បន្ថយចំនួនទីកន្លែងដែលត្រូវមាន ដើម្បីផ្តល់សេវាសុខភាព និងបង្កើនប្រសិទ្ធភាពប្រើប្រាស់បុគ្គលិកសុខាភិបាល។ សំណុំសកម្មភាពអប្បបរមា (MPA) និង សំណុំសកម្មភាពបង្គ្រប់ (CPA)[២] ក៏ផ្តល់ជាក្របខ័ណ្ឌមួយដែរសម្រាប់ការអភិវឌ្ឍបុគ្គលិកក្នុងអំឡុងពេលនោះ។

កំណែទម្រង់ហិរញ្ញវត្ថុ កើតចេញពីបទបញ្ញត្តិស្តីពីហិរញ្ញប្បទានសុខាភិបាល (១៩៩៦) បានផ្តល់ជាមូលដ្ឋានច្បាប់មួយ ដើម្បីសាកល្បងប្រើវិធីយកកម្រៃជាផ្លូវការពីអ្នកប្រើប្រាស់សេវានៅតាមទីតាំងផ្តល់សេវាសុខភាពសាធារណៈ ដោយបុគ្គលិកផ្នែកសុខាភិបាលអាចទទួលបានចំណែកខ្លះដែរពីប្រាក់កម្រៃនោះ ដែលនៅពេលខ្លះមានចំនួនច្រើនជាងប្រាក់ខែមូលដ្ឋានរបស់ពួកគេទៀតផង។

**ឆ្នាំ២០០២ មកទល់បច្ចុប្បន្ន៖** ក្រសួងសុខាភិបាល បានបង្កើតក្របខ័ណ្ឌមួយសម្រាប់ការគ្រប់គ្រងវិស័យសុខាភិបាលទាំងមូល ដោយផ្តោតលើការកាត់បន្ថយភាពក្រីក្រក្នុងប្រាំឆ្នាំខាងមុខ ហើយបានដាក់បញ្ចូលក្នុងយុទ្ធសាស្ត្រជាតិដើម្បីកាត់បន្ថយភាពក្រីក្រឆ្នាំ២០០៣-២០០៥ (RGC 2002)។ ឆ្នាំ២០០៣គឺជាឆ្នាំដំបូងនៃការអនុវត្តផែនការយុទ្ធសាស្ត្រវិស័យសុខាភិបាល (HSSP) ឆ្នាំ២០០៣-២០០៧ របស់ក្រសួងសុខាភិបាល។ ការសាងសង់មណ្ឌលសុខភាពនានាក្រោមគំនិតផ្តួចផ្តើមនេះ សម្រេចបាន ៨៧% នៃបរិមាណគោលដៅ ប៉ុន្តែមណ្ឌលសុខភាពខ្លះមិនទាន់មានបុគ្គលិកគ្រប់គ្រាន់នៅឡើយទេ (MoH 2004)។ ផែនការយុទ្ធសាស្ត្រសុខាភិបាលលើកទី២ ឆ្នាំ២០០៨-២០១៥ ស្តីពីគណនេយ្យភាព ប្រសិទ្ធភាព គុណភាព និងសមធម៌ បានចាប់អនុវត្តក្នុងឆ្នាំ២០០៨ ហើយបានកំណត់ធនធានមនុស្សផ្នែកសុខាភិបាល ជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធសុខាភិបាល។

## ៣. ការពិនិត្យទូទៅលើប្រព័ន្ធសេវាសុខាភិបាលបច្ចុប្បន្ន

ប្រព័ន្ធសុខាភិបាលរបស់រដ្ឋាភិបាល មានបីកម្រិត៖ កម្រិតបឋម (ប៉ុស្តិ៍សុខភាព និងមណ្ឌលសុខភាព) កម្រិតមធ្យម (មន្ទីរពេទ្យបង្អែក) និង កម្រិតឧត្តម (មន្ទីរពេទ្យជាតិ)។ រូបភាព ១ បង្ហាញពីទិដ្ឋភាពទូទៅនៃប្រព័ន្ធសុខាភិបាលរបស់រដ្ឋាភិបាល។

---

២ MPA និង CPA មានលក្ខណៈស្រដៀងគ្នាក្នុងការផ្តល់សេវាកម្ម តែខុសគ្នាត្រង់ MPA ផ្តល់សេវានៅតាមមណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព រីឯ CPA បង្កើតឡើងដោយស្រុកប្រតិបត្តិដែលត្រូវបានធ្វើចំណាត់ថ្នាក់ទៅតាមសមត្ថភាពក្នុងការផ្តល់សេវា។ CPA មានបីប្រភេទ គឺ៖ CPA 1 ផ្តល់ពី ៤០-៦០គ្រែ CPA 2 ផ្តល់ពី ៦០-១០០គ្រែ និង CPA 3 ផ្តល់ពី ១០០-២៥០គ្រែ។

រូបភាព ១៖ ប្រព័ន្ធសេវាសុខាភិបាលរបស់រដ្ឋាភិបាល

**ប៉ុស្តិ៍សុខភាព**
- បុគ្គលិក ម្នាក់ ឬ ពីរនាក់៖ គិលានុបដ្ឋាក និងពេទ្យឆ្មប

↓

**មណ្ឌលសុខភាព**
- ភាគច្រើននៅតំបន់ជនបទ
- មានបុគ្គលិកច្រើនជាង៖ គិលានុបដ្ឋាក និងពេទ្យឆ្មប (ប្រាំបី-១១នាក់)

↓

**មន្ទីរពេទ្យបង្អែក៖**
(ផ្តល់ជំនួយទ្រទ្រង់ដល់ប៉ុស្តិ៍សុខភាព និងមណ្ឌលសុខភាព)

CPA 1 (មានគ្រែពី ៤០-៦០) គួរមានបុគ្គលិក ៥៧នាក់
- វេជ្ជបណ្ឌិត គិលានុបដ្ឋាក និងពេទ្យឆ្មប
- មិនផ្តល់សេវាវះកាត់ ឬការប្រើថ្នាំស្ពឹក

CPA 2 (មានគ្រែពី ៦០-១០០) គួរមានបុគ្គលិក ៨៣នាក់
- វេជ្ជបណ្ឌិត គិលានុបដ្ឋាក និងពេទ្យឆ្មប
- ផ្តល់សេវាវះកាត់ និងការប្រើថ្នាំស្ពឹកទូទៅ

CPA 3 (មានគ្រែពី ១០០-២៥០) គួរមានបុគ្គលិក ១៨៤នាក់
- មន្ទីរពេទ្យបង្អែកកម្រិតខ្ពស់បំផុត
- ជាទូទៅមានទីតាំងនៅកណ្តាលខេត្ត
- ផ្តល់សេវាឯកទេស សេវាវះកាត់ និងការប្រើថ្នាំស្ពឹកទូទៅ

↓

**មន្ទីរពេទ្យជាតិ**
- មានប្រាំមន្ទីរពេទ្យរបស់ក្រសួងសុខាភិបាល នៅក្រុងភ្នំពេញ ដែលមានផ្តល់សេវាឯកទេសផ្សេងៗ
- មានមន្ទីរពេទ្យឯកជនមិនស្វែងរកចំណេញចំនួនពីរ នៅក្រុងភ្នំពេញ និងមួយទៀតនៅខេត្តសៀមរាប
- ក្រុមមន្ទីរពេទ្យគន្ធបុប្ផា មានបីកន្លែង

វិស័យថែទាំសុខភាពឯកជនដើម្បីរកប្រាក់ចំណេញ បានរីកដុះដាលខ្លាំង ចាប់ពីឆ្នាំ១៩៩៣មក។ នៅទូទាំងប្រទេសកម្ពុជា មានគ្លីនិកទាំងអស់ ២៤៥៧កន្លែងដែលមិនមានគ្រែសម្រាប់អ្នកជំងឺស្នាក់នៅ និង ២៧៤កន្លែងដែលមានគ្រែសម្រាប់អ្នកជំងឺ ហើយគ្លីនិកទាំងនោះគ្របដណ្តប់លើតែ ៩,៥% នៃចំនួនប្រជាជនសរុបប៉ុណ្ណោះ (MoH 2006)។ កន្លែងផ្តល់សេវាសុខភាពឯកជនភាគច្រើនមានទាំងមន្ទីរពេទ្យឯកជនចំនួនពីរផង ស្ថិតនៅក្នុងទីក្រុងភ្នំពេញ (MoH 2006a)។ ម្យ៉ាងទៀត អង្គការផ្សេងៗ ដូចជា មន្ទីរពេទ្យមណ្ឌលនៃក្តីសង្ឃឹម និងសមាគមថែទាំសុខភាពគ្រួសារកម្ពុជា "រ៉ាក់" (RHAC) ក៏មានផ្តល់សេវាថែទាំសុខភាពក្រៅប្រព័ន្ធសុខាភិបាលរបស់រដ្ឋាភិបាលផងដែរ។

## ៤. ការអភិវឌ្ឍធនធានមនុស្សសម្រាប់វិស័យសុខាភិបាល

បន្ទាប់ពីរបបខ្មែរក្រហមដួលរលំទៅ រដ្ឋាភិបាលបានទទួលស្គាល់ពីតម្រូវការបន្ទាន់លើការបណ្តុះបណ្តាលបុគ្គលិកផ្នែកសុខាភិបាលឲ្យបានយ៉ាងច្រើន ក្នុងរយៈពេលដ៏ខ្លីមួយ។ ជាលទ្ធផល ការបណ្តុះបណ្តាលបានអនុវត្តយ៉ាងឆាប់រហ័សដោយតួអង្គផ្សេងៗ ដោយមិនមានការសម្របសម្រួលអ្វីច្រើន និងមិនបានផ្តែកលើការវាយតម្លៃពីតម្រូវការបណ្តុះបណ្តាលជារួមនោះទេ ហើយភាគច្រើនផ្តោតលើការព្យាបាលរោគ ជាជាងការថែទាំសុខភាពបឋម (Schonhals 2004)។ នៅឆ្នាំ១៩៩៦ បុគ្គលិកសុខាភិបាលសាធារណៈ មានសរុប ១៨.២៣៣នាក់ ក្នុងនោះ ១២៤៧នាក់ជាវេជ្ជបណ្ឌិត (Schonhals 2004)។

នៅឆ្នាំ១៩៩៤ ការិយាល័យបណ្តុះបណ្តាលក្នុងក្រសួងសុខាភិបាល បានពង្រីកទៅជានាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងផ្តាច់ចេញពីនាយកដ្ឋានបុគ្គលិក។

កម្មវិធីពេទ្យឆ្មប និងគិលានុបដ្ឋាកកម្រិតមធ្យម បានបញ្ចប់នៅដើមទសវត្សរ៍១៩៩០ និងជំនួសដោយកម្មវិធីគិលានុបដ្ឋាក ដែលធ្វើឲ្យពុំមានការបណ្តុះបណ្តាលពេទ្យឆ្មបថ្មីៗទេក្នុងរយៈពេលជិតប្រាំមួយឆ្នាំ។ នៅដើមឆ្នាំ២០០០ កម្មវិធី ៣+១ ត្រូវបានបង្កើតឡើង ដោយក្នុងនោះមានបន្ថែមវគ្គបណ្តុះបណ្តាលពេទ្យឆ្មបរយៈពេលមួយឆ្នាំ បន្ទាប់ពីបញ្ចប់កម្មវិធីបណ្តុះបណ្តាលគិលានុបដ្ឋាកមធ្យមរយៈពេលបីឆ្នាំ។ ក្រោយមក កម្មវិធីគិលានុបដ្ឋាកមធ្យម (secondary nurse program) ត្រូវបានជំនួសដោយកម្មវិធីគិលានុបដ្ឋាកកម្រិតមធ្យម (Associate Degree Nurse program) ដែលមានផ្តល់នៅក្នុងមជ្ឈមណ្ឌលបណ្តុះបណ្តាលតាមតំបន់។ កម្មវិធី ៣+១ នេះ មិនបានផ្តល់គ្រូពេទ្យឆ្មបឲ្យគ្រប់តាមចំនួនត្រូវការទេ ដូច្នេះ កម្មវិធីពេទ្យឆ្មបកម្រិតមធ្យម (Associate Degree Midwifery) ក៏បានចាប់ផ្តើមឡើងក្នុងឆ្នាំ២០០៩។

ក្នុងអាណត្តិទី៣ របស់រដ្ឋាភិបាល ក្រោយការបោះឆ្នោតថ្នាក់ជាតិឆ្នាំ២០០៣ បុគ្គលិកសុខាភិបាលសាធារណៈបានកើនឡើង ៩% នៅចន្លោះឆ្នាំ២០០៤ និង ២០០៨ ខណៈដែលចំនួនប្រជាជនសរុប កើនឡើងតែ ៦,៥% ប៉ុណ្ណោះ។ អត្រាកំណើនបុគ្គលិកសុខាភិបាល មានលក្ខណៈខុសប្លែកគ្នាទៅតាមក្រុមបុគ្គលិក ដោយក្រុមពេទ្យឆ្មបបឋម កើន ៣៩% ក្រុមពេទ្យឆ្មបមធ្យម កើន ១៥% ប៉ុន្តែជំនួយការវេជ្ជសាស្ត្រ មានកំណើនអវិជ្ជមាន -៦% (Seng *et al.* 2011)។

នាបច្ចុប្បន្ន ក្រសួងសុខាភិបាលកំពុងព្យាយាមលើកកម្ពស់ទាំងបរិមាណ និងគុណភាពនៃគ្រូពេទ្យជំនាញ។ នៅទីក្រុងភ្នំពេញ មានសាលាវេជ្ជសាស្ត្រចំនួនពីរ គឺសាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល (រដ្ឋ) និង សាកលវិទ្យាល័យអន្តរជាតិ (ឯកជន)។ សាកលវិទ្យាល័យឯកជនប្រាំផ្សេងទៀត កំពុងចាប់ផ្តើមបណ្តុះបណ្តាលជំនាញផ្នែកថែទាំសុខភាព ប៉ុន្តែមានសាកលវិទ្យាល័យតែមួយប៉ុណ្ណោះ ដែលកំពុងបណ្តុះបណ្តាលថ្នាក់វេជ្ជបណ្ឌិត។

មួយចំណែកទៀត មានមជ្ឈមណ្ឌលបណ្តុះបណ្តាលតាមតំបន់ចំនួនប្រាំ (RTCs) ដែលផ្តល់ការបណ្តុះបណ្តាលគិលានុបដ្ឋាក និងពេទ្យឆ្មបកម្រិតមធ្យម។ សិស្សនៅ RTCs ទាំងអស់ ទទួលបានអាហារូបករណ៍ពីរដ្ឋាភិបាល។ បន្ទាប់ពីបញ្ចប់ការសិក្សា ពួកគេអាចដាក់ពាក្យសុំប្រឡងចូលធ្វើការឲ្យរដ្ឋ។ ពីឆ្នាំ២០០២ ដល់ ២០០៧ គិលានុបដ្ឋាក និងពេទ្យឆ្មបទាំងអស់ ដែលបញ្ចប់ការសិក្សាពី RTCs បានទទួលការជ្រើសរើសឲ្យចូលបម្រើការងាររដ្ឋ ហើយពីឆ្នាំ២០០៧ ដល់ ២០១០ រដ្ឋាភិបាលទទួលយកគិលានុបដ្ឋាកតិចជាងមុន ប៉ុន្តែបន្តទទួលយកពេទ្យឆ្មប ១០០% ពី RTCs (សម្ភាសន៍ជាមួយមន្ត្រីក្រសួងសុខាភិបាល ថ្ងៃទី២៥ ឧសភា ២០១១)។

## ៥. បញ្ហាប្រឈមចំពោះ ការជ្រើសរើសបុគ្គលិក ការរក្សា ការបែងចែក និងការអនុវត្តរបស់បុគ្គលិកសុខាភិបាល

ចំនួនបុគ្គលិកសុខាភិបាលសរុបបានកើនឡើងក៏ពិតមែន ប៉ុន្តែមានបញ្ហាជាច្រើនចោទលើការបែងចែកបុគ្គលិកទាំងនោះ។ តាមការប៉ាន់ស្មាន មានវេជ្ជបណ្ឌិត ប្រហែល ៥៤% មកផ្តុំគ្នានៅទីក្រុងភ្នំពេញ ដែលមានត្រឹម ៩,៣% នៃប្រជាជនសរុបនៅកម្ពុជាប៉ុណ្ណោះ (Oum *et al.* 2005)។ តារាង ១ បង្ហាញពីភាពខុសគ្នារវាងចំនួនវេជ្ជបណ្ឌិត គិលានុបដ្ឋាក និងពេទ្យឆ្មប នៅទីក្រុងភ្នំពេញ ធៀបនឹងខេត្តនានាក្នុងប្រទេសកម្ពុជា។ តួលេខទាំងនេះបង្ហាញថា ការបែងចែកបុគ្គលិកសុខាភិបាលតាមតំបន់ មិនមានការប្រែប្រួលទេក្នុងរយៈពេលប្រាំឆ្នាំកន្លងទៅនេះ។

តារាង ១៖ ចំនួនវេជ្ជបណ្ឌិត គិលានុបដ្ឋាក និងពេទ្យឆ្មប នៅទីក្រុងភ្នំពេញ ធៀបនឹងខេត្តនានា (ឆ្នាំ២០០៣ និង ២០០៨)

| ប្រភេទ | 2003 | | | 2008 | | |
|---|---|---|---|---|---|---|
| | ក្រុងភ្នំពេញ | ខេត្តនានា | ភាពខុសគ្នា | ក្រុងភ្នំពេញ | ខេត្តនានា | ភាពខុសគ្នា |
| វេជ្ជបណ្ឌិត | 1200 | 12,300 | 10.2 | 1155 | 11,511 | 10.0 |
| គិលានុបដ្ឋាក | 850 | 2000 | 2.3 | 787 | 1714 | 2.2 |
| ពេទ្យឆ្មប | 3200 | 5200 | 1.6 | 3339 | 4124 | 1.2 |

*ប្រភព៖ ស្ថិតិសុខភាពជាតិ 2004 & 2008a cited in Seng et al. 2011*

ប្រទេសកម្ពុជា មានការលំបាកក្នុងការបែងចែក និងរក្សា វេជ្ជបណ្ឌិត គិលានុបដ្ឋាក និងពេទ្យឆ្មប នៅតំបន់ជនបទដាច់ស្រយាល ដោយសារជាសំខាន់មកពីបញ្ហាហិរញ្ញវត្ថុខ្សត់ខ្សោយ និងកត្តាមិនមែនហិរញ្ញវត្ថុទាក់ទងនឹងការងារនៅជនបទ ដូចជា ប្រាក់កម្រៃទាបពីវិស័យសាធារណៈ ឱកាសតិចតួចក្នុងការរកកម្រៃបែបឯកជន ភាពទន់ខ្សោយនៃការអប់រំ បញ្ហាកន្លែងស្នាក់នៅ និងគ្រឿងសម្រួលការសម្រាប់ក្រុមគ្រួសាររបស់បុគ្គលិកសុខាភិបាល របបគ្រប់គ្រងមានលក្ខណៈទន់ខ្សោយ ការទ្រទ្រង់ខាងវិជ្ជាជីវៈមានកម្រិត និងការងារឆ្ងាយពីគ្រួសារ (Viviretto & White 2010)។

ប្រាក់បៀវត្សរ៍របស់បុគ្គលិកសុខាភិបាល មិនបានដូចការរំពឹងទុកអំពីប្រាក់ខែសមស្របរបស់ពួកគេនោះទេ ហើយបញ្ហានេះបានបង្កការធ្លាក់ទឹកចិត្ត ការលំបាកក្នុងការត្រួតពិនិត្យ និងការយកកម្រៃក្រៅផ្លូវការពីអ្នកជំងឺ ដោយធ្វើឲ្យធ្លាក់ចុះប្រសិទ្ធភាពរួម សមធម៌នៃប្រព័ន្ធសុខាភិបាល និងរារាំងដល់ដំណើរការអនុវត្តន៍កំណែទម្រង់វិស័យសុខាភិបាល (Bun Theth 2005)។

បុគ្គលិកសុខាភិបាលជាច្រើននាក់ ស្វែងរកចំណូលបន្ថែមពីប្រភពផ្សេងទៀត ដូចជា ការបើកព្យាបាលជាឯកជនជាដើម ហើយច្រើននាក់ទៀតបានធ្លាក់ទឹកចិត្ត និងតែងអវត្តមានជាញឹកញាប់ពីកន្លែងធ្វើការ (Viviretto & White 2010; Darapheak *et al.* 2009)។

កង្វះខាតពេទ្យឆ្មបធ្ងន់ធ្ងរ បានកើតមានឡើង មួយផ្នែកមកពី "ការបណ្តុះបណ្តាលពេទ្យឆ្មបមធ្យម ដែលជាវគ្គបណ្តុះបណ្តាលរយៈពេលបីឆ្នាំនោះ បានផ្អាកអស់ប្រាំមួយឆ្នាំ ដោយសារតែភាពយឺតយ៉ាវក្នុងការកែសម្រួលកម្មវិធីបណ្តុះបណ្តាល" (Kanchanachitra *et al.* 2011)។ ក្រសួងសុខាភិបាល បានប្តេជ្ញាផ្តល់ ពេទ្យឆ្មបបឋមមួយនាក់ និងមធ្យមមួយនាក់ សម្រាប់មណ្ឌលសុខភាពនីមួយៗ ហើយក្នុងឆ្នាំ២០១០ ក្រសួងបានសម្រេចគោលដៅក្នុងការផ្តល់ពេទ្យឆ្មបបឋម។

## ៦. បរិយាកាសលើកទឹកចិត្តសម្រាប់បុគ្គលិកសុខាភិបាល

ក្នុងចំណោមបញ្ហាប្រឈមសំខាន់ៗដែលរដ្ឋាភិបាលកំពុងជួបប្រទះ គឺមានអត្រាទាបនៃការសម្រាលកូនអនុវត្តដោយពេទ្យឆ្មបជំនាញ។ ដើម្បីសម្រេចគោលដៅ ៨០% នៃការសម្រាលកូនអនុវត្តដោយអ្នកមានជំនាញ រដ្ឋាភិបាលបានអនុវត្តរបបលើកទឹកចិត្តដល់ពេទ្យឆ្មបក្នុងទម្រង់ជាការផ្តល់កម្រៃបន្ថែម ៦០.០០០រៀល (១៥ដុល្លារ) ក្នុងមួយខែ សម្រាប់អ្នកធ្វើការនៅមណ្ឌលសុខភាព និង ៤០.០០០រៀល (១០ដុល្លារ) ក្នុងមួយខែ សម្រាប់អ្នកធ្វើការនៅមន្ទីរពេទ្យបង្អែក។ ការអនុវត្តនេះ បានធ្វើឲ្យអត្រានៃការសម្រាលកូននៅមន្ទីរពេទ្យ កើនពី ៣៨% នៅឆ្នាំ២០០៨ ដល់ ៤៤% នៅឆ្នាំ២០០៩ ប៉ុន្តែវាក៏បានបង្កជាបញ្ហាយឺតយ៉ាវក្នុងការបញ្ជូនអ្នកជំងឺក្នុងករណីខ្លះៗដែរ (MoH 2010a)។

ថវិការបស់ក្រសួងសុខាភិបាល សម្រាប់ឆ្នាំ២០១០ បានផ្តល់បៀវត្សរ៍ប្រចាំខែជាមធ្យម ៦៥ដុល្លារសម្រាប់បុគ្គលិកសុខាភិបាលទាំងអស់ ហើយរដ្ឋាភិបាលគ្រោងតម្លើងប្រាក់បៀវត្សរ៍ ២០% រៀងរាល់ឆ្នាំ ដើម្បីដោះស្រាយបញ្ហាប្រាក់បៀវត្សរ៍ទាប។ ទោះយ៉ាងនេះក្តី ចំណាយរបស់ក្រសួងលើធនធានមនុស្ស សម្រាប់វិស័យសុខាភិបាល នៅមានកម្រិតទាប បើធៀបនឹងស្តង់ដារអន្តរជាតិ ដោយមានតែ ១៥% នៃចំណាយរបស់រដ្ឋាភិបាលប៉ុណ្ណោះ ដែលត្រូវបានបែងចែកសម្រាប់កម្លាំងពលកម្មសុខាភិបាលក្នុងឆ្នាំ២០០៨ ហើយតួលេខនេះឆ្លុះបញ្ចាំងពីបញ្ហាប្រាក់បៀវត្សរ៍ទាប និងចំនួនបុគ្គលិកតិច (Buchan 2011)។

សម្រាប់មណ្ឌលសុខភាពនៅកម្ពុជា មានពីរភាគបីមិនអាចអនុវត្តកម្មវិធីសំណុំសកម្មភាពអប្បបរមា (MPA) បានទេ ដោយសារកង្វះខាតពេទ្យឆ្មប និងគិលានុបដ្ឋាក (Chhea *et al.* 2010)។ ដើម្បីឆ្លើយតបនឹងកង្វះខាតពេទ្យឆ្មប និងការបែងចែកពេទ្យឆ្មបមិនត្រឹមត្រូវនោះ នៅឆ្នាំ២០០៣ រដ្ឋាភិបាលបានបង្កើតកម្មវិធីបណ្តុះបណ្តាលពេទ្យឆ្មបបឋមរយៈពេលមួយឆ្នាំ ដោយជ្រើសយកសិស្សថ្នាក់ទី៧ នៅកន្លែងនោះឲ្យចូលរៀន ហើយរហូតដល់ឆ្នាំ២០០៥ ទើបបង្កើនការជ្រើសរើសដល់សិស្សនៅទូទាំងប្រទេស ប៉ុន្តែបានជ្រើសយកសិស្សរៀនថ្នាក់ទី១០ ឲ្យចូលរៀនជំនួសវិញ ដើម្បីបង្កើនគុណភាព (Kanchanachitra *et al.* 2011)។ កម្មវិធីនេះបានទទួលជោគជ័យក្នុងការដាក់ពង្រាយពេទ្យឆ្មបទៅតាមទីជនបទ ប៉ុន្តែបានទទួលការរិះគន់នៅក្នុងការពិនិត្យឡើងវិញលើពេទ្យឆ្មប ឆ្នាំ២០០៦ ពីព្រោះកម្រិតទាបនៃការអប់រំរបស់សិស្ស ធ្វើឲ្យពួកគេពិបាកបំពេញតាមស្តង់ដារក្នុងពេលបណ្តុះបណ្តាល (MoH 2010b & MoH, 2006c)។

មូលនិធិសមធម៌សុខភាព បានបង្កើតឡើងក្នុងឆ្នាំ២០០០ ដើម្បីបង្កើនលទ្ធភាពប្រើប្រាស់សេវាថែទាំសុខភាពសម្រាប់ប្រជាជនក្រីក្រ។ ប្រាក់ចំណូលប្រមូលបានពីការយកថ្លៃព្យាបាល (រដ្ឋជួយចេញមួយភាគ) ពីអ្នកជំងឺ ត្រូវបានបែងចែកជា ៤០% ទុកប្រើប្រាស់សម្រាប់ដោះស្រាយចំណាយប្រតិបត្តិការទូទៅ និង ៦០% សម្រាប់ជាគ្រឿងលើកទឹកចិត្តដល់បុគ្គលិក (MoH 2008)។

បន្ថែមពីនេះទៀត អនុក្រឹត្យលេខ ២៩ ចុះខែមេសា ២០០៨ បានចែងពីការអនុវត្តគម្រោងប្រាក់លាភការបន្ថែមដោយផ្អែកលើលទ្ធផលការងារ (MBPI) ដើម្បីផ្តល់ប្រាក់បន្ថែមដល់បុគ្គលិកដែលអនុវត្តការងារបានល្អខ្លាំង និងល្អវិសេស និងជំនួសប្រព័ន្ធផ្តល់ប្រាក់បន្ថែមតាមការចាំបាច់ (MoH 2008d; RGC 2009b)។ ទោះយ៉ាងណាក៏ដោយ គម្រោងនេះបានបញ្ចប់ក្នុងខែធ្នូ ២០០៩ ដោយសារការកាត់បន្ថយថវិកាជាតិ។

នៅមុនពេលបង្កើតគម្រោង MBPI គណៈរដ្ឋមន្ត្រីបានផ្ដួចផ្ដើមគំនិតបង្កើតកម្មវិធីកន្សោមអាទិភាព (PMG) ដែលទទួលហិរញ្ញប្បទានពីរដ្ឋាភិបាល ក្នុងបំណងជំរុញទឹកចិត្តក្រុមមន្ត្រីរាជការស៊ីវិលនានា។ ក្រសួងសុខាភិបាលបានប្រើប្រាស់គំនិតផ្ដួចផ្ដើមនេះ ដើម្បីលើកទឹកចិត្តបុគ្គលិកសុខាភិបាលឲ្យកែលម្អលទ្ធផលសុខភាពមាតា និងកុមារ។ PMG បានផ្អាកទៅវិញក្នុងពេលដំណាលគ្នានឹង MBPI ដែរ។

ទីភ្នាក់ងារប្រតិបត្តិការពិសេស (SOAs) បានកកើតឡើងដោយអនុក្រឹត្យលេខ ៦៩ របស់រដ្ឋាភិបាល ចុះខែមេសា ២០០៩ (RGC 2009a) និងបានដំណើរការក្នុងលក្ខណៈពាក់កណ្ដាលស្វយ័ត ដោយត្រួតពិនិត្យលើធនធានមនុស្ស រួមមាន ការជួល និងការបញ្ឈប់បុគ្គលិកចុះកិច្ចសន្យា ការគ្រប់គ្រងហិរញ្ញវត្ថុ និងការបែងចែកគ្រឿងលើកទឹកចិត្តបុគ្គលិក (Keovathanak 2010)។

នៅខែកក្កដា ២០១០ គណៈរដ្ឋមន្ត្រីបានចាប់អនុវត្តគម្រោងចំណាយប្រតិបត្តិការអាទិភាព (POC) ដោយទុកជាក្របខ័ណ្ឌរបស់រដ្ឋាភិបាល សម្រាប់តម្រង់ទិសគ្រឿងលើកទឹកចិត្តរបស់ដៃគូអភិវឌ្ឍន៍ទាំងអស់។ ក្រសួងសុខាភិបាល បានអនុវត្តគម្រោងនេះ នៅឆ្នាំ២០១១ ក្នុងបំណងលើកទឹកចិត្តបុគ្គលិកសុខាភិបាលឲ្យកែលម្អលទ្ធផល និងដើម្បីជំនួសគម្រោង PMG និង MBPI ដែលបានបញ្ចប់ទៅ (RGC 2010)។

ទាំង SOAs និង POC ប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងការអនុវត្ត និងគណនេយ្យភាព (PMAS) ដើម្បីគ្រប់គ្រងលើការអនុវត្តរបស់បុគ្គលិកផ្អែកតាមលទ្ធផល។

## ៧. តួអង្គខាងរដ្ឋាភិបាល

រដ្ឋបាលសាធារណៈប្រទេសកម្ពុជា បានកសាងឡើងវិញទាំងស្រុងក្រោយពីការដួលរលំរបបខ្មែរក្រហមនៅឆ្នាំ១៩៧៩។ ក្នុងទសវត្សរ៍១៩៨០ ការកសាងឡើងវិញបានអនុវត្តដោយមានវៀតណាមជួយពិនិត្យ និងដោយផ្អែកតាមមនោគមន៍វិជ្ជាបែបសង្គមនិយម។ បន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពក្រុងប៉ារីស ឆ្នាំ១៩៩១ ម្ចាស់ជំនួយអន្តរជាតិដែលមានរបៀបរបបបែបសេរីនិងពហុបក្សជាង បានក្លាយជាដៃគូអភិវឌ្ឍន៍ចម្បងៗរបស់កម្ពុជា។ នៅពេលនោះ ធនធានដែលមាន គឺតិចតួចណាស់ រាប់បញ្ចូលទាំងបុគ្គលិកមានបទពិសោធន៍ និងការអប់រំផង។ ម៉្យាងទៀត ទំនាស់ផ្ទៃក្នុងនៅតែចោទបញ្ហាធ្ងន់ធ្ងររហូតដល់ចុងទសវត្សរ៍១៩៩០ ធ្វើឲ្យខ្សែរយៈ និងភាពស្មោះត្រង់ជាមួយគណបក្ស បានក្លាយជាលក្ខណៈសម្បត្តិសំខាន់បំផុតក្នុងវិស័យរដ្ឋបាលសាធារណៈ។ ប្រព័ន្ធខ្សែខ្នង និងបណ្ដាញក្រៅផ្លូវការ បានបង្កើតជាយន្តការផ្សេងៗ ដើម្បីក្ដោបក្ដាប់ និងរក្សាអំណាចត្រួតត្រា ហើយជាការតបស្នងចំពោះមន្ត្រីរាជការដែលស្មោះស្ម័គ្រនឹងគណបក្ស មន្ត្រីទាំងនោះទទួលបានច្រករកប្រាក់កម្រៃក្រៅផ្លូវការពីប្រភពផ្សេងៗ ដើម្បីបំពេញបន្ថែមលើប្រាក់ខែ និងប្រាក់ឧបត្ថម្ភផ្លូវការដ៏តិចតួចរបស់ខ្លួន (Hughes & Conway 2004)។

ក្រោយបានកកើតឡើងភ្លាមក្នុងឆ្នាំ១៩៩៣ រដ្ឋាភិបាលអាណត្តិទីមួយបានចាប់អនុវត្តកម្មវិធីកំណែទម្រង់មួយ ដើម្បីលើកកម្ពស់អភិបាលកិច្ច និងរដ្ឋបាលសាធារណៈ។ គោលបំណងចម្បងមួយ គឺធ្វើសមាហរណកម្មស្ថាប័នរដ្ឋបាលផ្សេងៗ ឲ្យក្លាយជារដ្ឋបាលស៊ីវិលឯកភាពមួយ តាមរយៈការកំណត់មន្ត្រីរាជការស៊ីវិលស្នូលមួយក្រុម ដើម្បីផ្ដល់ការទទួលស្គាល់គុណសម្បត្តិ និងផ្ដល់លាភការឲ្យបានគ្រប់គ្រាន់។ រដ្ឋបាលស៊ីវិលត្រូវបានបង្កើតឡើងដោយច្បាប់ស្ដីពីមុខងារសាធារណៈឆ្នាំ១៩៩៧ និងមានភារកិច្ចចម្បង រក្សាសន្តិភាព សមភាព និងស្ថិរភាព។

នៅឆ្នាំ១៩៩៩ មានការបង្កើតក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល (CAR) ដែលជាអង្គភាពអន្តរក្រសួងពាក់ព័ន្ធច្រើនវិស័យ មានអំណាចធ្វើសេចក្តីសម្រេច និងមានអាណត្តិធ្វើការសម្របសម្រួលដំណើរការ និងគំនិតផ្តួចផ្តើមធ្វើកំណែទម្រង់ផ្សេងៗ ដើម្បីត្រួតពិនិត្យលើកំណែទម្រង់រដ្ឋបាលសាធារណៈ។ CAR ជាតួអង្គដ៏សំខាន់ និងជាគន្លឹះ ដើម្បីស្វែងយល់ពីដំណើរការយឺតយ៉ាវក្នុងវិស័យសុខាភិបាលមកទល់បច្ចុប្បន្ន។ CAR ដែលមានបុគ្គលិក សមត្ថភាព និងធនធានមានកម្រិត បានចូលរួមក្នុងវិស័យ និងសកម្មភាពជាច្រើន ដើម្បីព្យាយាមគ្រប់គ្រងលើដំណើការកំណែទម្រង់រដ្ឋបាល (Danida 2004)។

កំណែទម្រង់រដ្ឋបាលសាធារណៈជាតិ (NPAR) ឬកំណែទម្រង់រដ្ឋបាលស៊ីវិល អាចចែកចេញជាពីរផ្នែកសំខាន់ៗ៖ កំណែទម្រង់ប្រាក់បៀវត្សរ៍ និងកំណែទម្រង់ការគ្រប់គ្រងនិងការងារ។

គោលនយោបាយស្តីពីការផ្តល់សេវាសាធារណៈ (២០០៦) "បម្រើប្រជាពលរដ្ឋឲ្យបានកាន់តែប្រសើរ" កំណត់ឡើងដោយ CAR បានបញ្ជាក់ពីចក្ខុវិស័យរបស់រដ្ឋាភិបាលលើការផ្លាស់ប្តូរពីអង្គភាពរដ្ឋបាលទៅជាអង្គភាពផ្តល់សេវា ព្រមទាំងអធិប្បាយពីមុខងាររបស់សហគ្រាសរដ្ឋបាលសាធារណៈ និង SOAs ផងដែរ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលជាដៃគូមួយនៅក្នុងកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ បានអនុវត្តគម្រោង SOAs ដើម្បីលើកកម្ពស់លទ្ធផល និងគណនេយ្យភាពក្នុងរដ្ឋបាល (MoH 2009)។

## ៨. ចន្លោះខ្វះខាតសំខាន់ៗក្នុងការយល់ដឹងពីគ្រឿងលើកទឹកចិត្តបុគ្គលិកសុខាភិបាល

អង្កេតវិស័យសុខាភិបាល និងប្រជាសាស្ត្រកម្ពុជា ឆ្នាំ២០១០ បានប៉ាន់ស្មានថា អត្រាមរណមាតា មានប្រមាណ ២០៦នាក់ ក្នុង ១០០.០០០កំណើត (RGC 2011; CDHS 2010; RGC 2011) ដែលមានន័យថា MoH បានសម្រេចតាមគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDG) ក្នុងការលើកកម្ពស់សុខភាពមាតា និងកាត់បន្ថយអត្រាមរណមាតាឲ្យបាន ៧៥% នៅចន្លោះឆ្នាំ១៩៩០ ដល់ ២០១៥ (MoH, 2011)។ ទោះយ៉ាងណាក្តី កង្វះពេទ្យឆ្មប ជាពិសេសនៅតាមតំបន់ជនបទ និងតម្រូវការអភិវឌ្ឍជំនាញពេទ្យឆ្មបដើម្បីកាត់បន្ថយថែមទៀតនូវអត្រាមរណមាតាមានន័យថា MoH នៅតែផ្តោតលើការអភិវឌ្ឍ និងបណ្តុះបណ្តាលពេទ្យឆ្មប។ ពេទ្យឆ្មបថ្នាក់ខ្ពស់ត្រូវមានជំនាញខាងគ្រប់គ្រង ដើម្បីគ្រប់គ្រងសេវាសម្រាលកូននៅតាមកន្លែងផ្តល់សេវាសុខភាព ឬនៅតាមសហគមន៍ (MoH 2007)។ ការវិនិយោគលើផ្នែកអប់រំមុនពេល និងក្នុងពេលផ្តល់សេវាកម្ម ជាតម្រូវការចាំបាច់ (MoH 2006b)។ សិស្សមកពីតំបន់ជនបទ និងតំបន់ដាច់ស្រយាលត្រូវការជំនួយទ្រទ្រង់ ដើម្បីបញ្ចប់ការសិក្សាកម្រិតមធ្យម និងការបណ្តុះបណ្តាលជំនាញសុខាភិបាល។ លើសពីនេះ ប្រព័ន្ធត្រួតពិនិត្យ និងបញ្ជូនអ្នកជំងឺ ក៏ត្រូវពង្រឹងបន្ថែមដែរ ហើយ MoH គួរបន្តព្យាយាមផ្តល់ឲ្យបាននូវពេទ្យឆ្មបបឋមមួយនាក់ និងពេទ្យឆ្មបមធ្យមមួយនាក់ សម្រាប់មណ្ឌលសុខភាពនីមួយៗ។

នាបច្ចុប្បន្ន នៅមានចន្លោះខ្វះខាតខ្លះៗក្នុងការយល់ដឹងពីគម្រោងគ្រឿងលើកទឹកចិត្តរបស់រដ្ឋាភិបាល ដូចជា កង្វះការកំណត់ពីបទពិសោធន៍ទទួលបាន ជាដើម។ ទាក់ទងនឹងគម្រោង MPBIs, PMG, SOAs និងការគ្រប់គ្រងបុគ្គលិកជាប់កិច្ចសន្យា គេមានព័ត៌មានតិចតួចណាស់ពីរបៀប និងកម្រិតនៃការបែងចែកគ្រឿងលើកទឹកចិត្ត និងវិធីឥរិយាបថរបស់បុគ្គលិកសុខាភិបាលទល់នឹង

បញ្ហាប្រឈមខាងហិរញ្ញវត្ថុ និងខាងស្ថាប័ន ដើម្បីអាចបន្តការងារផ្តល់សេវាសុខភាពសាធារណៈនៅតំបន់ជនបទទៀតបាន (Chhea *et al.* 2010)។ គម្រោងមួយចំនួន ដូចជា MBPI និង PMG បានផ្អាក បន្ទាប់ពីអនុវត្តបានមួយរយៈខ្លី ដោយសារមានផលប៉ះពាល់អវិជ្ជមាន ដូចជា ការបែងចែកគ្រឿងលើកទឹកចិត្តមិនស្មើភាព បណ្តាលឲ្យមានទំនាស់រវាងអ្នកផ្តល់សេវាថែទាំសុខភាព ជាដើម (RGC 2009b)។ ទោះយ៉ាងនេះក្តី មិនទាន់មានការសិក្សា ឬការវាយតម្លៃយ៉ាងល្អិតល្អន់ណាមួយទៅលើគម្រោង MBPI និង PMG នោះទេ។ គម្រោង SOA មិនដែលបានឆ្លងកាត់ការវាយតម្លៃអ្វីសោះ ចាប់តាំងពីពេលបង្កើតឡើងក្នុងឆ្នាំ២០០៩ រីឯគម្រោងចំណាយប្រតិបត្តិការអាទិភាពទើបតែចាប់ផ្តើមអនុវត្តប៉ុណ្ណោះ។ មានការសិក្សាមួយចំនួនពីឥទ្ធិពលនៃគម្រោងយកថ្លៃព្យាបាលពីអ្នកជំងឺ ទៅលើការលើកកម្ពស់លទ្ធផលការងាររបស់បុគ្គលិកផ្នែកសុខាភិបាល ប៉ុន្តែការសន្និដ្ឋានមានលក្ខណៈចម្រុះ។ ការសិក្សាពីរបង្ហាញថា ការដាក់អនុវត្តគម្រោងយកថ្លៃព្យាបាលពីអ្នកជំងឺនៅមណ្ឌលសុខភាពសាធារណៈ បានជួយលើកកម្ពស់លទ្ធផលការងារ និងឥរិយាបថបុគ្គលិក ដូចជា កែលម្អវត្តមានបុគ្គលិក និងការប្រាស្រ័យទាក់ទងផ្នែកខាងក្នុង និងជាមួយខាងក្រៅ (Bigdeli & Ir 2010; Akashi *et al.* 2004)។ ទោះយ៉ាងណាក្តី ការសិក្សារបស់ Barber *et al.* (2004) មិនបានរកឃើញពីទំនាក់ទំនងខ្លាំងរវាង ប្រាក់បន្ថែមលើបៀវត្សរ៍ និងលទ្ធផលការងាររបស់បុគ្គលិកនោះទេ។

## ៩. សេចក្តីសន្និដ្ឋាន

រដ្ឋាភិបាល បានអនុវត្តកំណែទម្រង់សកម្មភាព អន្តរាគមន៍ខាងគោលនយោបាយ និងគម្រោងលើកទឹកចិត្តជាច្រើន ដើម្បីលើកកម្ពស់លទ្ធផលការងារ និងទាក់ទាញបុគ្គលិកសុខាភិបាលឲ្យធ្វើការនៅតំបន់ជនបទ។ ទោះយ៉ាងនេះក្តី មានព័ត៌មានតិចតួចណាស់ពីរបៀបបែងចែកគ្រឿងលើកទឹកចិត្ត វិធីតស៊ូរបស់បុគ្គលិកសុខាភិបាលទល់នឹងបញ្ហាប្រឈមផ្នែកហិរញ្ញវត្ថុ និងផ្នែកស្ថាប័ន ដើម្បីអាចបន្តការងារផ្តល់សេវាសុខភាពសាធារណៈនៅតំបន់ជនបទទៀតបាន។ ចំណុចគួរបារម្ភដទៃទៀត ដែលត្រូវធ្វើការវិភាគជាលក្ខណៈប្រព័ន្ធ មានជាអាទិ៍៖

- ធនធានមនុស្សផ្នែកសុខាភិបាល ដោយផ្តោតជាពិសេសលើគោលនយោបាយទាក់ទាញ និងរក្សាបុគ្គលិកសុខាភិបាលនៅតំបន់ជនបទ
- ហិរញ្ញប្បទានសុខាភិបាល និងធនធានមនុស្សក្នុងវិស័យសុខាភិបាល ដោយផ្តោតជាពិសេសលើផលប៉ះពាល់នៃគោលនយោបាយហិរញ្ញប្បទានទៅលើបុគ្គលិកសុខាភិបាល
- អភិបាលកិច្ចសុខាភិបាល ដោយផ្តោតជាពិសេសលើនាទី និងភាពជាអ្នកដឹកនាំក្នុងវិស័យសុខាភិបាល

ផែនការយុទ្ធសាស្ត្រសុខាភិបាល ឆ្នាំ២០០៨-២០១៥ ក៏បានអំពាវនាវឲ្យមានការស្រាវជ្រាវអំពីប្រព័ន្ធសុខាភិបាល ដើម្បីបង្កើតជាកញ្ចប់គោលនយោបាយគ្រប់ជ្រុងជ្រោយមួយ ដែលផ្អែកលើភស្តុតាងជាក់ស្តែង និងអាចអនុវត្តបាន ហើយអនុលោមទៅតាមច្បាប់ និងបទបញ្ញត្តិរបស់កម្ពុជា។ វិស័យសំខាន់ៗសម្រាប់ការស្រាវជ្រាវ រួមមាន៖

- កិច្ចសន្យាផ្តល់សេវាសុខភាព (គ្របដណ្តប់លើ SOAs ការចុះកិច្ចសន្យាជាមួយបុគ្គលិកផ្ទៃក្នុង និងអ្នកមកពីខាងក្រៅ)
- វិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យសុខាភិបាល

- ការគាំពារសុខភាពសង្គម ដូចជា មូលនិធិសមធម៌សុខភាព និងធានារ៉ាប់រងសុខភាពសង្គម ជាដើម
- ការគ្រប់គ្រងបុគ្គលិក និងការផ្តល់លាភការដល់បុគ្គលិក រាប់បញ្ចូលទាំងគ្រឿងលើកទឹកចិត្តផ្អែកលើលទ្ធផលការងារ ប្រាក់កម្រៃផ្អែកលើគុណសម្បត្តិ ប្រាក់បន្ថែមលើបៀវត្សរ៍ផ្អែកលើសេវាបន្ថែម ប្រាក់ឧបត្ថម្ភលើចំណាយតាមថ្ងៃ និងការងារចុះកិច្ចសន្យា (MoH 2008c: 44)។

## គន្ថនិទ្ទេស


Akashi, H., T. Yamada, E. Huot, K. Kanal & T. Sugimoto (2004), "User Fee at a Public Hospital in Cambodia: Effects on hospital Performance and provider attitudes", *Social Science and Medicine*, 58 (2004), pp. 553-564

Barber S., F. Bonnet, H. Bekedam (2004), "Formalizing under-the-table payments to control out-of-pocket hospital Expenditures in Cambodia", *Health Policy and Planning,* 19 (4), pp. 199-208

Beitz, J., (2004) "Increasing Access to Reproductive Health Services through Pharmacists", *Outlook,* Vol.21, No.2, September 2004

Bigdeli, M. & P. Ir (2010), "A Role for User Charges? Thoughts from Health Financing Reforms in Cambodia", World Health Report 2010, Background Paper, No. 42 (Geneva: WHO)

Buchan, J. (2011), "Cambodia: Improving Retention of Health Workers in Remote and Rural Areas: A review of Incentives", presentation on Human Resources for Health Coordination meeting at WHO, Cambodia

Bun Theth, V. (2005), Workshop on Healthcare for the Poor in Asia: Health Policies for the Poor in Cambodia, Network of Asia-Pacific Schools and Institutes of Public Administration and Governance (NAPSIPAG) Annual Conference 2005, Beijing, PRC, 5-7 December 2005

Chhea, C., N. Warren & L. Manderson (2010), "Health Worker Effectiveness and Retention in Rural Cambodia", *Rural and Remote Health,* 10, pp. 1391,

Danida (2004), *Public Administration Reform in Cambodia*, draft working paper, at www.phnompenh.un.dr/NR/.../MBPBACKGROUNDDOCUMENTS14MARCH2007.pdf

Darapheak, C., de J. Sa, S. Mounter-Jack & L.K. Narann & S. Touch (2009), "Cambodia Health System and Pandemic Preparedness", Rapid Situational Analysis Report (London: School of Hygiene and Tropical Medicine)

Hughes,C. & T. Conway (2004), *Understanding Pro-poor Political Change* (London: ODI)

Kanchanachitra, C., M. Lindelow, T. Johnston, P. Hanvoravongchai, F.M. Lorenzo, Nguyen Lan Huang, S. Agus & J.F. del Rosa (2011), "Human Resources for Health in Southeast Asia: Shortages, Distributional Challenges, and international trade in Health Services", Health in Southeast Asia 5, *The Lancet*, 377, pp. 769-81

Keovathanak, K. & P.L. Annea (2010), “The transaction to Semi-autonomous management of Health Services at District-level in Cambodia: Assessing Purchasing arrangements, Transaction Costs and Operational Efficiencies of Special Operating Agencies”, paper for the Conference on Health Sector Institutions, Motivations and Incentives, Phnom Penh, April 2010

Ministry of Health (2011), “Maternal Health in Cambodia”, presentation by H.E. Professor Eng Huot, Secretary of State, Ministry of Health Cambodia, at the National Assembly Workshop, 10 March 2011

Ministry of Health (2010a), *2009 Annual Performance Monitoring Report,* Second Health Sector Support Programme 2009-13 (Phnom Penh: MoH)

Ministry of Health (2010b), “Needs Assessment of Cambodian Public Midwifery Training Institutions and Clinical Practice Sites” (Phnom Penh: MoH)

Ministry of Health (2009), *Special Operation Agency Manual,* final draft, main text (Phnom Penh: Department of Planning and Health Information)

Ministry of Health (2008a), *National Health Statistics Report 2008* (Phnom Penh: MoH)

Ministry of Health (2008b), *Guideline for Implementation of Health Equity Funds and Government Subsidy Schemes,* Issue 1, (English version 28 July 2008) (Phnom Penh: Department of Planning & Health Information)

Ministry of Health (2008c), *Health Strategic Plan 2008-2015-Accountability, Efficiency, Quality, Equity* (Phnom Penh: MoH)

Ministry of Health (2008d), *Manual for Implementation of Merit-Based Pay Incentives* (draft) (Phnom Penh: MoH)

Ministry of Health (2007), *Joint Annual Performance Review 2007* (Phnom Penh: Department of Planning and Health Information)

Ministry of Health (2006a), *National Guidelines on Complementary Package of Activities for Referral Hospital Development 2006-2010* (Phnom Penh: MoH)

Ministry of Health (2006b), *Health Workforce Development Plan 2006-2015* (Phnom Penh: MoH)

Ministry of Health (2006c), “Report of the Comprehensive Midwifery Review in September” 2006 (Phnom Penh: MoH)

Ministry of Health (2001), “Joint Health Sector Review Report” (Phnom Penh: MoH)

National Institute of Statistics (2008) *General Population Census of Cambodia,* Final Census Result (Phnom Penh: NIS)

Ortendahl, C., E. Lau, M. Donoghue, M. Pearson & C. Taylor (2007), “Cambodia’s Health Sector Review (2003-2007)”

Oum, S., K. Phuong, S. Vonthanak & O. Phalyka (2005), “Human Resource for Health and Child Survival in Cambodia” (Phnom Penh: University of Health Science)

Royal Government of Cambodia (2011), "Cambodia Demographic and Health Survey Results 2010", opening speech by Deputy Prime Minister Keat Chhon, MP Minister of Economy and Finance, Phnom Penh, 24 October 2011

Royal Government of Cambodia (2010), Cambodia Rehabilitation and Development Board, Council for the Development of Cambodia, minutes of the sixteenth meeting of the Government-Development Partner Coordination Committee (GDCC), 29 April 2010 at CDC

Royal Government of Cambodia (2009a), "Sub-Decree 69 on the Designation of Health Institution as SOA" (Phnom Penh: RGC)

Royal Government of Cambodia (2009b), "The cancellation of Priority Mission Group and Merit-Based Performance Incentive", in Sub-decree 206, 2009 (Phnom Penh: RGC)

Schonhals, C. (2004), "Eight Years Cambodian-German Development Cooperation in the Health Sector", http://www.human-resources-health.com/content/6/1/18

Seng, B., N. Neath, P. Nonglak & S. Sethea (2011), "Understanding Rural health Service in Cambodia: Results of a Discrete Choice Experiment", in Hossein Jalilian & Vicheth Sen (eds.) *Improving Health Sector Performance* (Singapore: ISEAS) pp.202-247

United Nations Development Programme (2011), "Statistical Annex", *Human Development Report, http://hdr.undp.org/en/media/HDR_2011_EN_Tables.pdf (*accessed 17 January 2012)

Viviretto, E. & P. White (eds.) (2010), "The Aid Debate, the Donors' Challenge in Cambodia's Healthcare System", Harris School of Public Policy Studies International Policy Practicum, University of Chicago

# ផ្នែកទី ៤
# យេនឌ័រ

# -៧-
# ការវិភាគយេនឌ័រក្នុងកំណែទម្រង់វិមជ្ឈការនៅកម្ពុជា

*ដោយលោក គឹម សេតារា និង សាស្ត្រាចារ្យ Joakim Ojendal*
*និងលោកស្រី ឈួន ណារ៉េត*[១]

ដំណើរការវិមជ្ឈការនៅប្រទេសកម្ពុជា មានកំណត់ក្នុងច្បាប់រដ្ឋបាល ច្បាប់គ្រប់គ្រងឃុំសង្កាត់ និងច្បាប់នៃការបោះឆ្នោតឃុំ/សង្កាត់ ដែលបានអនុម័តនៅឆ្នាំ២០០១។

បន្តពីកំណែទម្រង់ដំណាក់កាលទី១ ដែលមានការបោះឆ្នោតឃុំ/សង្កាត់ ចំនួនពីរដង រួចមកហើយនៅឆ្នាំ២០០២ និង២០០៧ និងការបង្កើតច្បាប់អង្គការ ក្នុងខែឧសភា ២០០៨ ប្រទេសកម្ពុជាបានចាប់ផ្តើមដំណើរការកំណែទម្រង់ដំណាក់កាលទី២ ដែលមានការបោះឆ្នោតដោយប្រយោលនៃក្រុមប្រឹក្សាខេត្ត/ក្រុង ស្រុក/ខ័ណ្ឌ កាលពីខែឧសភា ២០០៩។ គោលបំណងសំខាន់នៃកំណែទម្រង់នេះគឺ ការផ្ទេរអំណាចមុខងារ និងតួនាទី ពីថ្នាក់ជាតិទៅដល់ថ្នាក់ក្រោមជាតិ ដូចជា ពីថ្នាក់ខេត្តទៅស្រុក/ខ័ណ្ឌ ពីថ្នាក់ក្រសួងទៅមន្ទីរពាក់ព័ន្ធ។

## ១. គោលបំណង និងវិធីសាស្ត្រនៃការស្រាវជ្រាវ

ជាការពិតណាស់ អ្នកតំណាងជានារីដែលចូលរួមក្នុងវិស័យនយោបាយ បានកើនចំនួនឡើង ប៉ុន្តែនិន្នាការនេះគ្រាន់តែជាផ្នែកមួយនៃដំណោះស្រាយបញ្ហាប៉ុណ្ណោះ។ កន្លងមកមានគម្រោងមួយចំនួនដែលសិក្សាពី តំណាងនារីចូលរួមក្នុងវិស័យនយោបាយ ដោយបានផ្តល់ជាតួលេខមួយចំនួន។ ដើម្បីយល់រឹតតែច្បាស់ពីសមភាពក្នុងរចនាសម្ព័ន្ធនៃ អំណាចយេនឌ័រក្នុងបរិបទនៃកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ក្រុមការងារបានលើកយកគម្រោងទាំងនោះមកធ្វើវិភាគទៅលើការទទួលយកមតិយោបល់របស់តំណាងជានារី និងពិនិត្យមើលថា តើនារីបានយកឱកាសដែលខ្លួនឯងមានក្នុងឋានៈជាតំណាងនេះ ដើម្បីបំពេញតម្រូវការបែបណាខ្លះ។

មានសំណួរពីរដែលបានលើកឡើងក្នុងការសិក្សានេះ៖

១. តើការបញ្ជ្រាបយេនឌ័រ តាមរយៈភាពជាតំណាងផ្នែកនយោបាយរបស់នារីក្នុងក្រុមប្រឹក្សាឃុំ មានដំណើរការទៅមុខយ៉ាងដូចម្តេច? តើភាពជាតំណាងរបស់នារីបានល្អប្រសើរឡើងបែបណា និងមានន័យយ៉ាងដូចម្តេច?
២. តើនារីជាសមាជិកក្រុមប្រឹក្សាឃុំ អាចបញ្ចេញមតិយោបល់ រក្សាទស្សនៈនយោបាយរបស់ខ្លួន និងលើកឡើងពីតម្រូវការរបស់ស្ថាប័នខ្លួនបានយ៉ាងដូចម្តេច?

ជាវិធីសាស្ត្រសម្រាប់ប្រមូលទិន្នន័យ ក្រុមការងារបានប្រមូលឯកសារពាក់ព័ន្ធ ដែលរួមមានច្បាប់ ក៏ដូចជារបាយការណ៍សិក្សាផ្សេងៗកន្លងមក និងបានធ្វើសម្ភាសន៍ជាមួយមេឃុំជានារី និងសមាជិកក្រុមប្រឹក្សាជានារី និងបុរស។ ក្រុមការងារបានជ្រើសរើសឃុំចំនួនបួន ស្ថិតក្នុង បួនខេត្ត

---

១ លោក គឹម សេតារា ជាអ្នកស្រាវជ្រាវ និងលោកស្រី ឈួន ណារ៉េត ជាជំនួយការកម្មវិធី នៅវិទ្យាស្ថាន CDRI ហើយសាស្ត្រាចារ្យ Joakim Ojendal បម្រើការនៅសាកលវិទ្យាល័យ Goteborg ប្រទេសស៊ុយអែត។

គឺ បាត់ដំបង កំពង់ចាម ក្រចេះ និង តាកែវ។ ទោះយ៉ាងនេះក្តី លទ្ធផលរកឃើញមិនអាចតំណាងឲ្យបញ្ហាយេនឌ័រនៅទូទាំងប្រទេសកម្ពុជា ឬក៏នៅទូទាំង បួនខេត្តនោះបានទេ។

## ២. យេនឌ័រក្នុងបរិបទប្រទេសកម្ពុជា

តួនាទីនារីនៅក្នុងប្រទេសកម្ពុជា មានភាពស្មុគស្មាញពិបាកបរិយាយឲ្យច្បាស់ ដោយសារទំនៀមទម្លាប់ សង្គម និងបរិបទផ្សេងៗដែលប្រែប្រួលក្នុងរដ្ឋាភិបាល ( Kent & Chandler 2008 )។

ការសិក្សាដោយ Thon *et al* អំពីការគ្រប់គ្រងនៅថ្នាក់មូលដ្ឋាន បានបង្ហាញថា អ្នកដឹកនាំជានារីជួបប្រទះបញ្ហាប្រឈមដូចជា ប្រពៃណី ទំនៀមទម្លាប់ និងសម្ពាធពីគ្រួសារ ដែលធ្វើឲ្យពួកគាត់កើនការងារមួយជាពីរ។ ដោយសារពុំមានការគាំទ្រពីក្រុមគ្រួសារ អ្នកខ្លះត្រូវលែងលះគ្នា ព្រោះតែការចូលរួមក្នុងវិស័យនយោបាយនេះ។ បញ្ហាខាងលើ ធ្វើឲ្យនារីភាគច្រើនមិនសូវចាប់អារម្មណ៍នឹងវិស័យនយោបាយ ឬការងារដឹកនាំ។

ជារួម បញ្ហាយេនឌ័រ ជាលទ្ធផលនៃប្រព័ន្ធគ្រប់គ្រងដែលពាក់ព័ន្ធគ្នាចុះឡើង នៅក្នុងឯកសារច្បាប់ និងឯកសារផ្សេងៗដែលកំពុងអនុវត្តនៅក្នុងប្រទេស ក៏ដូចជាសាកលលោក។ ច្បាស់ហើយ តំណាងនារីតាមផ្នែកផ្សេងៗបានកើនឡើង តាមរយៈការបោះឆ្នោតដោយផ្ទាល់ និងដោយប្រយោលនៅឆ្នាំ១៩៩៣ ២០០២ និង ២០០៧។ ឯកសារស្រាវជ្រាវរបស់ Lilja 2010 បានបង្ហាញថា ភាគរយអ្នកចូលរួមជានារីក្នុងការងារថ្នាក់ខេត្ត ក្រុង និងក្រុមប្រឹក្សា គឺ ១០,១% ហើយសម្រាប់ថ្នាក់ស្រុក ខណ្ឌ គឺ ១២,៦%។ គួរកត់សម្គាល់ដែរថា តំណាងនារីនៅថ្នាក់ឃុំបានកើនឡើងពី ៨% ក្នុងឆ្នាំ២០០២ ដល់ ១៤.៦% ក្នុងឆ្នាំ២០០៧។

## ៣. ការយល់ឃើញជារួមរបស់មេឃុំ និងក្រុមប្រឹក្សា អំពីកំណែទម្រង់វិមជ្ឈការ និងយេនឌ័រ

តាំងពីមានការបោះឆ្នោតឃុំសង្កាត់លើកទី១ នៅឆ្នាំ២០០២ មក នារីមានឱកាសបានចូលរួមច្រើនជាងមុនក្នុងការងារភូមិ ឃុំ សង្កាត់ និងការងារសហគមន៍។ គាត់ក៏មានឱកាសផងដែរដើម្បីកសាងសមត្ថភាព ស្វែងយល់ពីសិទ្ធិសេរីភាព និងលើកជាសំណើនៅពេលមានតម្រូវការនៅក្នុងសហគមន៍។ កំណែទម្រង់នេះ បានជះឥទ្ធិពលជួយផ្លាស់ប្តូរទំនៀមទម្លាប់ចាស់មួយចំនួនរបស់នារីក្នុងការដឹកនាំនៅថ្នាក់មូលដ្ឋាន។ ជាក់ស្តែង សមាជិកជាបុរសជាច្រើនក្នុងក្រុមប្រឹក្សាផ្សេងៗនៅខេត្តក្រចេះ បានលើកថា ទំនៀមទម្លាប់លែងជាបញ្ហាចម្បងសម្រាប់នារីទៀតហើយ ដោយសារគាត់បានយល់ដឹងពីសិទ្ធិរបស់ខ្លួន ក្នុងការចូលរួមអភិវឌ្ឍសហគមន៍។ គាត់បានបញ្ជាក់ទៀតថា ដោយមានការគាំទ្រពីអង្គការ ស្ថាប័នពាក់ព័ន្ធ និងជាពិសេសការចូលរួមពីគណបក្សនយោបាយផ្សេងៗ នារីក៏មានទឹកចិត្តចូលរួមក្នុងការងារសង្គមច្រើនជាងមុនដែរ។

នារីដើរតួនាទីយ៉ាងសំខាន់ក្នុងការប្រមូលចំណូល និងមានការទទួលខុសត្រូវលើស្ថានភាពសេដ្ឋកិច្ចក្នុងគ្រួសារ និងការងារសង្គមតាមមុខតំណែងក្នុងក្រុមប្រឹក្សាឃុំ។

- ឥរិយាបទ និងការគិតគូររបស់បុរស និងនារីខ្លួនឯងផ្ទាល់ នៅក្នុងសហគមន៍បានផ្លាស់ប្តូរគួរឲ្យកត់សម្គាល់ ដោយសារមានការជឿជាក់ទៅលើនារីដែលជាថ្នាក់ដឹកនាំ។
- ទោះបីជាមតិជាច្រើនបានគាំទ្រ និងទទួលស្គាល់ការងាររបស់នារីនៅក្នុងសហគមន៍ក្តី ក៏នៅមានក្រុមប្រឹក្សាមួយចំនួន ដែលមិនសូវពេញចិត្តនឹងតួនាទីរបស់នារីក្នុងការដឹកនាំ ដោយគាត់យល់ឃើញថា នារីនៅមានចំណុចខ្វះខាត ដូចជា នៅពេលមានជម្លោះធំៗ

ខាងដីធ្លី បញ្ហាសន្តិសុខពេលយប់ ជាដើម គាត់នៅមិនទាន់មានទំនុកចិត្តទៅលើសេចក្តីសម្រេចរបស់នារីទេ។

- មេឃុំនារីមួយចំនួនក៏បានទទួលស្គាល់ដែរថា សន្តិសុខជាបញ្ហាមួយដែលគាត់មិនអាចធ្វើបានដូចបុរស គឺចុះទៅផ្ទាល់ប្រសិនបើមានហេតុការណ៍ពេលយប់កើតឡើង ប៉ុន្តែគាត់ក៏មានវិធីសាស្ត្រផ្សេងក្នុងការដោះស្រាយ ដោយធ្វើសហការជាមួយមន្ត្រីពាក់ព័ន្ធ។
- វត្តមានតំណាងនារីនៅក្នុងវិស័យនយោបាយតាមតំបន់មូលដ្ឋាន គឺអាស្រ័យទៅលើគណបក្សនយោបាយនីមួយៗ ពីព្រោះប្រព័ន្ធបោះឆ្នោតនៅប្រទេសកម្ពុជា ជាប្រព័ន្ធបោះឆ្នោតសមាមាត្រ។ ដូច្នេះ លុះត្រាតែគណបក្សនយោបាយបានដាក់ឈ្មោះបេក្ខនារីក្នុងបញ្ជីឈ្មោះបោះឆ្នោត ទើបពួកគាត់មានឱកាសចូលរួមក្នុងការងារឃុំសង្កាត់។

## ៤. ការពិភាក្សា និងសេចក្តីសន្និដ្ឋាន

ការចូលរួមរបស់នារីក្នុងការងារនយោបាយបានកើនឡើង ឆ្លងតាមការវិវត្តសំខាន់ៗដូចតទៅ៖

**កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ៖** កំណែទម្រង់នេះ បើកឱកាសជាច្រើនឲ្យនារីបានចូលរួមក្នុងការងារនៅថ្នាក់មូលដ្ឋាន និងបានស្វែងយល់ពីបញ្ហាយេនឌ័រ តាមរយៈការផ្តល់លទ្ធភាព និងវេទិកាដល់នារី ដើម្បីចូលរួមនៅក្នុងការងារនយោបាយ ឬយ៉ាងហោចណាស់ក្នុងការងារគ្រប់គ្រងថវិកា។

**ការបញ្ចេញយោបល់ជាទូទៅ៖** ការយល់ដឹងពីបញ្ហាយេនឌ័រ និងការទទួលស្គាល់ថ្នាក់ដឹកនាំជានារី បានកើនឡើងគួរឲ្យកត់សម្គាល់ ក្រោយពេលបានចាប់ផ្តើមអនុវត្តកំណែទម្រង់វិមជ្ឈការនៅឆ្នាំ២០០២។ មានកត្តា បួនសំខាន់ៗ ដែលនាំឲ្យមានការរីកចម្រើនក្នុងបញ្ហាយេនឌ័រ៖ ១) មានការគាំទ្រពីស្ថាប័នរដ្ឋ ២) មានការបណ្តុះបណ្តាល និងការជួយឧបត្ថម្ភពីអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល ៣) កំណើនសេដ្ឋកិច្ច និងការផ្លាស់ប្តូរក្នុងសង្គម និង ៤) ការផ្លាស់ប្តូរក្នុងការបញ្ចេញយោបល់ជាទូទៅ ដែលជាឥទ្ធិពលនៃប្រព័ន្ធផ្សព្វផ្សាយ។

**គោលនយោបាយ៖** ថ្មីៗនេះ មានការដាក់បញ្ចូលបញ្ហាយេនឌ័រទៅក្នុងគោលនយោបាយរបស់រដ្ឋាភិបាលនៅគ្រប់លំដាប់ថ្នាក់ និងផ្នែកផ្សេងៗ។

អ្នកផ្តល់ព័ត៌មានភាគច្រើនបានលើកថា ប្រសិនបើមិនមានកំណែទម្រង់វិមជ្ឈការនៅថ្នាក់ឃុំសង្កាត់ និងការគាំទ្រពីគោលនយោបាយពាក់ព័ន្ធផ្សេងៗទេ នារីពិតជាលំបាកនឹងបានចូលរួមក្នុងការងារនយោបាយ។

**បទដ្ឋានសង្គម៖** មានការរីកចម្រើនឡើង ប្រសិនបើប្រៀបធៀបទៅនឹងកាលពី ១០ឆ្នាំមុន។ អ្នកផ្តល់ព័ត៌មានជាបុរសជាច្រើននាក់បានទទួលស្គាល់ថា ឥឡូវនេះ នារីពូកែខាងគ្រប់គ្រងការងារនៅក្នុងសហគមន៍។ ពួកគាត់យល់ឃើញថា រឿងនេះមកពីនារីមានការអត់ធ្មត់ ដូច្នេះងាយស្រួលធ្វើការជាមួយក្មេងៗ សង្គម និងធ្វើការងារយុត្តិធម៌នៅក្នុងសង្គម។ ទោះបីនារីមានចំណុចវិជ្ជមានជាច្រើនដូចបានលើកឡើងខាងលើក្តី ក៏នៅតែមានគំនាបការងារមួយចំនួនចំពោះពួកគាត់ផងដែរ ដូចជា ការងារសន្តិសុខក្នុងសហគមន៍ជាដើម ដែលភាគច្រើនទាក់ទងនឹងទំនៀមទម្លាប់។

លទ្ធផលអង្កេត និងការស្រាវជ្រាវ បានបង្ហាញថា ឆន្ទៈនយោបាយក្នុងការសម្រេចចិត្តរបស់គណបក្ស មានចំណែកយ៉ាងធំ និងជះឥទ្ធិពលយ៉ាងខ្លាំងក្នុងគោលនយោបាយយេនឌ័រ។ ដូច្នេះ ដើម្បីស្វែងយល់ឲ្យកាន់តែច្បាស់ពីបញ្ហាចោទ និងដំណោះស្រាយ ដើម្បីបង្កើនការចូលរួមរបស់នារីក្នុងការងារនយោបាយ ត្រូវមានការសិក្សាបន្តផ្តោតលើការវិភាគរចនាសម្ព័ន្ធអំណាចយេនឌ័រនៅក្នុងគណបក្សនយោបាយ។

## គន្ថនិទ្ទេស


Ahikire, Josephine (2007), *Localised or Localising Democracy: Gender and the Politics of Decentralisation in Contemporary Uganda* (Kampala: Fountain Publishers)

Beall, Jo (2005), *Decentralizing Government and Centralizing Gender in Southern Africa: Lessons from the South African Experience.* (Geneva: United Nations Research Institute for Social Development)

Blunt, Peter & Mark Turner (2005), "Decentralisation, Democracy and Development in a Post-Conflict Society: Commune Councils in Cambodia", *Public Administration and Development*, Vol. 25 (1), pp. 75-87

Campbell, Harry F. (2003), "Are Culturally Diverse Countries More Fiscally Decentralized?" in Harry Bloch (ed.), *Growth and Development in the Global Economy* (Cheltenham,UK: Edward Elgar Publishing) pp. 203-223

Chandler, David P. (2000), *Voices from S-21: Terror and History in Pol Pot's Secret Prison* (Chiang Mai: Silkworm)

Committee for Free and Fair Elections in Cambodia (COMFREL) (2007), Final Assessment and Report on 2007 Commune Council Elections" (Phnom Penh: COMFREL)

Crook, Richard & James Manor (1998), *Democracy and Decentralization in South Asia and West Africa: Participation, Accountability, and Performance* (Cambridge, UK: Cambridge University Press).

Derks, Annuska (2008), *Khmer Women on the Move: Exploring Work and Life in Urban Cambodia* (Honolulu: Hawaii University Press)

Diamond, Larry (2000) "Is Pakistan the (Reverse) Wave of the Future?" *Journal of Democracy*, July, 11, pp. 91-106

Ebihara, May (1968), *Svay, a Khmer Village in Cambodia*, PhD dissertation, Department of Anthropology, Columbia University, NY

Frieson, Kate (2001), *In the Shadows: Women, Power and Politics in Cambodia* (Victoria BC, Canada: Centre for Asia Pacific Initiatives)

Gottesman, Evan (2003), *Cambodia after the Khmer Rouge: Inside the Politics of Nation Building* (New Haven: Yale University Press)

Grindle, Merilee S. (2009), *Going Local: Decentralization, Democratization, and the Promise of Good Governance* (Princeton, NJ: Princeton University Press)

Hughes, Caroline, K. Sedara & J. Öjendal (2006), "Introduction: Tradition vs. Progress? Rethinking Culture and Power in the Context of Internationally Sponsored Reform", Symposium on "Cambodia: Reassessing Political Culture in Times of Political Change" *Journal of South East Asian Studies,* 36 (2), pp. 415-420

Hughes, Caroline & Joakim (2006), "Cambodia: Reassessing Political Culture in Times of Political Change", *Journal of South East Asian Studies,* 36 (2), pp. 415-420

Hughes, Caroline & Un Kheang (2007), "Cambodia Governance Analysis" (Phnom Penh: DFiD)

International Union of Local Authorities (IULA) (1998), Report of the Worldwide Association of Local Governments meeting, Zimbabwe, November 1998

http://www.cityshelter.org/13_mobil/18tend.htm (accessed November 2011)

Iwanaga, Kazuki (2008), *Women's Political Participation and Representation in Asia* (Copenhagen: NIAS Press)

Kayumba, Christopher (2010), *Threatening and Appropriate Bodies in Nation-building: Paths to World's First Female Parliamentary Majority in Post-Genocide Rwanda,* PhD thesis, Peace and Development Research, School of Global Studies, University of Gothenburg, Sweden

Kent, Alexandra & David Chandler (2008), *People of Virtue: Reconfiguring Religion, Power and Moral Order in Cambodia Today* (Copenhagen: NIAS Press)

Kim Sedara (2011), "Reciprocity: Informal Patterns of Social Interactions in a Cambodian Village", in John Marston (ed.) *Anthropology and Community in Cambodia: Reflections on the Work of May Ebihara* (Melbourne: Monash University Press)

Kim Sedara & Jaokim Öjendal (2009), "Decentralization as a Strategy for State Reconstruction in Cambodia", in Joakim Öjendal & Mona Lilja (eds.) *Beyond Democracy in Cambodia: Political Reconstruction in a Post-Conflict Society* (Denmark: NIAS Press)

Kim Sedara (2012), *Democracy in Action: Decentralisation in Post-Conflict Cambodia*, PhD dissertation, School of Global Studies Department of Peace and Development Research, Göteborg University, Sweden

Ledgerwood, Judy & John Vijghen (2002), "Decision Making in Rural Khmer Villages", in Judy Lederwood (ed.), *Cambodia Emerges from the Past: Eight Essays* (Dekalb Illinois: Northern Illinois University)

Ledgerwood, Judy (1990), *Changing Khmer Conceptions of Gender: Women, Stories and the Moral Order,* PhD dissertation, Anthropology Department, Cornell University

Ledgerwood, Judy (1992), "Analysis of the Situation of Women in Cambodia" (Phnom Penh: Cambodia)

Lilja, Mona (2006) "Performances of Resistance: Women's Struggle for Political Power in Cambodia", *The New Voices, New Perspective Series* (Santo Domingo: United Nations)

Lilja, Mona (2008) "Globalization, Women's Political Participation and the Politics of Legitimacy and Reconstruction in Cambodia", in Mona Lilja &Joakim Öjendal (eds.), *Imaging Political Legitimacy in Cambodia: Reconstruction in a Post-conflict Society* (Copenhagen: NIAS Press)

Lilja, Mona (2009), "Gendering Legitimacy through the Reproduction of Violent Discourses in Cambodia", in Joakim Öjendal & Mona Lilja (eds.) *"Beyond Democracy in Cambodia"*: P*olitical Reconstruction in a Post-conflict Society* (Copenhagen: NIAS Press)

Lilja, Mona (2010), *Resistance: Strengthening Power, Resisting Power Women Politicians in Cambodia Negotiating Power* (Copenhagen: NIAS Press)

Litvack, Jennie, Ahmad Junaid & Richard Bird (1998), "Rethinking Decentralization in Developing Countries", *Sector Studies Series* (Washington, DC: World Bank)

Luco, Fabienne (2002), "Management of Local Conflicts in Cambodia: Anthropological Approaches to Traditional and New Practices" (Phnom Penh: UNESCO)

Mabbett, Ian & David Chandler (1995), *The Khmers* (Oxford, UK; Cambridge MA: Blackwell)

Manor, James (1999), *The Political Economy of Democratic Decentralization* (Washington, DC: World Bank)

Manor, James (2008), "Supporting Cambodia's Decentralisation and Deconcentration Reforms: Issues and Options for Development Partners", study commissioned by Sida as input to the EU division of labour process for D&D reform in Cambodia

Manor, James (2011), *Perspectives on Decentralization,* Working Paper No 3, Swedish International Centre for Local Democracy (Visby, Sweden: ICLD)

Marston, John (1997), *Cambodia 1991-94: Hierarchy, Neutrality and Etiquettes of Discourse*, Doctoral Dissertation, University of Washington

Ministry of Interior (May 2008), "Organic Law on Administrative Management of the Capital, Provinces, Municipalities, Districts and Khans" (Phnom Penh: Ministry of Interior)

Ministry of Women's Affairs (2008), "A Fair Share for Women: Cambodia Gender Assessment and Policy Brief" (Phnom Penh: Ministry of Women's Affairs)

National Institute of Statistics (NIS) (2008), *Statistical Yearbook of Cambodia* (Phnom Penh: NIS)

Öjendal, Joakim (2002), "Understanding Decentralisation in Cambodia: A Research Proposal on the Processes of Devolution and Deconcentration in Cambodia" (Phnom Penh: CDRI)

Öjendal, Joakim & Kim Sedara (2006), "*'Korob Kaud, Klach':* In Search of Agency in Rural Cambodia", *Journal of Southeast Asian Studies,* Vol. 37 (3), pp. 507-526

Öjendal, Joakim & Kim Sedara (2011), *Real Democratization in Cambodia? An Empirical Review of the Potential of a Decentralisation Reform,* Working Paper No. 98 (Visby, Sweden: ICLD)

Öjendal, Joakim & Mona Lilja (eds.) (2009), *Beyond Democracy in Cambodia: Political Reconstruction in a Post-conflict Society* (Copenhagen: NIAS Press)

Ovesen, Jan, Ing-Britt Trankell & Joakim Öjendal (1996), *When Every Household is an Island* (Stockholm: SIDA; Uppsala: Research Reports in Cultural Anthropology, Uppsala University)

Pak, Kimchoeun & David Craig (2008), *Accountability and Public Expenditure Management in Decentralised Cambodia,* Working Paper No. 38 (Phnom Penh: CDRI)

Pak Kimchoeun, Horng Vuthy, Eng Netra, Ann Sovatha, Kim Sedara, Jenny Knowles & David Craig (2007), *Accountability and Neo-patrimonialism in Cambodia: A Critical Literature Review,* Working Paper No. 34 (Phnom Penh: CDRI)

Roberts, David (2006), "The Superficiality of State Building in Cambodia: Patronage and Clientelism as Enduring Forms of Politics", draft for Research Partnership on Post-war State-building, htt://state.building.org (accessed November 2011)

Rondinelli, D., J. Nellis &G. Cheema (1983), *Decentralization in Developing Countries: A Review of Recent Experience,* World Bank Staff Working Papers No. 581(Washington, DC: World Bank)

Royal Government of Cambodia (2001), *The Law on the Administration and Management of Commune/Sangkat* (Phnom Penh: RGC)

Royal Government of Cambodia (2005), Strategic Framework for Decentralisation and Deconcentration Reform (Phnom Penh: Cambodia)

Royal Government of Cambodia (2010), Rectangular Strategy and National Programme for Sub-National Democratic Development 2010-19 (Phnom Penh: RGC)

Rydström, Helle (2010), *Gendered Inequalities in Asia: Configuring, Contesting and Recognizing Women and Men* (Copenhagen: NIAS Press)

Sen, Krishna & Maila Stivens (1998), *Gender and Power in Affluent Asia* (London: Routledge)

Sylvester, Christine (1994), *Feminist Theory and International Relations in Postmodern Era* (New York: Cambridge University Press)

Thion, Serge (1993), *Watching Cambodia: Ten Paths to Enter the Cambodian Tangle* (Bangkok; Chennai: White Lotus)

Thon Vimealea, Ou Sivhuoch, Eng Netra & Ly Tem (2009), *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces*, Working Paper No. 42 (Phnom Penh: CDRI).

Treisman, Daniel (2006), "Fiscal Decentralization, Governance, and Economic Performance: A Reconsideration," *Economics and Politics*, 18 (2), pp. 219-235

UNDP (2000), *Women's Political Participation and Good Governance* (Phnom Penh: UNDP)

World Bank (2001a), "Engendering Development: Through Gender Equality in Rights, Resources and Voice", World Bank Policy Research Report (Oxford: Oxford University Press)

World Bank, United Cities & Local Governments (2008), *Decentralization and Local Democracy in the World: First Global Report 2008* (Barcelona: United Cities and Local Governments)

# -៨-
# យេនឌ័រក្នុងការបន្សាំនឹងបម្រែបម្រួលអាកាសធាតុៈ ករណីសិក្សាតាមដងទន្លេមេគង្គ និងក្នុងអាងទន្លេសាប

*ដោយលោក កុយ រ៉ា និងលោក អែម ស្ងៅនី[១]*

## ១. សេចក្តីផ្តើម

មានការទស្សន៍ទាយថា បម្រែបម្រួលអាកាសធាតុនឹងធ្វើឲ្យទិន្នផលដំណាំនិងផលិតកម្មស្បៀងធ្លាក់ចុះនៅតាមតំបន់មួយចំនួនក្នុងពិភពលោក។ ការគំរាមកំហែងនៃបម្រែបម្រួលអាកាសធាតុចំពោះសង្គមមនុស្ស និងប្រព័ន្ធអេកូឡូស៊ី ជាបញ្ហាមានអាទិភាពខ្ពស់បំផុត ចាប់តាំងពីមានការចេញផ្សាយរបាយការណ៍វាយតម្លៃលើកទី៤ លើបម្រែបម្រួលអាកាសធាតុ ដោយក្រុមអន្តររដ្ឋាភិបាល នៅឆ្នាំ២០០៧ មក (FAO 2009)។ ការវាយតម្លៃនេះកំណត់ថា បម្រែបម្រួលអាកាសធាតុ ជាការប្រែប្រួលបរិយាកាសពីមួយឆ្នាំទៅមួយឆ្នាំ ទោះជាដោយសារការប្រែប្រួលធម្មជាតិ ឬដោយសារសកម្មភាពមនុស្សក្តី (IPCC 2007)។ អ្នកនិពន្ធ CARE (2009) បានបែងចែកផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុទៅជាភាពមហន្តរាយ ឬ ភាពពុំរ៉ៃ ដោយភាពមហន្តរាយសំដៅដល់ ឥទ្ធិពលនៃគ្រោះធម្មជាតិឬស្ថានភាពធាតុអាកាសអាក្រក់ខ្លាំង ដូចជា ព្យុះកំបុតត្បូង ព្យុះព្រិល គ្រោះរាំងស្ងួត និងគ្រោះទឹកជំនន់ ។ល។ ហើយភាពពុំរ៉ៃសំដៅដល់ស្ថានភាពថ្មីៗ ដូចជា កំណើនសីតុណ្ហភាពខ្ពស់ជាងមុន កំណើនកម្រិតកម្ពស់ទឹកសមុទ្រ ការជ្រាបចូលទឹកប្រៃ ស្រទាប់ទឹកក្នុងដីស្រកទាបជាងមុន បម្រែបម្រួលរបបទឹកភ្លៀង និងរដូវមិនទៀងទាត់។

កម្ពុជា ស្ថិតក្នុងចំណោមបណ្តាប្រទេសនៅតំបន់អាស៊ីបូព៌ាដែលងាយរងការប៉ះពាល់ដោយគ្រោះធម្មជាតិជាងគេ ជាពិសេស គ្រោះទឹកជំនន់ និងការរាំងស្ងួត ជារៀងរាល់ឆ្នាំ (Nguyen 2007)។ បញ្ហានេះ បណ្តាលមកពីប្រជាជនភាគច្រើនពឹងផ្អែកខ្លាំងលើធនធានធម្មជាតិ ដូចជា ព្រៃឈើ ផលនេសាទ ទឹក និងធនធានទ្រព្យរួមផ្សេងទៀត ក៏ដូចជាដំណាំ (ជាពិសេស ស្រូវ) និង សត្វចិញ្ចឹម សម្រាប់ជីវភាពរស់នៅរបស់ខ្លួន។ ការប្រែប្រួលអាកាសធាតុបច្ចុប្បន្ន ជាបញ្ហាប្រឈមធ្ងន់ធ្ងរ ចំពោះជីវភាពនៅជនបទ។ នារីតែងរងផលប៉ះពាល់ធ្ងន់ធ្ងរជាង និងខុសគ្នាពីបុរស ដោយការប្រែប្រួលអាកាសធាតុ និងគ្រោះធម្មជាតិ ដូចជា ទឹកជំនន់ គ្រោះរាំងស្ងួត ព្យុះកំបុតត្បូង និង ព្យុះភ្លៀង (UNDP 2009a)។

កម្ពុជា បានជឿនលឿនទៅមុខមួយចំនួន ក្នុងការបញ្ជ្រាបគោលការណ៍យេនឌ័រទៅក្នុងគោលនយោបាយ និងកម្មវិធីនានារបស់ខ្លួន ហើយសម្រេចបាននូវសមភាពខាងយេនឌ័រ[២]។

---

១ លោក កុយ រ៉ា និងលោក អែម ស្ងៅនី ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។

២ យេនឌ័រ សំដៅលើភាពខុសគ្នាក្នុងឱកាស និងតួនាទីបង្កើតឡើងដោយសង្គម ដោយសារតែបុគ្គលនោះជាបុរស ឬជានារី ព្រមទាំងអន្តរកម្ម និងទំនាក់ទំនងខាងសង្គម រវាងបុរស និងនារី។ យេនឌ័រកំណត់ពីអ្វីដែលគេរំពឹងទទួលបានពី បុរស ឬ នារី ដោយសារមានការអនុញ្ញាត ឬការឲ្យតម្លៃ នៅក្នុងបរិបទជាក់លាក់ណាមួយ (UNDP 2009b)។

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវក្របខ័ណ្ឌច្បាប់ និងគោលនយោបាយជាច្រើន ដើម្បីលើកកម្ពស់ឋានៈនិងតួនាទីរបស់នារី ទាំងក្នុងវិស័យសាធារណៈ និងឯកជន ព្រមទាំងធានាឲ្យនារីមានសិទ្ធិទទួលបានអត្ថប្រយោជន៍ផ្សេងៗ (Wong 2011)។ ការសិក្សានេះ មានគោលបំណង៖ ១) ស្វែងយល់ពី ទស្សនៈរបស់ប្រជាជនមូលដ្ឋានអំពី បម្រែបម្រួលអាកាសធាតុនិងផលប៉ះពាល់របស់វា និង យុទ្ធសាស្ត្រទប់ទល់របស់គ្រួសារដែលមាននារីជាមេគ្រួសារ និងគ្រួសារដែលមានបុរសជាមេគ្រួសារ និង ២) បង្កើនចំណេះដឹងពីយុទ្ធសាស្ត្របន្សាំនឹងបម្រែបម្រួលអាកាសធាតុរបស់គ្រួសារទាំងពីរប្រភេទខាងលើ ដែលរស់នៅតាមដងទន្លេមេគង្គនិងក្នុងអាងទន្លេសាប។

## ២. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះ ធ្វើឡើងក្នុង ៣៨ភូមិ ដែលជ្រើសរើសក្នុងចំណោមភូមិនានាស្ថិតក្នុងចម្ងាយមិនលើសពី ១៥គ.ម ពីច្រាំងតាមដងទន្លេមេគង្គ ដងទន្លេសាប និងនៅជុំវិញបឹងទន្លេសាប ក្នុងខេត្ត កំពង់ចាម ក្រចេះ កំពង់ធំ សៀមរាប បាត់ដំបង ពោធិ៍សាត់ កំពង់ឆ្នាំង កណ្ដាល តាកែវ ព្រៃវែង និងកំពត (រូបភាព ១)។ ភូមិទាំងនេះ បានជ្រើសរើសឡើង ដោយផ្អែកតាមចំនួនប្រជាជនពោលគឺ ភូមិមានដង់ស៊ីតេប្រជាជនខ្ពស់ ទំនងត្រូវបានជ្រើសរើស។ គួរកត់សម្គាល់ថា ភូមិនៅក្នុងទីប្រជុំជន មិនបានស្រង់មកសម្រាប់ធ្វើការជ្រើសរើសនោះទេ។

ការសិក្សានេះ បានជ្រើសរើសត្រឹមតែ ២០គ្រួសារ ចេញពីភូមិសិក្សានីមួយៗប៉ុណ្ណោះសម្រាប់ធ្វើសម្ភាសន៍។ ក្រុមស្រាវជ្រាវបានសុំបញ្ជីឈ្មោះគ្រួសារ ពីមេភូមិ ដើម្បីធ្វើការជ្រើសរើសគ្រួសារសំណាកក្នុងភូមិនីមួយៗ។ ក្នុងករណីខ្លះ បញ្ជីឈ្មោះគ្រួសារ មិនអាចរកបានទេក្នុងពេលអង្កេត ព្រោះអ្នកកាន់បញ្ជីមិននៅ។ ក្នុងករណីនេះ អ្នកសម្ភាសន៍ បានព្យាយាមបង្កើតបញ្ជីគ្រួសារក្នុងភូមិដោយខ្លួនឯង តាមការចុះសាកសួរផ្ទាល់ពីផ្ទះមួយទៅផ្ទះមួយ។

ក្រោយទទួលបានបញ្ជីឈ្មោះគ្រួសារ ក្រុមអង្កេតបានកំណត់ចំនួនគំលាតសម្រាប់ការជ្រើសរើសគ្រួសារក្នុងបញ្ជី ដោយយកចំនួនគ្រួសារសរុបចែកនឹង២០។ ក្នុងភូមិនីមួយៗ ការជ្រើសរើសគ្រួសារទី១ បានធ្វើឡើងដោយចៃដន្យ ហើយគ្រួសារ១៩ ផ្សេងទៀត ត្រូវជ្រើសរើសដោយរាប់តាមចំនួនគំលាតខាងលើ គឺ រាប់ចេញពីគ្រួសារទី១ដែលជ្រើសយក និងបន្តបន្ទាប់ទៀត។ នៅពេលគ្រួសារជ្រើសរើសណាមួយមិនអាចជួបធ្វើសម្ភាសន៍បាន គ្រួសារមានរាយឈ្មោះជាបន្ទាប់នៅក្នុងបញ្ជី ត្រូវបានជ្រើសរើសមកជំនួស។

រូបភាព ១៖ ផែនទីភូមិអង្កេតនានា




## ៣. លទ្ធផលស្រាវជ្រាវ

### *៣.១. បម្រែបម្រួលអាកាសធាតុ*

*៣.១.១. គ្រោះទឹកជំនន់ និង គ្រោះរាំងស្ងួត*

គ្រោះទឹកជំនន់និងគ្រោះរាំងស្ងួតដែលគេកំណត់ថាជាលទ្ធផលនៃបម្រែបម្រួលអាកាសធាតុ បានបង្កហានិភ័យខ្ពស់ចំពោះប្រទេសកសិកម្ម ជាពិសេសប្រទេសកំពុងអភិវឌ្ឍ។ កម្ពុជាជាប្រទេសកសិកម្មមួយ មានប្រជាជនជាង ៨០% ពឹងផ្អែកលើការដាំដុះ និងសកម្មភាពកសិកម្មផ្សេងទៀត ដែលបានទទួលរងការខូចខាតដោយគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត។

លទ្ធផលអង្កេតពីទស្សនៈរបស់កសិករ ចំពោះគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត បានបង្ហាញថា ពួកគាត់បានជួបនឹងគ្រោះរាំងស្ងួត ច្រើនជាងគ្រោះទឹកជំនន់ ក្នុងអំឡុងពេលប្រាំឆ្នាំចុងក្រោយនេះ ដូចមានបង្ហាញក្នុងរូបភាព ២។ ស្ថានភាពមានគ្រោះរាំងស្ងួតញឹកញាប់នេះ មានលក្ខណៈមិនល្អទេសម្រាប់ការធ្វើកសិកម្ម។

រូបភាព ២៖ ការយល់ឃើញពីការខូចខាតបង្កដោយគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ក្នុងរយៈពេល ៥ឆ្នាំមុន ធៀបនឹងរយៈពេល ១០-១៥ឆ្នាំមុន




| | ដូចគ្នា | រង្វើលជាងមុន | ញឹកញាប់ជាងមុន | មិនដឹង |
|---|---|---|---|---|
| ■ ទឹកជំនន់ | 118 | 397 | 125 | 40 |
| ■ គ្រោះរាំងស្ងួត | 99 | 141 | 418 | 22 |

គ្រួសារជាច្រើន បានរងឥទ្ធិពលពីគ្រោះរាំងស្ងួត ច្រើនជាងគ្រោះទឹកជំនន់៖ ២៣០ គ្រួសារ (៣៤%) បានបាត់បង់ទ្រព្យសម្បត្តិដោយសារគ្រោះរាំងស្ងួត ធៀបនឹង ៨៤ គ្រួសារ (១២%) ដែលបានបាត់បង់ទ្រព្យសម្បត្តិដោយសារគ្រោះទឹកជំនន់ (តារាង ១)។ តារាង ១ សង្ខេបពីការបាត់បង់ទ្រព្យសម្បត្តិរបស់គ្រួសារអង្កេត បង្កដោយគ្រោះទឹកជំនន់និងគ្រោះរាំងស្ងួត ក្នុងភូមិសិក្សា ហើយបង្ហាញថា គ្រួសារសំណាកងាយរងឥទ្ធិពលពីគ្រោះរាំងស្ងួត ជាងគ្រោះទឹកជំនន់ ពីព្រោះ គោនិងក្របីដែលជាកម្លាំងចម្បងក្នុងផលិតកម្មកសិកម្ម តែងតែស្លាប់ក្នុងអំឡុងពេលរាំងស្ងួត។ សត្វអូសទាញ ជាទ្រព្យដ៏មានតម្លៃសម្រាប់បង្កបង្កើនផល ហើយគេត្រូវចំណាយដើមទុនច្រើនណាស់ បើសិនត្រូវរកអ្វីមកប្រើជំនួសកម្លាំងពួកវា។ ផ្អែកតាមបទពិសោធន៍របស់គ្រួសារសំណាក តម្លៃជាមធ្យមនៃការបាត់បង់ក្របីដោយសារគ្រោះរាំងស្ងួត គឺ ៥០០.០០០រៀល និង សម្រាប់គោ គឺ ១៨.៦៩៥រៀល។ ជាមធ្យម ការខាតបង់សរុបបង្កឡើងដោយទឹកជំនន់ គឺ ៥៨.២១៤រៀល រីឯការខាតបង់បង្កដោយគ្រោះរាំងស្ងួត គឺ ២៤៦.៤៧៦រៀល។ លទ្ធផលនេះ បង្ហាញថា ប្រជាជនមូលដ្ឋានងាយទ្រាំទ្រនឹងគ្រោះទឹកជំនន់ជាងគ្រោះរាំងស្ងួត។ ទោះយ៉ាងនេះក្តី គ្រោះរាំងស្ងួតនិងគ្រោះទឹកជំនន់យូរខែយូរថ្ងៃ ធ្វើឲ្យប្រជាជនកាន់តែងាយធ្លាក់ចូលក្នុងស្ថានភាពលំបាក។ ដូច្នេះ ការរៀបចំវិធានការសម្របខ្លួនមានសារៈសំខាន់ខ្លាំងណាស់ ដើម្បីជួយពង្រឹងភាពធន់ទ្រាំរបស់សហគមន៍ ទប់ទល់នឹងគ្រោះធម្មជាតិ និងហានិភ័យបង្កភាពងាយរងគ្រោះផ្សេងៗ។

តារាង ១៖ ការខាតបង់ទ្រព្យសម្បត្តិបង្កដោយគ្រោះទឹកជំនន់ និងការរាំងស្ងួត ក្នុងរយៈពេល ៥ឆ្នាំកន្លងទៅ ធៀបនឹងកាលពី ១០-១៥ឆ្នាំមុន

| | អតិបរមា | មធ្យម | គំលាតស្តង់ដារ |
|---|---|---|---|
| ការខាតបង់ដោយសារទឹកជំនន់ (៨៤គ្រួសារ ១២% នៃសំណាក) | | | |
| ដីស្រែ (ហិកតា) | 70 | 3.28 | 10.57 |
| ភាគរយនៃផ្ទៃដីសរុប | 100 | 49.27 | 32.59 |
| ភាគរយនៃផលិតកម្មធម្មតា | 100 | 48.45 | 31.05 |
| ចំនួនថ្ងៃធ្វើការ | 90 | 4.95 | 13.38 |
| ជីវិតមនុស្ស | - | - | - |
| កង្វះលទ្ធភាពទទួលបានទឹកស្អាត (ថ្ងៃ) | 60 | 2.80 | 10.13 |
| កង្វះខាតអនាម័យ (ថ្ងៃ) | 60 | 4.26 | 10.88 |
| ការរងរបួស | - | - | - |
| ការខាតបង់សរុបលើទ្រព្យខាងក្រោម (រៀល) | 1,280,000 | 58,214 | 176,745 |
| - គោ (រៀល) | - | - | - |
| - ក្របី (រៀល) | - | - | - |
| - ជ្រូកនិងពពែ (រៀល) | 1,000,000 | 13,690 | 110,134 |
| - មាន់និងទា (រៀល) | 500,000 | 31,310 | 99,792 |
| - ទ្រព្យផ្សេងៗ (រៀល) | 500,000 | 13,214 | 63,000 |
| ការខាតបង់ដោយសារគ្រោះរាំងស្ងួត (២៣០គ្រួសារ ៣៤% នៃសំណាក) | | | |
| ការខាតបង់សរុបលើទ្រព្យខាងក្រោម (រៀល) | 16,300,000 | 246,479 | 809,274 |
| - គោ (រៀល) | 3,500,000 | 18,695 | 236,510 |
| - ក្របី (រៀល) | 4,000,000 | 50,000 | 351,757 |
| - ជ្រូកនិងពពែ (រៀល) | 2,000,000 | 29,173 | 184,335 |
| - មាន់និងទា (រៀល) | 800,000 | 63,478 | 128,162 |
| - ទ្រព្យផ្សេងៗ (រៀល) | 6,000,000 | 85,133 | 457,740 |

លទ្ធផលស្រាវជ្រាវកម្រិតគ្រួសារនេះ បង្ហាញថា ទឹកជំនន់ ហាក់បង្កផលប៉ះពាល់លើជីវភាពរស់នៅតាមទីជនបទ តិចជាងគ្រោះរាំងស្ងួត។ ការប្រៀបធៀបពីទំហំនៃការបំផ្លិចបំផ្លាញដោយទឹកជំនន់ និងគ្រោះរាំងស្ងួត នៅកម្រិតខេត្ត និងកម្រិតជាតិ អាចផ្តល់លទ្ធផលគួរឲ្យចាប់អារម្មណ៍ ព្រោះទឹកជំនន់មិនត្រឹមតែបំផ្លាញទ្រព្យសម្បត្តិរបស់គ្រួសារនៅមូលដ្ឋានប៉ុណ្ណោះទេ វាថែមទាំងបានបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរបស់សហគមន៍ទាំងមូលទៀតផង។

តារាង ២៖ ការបាត់បង់ទ្រព្យសម្បត្តិក្នុងគ្រួសារបង្កដោយគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត

| យេនឌ័រ | | ការខាតបង់បង្កដោយគ្រោះទឹកជំនន់ | | | | ការខាតបង់បង្កដោយគ្រោះរាំងស្ងួត | | | |
|---|---|---|---|---|---|---|---|---|---|
| | | ផលិតកម្មស្រូវ (%) | គោ(រៀល) | ក្របី (រៀល) | បសុបក្សី (រៀល) | ផលិតកម្មស្រូវ (%) | គោ(រៀល) | ក្របី (រៀល) | បសុបក្សី (រៀល) |
| បុរស | មធ្យម | 54.86 | 0.00 | 0.00 | 37,500.00 | 34.97 | 22,513.09 | 49,738.22 | 59,183.25 |
| | ចំនួនគ្រួសារ | 64 | 64 | 64 | 64 | 191 | 191 | 191 | 191 |
| | គំលាតស្តង់ដា | 28.32 | 0.00 | 0.00 | 112,687.23 | 26.32 | 259,485.26 | 372,456.19 | 117,535.41 |
| នារី | មធ្យម | 39.73 | 0.00 | 0.00 | 11,500.00 | 23.81 | 0.00 | 39,215.69 | 64,627.45 |
| | ចំនួនគ្រួសារ | 20 | 20 | 20 | 20 | 51 | 51 | 51 | 51 |
| | គំលាតស្តង់ដា | 34.27 | 0.00 | 0.00 | 29,249.38 | 22.16 | 0.00 | 200,078.42 | 153,716.88 |
| សរុប | មធ្យម | 51.26 | 0.00 | 0.00 | 31,309.52 | 32.62 | 17,768.60 | 47,520.66 | 60,330.58 |
| | ចំនួនគ្រួសារ | 84 | 84 | 84 | 84 | 242 | 242 | 242 | 242 |
| | គំលាតស្តង់ដា | 30.33 | 0.00 | 0.00 | 99,792.31 | 25.86 | 230,582.84 | 343,061.11 | 125,691.54 |

អង្កេតបង្ហាញថា ការបាត់បង់ទ្រព្យសម្បត្តិក្នុងគ្រួសារ ដូចជា ស្រូវ គោ ក្របី និង បសុបក្សី មានភាពខុសគ្នារវាង គ្រួសារមានបុរសជាមេគ្រួសារ និង គ្រួសារមាននារីជាមេគ្រួសារ (តារាង ២) ហើយភាពខុសគ្នានេះក៏អាចមើលឃើញ នៅពេលពិនិត្យទៅតាមប្រភេទផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ ដូចជា ទឹកជំនន់ និង គ្រោះរាំងស្ងួត ជាដើម។ ការសង្កេតបង្ហាញពីការបាត់បង់សត្វចិញ្ចឹម និងបសុបក្សីយ៉ាងច្រើនបង្កដោយគ្រោះរាំងស្ងួត ប៉ុន្តែគ្រោះទឹកជំនន់បង្កការខូចខាតដល់ផលិតកម្មស្រូវធ្ងន់ធ្ងរជាងគ្រោះរាំងស្ងួត សម្រាប់គ្រួសារទាំងពីរប្រភេទខាងលើ។

*៣.១.២. ស្ថានភាពបម្រែបម្រួលអាកាសធាតុដទៃទៀត*

ក្រៅពីការខូចខាតបង្កដោយទឹកជំនន់ និងគ្រោះរាំងស្ងួត ដូចរៀបរាប់ខាងលើ គ្រួសារឆ្លើយសម្ភាសន៍ប្រមាណ ៣៥% (តារាង ៣) បានរាយការណ៍ពីស្ថានភាពបម្រែបម្រួលអាកាសធាតុដទៃទៀត ដូចជា បម្រែបម្រួលសីតុណ្ហភាពនិងលំនាំទឹកភ្លៀង និង រដូវវស្សាមានរយៈពេលខ្លីជាងមុន ប៉ុន្តែមានភ្លៀងធ្លាក់ខ្លាំងជាងមុន ដែលចោទជាបញ្ហាដល់ជីវភាពរស់នៅរបស់ប្រជាជន។

តារាង ៣៖ ទស្សនៈរបស់អ្នកឆ្លើយសម្ភាសន៍អំពីស្ថានភាពបម្រែបម្រួលអាកាសធាតុនានា

| តើគ្រួសាររបស់អ្នកមានធ្លាប់រងការខូចខាតបង្កដោយបម្រែបម្រួលអាកាសធាតុដែរ ឬទេ? | គ្រួសារមានបុរសជាមេគ្រួសារ | | គ្រួសារមាននារីជាមេគ្រួសារ | | សរុប | |
|---|---|---|---|---|---|---|
| | ញឹកញាប់ | ភាគរយ | ញឹកញាប់ | ភាគរយ | ញឹកញាប់ | ភាគរយ |
| មាន | 176 | 33.5 | 52 | 33.5 | 228 | 33.5 |
| មិនមាន | 342 | 65.1 | 101 | 65.2 | 443 | 65.1 |
| មិនដឹង | 7 | 1.3 | 2 | 1.3 | 9 | 1.3 |
| សរុប | 525 | 100.0 | 155 | 100.0 | 680 | 100.0 |

ការស្រាវជ្រាវក៏មានបំណងស្វែងយល់ផងដែរពី ព័ត៌មានដែលគ្រួសារនៅមូលដ្ឋានទទួលបាន ទាក់ទងនឹងប្រព័ន្ធប្រកាសអាសន្ន។ ការស្រាវជ្រាវរកឃើញថា អ្នកឆ្លើយសម្ភាសន៍ជាង ៧០% បានដឹងមុនពីគ្រោះទឹកជំនន់ដែលអាចកើតមាន ហើយទូរទស្សន៍ និងវិទ្យុ ដើរតួយ៉ាងសំខាន់ក្នុងការផ្សព្វផ្សាយព័ត៌មានដែលគួរឲ្យជឿជាក់ (តារាង ៤)។

តារាង ៤៖ ទស្សនៈរបស់អ្នកឆ្លើយសម្ភាសន៍អំពីប្រព័ន្ធប្រកាសអាសន្ន និងការផ្សព្វផ្សាយព័ត៌មាន

| | | គ្រួសារមានបុរសជាមេគ្រួសារ | | គ្រួសារមាននារីជាមេគ្រួសារ | |
|---|---|---|---|---|---|
| | | ញឹកញាប់ | ភាគរយ | ញឹកញាប់ | ភាគរយ |
| តើមានវិធីអ្វីសម្រាប់ធ្វើឲ្យគ្រួសារអ្នកដឹងបានថា ទឹកជំនន់នឹងកើតមានដែរឬទេ? | មាន | 391 | 74 | 106 | 68 |
| | មិនមាន | 134 | 26 | 49 | 32 |
| *សរុប* | | *525* | *100* | *155* | *100* |

| | | | | | |
|---|---|---|---|---|---|
| វិទ្យុ | មិនគួរឲ្យជឿជាក់ | 6 | 2 | 1 | 1 |
| | គួរឲ្យជឿជាក់ | 110 | 28 | 26 | 25 |
| | គួរឲ្យជឿជាក់ខ្លាំង | 131 | 34 | 30 | 28 |
| | មិនដឹង | 144 | 37 | 49 | 46 |
| *សរុប* | | *391* | *100* | *106* | *100* |
| សេវាផ្ញើសារខ្លីៗ | មិនគួរឲ្យជឿជាក់ | 5 | 1 | 1 | 1 |
| | គួរឲ្យជឿជាក់ | 13 | 3 | 2 | 2 |
| | គួរឲ្យជឿជាក់ខ្លាំង | 9 | 2 | 6 | 6 |
| | មិនដឹង | 364 | 93 | 97 | 92 |
| *សរុប* | | *391* | *100* | *106* | *100* |
| ទូរទស្សន៍ | មិនគួរឲ្យជឿជាក់ | 5 | 1 | 1 | 1 |
| | គួរឲ្យជឿជាក់ | 93 | 24 | 23 | 22 |
| | គួរឲ្យជឿជាក់ខ្លាំង | 151 | 39 | 31 | 29 |
| | មិនដឹង | 142 | 36 | 51 | 48 |
| *សរុប* | | *391* | *100* | *106* | *100* |
| អ្នកនិយាយវិទ្យុក្នុងភូមិ ឬសហគមន៍ជនបទ | មិនគួរឲ្យជឿជាក់ | 16 | 4 | 2 | 2 |
| | គួរឲ្យជឿជាក់ | 15 | 4 | 3 | 3 |
| | គួរឲ្យជឿជាក់ខ្លាំង | 5 | 1 | 0 | 0 |
| | មិនដឹង | 355 | 91 | 101 | 95 |
| *សរុប* | | *391* | *100* | *106* | *100* |
| ចំណេះដឹងក្នុងមូលដ្ឋាន | មិនគួរឲ្យជឿជាក់ | 6 | 2 | 1 | 1 |
| | គួរឲ្យជឿជាក់ | 41 | 10 | 10 | 9 |
| | គួរឲ្យជឿជាក់ខ្លាំង | 41 | 10 | 9 | 8 |
| | មិនដឹង | 303 | 77 | 86 | 81 |
| *សរុប* | | *391* | *100* | *106* | *100* |
| ឮ តៗគ្នា | មិនគួរឲ្យជឿជាក់ | 42 | 11 | 8 | 8 |
| | គួរឲ្យជឿជាក់ | 83 | 21 | 18 | 17 |
| | គួរឲ្យជឿជាក់ខ្លាំង | 75 | 19 | 28 | 26 |
| | មិនដឹង | 191 | 49 | 52 | 49 |
| *សរុប* | | *391* | *100* | *106* | *100* |
| វិធីផ្សព្វផ្សាយផ្សេងៗទៀត | មិនគួរឲ្យជឿជាក់ | 2 | 1 | 0 | 0.0 |
| | គួរឲ្យជឿជាក់ | 2 | 1 | 0 | 0.0 |
| | គួរឲ្យជឿជាក់ខ្លាំង | 8 | 2 | 1 | 0.9 |
| | មិនដឹង | 379 | 97 | 105 | 99.1 |
| *សរុប* | | *391* | *100* | *106* | *100* |

## ៣.២. យេនឌ័រក្នុងការបន្សាំនឹងបម្រែបម្រួលអាកាសធាតុ

### *៣.២.១. យេនឌ័រក្នុងយុទ្ធសាស្រ្តដោះស្រាយបញ្ហាបម្រែបម្រួលអាកាសធាតុ*

ការស្រាវជ្រាវបង្ហាញថា មេគ្រួសារជាបុរស និងជានារី បានប្រើប្រាស់យុទ្ធសាស្រ្តសឹងតែដូចគ្នា ដើម្បីដោះស្រាយបញ្ហា។ ដូចមានបង្ហាញក្នុងតារាង ៥ ការខ្ចីបុលដើម្បីដោះស្រាយបញ្ហាគ្រោះរាំងស្ងួត ជាយុទ្ធសាស្រ្តទី១ ឬ ទី២ សម្រាប់មេគ្រួសារជាបុរសទាំងអស់ និងជាយុទ្ធសាស្រ្តទី៣ ឬ យុទ្ធសាស្រ្តចុងក្រោយសម្រាប់មេគ្រួសារជានារី។ ការស្រាវជ្រាវក៏បង្ហាញដែរថា ការស្វែងរកការងារយកថ្លៃឈ្នួលនៅក្រៅភូមិ ជាវិធីដោះស្រាយជាអាទិភាពរបស់មេគ្រួសារជានារី រីឯមេគ្រួសារជាបុរស ទំនងស្វែងរកការងារមានប្រាក់ខែទាំងនៅក្នុង និងក្រៅភូមិ ច្រើនជាង។

តារាង ៥៖ យុទ្ធសាស្រ្តដោះស្រាយ តាមប្រភេទមហន្តរាយ

| លេខរៀង | | បុរស | | នារី | | សរុប | |
|---|---|---|---|---|---|---|---|
| | | ប្រេកង់ | ភាគរយ | ប្រេកង់ | ភាគរយ | ប្រេកង់ | ភាគរយ |
| 1 | គ្រោះទឹកជំនន់ | | | | | | |
| 1.1 | នេសាទ | 15 | 16 | 4 | 16 | 19 | 16 |
| 1.2 | ធ្វើកសិកម្ម | 11 | 12 | 2 | 8 | 13 | 11 |
| 1.3 | លក់ពលកម្មក្នុងភូមិ | 8 | 9 | 2 | 8 | 10 | 8 |
| 1.4 | ស្វែងរកការងារយកថ្លៃឈ្នួលនៅក្រៅភូមិ | 18 | 19 | 6 | 24 | 24 | 20 |
| 1.5 | ផលិតទំនិញសម្រាប់លក់ | 2 | 2 | 1 | 4 | 3 | 3 |
| 1.6 | លក់ទ្រព្យសម្បត្តិសម្រាប់ទ្រទ្រង់ជីវភាព | 5 | 5 | 1 | 4 | 6 | 5 |
| 1.7 | ពឹងពាក់គ្រួសារសាច់ញាតិ និងមិត្តភក្តិ | 3 | 3 | 5 | 20 | 8 | 7 |
| 1.8 | ខ្ចីបុល | 17 | 18 | 1 | 4 | 18 | 15 |
| 1.9 | ពឹងផ្អែកលើធនធានព្រៃឈើ | 2 | 2 | 0 | 0 | 2 | 2 |
| 1.10 | ផ្សេងៗ | 12 | 13 | 3 | 12 | 15 | 13 |
| | *សរុប* | *93* | *100* | *25* | *100* | *118* | *100* |
| 2 | គ្រោះរាំងស្ងួត | | | | | | |
| 2.1 | គ្មានការផ្លាស់ប្តូរ | 30 | 10 | 7 | 9 | 37 | 10 |
| 2.2 | នេសាទ | 24 | 8 | 4 | 5 | 28 | 8 |
| 2.3 | ធ្វើកសិកម្ម | 32 | 11 | 9 | 12 | 41 | 11 |
| 2.4 | លក់ពលកម្មក្នុងភូមិ | 41 | 14 | 16 | 21 | 57 | 16 |
| 2.5 | ស្វែងរកការងារនៅក្រៅភូមិ | 51 | 17 | 14 | 19 | 65 | 18 |
| 2.6 | ផលិតទំនិញសម្រាប់លក់ | 19 | 7 | 4 | 5 | 23 | 6 |
| 2.7 | លក់ទ្រព្យសម្បត្តិសម្រាប់ទ្រទ្រង់ជីវភាព (ឧ. ដីគោ) | 23 | 8 | 2 | 3 | 25 | 7 |

| | | | | | | | |
|---|---|---|---|---|---|---|---|
| 2.8 | ពឹងពាក់គ្រួសារ សាច់ញាតិ និងមិត្តភក្តិ | 9 | 3 | 8 | 11 | 17 | 5 |
| 2.9 | ទទួលបានជំនួយ | 2 | 1 | 0 | 0 | 2 | 1 |
| 2.10 | ខ្ចីបុល | 50 | 17 | 9 | 12 | 59 | 16 |
| 2.11 | ពឹងផ្អែកលើធនធានព្រៃឈើ | 2 | 1 | 1 | 1 | 3 | 1 |
| 2.12 | ផ្សេងៗ | 9 | 3 | 1 | 1 | 10 | 3 |
| | *សរុប* | *292* | *100* | *75* | *100* | *367* | *100* |
| 3 | បម្រែបម្រួលអាកាសធាតុផ្សេងទៀត | | | | | | |
| 3.1 | គ្មានការផ្លាស់ប្តូរ | 10 | 7 | 3 | 8 | 13 | 7 |
| 3.2 | នេសាទ | 17 | 11 | 2 | 5 | 19 | 10 |
| 3.3 | ធ្វើកសិកម្ម | 19 | 13 | 4 | 10 | 23 | 12 |
| 3.4 | លក់ពលកម្មក្នុងភូមិ | 24 | 16 | 7 | 18 | 31 | 16 |
| 3.5 | ស្វែងរកការងារនៅក្រៅភូមិ | 16 | 11 | 8 | 20 | 24 | 13 |
| 3.6 | ផលិតទំនិញសម្រាប់លក់ | 5 | 3 | 3 | 8 | 8 | 4 |
| 3.7 | លក់ទ្រព្យសម្បត្តិសម្រាប់ទ្រទ្រង់ជីវភាព | 14 | 9 | 0 | 0 | 14 | 7 |
| 3.8 | ពឹងពាក់គ្រួសារ សាច់ញាតិ និងមិត្តភក្តិ | 7 | 5 | 5 | 13 | 12 | 6 |
| 3.9 | ទទួលជំនួយពីអង្គការផ្សេងៗ | 1 | 1 | 0 | 0 | 1 | 1 |
| 3.10 | ខ្ចីបុល | 31 | 21 | 4 | 10 | 35 | 19 |
| 3.11 | ផ្សេងៗ | 4 | 3 | 4 | 10 | 8 | 4 |
| | *សរុប* | *148* | *100* | *40* | *100* | *188* | *100* |

### *៣.២.២. យេនឌ័រក្នុងការបន្សាំនឹងបម្រែបម្រួលអាកាសធាតុ*

អ្នកឆ្លើយសម្ភាសន៍ភាគច្រើន ទាំងគ្រួសារមានបុរស ឬនារីជាមេគ្រួសារ បន្តប្រើប្រាស់បច្ចេកទេសផលិតកម្មកសិកម្មដែលខ្លួនធ្លាប់អនុវត្ត ដូចជា ប្រភេទគ្រាប់ពូជនិងដំណាំដដែលៗ និងពេលវេលាធ្វើកសិកម្មដូចពីដើម។ មានអ្នកឆ្លើយសម្ភាសន៍តែ ១៧% សម្រាប់គ្រួសារមានបុរសជាមេគ្រួសារ និង ២៨% សម្រាប់គ្រួសារមាននារីជាមេគ្រួសារ ដែលបានផ្លាស់ប្តូរការអនុវត្ត ដូចជា ចាប់ផ្តើមធ្វើការដាំដុះដើមរដូវ ឬចុងរដូវជាង បើធៀបនឹងទម្លាប់ពីមុនរបស់គាត់ (តារាង ៦)។

តារាង ៦៖ វិធានការសម្របខ្លួនរបស់អ្នកឆ្លើយសម្ភាសន៍

| | វិធានការសម្របខ្លួន | បុរស | | នារី | | សរុប | |
|---|---|---|---|---|---|---|---|
| | | ហ្វ្រេកង់ | ភាគរយ | ហ្វ្រេកង់ | ភាគរយ | ហ្វ្រេកង់ | ភាគរយ |
| តើគ្រួសារអ្នកបានផ្លាស់ប្តូររដូវធ្វើស្រែដែរឬទេ? | ពីរដូវវស្សាទៅរដូវប្រាំង | 6 | 1.1 | 1 | 0.6 | 7 | 1.0 |
| | ពីរដូវប្រាំងទៅរដូវវស្សា | 17 | 3.2 | 2 | 1.3 | 19 | 2.8 |
| | មិនពាក់ព័ន្ធ/គ្មានការផ្លាស់ប្តូរ | 429 | 81.7 | 121 | 78.1 | 550 | 80.9 |
| | មិនដឹង | 73 | 13.9 | 31 | 20.0 | 104 | 15.3 |
| *សរុប* | | *525* | *100* | *155* | *100.0* | *680* | *100.0* |
| តើគ្រួសារអ្នកបានផ្លាស់ប្តូរពេលវេលា ធ្វើស្រែដែរឬទេ? | ចាប់ដាំដើមរដូវជាងមុន | 77 | 17.5 | 22 | 17.7 | 99 | 17.6 |
| | ចាប់ដាំនៅចុងរដូវជាងមុន | 133 | 30.3 | 28 | 22.6 | 161 | 28.6 |
| | គ្មានការផ្លាស់ប្តូរ | 208 | 47.4 | 60 | 48.4 | 268 | 47.6 |
| | មិនដឹង | 21 | 4.8 | 14 | 11.3 | 35 | 6.2 |
| *សរុប* | | *439* | *100* | *124* | *100* | *563* | *100* |
| តើគ្រួសារអ្នកមានផ្លាស់ប្តូរប្រភេទដំណាំដាំដុះដោយសារការខូចខាតបង្កដោយគ្រោះទឹកជំនន់ដែរឬទេ? | មាន | 98 | 22.3 | 25 | 20.2 | 123 | 21.8 |
| | មិនមាន | 341 | 77.7 | 99 | 79.8 | 440 | 78.2 |
| *សរុប* | | *439* | *100* | *124* | *100* | *563* | *100* |
| តើគ្រួសារអ្នកមានផ្លាស់ប្តូរប្រភេទដំណាំដាំដុះ ដោយសារការខូចខាតបង្កដោយគ្រោះរាំងស្ងួត ដែរឬទេ? | មាន | 147 | 33.5 | 38 | 30.6 | 185 | 32.9 |
| | មិនមាន | 292 | 66.5 | 86 | 69.4 | 378 | 67.1 |
| *សរុប* | | *439* | *100* | *124* | *100* | *563* | *100* |

## ៤. សេចក្តីសន្និដ្ឋាន និងអនុសាសន៍

គ្រួសារក្នុងអង្កេតយល់ឃើញថា ពួកគាត់រងផលប៉ះពាល់ពីគ្រោះរាំងស្ងួត ធ្ងន់ធ្ងរជាងគ្រោះទឹកជំនន់។ គ្រោះរាំងស្ងួតញឹកញាប់ ធ្វើឲ្យខូចខាតផលដំណាំ និងស្លាប់គោក្របីដែលជាកម្លាំងពលកម្មចម្បងសម្រាប់ផលិតកម្មកសិកម្ម។

ជាទូទៅ ទាំងគ្រួសារមានបុរសជាមេគ្រួសារ និង គ្រួសារមាននារីជាមេគ្រួសារ បានប្រើយុទ្ធសាស្ត្រដោះស្រាយសឹងតែដូចគ្នា ដើម្បីកាត់បន្ថយផលប៉ះពាល់នៃបម្រែបម្រួលអាកាសធាតុ។ ទោះយ៉ាងនេះក្តី គ្រួសារមានបុរសជាមេគ្រួសារ ទំនងជ្រើសយកការខ្ចីបុលច្រើនជាងមធ្យោបាយផ្សេងៗ ដែលនាំឲ្យពួកគាត់ជំពាក់បំណុលច្រើនជាង គ្រួសារមាននារីជាមេគ្រួសារ។ ម្យ៉ាងទៀត គ្រួសារមានបុរសជាមេគ្រួសារ ទំនងមានលក់ទ្រព្យសម្បត្តិក្នុងគ្រួសារ ច្រើនជាង គ្រួសារមាននារីជាមេគ្រួសារ។ ចំណែកឯគ្រួសារមាននារីជាមេគ្រួសារវិញ ពួកគេទំនងស្វែងរកបន្ថែមនូវការងារយកថ្លៃឈ្នួល ទាំងនៅក្នុង និងនៅក្រៅភូមិ ច្រើនជាង គ្រួសារមានបុរសជាមេគ្រួសារ។

គ្រួសារឆ្លើយសម្ភាសន៍ភាគច្រើន នៅតែធ្វើកសិកម្មតាមរបៀប និងវិធីដែលពួកគាត់តែងអនុវត្តជារៀងរហូតមក។ មិនដល់ ៥០% នៃអ្នកឆ្លើយសម្ភាសន៍ទេ ដែលបានចាប់ផ្តើមសម្របការដាំដុះរបស់ខ្លួនទៅតាមបម្រែបម្រួលអាកាសធាតុ ដោយបានផ្លាស់ប្តូរពេលវេលាធ្វើការដាំដុះ (ដាំដើមរដូវជាងមុន ឬចុងរដូវជាងមុន) និង ដាំដំណាំប្រភេទថ្មីៗ។

## គន្ថនិទ្ទេស


CARE (2009), *Mainstreaming Climate Change Adaptation: A Practioner's Handbook*, CARE International in Vietnam. http://www.careclimatechange.org/files/adaptation/ CARE_VN_Mainstreaming_Handbook.pdf (Access on 20 Nov 2011)

FAO (2009), "Climate Change Implications for Fisheries and Aquaculture: Overview of Current Scientific Knowledge", FAO Fishery and Aquaculture Technical Paper 530 (Rome: FAO)

IPCC (2007), "Summary for Policymakers", in M.C. Parry, C.F. Canziani, E.D. Palutihof, van der Vincent & C.E. Hansen (eds.) *Climate Change 2007: Impacts, Adaptation and Vulnerability. Contribution of Working Group II to the Fourth Assessment Report of the Intergovernmental Panel on Climate Change* (Cambridge, UK: Cambridge University Press)

Nguyen H. (2007), "Drought Management Considerations for Climate Change Adaptation: Focus on the Mekong Region, Cambodia Report", Oxfam Cambodia and Graduate School of Global Environmental Studies of Kyoto University

NIS (2009), *General Population Census of Cambodia 2008*, (Phnom Penh: Ministry of Planning)

UNDP (2009a), "Gender and Climate Change: Impact and Adaptation", report for the Asia-Pacific Gender Community of Practice Annual Learning Workshop, Negombo, Sri Lanka, 24–26 September 2008

UNDP (2009b), "Resource Guide on Gender and Climate Change" http://www.uneca.org/acpc/about_acpc/docs/UNDP-GENDER-CLIMATE-CHANGE-RESOURCE-GUIDE.pdf (*Access on 15 Nov 2011*)

Wong F. Franz (2011), "Navigating the Mainstream: research on strategies to resist gender discrimination and violence against women", prepared for Deutsche Gesellschaft für Internationale Zusammenarbeit (GIZ) and Heinrich-Böll-Foundation in cooperation with the Ministry of Women's Affairs Royal Government of Cambodia

# -៩-
# ការផ្តល់សិទ្ធិអំណាចឲ្យនារី ចូលរួមកាន់តែច្រើន ក្នុងទីផ្សារពលកម្ម

*ដោយលោកស្រី ស៊ុំ ស្រីមុំ និង លោក កែវ សុជាតិ*[១]

## ១. សេចក្តីផ្តើម

### ***១.១. សាវតារ***

និន្នាការផ្លាស់ប្តូរការងារទាំងនារី និងបុរស ពីវិស័យកសិកម្ម ទៅខាងឧស្សាហកម្ម និងសេវាកម្មវិញ អាចមើលឃើញច្បាស់នៅប្រទេសកម្ពុជា។ ចំនួនការងារបានកើនឡើង ហើយនារីក៏ចូលរួមចំណែកបំពេញការងារ ក្នុងចំនួនស្មើគ្នានឹងបុរសដែរ សម្រាប់វិស័យកសិកម្ម និងឧស្សាហកម្ម (MoWA 2008)។ រាជរដ្ឋាភិបាលកម្ពុជា បានចាត់ទុកនារីជាឆ្អឹងខ្នងរបស់សង្គម និងសេដ្ឋកិច្ច ហើយទទួលស្គាល់ច្បាស់លាស់ថា បញ្ហាយេនឌ័រមិនអាចចាត់ទុកជាបញ្ហាដាច់តែឯងបានទេ ព្រោះជាប់ពាក់ព័ន្ធជិតស្និទ្ធនឹងការកាត់បន្ថយភាពក្រីក្រ និងជាគន្លឹះសម្រាប់លើកកម្ពស់សុខុមាលភាពនារី និងគ្រួសាររបស់ពួកគេ។ ក្នុងវិស័យសេដ្ឋកិច្ច រដ្ឋាភិបាលបានការពារសិទ្ធិពលករនារី តាមការជួយគាំទ្រ និងអន្តរាគមន៍គោលនយោបាយនានា ដូចជា តាមរយៈ "ផែនការនារីរតនៈ" ជាដើម។ ថ្វីបើមានការរីកចម្រើនក្នុងការអនុវត្តគោលនយោបាយរបស់ប្រទេសក្តី ក៏ការជំរុញសមភាពយេនឌ័រ និងការពង្រឹកសិទ្ធិអំណាចនារី នៅតែបន្សល់ទុកបញ្ហាប្រឈមជាច្រើនដែលត្រូវដោះស្រាយជាបន្តទៀត។ នារីដែលបានសិក្សាដល់កម្រិតវិទ្យាល័យ និងមហាវិទ្យាល័យក៏នៅទទួលបានថ្លៃឈ្នួលខុសគ្នាខ្លាំង។ ប្រភពជីវភាពចម្បងរបស់នារីនៅកម្ពុជា គឺចំណូលទទួលបានពីសេដ្ឋកិច្ចក្រៅផ្លូវការ។ អាកប្បកិរិយាជាប្រពៃណីចំពោះវិជ្ជាជីវៈសមស្របសម្រាប់នារី និងបុរស ជាចំណុចស្នូលនៃភាពខុសប្លែកគ្នាយ៉ាងធំខាងយេនឌ័រដែលកំពុងបន្តនៅកម្ពុជា។ កត្តាផ្សេងៗទៀត ដែលដាក់កម្រិតលើមធ្យោបាយចិញ្ចឹមជីវិតសម្រាប់នារីធ្វើការងារ គឺ កម្រិតអប់រំទាបរបស់នារីដែលចូលរួមក្នុងកម្លាំងពលកម្មបច្ចុប្បន្ន និង អត្រាអក្ខរកម្មរបស់នារីនៅក្នុងទីផ្សារពលកម្ម។ ម្យ៉ាងវិញទៀត ការផ្លាស់ប្តូររចនាសម្ព័ន្ធសេដ្ឋកិច្ច និងកំណើនចំណាកស្រុកទាក់ទងនឹងបញ្ហាសេដ្ឋកិច្ច កំពុងរួមចំណែកក្នុងកំណើនភាពងាយរងគ្រោះដល់ពលករនារី ហើយវិបត្តិសេដ្ឋកិច្ច កាន់តែធ្វើឲ្យសភាពការណ៍អាក្រក់ឡើង (RGC 2009)។ ការជំរុញឱកាសការងារសម្រាប់នារី មិនត្រឹមតែផ្តល់អត្ថប្រយោជន៍ដល់បុរស នារី និងគ្រួសារទាំងមូលរបស់ពួកគេនោះទេ ប៉ុន្តែថែមទាំងជួយនារីឲ្យចូលរួមក្នុងការងារបានជាទូទៅ ដែលផ្តល់អត្ថប្រយោជន៍ដល់សេដ្ឋកិច្ច តាមរយៈការប្រើប្រាស់ធនធានមនុស្សបានពេញលេញ។ ការវិភាគយេនឌ័រក្នុងទីផ្សារពលកម្ម ដូចជា ទិន្នន័យបំបែកតាមភេទ (sex-disaggregated data) ជាកត្តាចាំបាច់ដើម្បីបញ្ជាក់ពីគោលនយោបាយការងារសមស្របនានាសម្រាប់នារីនៅកម្ពុជា។

---

១ លោកស្រី ស៊ុំ ស្រីមុំ និង លោក កែវ សុជាតិ ជាអ្នកស្រាវជ្រាវ នៅវិទ្យាស្ថាន CDRI។

### ១.២. គោលបំណង

អត្ថបទនេះ មានគោលបំណងទូទៅ ពិនិត្យលើយន្តការមានស្រាប់នៃការជំរុញការងារសមស្របសម្រាប់នារីនៅកម្ពុជា ជាពិសេស កំណត់ពីបញ្ហាជាសក្តានុពលនានានៃទីផ្សារការងារនៅកម្ពុជាក្នុងបំណងបង្កើនការងារសមស្របនិងពង្រីកឱកាសការងារសម្រាប់នារីហើយរួមចំណែកជំរុញទៅរកកំណើនដែលមានការរាប់បញ្ចូលកាន់តែប្រសើរ។

### ១.៣. វិធីសាស្ត្រស្រាវជ្រាវ

ដើម្បីសម្រេចតាមគោលបំណងនៃការសិក្សា អត្ថបទនេះចែកចេញជាពីរផ្នែក៖ (១) ការអធិប្បាយត្រួសៗ ដោយផ្តោតទៅលើបញ្ហានារី ទីផ្សារការងារ និងការងារសមស្រប និង (២) ការវិភាគយេនឌ័រនៃក្របខ័ណ្ឌនយោបាយដើម្បីគាំទ្រការផ្តល់ការងារសម្រាប់នារី។ ទិន្នន័យប្រភពទីពីរដែលអាចរកបាន (ដូចជា មូលដ្ឋានទិន្នន័យ និងរបាយការណ៍ជាតិ និងឯកសារស្រាវជ្រាវពាក់ព័ន្ធផ្សេងទៀត) បានយកមកប្រើជាទិន្នន័យចម្បងសម្រាប់ការសិក្សានេះ។

> និយមន័យនៃការងារសមស្រប "Decent Work"
>
> *តាមនិយមន័យរបស់អង្គការពលកម្មអន្តរជាតិ (International Labour Organization) ពាក្យ "ការងារសមស្រប" មានបួនសមាសធាតុ គឺ៖ (១) ការងារគ្រប់ប្រភេទ រាប់បញ្ចូលទាំងការងារក្នុងសេដ្ឋកិច្ចផ្លូវការ ការងារផ្ទាល់ខ្លួន ការងារមានប្រាក់កម្រៃមិនទៀងទាត់ និងការងារតាមផ្ទះ (២) សន្តិសុខសង្គមទាក់ទងនឹងការការពារទល់នឹងហានិភ័យនៃការបាត់បង់ប្រាក់ចំណូល ដូចជា សុវត្ថិភាព និងសុខុមាលភាពការងារជាដើម (៣) សិទ្ធិការងារ ដែលសំដៅលើសេរីភាពក្នុងការបង្កើតជាសមាគម ការងារគ្មានការរើសអើង និង ការងារមិនមានការបង្ខិតបង្ខំ និងរំលោភពលកម្មកុមារ និង (៤) ការសន្ទនាដែលផ្តោតលើសិទ្ធិពលករក្នុងការពិភាក្សាជាមួយនិយោជក ឬអាជ្ញាធរពាក់ព័ន្ធនឹងបញ្ហាស្ថានភាពការងារ (ILO 2002)។*

## ២. កំណើនមានការរាប់បញ្ចូល (សូចនាករសមភាពយេនឌ័រ)

ដើម្បីសម្រេចបានគោលដៅទី៣ នៃគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (ការជំរុញសមភាព និងអំណាចនារី) រដ្ឋាភិបាលបានជ្រើសរើសសូចនាករជាច្រើននៃសមភាពយេនឌ័រ ដូចមានបង្ហាញក្នុងតារាង ១។ សូចនាករទាំងនោះ មានបញ្ចូលវិស័យសំខាន់ៗខ្លះ ដែលតំណាងឲ្យការផ្តល់អំណាចផ្នែកសេដ្ឋកិច្ចដល់នារី (ការចូលរួមក្នុងការងាររកប្រាក់កម្រៃ) និងការអប់រំ។

តារាង ១៖ សូចនាករសមភាពយេនឌ័រសំខាន់ៗ

| សូចនាករ | កម្រិតគោល | | គោលដៅ | | |
|---|---|---|---|---|---|
| | តម្លៃ | ឆ្នាំ | 2005 | 2010 | 2015 |
| អនុបាតក្មេងស្រីសិក្សាថ្នាក់បឋមសិក្សា ធៀបនឹងក្មេងប្រុស (%) | 87 | 2002 | 98 | 100 | 100 |
| អនុបាតក្មេងស្រីសិក្សាថ្នាក់អនុវិទ្យាល័យ ធៀបនឹងក្មេងប្រុស (%) | 63 | 2002 | 96 | 100 | 100 |
| អនុបាតក្មេងស្រីសិក្សាថ្នាក់វិទ្យាល័យ ធៀបនឹងក្មេងប្រុស (%) | 48 | 2002 | 59 | 80 | 100 |
| អនុបាតនារីសិក្សាថ្នាក់ឧត្តមសិក្សា ធៀបនឹងបុរស (%) | 38 | 2002 | 50 | 70 | 85 |
| អនុបាតនារីចេះអក្សរ ធៀបនឹងបុរសចេះអក្សរ អាយុ 15-24 ឆ្នាំ (%) | 87 | 1998 | 95 | 100 | 100 |
| អនុបាតនារីចេះអក្សរ ធៀបនឹងបុរសចេះអក្សរ អាយុ 25-44 ឆ្នាំ (%) | 78 | 1998 | 85 | 100 | 100 |
| ចំណែកនារីចូលរួមក្នុងការងាររកកម្រៃក្នុងវិស័យកសិកម្ម (%) | 35 | 1998 | 50 | 50 | 50 |
| ចំណែកនារីចូលរួមក្នុងការងាររកកម្រៃក្នុងវិស័យឧស្សាហកម្ម (%) | 44 | 1998 | 50 | 50 | 50 |
| ចំណែកនារីចូលរួមក្នុងការងាររកកម្រៃក្នុងវិស័យសេវាកម្ម (%) | 21 | 1998 | 30 | 37 | 50 |

*ប្រភព៖ MOP (2007) and Ministry of Women's affairs (2008)*

## ៣. ការវិភាគយេនឌ័រនៃទីផ្សារពលកម្ម និង ការងារសមរម្យ

### *៣.១. ការរួមចំណែកក្នុងទីផ្សារពលកម្ម*

ប្រជាជនគ្រប់អាយុធ្វើការ បានកើនឡើង ពី ៥៣,៧% នៅឆ្នាំ១៩៩៨ ដល់ ៦២% នៅឆ្នាំ២០០៨ (NIS 2009a) ដែលបង្ហាញពីកំណើនកម្លាំងពលកម្មសម្រាប់សកម្មភាពសេដ្ឋកិច្ច និងជាសញ្ញាប្រាប់ដល់រដ្ឋាភិបាលពី បញ្ហាប្រឈមជាសក្តានុពលនានាក្នុងការបង្កើនឱកាសការងារសមរម្យនៅក្នុងទីផ្សារការងារកម្ពុជា។

*៣.១.១. ការអប់រំ ការបណ្តុះបណ្តាល និង តម្រូវការពលកម្ម*

អត្រាចុះឈ្មោះចូលរៀនសុទ្ធសម្រាប់ក្មេងស្រីនៅកម្រិតបឋមសិក្សា មានត្រឹម ៨៤,២% នៅឆ្នាំ២០០២ ហើយកើនឡើងបន្តិចដល់ ៩០,៧% នៅឆ្នាំ២០០៥ និង ដល់ ៩១% នៅឆ្នាំ២០០៧ (NIS 2009a: 72) ដែលនៅតែមានកម្រិតទាបជាងតួលេខគោលដៅ ៩៥% ត្រឹមឆ្នាំ២០០៥។ សម្រាប់ថ្នាក់អនុវិទ្យាល័យ អត្រាចុះឈ្មោះចូលរៀនរបស់សិស្សស្រី មានត្រឹម ១៦,៤% នៅឆ្នាំ២០០២ ហើយកើនដល់ ២៤,៨% នៅឆ្នាំ២០០៥ ដែលស្មើនឹងពាក់កណ្តាលនៃតួលេខគោលដៅ។ អត្រានេះបានកើនឡើងគួរឲ្យកត់សម្គាល់ ដល់ ៣៣,៤% នៅឆ្នាំ២០០៧។

នៅឆ្នាំ២០០៥ អនុបាតនារីចេះអក្សរ ធៀបនឹងបុរសចេះអក្សរ អាយុពី ១៥-២៤ឆ្នាំ កើនបានត្រឹម ៣ឯកតាភាគរយប៉ុណ្ណោះ បើធៀបនឹងឆ្នាំ១៩៩៨ ដែលទាបជាងការគ្រោងទុក (៩៥%) ដល់ទៅ ៥ឯកតាភាគរយ (MoWA 2008)។ ក្នុងអំឡុងឆ្នាំ២០០២-២០០៥ ផលធៀបរវាងក្មេងស្រី និង ក្មេងប្រុស ដែលសិក្សានៅកម្រិតបឋមសិក្សា អនុវិទ្យាល័យ និង វិទ្យាល័យ បានកើនឡើង ប៉ុន្តែមានតែផលធៀបសម្រាប់កម្រិតអនុវិទ្យាល័យប៉ុណ្ណោះ ដែលអាចកើនឡើងដល់គោលដៅគ្រោងទុក (តារាង ១)។

អង្កេតសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៩ (CSES 2009) បង្ហាញថា ២៨,៣% នៃចំនួនប្រជាជនអាយុ ២៥ឆ្នាំ ឬលើសពីនេះ គ្មាន ឬមានការអប់រំតិចតួច ហើយភាគច្រើនជានារី

(រូបភាព ១)។ នារីដែលមិនបានបញ្ចប់ថ្នាក់បឋមសិក្សា មានភាគរយច្រើនជាងបុរសបន្តិច។ ភាគរយនារីដែលទទួលបានការសិក្សាផ្លូវការនៅកម្រិតបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យ មានកម្រិតទាបជាងបុរស នៅក្នុងកម្រិតសិក្សាទាំងបី។ ទិន្នន័យនេះបង្ហាញថា ភាពមិនស្មើគ្នាខាងយេនឌ័រក្នុងការអប់រំ នៅតែឃើញមានយ៉ាងច្បាស់នៅគ្រប់កម្រិតសិក្សា។

រូបភាព ១៖ ភាគរយនៃប្រជាជនកម្ពុជាអាយុ ២៥ឆ្នាំ ឬលើសពីនេះ បែងចែកតាមកម្រិតសិក្សា និងភេទ ក្នុងឆ្នាំ២០០៩




*ប្រភព៖ CSES 2009 ( NIS/MOP, 2010 )*

### *៣.១.២. ការបណ្តុះបណ្តាលវិជ្ជាជីវៈ និង បច្ចេកទេស*

ជាទូទៅ ការបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសសម្រាប់នារីកម្ពុជា មានធ្វើឡើងត្រឹមតែជំនាញជាប្រពៃណីរបស់នារីៗប៉ុណ្ណោះ (ឧទាហរណ៍ ដេរប៉ាក់ តុបតែងសក់ ជំនាញទាក់ទងនឹងការថែរក្សាសម្ផស្ស) (MoWA 2008: 81)។ វិភាគសេដ្ឋកិច្ច-សង្គមកិច្ចកម្ពុជាឆ្នាំ២០០៩ រកឃើញថា នារីប្រហែល ៨៥% បានចូលរួមវគ្គបណ្តុះបណ្តាលភាសាបរទេស គឺដូចគ្នានឹងបុរសដែរ។ តម្រូវការខ្ពស់ខាងភាសាបរទេសនេះ អាចមកពីការងារភាគច្រើននៅក្នុងទីផ្សារពលកម្ម មានជាប់ទាក់ទងជាចម្បងនឹង ការលក់ដូរ ម៉ាឃីតទីង និងការគ្រប់គ្រងអាជីវកម្ម ដែលទាមទារចំណេះដឹងភាសាបរទេស ជាពិសេសភាសាអង់គ្លេស[២]។ ប៉ុន្តែសម្ភាសន៍ជាមួយអ្នកគ្រប់គ្រងជំនួញ បង្ហាញថា គុណភាពនៃការអប់រំ និងបណ្តុះបណ្តាលនៅកម្ពុជា នៅមានកម្រិតទាប។ ធនាគារពិភពលោក (២០១០) បានសន្មតថា បញ្ហានេះបណ្តាលមកពីការទទួលបានចំណូលត្រឡប់ទាប ពីបទពិសោធន៍ និងការអប់រំ ដែលអាចជាហេតុផលមួយដែរនៃការចុះឈ្មោះចូលរៀនតិចតួច។ នៅកម្ពុជា អ្នកទទួលបានការអប់រំកម្រិតឧត្តមសិក្សា រកកម្រៃបាន

---

២ សូមចូលទៅកាន់ http://www.nea.gov.kh/main/images/stories/nea/LMI/graphic_2010_2011.pdf

ជាមធ្យម ៦៧% ខ្ពស់ជាងអ្នកមិនបានចូលរៀន ហើយអនុបាតនេះ មានប្រមាណ ១៣៨% នៅថៃ និង ១១២% នៅឥណ្ឌូនេស៊ី (World Bank 2010: 44)។

*៣.១.៣. ឧបសគ្គរារាំងនារីក្នុងការទទួលបានការអប់រំ និងបណ្តុះបណ្តាលប្រកបដោយគុណភាព*

ឧបសគ្គមួយក្នុងចំណោមឧបសគ្គជាច្រើនដែលតាមរារាំងកម្ពុជា ក្នុងដំណើរការឆ្ពោះទៅរកសមភាពយេនឌ័រក្នុងវិស័យអប់រំ គឺផ្នត់គំនិតយេនឌ័រ ដែលកើតឡើងពីវប្បធម៌ប្រពៃណី និងសង្គម។ នារីស្ទើរតែ ៥០% ផ្តល់អាទិភាពដល់កូនប្រុសច្រើនជាងកូនស្រី ក្នុងការទទួលបានឱកាសចូលរៀន (MoWA 2008: 83)។ ភាពក្រីក្រ ជាឧបសគ្គមួយផ្សេងទៀតចំពោះលទ្ធភាពទទួលបានការអប់រំរបស់នារី។ ឧទាហរណ៍ ចំពោះកូនស្រី គេរំពឹងថា ត្រូវជួយឪពុកម្តាយធ្វើការងារផ្ទះ ឬចូលរួមសកម្មភាពរកចំណូលតាំងពីនៅវ័យក្មេង។ ឧបសគ្គផ្សេងៗទៀត រួមមាន កង្វះគុណភាព និងភាពលំបាកក្នុងការធ្វើដំណើរទៅសាលារៀន កង្វះគ្រូបង្រៀន និងកំហិតនៃប្រព័ន្ធអប់រំនៅក្នុងប្រទេស ហើយកត្តាទាំងអស់នេះ ជះឥទ្ធិពលអវិជ្ជមានទៅលើការពេញចិត្តធ្វើវិនិយោគទៅលើការអប់រំរបស់កូនៗ (MoWA 2008: 84)។

## ៣.២. ការចូលរួមក្នុងកម្លាំងពលកម្ម

ចំនួនប្រជាជនគ្រប់អាយុធ្វើការនៅកម្ពុជា បានកើនឡើង ១,៣លាននាក់ ដល់ ៨,៩ លាននាក់ ឬ ១៦,៨% ក្នុងចន្លោះឆ្នាំ២០០៤-២០០៩ (NIS 2010: 58) ហើយក្នុងនោះ កម្លាំងពលកម្ម កើនឡើង ១,២៨លាននាក់ ឬ ២០%។ ទោះយ៉ាងនេះក្តី អត្រាចូលរួមក្នុងកម្លាំងពលកម្ម បានកើនឡើងត្រឹម ២,២% ប៉ុណ្ណោះ ក្នុងអំឡុងពេលនោះ (តារាង ២)។

តារាង ២៖ កម្លាំងពលកម្ម អាយុ ១៥-៦៤ឆ្នាំ គិតតាមភេទ

| | 2004 | 2009 |
|---|---|---|
| អត្រាចូលរួមក្នុងកម្លាំងពលកម្ម | | |
| ទាំងពីរភេទ | 82.2 | 84.4 |
| នារី | 77.5 | 80.4 |
| បុរស | 87.4 | 88.8 |
| អត្រាមានការងារធ្វើ | | |
| ទាំងពីរភេទ | 81.3 | 84.3 |
| នារី | 76.6 | 80.3 |
| បុរស | 86.6 | 88.6 |
| អត្រាមិនមានការងារធ្វើ | | |
| ទាំងពីភេទ | 1.0 | 0.1 |
| នារី | 1.1 | 0.1 |
| បុរស | 1.0 | 0.2 |

*ប្រភព៖ CSES 2009 (NIS/MOP, 2010)*

អត្រាមានការងារធ្វើ បានកើនឡើង ៣ឯកតាភាគរយ ដោយសារមានកំណើនទាំងនារី និងបុរស ក្នុងអំឡុងពេលដូចគ្នា។ អត្រាមិនមានការងារធ្វើសម្រាប់នារី និងបុរស មានត្រឹម ១% ប៉ុណ្ណោះ ក្នុងឆ្នាំ២០០៤ និងបានថយចុះថែមទៀតនៅឆ្នាំ២០០៩។

### ៣.៣. ចំណាកស្រុក

ជំរឿនប្រជាជនឆ្នាំ២០០៨ បង្ហាញថា ជនចំណាកស្រុក មានចំនួន ៣,៥៣លាននាក់ ឬ ២៦,៥% នៃចំនួនប្រជាជនសរុប (NIS 2009a)។ មូលហេតុចម្បងនៃការធ្វើចំណាកស្រុកគឺការស្វែងរកឱកាសការងារ។ ជំរឿនឆ្នាំ២០០៨ (Census 2008) បង្ហាញថា លំហូរចំណាកស្រុកពីជនបទទៅជនបទ មានច្រើនជាងគេ គឺ ៥០,៨៨% ហើយបន្ទាប់មកគឺ លំហូរពីជនបទទៅទីក្រុង។

ជនចំណាកស្រុកឆ្លងកាត់ព្រំដែន យល់ថា ចំណាកស្រុកមិនស្របច្បាប់ជាមធ្យោបាយងាយស្រួល មានប្រសិទ្ធភាព និងប្រាកដប្រជា ដោយសារវាមិនត្រូវការភាពស្របច្បាប់ ឬការអនុញ្ញាតឲ្យធ្វើការក្នុងប្រទេសគោលដៅ (Hing *et al.* 2011) ដែលរួមមានជាសំខាន់ ប្រទេសថៃតាមព្រំដែនថៃ និង ប្រទេសម៉ាឡេស៊ី។ ជាទូទៅ ការងាររយៈចម្ងាយជិត គឺជាការងារកសិកម្ម ហើយការងាររយៈចម្ងាយឆ្ងាយ មានដូចជា ការងារនេសាទ សំណង់ និងរោងចក្រ។ Hing *et al.* (2011) បានសន្និដ្ឋានថា ចំណាកស្រុកមិនស្របច្បាប់ មានដើមហេតុមកពីភាពក្រីក្រពុំរ៉ែ កង្វះការងារធ្វើ ចំណាយខ្ពស់ និងភាពស្មុគស្មាញនៃនីតិវិធីជ្រើសរើសតាមផ្លូវច្បាប់។

ដោយគ្មានឋានៈស្របច្បាប់ ជនចំណាកស្រុកមិនស្របច្បាប់ ត្រូវប្រឈមមុខកាន់តែខ្លាំងឡើងជាមួយស្ថានភាពរំលោភបំពាន និងការកេងប្រវ័ញ្ច ដូចជា ការបំពានលើរាងកាយនិងផ្លូវភេទ និង ការជំពាក់បំណុល ជាដើម។ ក្នុងករណីធ្ងន់ធ្ងរ បុរសខ្លះត្រូវគេបង្ខំឲ្យធ្វើការក្នុងស្ថានភាពលំបាកខ្លាំង រីឯនារីមួយចំនួនត្រូវគេបង្ខំឲ្យធ្វើជាស្រីរកស៊ីផ្លូវភេទ។

### ៣.៤. ការងារក្នុងវិស័យក្រៅផ្លូវការ

ការងារផ្ទាល់ខ្លួន និង ការងារផ្ទះ អាចយកមកតំណាងឲ្យសេដ្ឋកិច្ចក្រៅផ្លូវការបាន (Hing *et al.* 2011: 41)។ ដូចបានកត់សម្គាល់នៅខាងលើ នៅឆ្នាំ២០០៩ នារី ៥២,៤% បម្រើការងារផ្ទាល់ខ្លួន និង ២៤,៥% ធ្វើការងារផ្ទះដោយមិនមានប្រាក់កម្រៃ ដូច្នេះនារីស្ទើរតែ ៧៧% បានចូលរួមក្នុងវិស័យក្រៅផ្លូវការក្នុងឆ្នាំ២០០៩។ ករណីនេះ ក៏កើតមានចំពោះបុរសដែរ ដោយមាន ៦៨,៧% បានចូលរួមក្នុងសេដ្ឋកិច្ចក្រៅផ្លូវការក្នុងឆ្នាំដូចគ្នានោះ។ សរុបមក ភាគច្រើននៃកម្លាំងពលកម្មកម្ពុជា ធ្វើការក្នុងវិស័យក្រៅផ្លូវការ។

## ៤. ការវិភាគយេនឌ័រនៃក្របខ័ណ្ឌគោលនយោបាយការងារ

ដើម្បីឆ្លើយតបនឹងវិសមភាពយេនឌ័រនៅកម្ពុជា រដ្ឋាភិបាលបានកំណត់ជាគោលដៅផ្សេងៗទាក់ទងនឹងយេនឌ័រ នៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៦-២០១០ និងផែនការថ្មីឆ្នាំ២០០៩-២០១៣ ដោយប្រើប្រាស់យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ (NPRS) ឆ្នាំ២០០២។ គោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា (CMDGs) ឆ្នាំ២០០៥-២០១៥ ក៏បានពង្រីកថែមផងដែរ ដើម្បីចូលរួមក្នុងការលុបបំបាត់វិសមភាពយេនឌ័រនៅគ្រប់វិស័យ ដូចជា ការអប់រំ សុខភាព សកម្មភាពសេដ្ឋកិច្ច កសិកម្ម ព្រៃឈើនិងនេសាទ វិស័យសាធារណៈ និង អំពើហិង្សាលើនារីនិង

កុមារ។ ជាក់ស្តែង សម្រាប់វិស័យអប់រំ កម្ពុជាបានប្តេជ្ញាលុបបំបាត់គំលាតយេនឌ័រក្នុងផ្នែកអក្ខរកម្ម ត្រឹមឆ្នាំ២០១០ និងសម្រេចឲ្យបានសមភាពយេនឌ័រនៅក្នុងការងាររកប្រាក់កម្រៃក្នុងវិស័យកសិកម្ម និងឧស្សាហកម្មត្រឹមឆ្នាំ២០១០ និងវិស័យសេវាកម្មត្រឹមឆ្នាំ២០១៥ (MoWA 2008)។

ការងារនៅកម្ពុជា ផ្សារភ្ជាប់ទៅនឹងវិស័យឯកជន ចាប់តាំងពីរដ្ឋាភិបាលបានកំណត់ថា វិស័យនេះ ជាក្បាលម៉ាស៊ីននៃកំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ការធ្វើឲ្យប្រសើរនូវបរិយាកាសអាជីវកម្ម និង ការបង្កើតបរិស្ថានងាយស្រួលសម្រាប់ការអភិវឌ្ឍវិស័យឯកជនជាបុព្វលក្ខខណ្ឌ ដើម្បីជំរុញកំណើន បង្កើតការងារ កាត់បន្ថយភាពក្រីក្រ និងសម្រេចបានការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព ដូចមានចែងក្នុងផ្នែក វិស័យឯកជន ការអភិវឌ្ឍ និង ការងារ នៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០០៩-២០១៣។ ដើម្បីឈានទៅរកការអភិវឌ្ឍវិស័យឯកជន និងភាពមានការងារធ្វើ រដ្ឋាភិបាលបានកំណត់នូវអាទិភាពខាងគោលនយោបាយដូចតទៅ៖ (១) ពង្រីកវិស័យឯកជន និងទាក់ទាញការវិនិយោគ (២) បង្កើតការងារ និងធានានូវលក្ខខណ្ឌការងារកាន់តែប្រសើរឡើងសម្រាប់និយោជិត (៣) ជំរុញសហគ្រាសខ្នាតតូចនិងមធ្យម និង (៤) បង្កើតសំណាញ់សុវត្ថិភាពសង្គម។ អាទិភាពគោលនយោបាយចម្បងៗ បី ក្នុងចំណោមអាទិភាពទាំងបួន ខាងលើ មានអធិប្បាយដូចខាងក្រោម៖

**ការបង្កើតការងារ និងធានានូវលក្ខខណ្ឌការងារកាន់តែប្រសើរឡើង រួមមាន៖**

- ការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវស្តង់ដារ និងបទដ្ឋានកម្លាំងពលកម្ម ច្បាប់ការងារ និងអនុសញ្ញាអន្តរជាតិ
- ការបន្តគម្រោង "រោងចក្រកាន់តែប្រសើរ"
- ការសម្របសម្រួលការស្វែងរកការងារនៅបរទេស
- ការកសាងសមត្ថភាព តាមរយៈការបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្លើយតបនឹងតម្រូវការទីផ្សារ ដោយផ្តោតជាក់លាក់ទៅលើ នារី ជនពិការ កុមារដែលបោះបង់ការសិក្សានៅថ្នាក់អនុវិទ្យាល័យ និងវិទ្យាល័យ ក្រុមមនុស្សគ្មានសិទ្ធិអំណាច និង ជនជាតិភាគតិច
- ការអភិវឌ្ឍប្រព័ន្ធស្ថិតិទីផ្សារកម្លាំងពលកម្ម និងស្តង់ដារលក្ខណៈសម្បត្តិជាតិ
- ការដាក់ចេញនូវយុទ្ធនាការឃោសនាផ្សព្វផ្សាយជាសាធារណៈ ពីតម្រូវការទីផ្សារពលកម្ម ដើម្បីជួយដល់ចលនាពលកម្ម និង
- ការពង្រឹងយន្តការដោះស្រាយទំនាស់ការងារដែលមានស្រាប់ ដូចជា ក្រុមប្រឹក្សាអាជ្ញាកណ្តាល និងគណៈកម្មការដោះស្រាយបញ្ហាបាតុកម្ម និងកូដកម្ម នៅគ្រប់កម្រិត។

សម្រាប់សកម្មភាពដែលគ្រោងឡើងដើម្បីអនុវត្តគោលនយោបាយការងារជាអាទិភាព និងធានានូវលក្ខខណ្ឌការងារល្អ សុវត្ថិភាព និង ភាពយុត្តិធម៌ MoLVT បាននិងកំពុងអនុវត្តសកម្មភាពរៀបចំកម្រិតអប្បរមានៃថ្ងៃឈប់សម្រាក និងប្រាក់បៀវត្សរ៍ប្រចាំខែ កាត់បន្ថយវិសមភាពបៀវត្សរ៍រវាងបុរសនិងនារី និង ដោះស្រាយទំនាស់ដោយសន្តិភាពនិងមិនមានការបាត់បង់ផលិតភាពនិងបៀវត្សរ៍និយោជិត។ ក្រសួងបានខិតខំផងដែរ ជំរុញសមភាពយេនឌ័រក្នុងកម្លាំងពលកម្ម និងដំណើរការកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈរយៈពេលខ្លី និងវែង ដើម្បីបង្កើតឱកាសការងារសមស្របក្នុងវិស័យផ្លូវការនិងក្រៅផ្លូវការ កាត់បន្ថយភាពគ្មានការងារធ្វើ និង ផ្តល់ការអប់រំនិងជំនាញដល់បុរសនារី ដើម្បីរៀបចំពួកគេឲ្យបានស្របតាមតម្រូវការទីផ្សារពលកម្ម។ ក្រៅពីនេះ ក្រសួង

បានបង្កើតប្រព័ន្ធអប់រំបច្ចេកទេសនិងវិជ្ជាជីវៈសម្រាប់ទាំងបុរសនិងនារី និងប្រព័ន្ធទិន្នន័យស្ថិតិបែងចែកតាមភេទ ព្រមទាំងដោះស្រាយបញ្ហាវិសមភាពប្រាក់កម្រៃរវាងបុរសនិងនារី ក៏ដូចជាពង្រឹងច្បាប់ការងារ និងច្បាប់ស្តីពីសន្តិសុខសង្គម (RGC 2010)។ លើសពីនេះទៀត នៅឆ្នាំ២០០៩ ទីភ្នាក់ងារការងារជាតិកម្ពុជា ត្រូវបានបង្កើតឡើងទុកជាទីភ្នាក់ងារប្រតិបត្តិការពិសេសមួយ ដើម្បីជួយសម្រួលដល់ការគ្រប់គ្រង ព្រមទាំងផ្តល់ព័ត៌មានពីទីផ្សារពលកម្មក្នុងប្រទេស និងព័ត៌មានទីផ្សារពលកម្មជាក់លាក់ ដើម្បីជួយដល់រដ្ឋាភិបាលក្នុងការបង្កើតផែនការអភិវឌ្ឍន៍ធនធានមនុស្ស និងផែនការទីផ្សារពលកម្មសមស្របនានា (RGC 2009)។

### ការជំរុញសហគ្រាសខ្នាតតូច និងមធ្យម

សម្រាប់ការពង្រីកឱកាសការងារ តាមរយៈការជំរុញសហគ្រាសខ្នាតតូច និងមធ្យម រដ្ឋាភិបាល បានសម្រួលដំណើរការចុះឈ្មោះសហគ្រាសខ្នាតតូច និងមធ្យម (SMEs) ដោយបានកាត់បន្ថយតម្រូវការ និងតម្លៃនៃការចុះឈ្មោះរបស់ក្រុមហ៊ុន។ រដ្ឋាភិបាលក៏បានផ្តល់អាទិភាពដល់ការធ្វើឲ្យប្រសើរឡើងនូវបរិយាកាសជំនួញសម្រាប់ SMEs ដោយផ្តោតលើទិដ្ឋភាពបួនៈ ក្របខ័ណ្ឌស្របច្បាប់ ហិរញ្ញវត្ថុ សកម្មភាពគាំទ្រ និង ការដាក់បញ្ចូល SMEs ទៅក្នុងចង្វាក់តម្លៃសាកល និងបង្ការនូវការគេចពន្ធគ្រប់ប្រភេទ។ ក្នុងពេលជាមួយគ្នា រដ្ឋាភិបាលបានជំរុញចលនាភូមិមួយផលិតផលមួយនៅតំបន់ជនបទ និងការបណ្តុះបណ្តាលបច្ចេកទេសសម្រាប់ផលិតផលពិសេសក្នុងតំបន់ខ្លះ ដើម្បីពង្រឹងគុណភាព និងពង្រីកទីផ្សារ (RGC 2010)។

ទាក់ទងនឹងការពង្រីកឱកាសការងារ ស្រដៀងគ្នានឹងកម្មវិធីបណ្តុះបណ្តាលរបស់ MoLVT ស្តីពីភាពរួចរាល់នៃទីផ្សារកម្លាំងពលកម្មនោះដែរ ផែនការយុទ្ធសាស្ត្រនារីរតនៈ ២និង៣[៣] របស់ក្រសួងកិច្ចការនារី (MoWA) ផ្តោតលើការជំរុញការចូលរួមរបស់នារីនៅក្នុងការអភិវឌ្ឍសេដ្ឋកិច្ច ជាពិសេសនៅក្នុងសហគ្រាសខ្នាតតូច និងមធ្យម ដើម្បីកសាងសមត្ថភាព និងពង្រឹងអំណាចនារីក្នុងការចូលរួមសកម្មក្នុងទីផ្សារពលកម្មឆ្ពោះទៅរកកំណើនមានការរាប់បញ្ចូល (MoWA 2004)។ ដើម្បីសម្រេចគោលដៅនេះ MoWA (ជាមួយនឹងដៃគូអភិវឌ្ឍន៍សំខាន់ៗ) បានបង្កើតមជ្ឈមណ្ឌលអភិវឌ្ឍន៍នារី (WDCs) ១១កន្លែង នៅតាមខេត្តនានា ដើម្បីផ្តល់ការអប់រំនិងការបណ្តុះបណ្តាលជំនាញ សេវាអភិវឌ្ឍន៍សហគ្រាស និង សកម្មភាពពង្រឹងអំណាចវប្បធម៌-សង្គមកិច្ចឲ្យនារី។ WDCs ភាគច្រើនស្ថិតនៅតាមតំបន់ជនបទ ហើយដោះស្រាយលើបញ្ហាជំនាញ និងការអប់រំកម្រិតទាប ដោយមានផ្តល់នូវកញ្ចប់បណ្តុះបណ្តាលផ្សេងៗ ដែលពឹងផ្អែកលើធនធានអាចរកបាន។ ការបណ្តុះបណ្តាលជំនាញសម្រាប់នារីនៅជនបទ មានដូចជា ដេរប៉ាក់ សំអាងការ និងការតុបតែងសក់ តម្បាញ និង ការកែច្នៃម្ហូប (Sok 2011)។ ទោះយ៉ាងនេះក្តី WDCs បានជួបបញ្ហាប្រឈមជាច្រើន ដូចជា ការបង្កើតតុល្យភាព និងការបំពេញតាមតម្រូវការទីផ្សារមូលដ្ឋាន ការជ្រើសរើសជំនាញ ការធានានូវធនធានហិរញ្ញវត្ថុសម្រាប់ឲ្យអ្នកហាត់រៀនយកជំនាញខ្លួនទៅអនុវត្តក្រោយបញ្ចប់វគ្គ។ ចំណុចចុងក្រោយនេះ ពិតជាមានផលប៉ះពាល់ទៅលើការអនុវត្តជំនាញរបស់ពួកគេ។ ទាក់ទងនឹងលទ្ធភាព និងធនធានហិរញ្ញវត្ថុរបស់ WDCs មិនមានថវិកាអ្វីសម្រាប់បែងចែកទៅលើការតាមដានការអនុវត្តជាក់ស្តែង និងសម្រាប់ជួយទ្រទ្រង់ផ្នែកបច្ចេកទេសក្រោយពេលអ្នកហាត់រៀនបានបញ្ចប់វគ្គសិក្សានោះទេ។

---

៣ នារីរតនៈ ២ ឆ្នាំ២០០៤-២០០៨ និង នារីរតនៈ ៣ ឆ្នាំ២០០៩-២០១៣។

**ការបង្កើតសំណាញ់សុវត្ថិភាពសង្គម**

ដើម្បីបន្តអនុវត្តគោលនយោបាយសុវត្ថិភាពសង្គម រដ្ឋាភិបាលបានផ្តល់អាទិភាពលើការកែលម្អលក្ខខណ្ឌការងារសម្រាប់និយោជិត ការពង្រឹងច្បាប់សន្តិសុខសង្គម ការអនុវត្តគម្រោងអត្ថប្រយោជន៍ និង សោធននិវត្តន៍សម្រាប់ជនពិការនិងសមាជិកគ្រួសារក្នុងបន្ទុករបស់ពួកគេ ការការពារអ្នកស្ថិតនៅក្រោមច្បាប់ការងារ និង ការបង្កើតធានារ៉ាប់រងលើគ្រោះថ្នាក់នៅពេលធ្វើការសម្រាប់និយោជិត។ នៅកម្ពុជា កម្មវិធីការការពារសង្គមនានា គឺរដ្ឋាភិបាលជាអ្នកផ្តល់ជាចម្បង។ ក្នុងករណីខ្លះ NGOs និង វិស័យឯកជន ក៏បានចូលរួមចំណែកសំខាន់ក្នុងការការពារសង្គមផងដែរ។ MoLVT និង MEF ទទួលខុសត្រូវលើការគ្រប់គ្រងមូលនិធិជាតិសុវត្ថិភាពសង្គម (NSSF) ដែលគ្របដណ្តប់លើអ្នកធ្វើការក្នុងវិស័យឯកជន។ NSSF បានដំណើរការចាប់ពីឆ្នាំ២០០៧ មក ដោយផ្តល់ជូនអ្នកធ្វើការនូវ៖ (១) គម្រោងស្តីពីការរងរបួសក្នុងពេលបំពេញការងារ (សំណង) (២) គម្រោងធានារ៉ាប់រងសុខភាព និង (៣) គម្រោងសោធននិវត្តន៍។ ត្រឹមចុងឆ្នាំ២០០៩ NSSF បានចុះឈ្មោះ ៨៨៤ សហគ្រាស ដែលមានបុគ្គលិក ៣៤០.៨៤០នាក់ ឬស្មើនឹង ៨៨% នៃកម្លាំងពលកម្មសរុប (MoLVT 2010 cited in Kem 2011)។ NSSF គ្របដណ្តប់តែលើសហគ្រាសដែលបានចុះឈ្មោះប៉ុណ្ណោះ ហើយមិនទទួលខុសត្រូវលើក្រុមណាដែលមិនបានចុះឈ្មោះឡើយ។

ដោយមិនមានក្របខ័ណ្ឌច្បាប់រឹងមាំ ក៏ដូចជាយន្តការ បទបញ្ញត្តិ និងសេវាជួយទ្រទ្រង់សុវត្ថិភាពដល់ការធ្វើចំណាកស្រុកនោះ នៅខែកក្កដា ឆ្នាំ២០០៥ MoLVT បានចុះហត្ថលេខាលើអនុស្សារណៈព្រមព្រៀង (MOU) មួយ ជាមួយនឹងមូលនិធិអភិវឌ្ឍន៍សហប្រជាជាតិសម្រាប់នារី (UNIFEM) ដើម្បីការពារសិទ្ធិពលការិនីចំណាកស្រុកកម្ពុជា ប្រឆាំងនឹងការកេងប្រវ័ញ្ច អំពើហិង្សា និង ការជួញដូរ ពីព្រោះពលការិនីចំណាកស្រុកកម្ពុជា ជាក្រុមងាយរងគ្រោះខ្លាំងដោយការអនុវត្តមិនស្មើភាពផ្នែកកម្លាំងពលកម្ម។ ក្រោមអនុស្សារណៈនេះ MoLVT និង UNIFEM សហការជាមួយរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល ដើម្បីបញ្ជ្រាបក្តីបារម្ភផ្នែកយេនឌ័រទៅក្នុងគោលនយោបាយ និងច្បាប់ទាក់ទងនឹងពលករចំណាកស្រុក។ សកម្មភាពយុទ្ធសាស្ត្រជាអាទិភាពមួយចំនួនដែលបានអនុវត្ត មានដូចតទៅ៖

- ការបង្កើត និងពង្រឹងគណៈកម្មការជាតិពាក់ព័ន្ធច្រើនវិស័យមួយ ដើម្បីសម្របសម្រួលផែនការសកម្មភាពជាតិ ស្តីពីការធ្វើចំណាកស្រុក
- ការបង្កើតកម្មវិធីបណ្តុះបណ្តាលមុនពេលចេញដំណើរសម្រាប់ពលការិនីចំណាកស្រុក
- ការប្រមូលនិងវិភាគទិន្នន័យ និងព័ត៌មាន ស្តីពីការធ្វើចំណាកស្រុករបស់នារី (MoWA 2008)

អ្នកធ្វើការក្នុងវិស័យក្រៅផ្លូវការ ទំនងងាយរងគ្រោះបំផុត ពីព្រោះមិនស្ថិតនៅក្រោមច្បាប់ការងាររបស់កម្ពុជា ដូច្នេះហើយក៏មិនអាចពឹងផ្អែកលើច្បាប់សន្តិសុខសង្គម ស្តីពីអត្ថប្រយោជន៍និងការការពារនោះទេ។ មាត្រា ១ នៃច្បាប់សន្តិសុខសង្គម បានចែងច្បាស់ថា ច្បាប់មានគោលបំណងបង្កើតសន្តិសុខសម្រាប់អ្នកដែលគ្រប់គ្រងដោយច្បាប់ការងារ។ ដូច្នេះ អ្នកធ្វើការក្រៅផ្លូវការ មិនអាចទទួលបាននូវសោធននិវត្តន៍ អត្ថប្រយោជន៍សម្រាប់ពេលឈឺថ្កាត់ និងការការពារលើហានិភ័យនៃការងារ ដូចជា គ្រោះថ្នាក់ និងការខូចសុខភាព ជាដើម។ ប៉ុន្តែអ្នកធ្វើការក្នុង

វិស័យក្រៅផ្លូវការ ប្រហែលមិនបានបាត់បង់អត្ថប្រយោជន៍ច្រើនទេ បើធៀបនឹងវិស័យផ្លូវការ ព្រោះច្បាប់សន្តិសុខសង្គមរបស់កម្ពុជានៅត្រូវការការពង្រឹងអនុវត្តន៍នៅឡើយ (ILO 2006)។

## ៥. សេចក្តីសន្និដ្ឋាន និង អនុសាសន៍

ផ្អែកតាមការវិភាគក្នុងការសិក្សានេះ កិច្ចខិតខំប្រឹងប្រែងរបស់រដ្ឋាភិបាលក្នុងការជំរុញសមភាពយេនឌ័រនៅក្នុងផ្នែកអប់រំ គួរតែអនុវត្តឲ្យបានកាន់តែរហ័ស។ ទន្ទឹមគ្នានេះ រដ្ឋាភិបាលគួរបន្តធ្វើពិពិធកម្មកម្មវិធីបណ្តុះបណ្តាល ដែលជួយឲ្យនារីកាន់តែច្រើនឡើងអាចចូលរួមក្នុងទីផ្សារការងារ ជាពិសេសក្នុងវិស័យផ្លូវការ និងគួរបង្កើតយន្តការ ដូចជា ក្របខ័ណ្ឌគោលនយោបាយ និងច្បាប់ ដើម្បីគាំទ្រកម្លាំងពលកម្មក្នុងវិស័យសេដ្ឋកិច្ចក្រៅផ្លូវការ។ ដើម្បីពង្រីកឱកាសការងារសម្រាប់នារីនៅក្នុងទីផ្សារការងារ តាមរយៈកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលបង្កើតឡើងដោយរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍នានានោះ ចាំបាច់ត្រូវគិតគូរពីកញ្ចប់ថវិកាគាំទ្រពេញលេញ ពិសេសការទ្រទ្រង់ផ្នែកបច្ចេកទេសបន្ទាប់ពីបញ្ចប់ការបណ្តុះបណ្តាល និងការផ្សារភ្ជាប់ទៅនឹងទីផ្សារ។

## គន្ថនិទ្ទេស


Hing Vutha, Lun Pide & Phann Dalis (2011), "Irregular Migration from Cambodia: Characteristics, Challenges and Regulatory Approach "(Phnom Penh: CDRI)

http://www.betterfactories.org/content/documents/Industry%20Data%20Sheet%20 2011_March2011%20%28EN%29.pdf

International Labour Organisation (2002), "Decent Work: Concepts, Models, and Indicators", discussion paper (Geneva: ILO)

International Labour Organisation (2006), *Handbook on Decent Work in the Informal Economy in Cambodia* http://ifwea-org-bin.directo.fi/@Bin/cae83cbe0c1a1000452b75d68692291c/1319084635/application/pdf/148881/2006Cambodia.pdf (accessed 15 September 2011)

Japan International Cooperation Agency (2007), "Cambodia: Country Gender Profile" (Phnom Penh: JICA)

Kem Sothorn (2010),"Policy Options for Vulnerable Groups: Income Growth and Social Protection" *Annual Development Review 2010-2011* (Phnom Penh: CDRI) pp. 105-125

Ministry of Planning (2007), "Achieving the Cambodia Millennium Development Goals 2005 Update" (Phnom Penh: MoP)

Ministry of Women's Affairs (2009), "Five Year Strategic Plan 2009-2013" (Phnom Penh: MoWA)

Ministry of Women's Affairs (2008), "A Fair Share for Women: Cambodia Gender Assessment" (Phnom Penh: MoWA)

National Institute of Statistics (2009a), *General Population Census of Cambodia 2008* (Phnom Penh: NIS/MoP)

National Institute of Statistics (2009b), *Nation-wide Establishment Listing 2009* (Phnom Penh: NIS/MoP)

National Institute of Statistics (2010), *Cambodia Socio-Economic Survey 2009* (Phnom Penh: NIS/MoP)

Royal Government of Cambodia (2009), Sub-decree on the Establishment and Functioning of the National Employment Agency (Phnom Penh: RGC)

Royal Government of Cambodia (2010) National Strategic Development Plan Update 2009-2013 (Phnom Penh: RGC)

Sok Somith (2011), "Study on the Employability of Rural Women Training Participants in Women's Development Centres" (Phnom Penh: MoWA, ILO, and Better factories Cambodia)

World Bank (2010), "Providing Skills for Equity and Growth: Preparing Cambodia's Youth for the Labour Market" (Washington, DC: World Bank)

# បញ្ជីឯកសារបោះពុម្ពផ្សាយរបស់វិទ្យាស្ថាន វបសអ


១. Kannan, K. P. (វិច្ឆិកា ១៩៩៥) *ការកសាងសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់សំរាប់ប្រទេសកម្ពុជា៖ ការពិនិត្យឡើងវិញលើការអនុវត្តន៍នាពេលបច្ចុប្បន្ន និងការលើកមតិកែលំអ* (ឯកសារពិភាក្សា លេខ ១)។

២. McAndrew, John P. (មករា ១៩៩៦) *ជំនួយហូរចូលជំនួយស្រពិចស្រពិល៖ ជំនួយសង្គ្រោះ និងអភិវឌ្ឍន៍ទ្វេ និងពហុភាគី ១៩៩២-៩៥* (ឯកសារពិភាក្សាលេខ ២)។

៣. Kannan, K. P. (មករា ១៩៩៧) *កំណែទំរង់សេដ្ឋកិច្ច កំណែតម្រូវរចនាសម្ព័ន្ធនិងការអភិវឌ្ឍន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៣)។

៤. ជឹម-ចរិយា ស្រ៊ុន-ពិធូ សូ-សុវណ្ណារិទ្ធ ចន-ម៉ាកយិនឌ្យូ ងួន-សុគន្ធា ប៉ុន-ដូរីណា និងរ៉ូប៊ីន-ប៊ីដឺលវ៍ (មិថុនា ១៩៩៨) *ការរៀនសូត្រពីកម្មវិធីអភិវឌ្ឍន៍ជនបទក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៤) ជាភាសាខ្មែរ តម្លៃ ៩.០០០រៀល ។

៥. Toshiyasu-Kato ច័ន្ទ-សុផល និង ឡុង-វូ-ពិសិដ្ឋ (កញ្ញា ១៩៩៨) *សមាហរណកម្មសេដ្ឋកិច្ចតំបន់សំរាប់ការ អភិវឌ្ឍន៍ជានិរន្តរ៍ក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ៥) ជាភាសាខ្មែរ តម្លៃ ៩.០០០រៀល។

៦. Murshid, K. A. S. (ធ្នូ ១៩៩៨) *សន្តិសុខស្បៀងនៅក្នុងសេដ្ឋកិច្ចអន្តរៈអាស៊ី៖ បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ៦) ជាភាសាខ្មែរ តម្លៃ ៧.៥០០រៀល។

៧. McAndrew, John P. (ធ្នូ ១៩៩៨) *ការពឹងពាក់គ្នាទៅវិញទៅមកក្នុងយុទ្ធសាស្ត្រចិញ្ចឹមជីវិតគ្រួសារនៅក្នុង ភូមិខ្មែរពីរ* (ឯកសារពិភាក្សាលេខ ៧) ជាភាសាខ្មែរ តម្លៃ ៧.៥០០រៀល។

៨. ច័ន្ទ-សុផល Martin-Godfrey, Toshiyasu-Kato, ឡុង-វូ-ពិសិដ្ឋ Nina-Orlova, Per-Ronnås ទា-សាវ៉ា (មករា ១៩៩៩) *ប្រទេសកម្ពុជា៖ បញ្ហាប្រឈមមុខនៃការបង្កើតការងារដែលមានផលិតភាព* (ឯកសារពិភាក្សាលេខ ៨) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល។

៩. តេង-យូគី ប៉ុន-ដូរីណា សូ-សុវណ្ណារិទ្ធ និង ចន-ម៉ាកយិន RDU (មេសា ១៩៩៩) *បទពិសោធន៍របស់សកម្មភាព សហគមន៍ដើម្បីអភិវឌ្ឍន៍សង្គមនៃអង្គការយូនីសេហ្វ* (ឯកសារពិភាក្សាលេខ ៩) ជាភាសាខ្មែរ តម្លៃ ៤.៥០០រៀល។

១០. Gormna, Siobham, ជាមួយ ប៉ុន-ដូរីណា និង សុខ-ខេង (មិថុនា ១៩៩៩) *បញ្ហាតួនាទីបុរស-ស្ត្រី និងការ អភិវឌ្ឍន៍នៅប្រទេសកម្ពុជា៖ ការពិនិត្យមើលជាទូទៅ* (ឯកសារពិភាក្សាលេខ ១០) ជាភាសាខ្មែរ តម្លៃ ៤.៥០០រៀល។

១១. ច័ន្ទ-សុផល និងសូ-សុវណ្ណារិទ្ធ (មិថុនា ១៩៩៩) *ចំណាកពលកម្មកម្ពុជាទៅប្រទេសថៃ៖ ការប៉ាន់ស្មានជំហានដំបូង* (ឯកសារពិគ្រោះលេខ ១១) ភាសាខ្មែរ តម្លៃ ៣.០០០រៀល។

១២. ច័ន្ទ-សុផល Toshiyasu Kato ឡុង-វូពិសិដ្ឋ ទា-សាវ៉ា សូ-សុវណ្ណារិទ្ធ ហង់-ជួនណារ៉ុន កៅ-គឹមហួន និង ជា-វុធណា (តុលា ១៩៩៩) *ផលប៉ះពាល់នៃវិបត្តិហិរញ្ញវត្ថុអាស៊ីលើសេដ្ឋកិច្ចអន្តរកាលនៅបណ្តាប្រទេស អាស៊ីអគ្នេយ៍៖ ទស្សនៈកម្ពុជា* (ឯកសារពិគ្រោះលេខ ១២) ជាភាសាខ្មែរ តម្លៃ ៤.៥០០រៀល។

១៣. អ៊ុង-ប៊ុនឡេង (សីហា ២០០០) *ការប្រែប្រួលតាមរដូវកាលនៃសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសកម្ពុជា* (ឯកសារពិភាក្សាលេខ ១៣) ជាភាសាខ្មែរ តម្លៃ ៣.០០០រៀល។

១៤. Toshiyasu-Kato, Jeffrey A. Kaplan, ច័ន្ទ-សុផល និង រៀល-សុភាព (សីហា ២០០០) *ប្រទេសកម្ពុជា៖ លើកកំពស់អភិបាលកិច្ចសំរាប់ការអភិវឌ្ឍន៍មាននិរន្តរភាព* (ឯកសារពិភាក្សាលេខ ១៤) ជាភាសាខ្មែរ តម្លៃ ៣.០០០រៀល។

១៥. Toshiyasu Kato ច័ន្ទ-សុផល Jeffrey A. Kaplan, (សីហា ២០០០) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍ សមត្ថភាពនៅក្នុងសេដ្ឋកិច្ចមួយដែលពឹងផ្អែកលើជំនួយ៖ បទពិសោធន៍កម្ពុជា* (ឯកសារពិភាក្សាលេខ ១៥) ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល។

១៦. ស៊ិក បូរ៉ាក្ស (ធ្នូ ២០០០) *កម្មសិទ្ធិ ការលក់ដូរ និងការប្រមូលផ្ដុំដីធ្លីនៅកម្ពុជា៖ ការពិនិត្យវិភាគដោយគ្រួសៗនូវទិន្នន័យទីពីរ និងទិន្នន័យដើម ដែលបានមកពីអង្កេតថ្មីៗចំនួនបួន* (ឯកសារពិភាក្សាលេខ ១៦) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

១៧. ច័ន្ទ-សុផល សូ-សុវណ្ណារិទ្ធ និងប៊ុន-ដូរីណា (មិថុនា ២០០១) *ជំនួយបច្ចេកទេស និងការអភិវឌ្ឍន៍សមត្ថភាព នៅសាលាកសិកម្មព្រែកលៀប* (ឯកសារពិភាក្សាលេខ ១៧) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ។

១៨. Martin Godfrey, សូ-សុវណ្ណារិទ្ធ ទេព-សាវ៉ារី ប៊ុន-ដូរីណា Claude-Katz, Sarthi-Acharya, ស៊ីសុវត្ថិ-ឌួង-ចាន់តូ និងហ៊ីង ថូរ៉ាក់ស៊ី (តុលា ២០០១) *ការសិក្សាអំពីទីផ្សារពលកម្មនៅកម្ពុជា៖ ការកាត់បន្ថយភាពក្រីក្រ ការលូតលាស់ និងការកែតំរូវចំពោះវិបត្តិ* (ឯកសារពិភាក្សាលេខ១៨) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

១៩. ច័ន្ទ-សុផល ទេព-សាវ៉ារី និង Sarthi Acharya, (ធ្នូ ២០០១) *ការកាន់កាប់ដីនៅកម្ពុជា៖ ការវិភាគលើទិន្នន័យចុងក្រោយ* (ឯកសារពិភាក្សាលេខ ១៩) ភាសាខ្មែរ តម្លៃ ៨.០០០រ។

២០. សូ-សុវណ្ណារិទ្ធ រៀល-សុភាព អ៊ុច-ឧទេយ្យ ស៊ី-រត្នមុនី, Brett Ballard និង Sarthi Acharya (មីនា ២០០២) *ការវាយតំលៃសង្គមពាក់ព័ន្ធនឹងដីធ្លីនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ២០) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

២១. Bhargavi Ramamurthy ស៊ិក-បូរ៉ាក្ស, Per Ronnås និង សុក-ហាច (មីនា ២០០២) ប្រទេសកម្ពុជាឆ្នាំ១៩៩៩-២០០០៖ *ការផ្ដោតលើបញ្ហាដីធ្លី កំលាំងពលកម្ម និងការចិញ្ចឹមជីវិតនៅជនបទ* (ឯកសារពិភាក្សាលេខ ២១)តម្លៃ ៨.០០០រៀល។

២២. ច័ន្ទ-សុផល និង Sarthi Acharya (កក្កដា ២០០២) *ការលក់ដូរដីធ្លីនៅកម្ពុជា៖ ការវិភាគទិន្នន័យនៃការផ្ទេរ និងការលក់ដូរដីធ្លី* (ឯកសារពិភាក្សាលេខ ២២) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ។

២៣. Bruce McKenney និង ព្រុំ-តុលា (កញ្ញា ២០០២) *ធនធានធម្មជាតិ និងជីវភាពនៅតាមជនបទក្នុងប្រទេសកម្ពុជា៖ ការវាយតំលៃជាមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៣) ជាភាសាខ្មែរ តម្លៃ ១០.០០០រៀល ជាអង់គ្លេស ១០.០០ដុល្លារ។

២៤. ច័ន្ទ-សុផល គឹម-សេតារា និង Sarthi Acharya (ធ្នូ ២០០២) *ដីធ្លី ជីវភាពជនបទ និងសន្តិសុខស្បៀងនៅកម្ពុជា៖ ទស្សនៈបានពីអង្កេតតាមមូលដ្ឋាន* (ឯកសារពិភាក្សាលេខ ២៤) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាអង់គ្លេស តម្លៃ ៧.០០ដុល្លារ ។

២៥. ច័ន្ទ-សុផល និង Sarthi Acharya (ធ្នូ ២០០២) *បញ្ហាប្រឈមចំពោះការចិញ្ចឹមជីវិតនៅជនបទ៖ ការសិក្សា លើភូមិចំនួន ៩ នៅកម្ពុជា* (ឯកសារពិភាក្សា លេខ២៥) ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ១០.០០ដុល្លារ។

២៦. Sarthi Acharya គឹម-សេតារា ចាប-សុថារិទ្ធ និង មាច-យ៉ាឌី (កញ្ញា ២០០៣) *ការងារក្រៅកសិដ្ឋាន និងការងារមិនមែនកសិកម្ម៖ ទស្សនៈស្តីពីការបង្កើតការងារនៅកម្ពុជា* (ឯកសារពិភាក្សាលេខ២៦) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៥,០០ដុល្លារ។

២៧. យឹម-ជា និង Bruce McKenney (ធ្នូ ២០០៣) *ការនាំចេញត្រីពីបឹងទន្លេសាបទៅប្រទេសថៃ៖ ការវិភាគលើការរាំងស្ទះពាណិជ្ជកម្ម អភិបាលកិច្ច និងបរិយាកាសសំរាប់ការលូតលាស់* (ឯកសារពិភាក្សាលេខ២៧) ជាភាសាខ្មែរ តម្លៃ ៧.០០០រៀល ជាភាសាអង់គ្លេស ១០,០០ដុល្លារ។

២៨. ព្រុំ-តុលា និង Bruce McKenney (ធ្នូ ២០០៣) *ការធ្វើពាណិជ្ជកម្មផលព្រៃឈើនៅកម្ពុជា៖ ការប្រឈម ការគំរាមកំហែង និងឱកាសសំរាប់ពាណិជ្ជកម្មជ័រទឹក* (ឯកសារពិភាក្សាលេខ២៨) ជាភាសាខ្មែរ ៧.០០០រៀល ជាភាសាអង់គ្លេស ១០,០០ដុល្លារ។

២៩. យឹម-ជា និង Bruce McKenney (វិច្ឆិកា ២០០៣) *ពាណិជ្ជកម្មត្រីក្នុងស្រុក៖ ករណីសិក្សានៃម៉ាឃីទីងត្រីពីបឹង ទន្លេសាបទៅក្រុងភ្នំពេញ* (ឯកសារពិភាក្សាលេខ២៩) ជាភាសាខ្មែរ ៥.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ។

៣០. Caroline Hughes និង គឹម-សេតារា (មិថុនា ២០០៤) *ការវិវត្តន៍នៃដំណើរការប្រជាធិបតេយ្យ និងការគ្រប់គ្រង ទំនាស់នៅកម្ពុជា៖ ការសិក្សាប្រៀបធៀបការបោះឆ្នោតបីលើកនៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៣០) ជាភាសាខ្មែរ ១០.០០០រៀល ជាភាសាអង់គ្លេស ១៣,៥០ដុល្លារ។

៣១. Robert Oberndorf (កក្កដា ២០០៤) *សុខដុមនីយកម្មច្បាប់ទាក់ទងនឹងដំណើរការវិមជ្ឈការនៅកម្ពុជា* (ឯកសារពិភាក្សាលេខ៣១) ជាភាសាខ្មែរ ៥.០០០រៀល ជាភាសាអង់គ្លេស ៦,៥០ដុល្លារ ។

៣២. K. A. S. Murshid និង ទូត-សុខផល្លី (ឧសភា ២០០៥) *សេដ្ឋកិច្ចឆ្លងកាត់ព្រំដែនរបស់ប្រទេសកម្ពុជា៖ ការសិក្សាជំហានដំបូង* (ឯកសារពិភាក្សាលេខ៣២) ជាភាសាខ្មែរ ៨.០០០រៀល ជាភាសាអង់គ្លេស ៥,០០ដុល្លារ។

៣៣. Hansen, Kasper K. និង តុប-នេត (ធ្នូ ២០០៦) *Natural Forest Benefits and Economic Analysis of Natural Forest Conversion in Cambodia* (Working Paper No. 33)។

៣៤. ប៉ក់-គឹមជឿន ហ៊ង-វុទ្ធី អេង-នេត្រា អាន-សុវត្ថា គឹម-សេតារា, Jenney Knowles និង David Craig (មីនា ២០០៧) *Accountability and Neo-patrimonialism in Cambodia: A Critical Literature Review* (ឯកសារពិភាក្សាលេខ៣៤) ជាអង់គ្លេស ៦,០០ដុល្លារ។

៣៥. គឹម-សេតារា និង Joakim Öjendal ( ឧសភា ២០០៧ ) *Where Decentralisation Meets Democracy: Civil Society, Local Government, and Accountability in Cambodia* ( ឯកសារពិភាក្សាលេខ៣៥ ) ជាភាសាអង់គ្លេស ៤,00ដុល្លារ ។

៣៦. លឹម-សុវណ្ណារា (វិច្ឆិកា ២០០៧) *Youth Migration and Urbanistion in Cambodia* ( ឯកសារពិភាក្សាលេខ ៣៦ ) ជាភាសាខ្មែរ ៦.០០០រៀល ជាអង់គ្លេស ៣,៥0ដុល្លារ ។

៣៧. Chem Phalla et al. ( May 2008 ), *Framing Research on Water Resources Management and Governance in Cambodia: A Literature Review*។

៣៨. Pak Kimchoeun and David Craig, *Accountability and Public Expenditure Management in Decentralised Cambodia* ( Working Paper No. 38 )។

៣៩. Horng Vuthy and David Craig, *Accountability and Planning in Decentralised Cambodia* ( Working Paper No. 39 )។

៤០. Eng Netra and David Craig ( forthcoming ), *Accountability and Human Resource Management in Decentralised Cambodia* ( Working Paper No. 40 )។

៤១. ហ៊ីងវុត្ថា និង Hossein Jalilian ( មេសា ២០០៩ ) *ផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ចំពោះបរិស្ថាន នៅតាមបណ្ដាប្រទេសក្នុងមហាអនុតំបន់មេគង្គ (ឯកសារពិភាក្សាលេខ ៤១)* ជាភាសាខ្មែរ តម្លៃ ៨.០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៣,០០ដុល្លារ។

៤២. Thon Vimealea, Ou Sivhuoch, Eng Netra and Ly Tem ( October 2009 ), *Leadership in Local Politics of Cambodia: A Study of Leaders in Three Communes of Three Provinces*។

៤៣. ហ៊ីងវុត្ថា និង បណ្ឌិត ធន់វឌ្ឍនា ( ធ្នូ ២០០៩ ) *ពាណិជ្ជកម្មកសិកម្មក្នុងមហាអនុតំបន់មេគង្គ៖ ករណីដំឡូងឈើ និងកៅស៊ូ នៅកម្ពុជា* (ឯកសារពិភាក្សាលេខ ៤៣) ជាភាសាខ្មែរ តម្លៃ ៦.០០០រៀល ជាភាសាអង់គ្លេស ៣,០០ដុល្លារ។

៤៤. ច័ន្ទ សុផល ( ធ្នូ ២០០៩ ) *ផលប្រយោជន៍និងចំណាយនៃទេសន្តរប្រវេសន៍កំលាំងពលកម្មក្នុងមហាអនុតំបន់មេគង្គ៖ ករណីសិក្សានៅប្រទេសកម្ពុជា* ជាភាសាខ្មែរតម្លៃ ៨,០០០រៀល ជាភាសាអង់គ្លេស តម្លៃ ៣.០០ដុល្លារ។

៤៥. CDRI Publication ( December 2009 ), *Costs and Benefits of Cross-country Labour Migration in the GMS: Synthesis of the Case Studies in Thailand, Cambodia, Laos and Vietnam*។

៤៦. CDRI Publication ( December 2009 ), *Agricultural Trade in the Greater Mekong Sub-region: Synthesis of the Case Studies on Cassava and Rubber Production and Trade in GMS Countries*។

៤៧. Chea Chou ( August 2010 ), *The Local Governance of Common Pool Resources: The Case of Irrigation Water in Cambodia*។

៤៨. CDRI Publication (August 2010), *Empirical Evidence of Irrigation Management in the Tonle Sap Basin: Issues and Challenges*។

៤៩. ចែម ផល្លា និងសុមេធ ប៉ារ៉ាឌី (មីនា ២០១១), *ការប្រើប្រាស់ចំណេះដឹងជលសាស្ត្រនៃអាងស្ទឹង និងការចូលរួមរបស់សហគមន៍ ដើម្បីលើកកម្ពស់ការធ្វើសេចក្តីសម្រេចចិត្តប្រកបដោយការចូលរួម ស្តីពីការបែងចែកទឹកសម្រាប់ស្រោចស្រព*។

៥០. ប៉ក់ គឹមជឿន (ឧសភា ២០១១) *វិមជ្ឈការហិរញ្ញវត្ថុនៅកម្ពុជា៖ ការងារសម្រេចបាន និងជំហានបន្ទាប់*។

៥១. Christopher Wokker, Paulo Santos, Ros Bansok and Kate Griffiths (June 2011), Irrigation Water Productivity in Cambodian Rice System។

៥២. អ៊ូច-ច័ន្ទតារ៉ានី សាំង-ច័ន្ទហង្ស និងផាន់-ដាលីស (មិថុនា ២០១១), *ការវាយតម្លៃផលប៉ះពាល់នៃប្រទេសចិន លើការកាត់បន្ថយភាពក្រីក្រនៅមហាអនុតំបន់ទន្លេមេគង្គ៖ ករណីសិក្សាប្រទេសកម្ពុជា*។

៥៣. Chann Sopheak, Nathan Wales and Tim Frewer (August 2011), An Investigation of Land Cover and Land Use Change in Stung Chrey Bak Catchment, Cambodia។

៥៤. ណាំង ភិរុណ ខៀវ ដារ៉ាវី Philip HIRSCH និង Isabelle WHITEHEAD (កក្កដា ២០១១) *លើកកម្ពស់អភិបាលកិច្ចធនធានទឹកនៅកម្ពុជា៖ ការវិភាគអ្នកពាក់ព័ន្ធ*។

៥៥. Kem Sothorn, Chhim Chhun, Theng Vuthy and So Sovannarith (July 2011), Policy Coherence in Agricultural and Rural Development: Cambodia។

៥៦. Tong Kimsun, Hem Socheth and Paulos Santos (July 2011), What Limits Agricultural Intensification in Cambodia? The role of emigration, agricultural extension services and credit constraints។

៥៧. Tong Kimsun, Hem Socheth and Paulos Santos (August 2011), The Impact of Irrigation on Household Assets។

៥៨. ហ៊ីង វុត្ថា លន់ ពិដេ និង ផាន់ ដាលីស (សីហា ២០០១) *ទេសន្តរប្រវេសន៍មិនស្របច្បាប់ពីកម្ពុជា*។

៥៩. Chem Phalla, Philip Hirsch and Someth Paradis (September 2011), Hydrological Analysis in Support of Irrigation Management: A Case Study of Stung Chrey Bak Catchment, Cambodia។

៦០. Saing Chan Hang, Hem Socheth and Ouch Chandarany with Phann Dalish and Pon Dorina (November 2011), Foreign Investment in Agriculture in Cambodia។

៦១. Ros Bandeth, Ly Tem and Anna Thompson (September 2011), Catchment Governance and Cooperation Dilemmas: A Case Study from Cambodia។

៦២. Chea Chou, Nang Phirun, Isabelle Whitehead, Phillip Hirsch and Anna Thompson (October 2011), Decentralised Governance of Irrigation Water in Cambodia: Matching Principles to Local Realities។

៦៣. Heng Seiha, Kim Sedara and So Sokbunthoeun (October 2011), Decentralised Governance in Hybrid Polity: Localisation of Decentralisation Reform in Cambodia។

៦៤. Tong Kimsun and Sry Bopharath (November 2011), Poverty and Evironment Links: The Case of Rural Cambodia។

៦៥. Ros Bansok, NANG Phirun and CHHIM Chhun(December 2011), Agricultural Development and Climate Change: The Case of Cambodia។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា**

☞ អគារលេខ ៥៦ ផ្លូវលេខ ៣១៥

🖂 ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

☎ ទូរស័ព្ទ៖ (៨៥៥-២៣) ៨៨១-៣៨៤, ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣

🖷 ទូរសារ៖ (៨៥៥-២៣) ៨៨០-៧៣៤

អ៊ីមែល៖ cdri@cdri.org.kh

គេហទំព័រ៖ http://www.cdri.org.kh

សង្ខេបរបាយការណ៍អភិវឌ្ឍន៍ប្រចាំឆ្នាំ២០១១-១២





លេខ ០៧

តម្លៃ ៨០០០រ

9 789995 052614